ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ផែនទីចង្អុលផ្លូវ

## ស្តីពី ផែនការស្តារ និងលើកស្ទួយ វិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយ វិបត្តិជំងឺកូវីដ-១៩ ( COVID-19 )

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## អារម្ភកថា

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនារីករាយថ្លែងនូវសារលិខិតជូនជនរួមជាតិទាំងអស់ជាទីស្នេហា អំពីឆន្ទៈ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល គាំទ្រផែនទីចង្អុលផ្លូវ (Roadmap) ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩។ **ផែនទីចង្អុលផ្លូវ**នេះបានបង្ហាញនូវចក្ខុវិស័យច្បាស់លាស់សម្រាប់ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយជំងឺកូវីដ-១៩ ដោយបានបង្ហាញថាកម្ពុជាអាចនឹងទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ **៧លាននាក់** យ៉ាងយូរនៅឆ្នាំ២០២៥ និងភ្ញៀវទេសចរក្នុងស្រុកប្រមាណ **១១លាននាក់** នៅឆ្នាំ២០២៣ ឡើងវិញ។ វិស័យទេសចរណ៍កម្ពុជាត្រៀមនឹងងើបឡើងវិញអាចក្រោមទម្រង់ជាអក្សរ “U” សម្រាប់ទេសចរណ៍អន្តរជាតិ និងទម្រង់អក្សរ “V” សម្រាប់ទេសចរណ៍ក្នុងស្រុក។

ជំងឺកូវីដ-១៩ បានបង្កឱ្យមានវិបត្តិដែលមិនធ្លាប់កើតមានឡើង និងបានផ្តល់ការភ្ញាក់ផ្អើលយ៉ាងខ្លាំងសម្រាប់កម្ពុជា តំបន់ និងសកលលោក។ ផលប៉ះពាល់នៃជំងឺកូវីដ-១៩ បាននាំឱ្យភ្ញៀវទេសចរអន្តរជាតិមកទស្សនាកម្ពុជាធ្លាក់ចុះ ៨០,២% និងភ្ញៀវទេសចរក្នុងស្រុកធ្លាក់ចុះក្នុងរង្វង់ប្រមាណ ២០% ជាមួយនឹងការខាតបង់ប្រាក់ចំណូលប្រមាណ ៣ ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០២០ នេះ។ រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញ**ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩** ដោយបែងចែកជា ០៣ ដំណាក់កាល៖

**១- ដំណាក់កាលទី១ (Resilience & Restart) :** សំដៅការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារទេសចរណ៍ឡើងវិញ (២០២០-២០២១) ពីព្រោះថាវិបត្តិនេះ បានផ្តល់នូវឱកាសឱ្យយើងពិចារណាឡើងវិញ នូវប្រព័ន្ធសម្រាប់ផ្តល់ឱ្យវិស័យទេសចរណ៍កម្ពុជាកាន់តែឱ្យមានភាពធន់ និងប្រកបដោយនិរន្តរភាពសម្រាប់អនាគត។ ក្នុងដំណាក់កាលនេះ យើងត្រូវរួមគ្នាកាត់បន្ថយផលប៉ះពាល់នៃជំងឺឆ្លងកូវីដ-១៩ ឱ្យបានជាអតិបរមា។ ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជាក្រោមកិច្ចសហការជាមួយវិស័យឯកជន បានដាក់ចេញវិធានការជាច្រើនសំដៅ ធ្វើយ៉ាងណាឱ្យអាជីវកម្ម**នៅរស់រាន** និងអាច**រក្សាការងារ**ក្នុងវិស័យទេសចរណ៍ឱ្យមានភាពធន់ ហើយស្តែងចេញតាមរយៈ ការអន្តរាគមន៍របស់រាជរដ្ឋាភិបាលជា**បន្តបន្ទាប់ចំនួន ០៧ជុំ** រួចហើយ និងការជំរុញចលនា**ទេសចរណ៍ក្នុងស្រុក** អមជាមួយការដាក់ចេញនូវ **“វិធានសុវត្ថិភាពទេសចរណ៍”**។

ក្នុងដំណាក់កាលនេះ ភាពជាដៃគូរដ្ឋ-ឯកជនដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមដល់យុទ្ធនាការទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ពិសេសត្រូវផ្តល់សេវាកម្មប្រកបដោយសុវត្ថិភាព ជាមូលដ្ឋានគ្រឹះនៃការស្តារវិស័យទេសចរណ៍ពីព្រោះថា **ការបង្កើននូវភាពជឿទុកចិត្ត និងភាពជឿជាក់** លើគ្រប់ខ្សែសង្វាក់នៃផលិតកម្មក្នុងវិស័យទេសចរណ៍ គឺជាចំណុចគន្លឹះអាទិភាពសម្រាប់ការទាក់ទាញទេសចរណ៍។ ភាពជឿជាក់ និងភាពទុកចិត្តត្រូវគិតពី **ដើមខ្សែ ដល់ចុងខ្សែ** គិតចាប់ពីច្រកទ្វារអន្តរជាតិនៃប្រទេសដែលភ្ញៀវទេសចរបានចាកចេញរហូតដល់ច្រកទ្វារអន្តរជាតិនៅប្រទេសកម្ពុជា និងបន្តដល់សេវាកម្មស្នាក់នៅ ហូបចុក ធ្វើដំណើរ សកម្មភាពកម្សាន្តនានា រហូតដល់ការត្រឡប់ទៅប្រទេសខ្លួនវិញប្រកបដោយភាពកក់ក្តៅ។ ក្នុងន័យនេះ គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងវិស័យទេសចរណ៍ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនវិធានសុវត្ថិភាពទេសចរណ៍ និងវិធានសុខាភិបាលព្រោះថា **“អ្វីៗ នឹងមិនត្រឡប់ទៅរកសភាពដើមវិញទេ ដូចនេះយើងត្រូវចេះសម្របខ្លួនរៀនរស់ក្នុងសភាពថ្មីមួយ ពោលគឺត្រូវចេះរក្សាអនាម័យឱ្យបានខ្ជាប់ខ្ជួន និងមានការប្រយ័ត្នប្រយែង កុំធ្វេសប្រហែសឱ្យសោះ”**។ ទន្ទឹមនេះ ដើម្បីត្រៀមការស្តារឡើងវិញវិស័យទេសចរណ៍ រាជរដ្ឋាភិបាលបានសម្រេចវិនិយោគសាធារណៈ

ក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវនៅប៉ូលទេសចរណ៍អាទិភាព រួមមាន ផ្លូវ៣៤ខ្សែ នៅក្រុងព្រះសីហនុ និងគម្រោងផ្លូវ ៣៨ខ្សែនៅក្រុងសៀមរាប ដែលនឹងផ្តល់ផ្លែផ្កាដល់ការលើកកម្ពស់ភាពទាក់ទាញទេសចរណ៍ចាប់ពីចុងឆ្នាំ២០២១ ជាពុំខាន។

**២- ដំណាក់កាលទី២ (Recovery) :** ដើម្បីស្តារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ (ឆ្នាំ២០២២-២០២៣) និងកាត់បន្ថយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ឱ្យបានជាអតិបរមា រាជរដ្ឋាភិបាលនឹងបន្តផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ជំនាញឌីជីថល និងជំនាញថ្មីៗឱ្យស្របតាមតម្រូវការទីផ្សារក្រោយវិបត្តិជំងឺកូវីដ-១៩ និងការខិតខំលើកកម្ពស់កិត្យានុភាពកម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយសុវត្ថិភាពក្រោយវិបត្តិជំងឺកូវីដ-១៩។ ក្នុងដំណាក់កាលនេះ ដើម្បីបង្កើនឧត្តមភាពប្រកួតប្រជែងទេសចរណ៍កម្ពុជាក្នុងតំបន់ និងសកលលោក រាជរដ្ឋាភិបាលក៏នឹងបង្កើតកញ្ចប់មូលនិធិលើកស្ទួយ ដើម្បីគាំទ្រលើគម្រោងអាទិភាព ដូចជាការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ការពង្រឹងគុណភាពទេសចរណ៍ ការបង្កើតឱ្យមានសាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅតាមប៉ូលទេសចរណ៍អាទិភាព ការលើកទឹកចិត្តដល់គំរូអាជីវកម្មទេសចរណ៍ថ្មីៗដែលមានភាពច្នៃប្រឌិត និងនវានុវត្តន៍ ការលើកកម្ពស់ធុរកិច្ចថ្មីៗ ក្នុងវិស័យទេសចរណ៍ ការចាប់យកបច្ចេកវិទ្យាឌីជីថល ការលើកកម្ពស់សមត្ថភាពទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយទេសចរណ៍។ល។

**៣- ដំណាក់កាលទី៣ (Relaunch) :** ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មី (ឆ្នាំ២០២៤-២០២៥) នៃវិស័យទេសចរណ៍កម្ពុជា សំដៅទាញយកផលប្រយោជន៍ពីការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាឱ្យបានជាអតិបរមា ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ ឱ្យបានលើសមុនពេលវិបត្តិ ដោយចាប់យកឱកាសនៃវិបត្តិជំងឺកូវីដ-១៩ កសាងអនាគតនៃវិស័យទេសចរណ៍កម្ពុជាឱ្យមាននិរន្តភាព គុណភាព និងឆ្លាតវៃ។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះក្រសួងទេសចរណ៍ និងផ្នែកឯកជន បានសហការគ្នាធ្វើឱ្យឯកសារផែនទីចង្អុលផ្លូវនេះ បានលេចចេញជារូបរាង ហើយត្រូវបានអនុម័តនិងបានក្លាយជាឯកសារដ៏មានតម្លៃបំផុតសម្រាប់ជាតិយើង។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវគ្រប់ក្រសួង-ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន ក៏ដូចជាប្រជាជនទាំងអស់ សូមចូលរួមគាំទ្រ និងរួមចំណែកឱ្យបានសកម្មក្នុងការអនុវត្ត ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ នេះឱ្យទទួលបានជោគជ័យជាស្ថាពរ។

ខ្ញុំសូមអំពាវនាវឱ្យគ្រប់ភាគីពាក់ព័ន្ធ វិស័យឯកជន ប្រជាពលរដ្ឋរួមគ្នាដើម្បី **"ប្រែក្លាយការគំរាមកំហែងពីជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់ការកែទម្រង់វិស័យទេសចរណ៍កម្ពុជា"** និងស្នើឱ្យវិស័យឯកជនត្រូវពង្រឹងខ្លួនដើម្បីសម្របក្នុងបរិបទថ្មី ពិសេសត្រូវចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងធុរកិច្ចរបស់ខ្លួនពីព្រោះថា បច្ចេកវិទ្យាឌីជីថលលែងជាជម្រើសទៀតហើយ ប៉ុន្តែគឺជាតម្រូវការចាំបាច់សម្រាប់វិស័យទេសចរណ៍កម្ពុជា។ **"ក្នុងកាលៈទេសៈនេះ យើងត្រូវរចេះ និងបង្កើនការទាក់ទាញយកប្រយោជន៍ពីបច្ចេកវិទ្យា ដើម្បីជីវភាពប្រចាំថ្ងៃការដឹកនាំ ការសិក្សា ការបំពេញការងារ និងការធ្វើអាជីវកម្ម"**។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា **ផែនទីចង្អុលផ្លូវនេះ** ក្លាយជាត្រីវិស័យក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាប្រកបដោយចីរភាព គុណភាព សុវត្ថិភាព និរន្តរភាព ការទទួលខុសត្រូវ និងបរិយាបន្ន និងក្នុងបុព្វហេតុលើកកម្ពស់ថែមទៀតនូវកិត្យានុភាពកម្ពុជា **"កម្ពុជាៈ ព្រះរាជាណាចក្រអច្ឆរិយៈ - ផ្តល់ភាពកក់ក្តៅ"** ឱ្យក្លាយជាគោលដៅទេសចរណ៍គុណភាពលំដាប់ពិភពលោកប្រកបដោយភាពជឿជាក់ និងទំនុកចិត្ត។

**ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤**

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១**

**ហ៊ុន សែន**

# មាតិកា

**សេចក្តីផ្តើម**........................................................ ១

**ជំពូកទី១: សេណារីយ៉ូនៃការអភិវឌ្ឍទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩**........................ ៦

១- ផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងការវិភាគSWOT លើវិស័យទេសចរណ៍កម្ពុជា........................ ៦

២- ជម្រើសសេណារីយ៉ូនៃការអភិវឌ្ឍទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩........................ ១៥

**ជំពូកទី២: ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩**.......... ២៤

១- ដំណាក់កាលទី១: ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (២០២០-២០២១)........................ ២៦

២- ដំណាក់កាលទី២: ការស្តារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២២-២០២៣)... ៦៣

៣- ដំណាក់កាលទី៣: ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា(២០២៤-២០២៥)........................ ៨៥

**ជំពូកទី៣ : យន្តការស្ថាប័ន និងគម្រោងកម្មវិធីអាទិភាព (២០២០-២០២៥)**........................ **៩៥**

១- រចនាសម្ព័ន្ធនៃយន្តការស្ថាប័ន........................ ៩៦

២- កាតព្វកិច្ច និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ........................ ៩៦

៣- គម្រោងកម្មវិធីអាទិភាព(២០២០-២០២៥)........................ ១០៣

៤- ហិរញ្ញប្បទានទ្រទ្រង់........................ ១០៤

៥- យន្តការតាមដាន និងត្រួតពិនិត្យ........................ ១០៤

**សេចក្តីសន្និដ្ឋាន**........................ **១០៥**

**ឧបសម្ព័ន្ធ**........................ **១០៦**

១- តារាងគម្រោងកម្មវិធីអាទិភាពសម្រាប់ស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា(២០២០-២០២៥)... ១០៦

២- ស្ថិតិភ្ញៀវទេសចរជាតិ-អន្តរជាតិចាប់ពីថ្ងៃទី១៧-២១ ខែសីហា ឆ្នាំ២០២០ នាឱកាសឈប់សម្រាកសងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ........................ ១៤២

៣- របាយការណ៍ស្ថិតិអាជីវកម្មទេសចរណ៍បានបិទ និងព្យួរទូទាំងប្រទេស ឆ្នាំ២០២០........................ ១៤៣

# សេចក្ដីផ្ដើម

## ១- ស្ថានភាពទេសចរណ៍សកល តំបន់ និងកម្ពុជា

**(១)**. ជំងឺកូវីដ-១៩ បាននឹងកំពុងគំរាមកំហែងដល់ការរស់នៅប្រចាំថ្ងៃ ទម្លាប់ ជីវភាព អាយុជីវិត សេដ្ឋកិច្ច និងសង្គមទាំងមូលនៅលើសកលលោក។ មកដល់បច្ចុប្បន្ន គ្មាននរណាដឹងថា ពេលណាជំងឺកូវីដ-១៩ នេះនឹងបញ្ចប់នោះឡើយ ហើយក៏គ្មាននរណាអាចទស្សន៍ទាយ អំពីផលប៉ះពាល់ជំងឺនេះមកលើទិដ្ឋភាពនៃជីវភាពរស់នៅរបស់សង្គមជាតិនីមួយៗ ទាំងសេដ្ឋកិច្ច នយោបាយ និងរបៀបរបបសង្គមបានជាក់លាក់នោះដែរ។ ជំងឺកូវីដ-១៩ នេះបានបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យទេសចរណ៍សកលលោក។

### ក- កម្រិតសកលលោក

**(២)**. យោងតាមការវាយតម្លៃរបស់**អង្គការទេសចរណ៍ពិភពលោក** (UNWTO) ផលប៉ះពាល់ទេសចរណ៍អន្តរជាតិនៅ **ឆ្នាំ២០២០** នេះមានការធ្លាក់ចុះក្នុងអត្រា **-៧៤%** ខាតបង់ប្រាក់ចំណូលក្នុងវិស័យទេសចរណ៍ **ប្រមាណ ១,៣ ទ្រីលានដុល្លារអាម៉េរិក** ស្មើនឹងការបាត់បង់ចំនួនភ្ញៀវទេសចរអន្តរជាតិ **១,១២ ប៊ីលាននាក់** ដោយសារស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ មានការវិវត្តកាន់តែធ្ងន់ធ្ងរដែលបង្ខំឱ្យប្រទេសទាំងអស់ដាក់ចេញវិធានការរឹតត្បិតការធ្វើដំណើរ (Travel Restrictions)។ យោងតាមរបាយការណ៍ ប្រទេសដែលជាគោលដៅទេសចរណ៍ទាំងអស់ (១០០%) លើសកលលោកបានដាក់ចេញវិធានការរឹតត្បិតការធ្វើដំណើរ ក្នុងនោះ **៩៧ ប្រទេស (ស្មើ ៤៥%)** បានបិទទាំងស្រុង ឬមួយផ្នែកនៃច្រកព្រំដែនរបស់ខ្លួន **៦៥ ប្រទេស (ស្មើ ៣០%)** បានពន្យារទាំងស្រុង ឬមួយផ្នែកនៃជើងហោះហើរអន្តរជាតិ និង **៣៩ ប្រទេស (ស្មើ១៨%)** បានដាក់ចេញវិធានការរឹតត្បិតការចូលមកដល់របស់ភ្ញៀវទេសចរមកពីបណ្ដាប្រទេស ឬតំបន់មួយចំនួន។ ទន្ទឹមនឹងនោះ **អង្គការទេសចរណ៍ពិភពលោក** បានស្នើឱ្យប្រទេសជាសមាជិកត្រូវមានការប្រុងប្រយ័ត្នចូលរួមទប់ស្កាត់ និងបង្ការការរីករាលដាលនៃជំងឺកូវីដ-១៩ នេះ និងស្នើឱ្យវិស័យឧស្សាហកម្មទេសចរណ៍ត្រូវអនុវត្តតាមការណែនាំរបស់**អង្គការសុខភាពពិភពលោក (WHO)** ឬក្រសួងសុខាភិបាលតាមប្រទេសនីមួយៗឱ្យបានខ្ជាប់ខ្ជួន និងជាប្រចាំ។

**(៣)**. យោងតាមរបាយការណ៍ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់**ក្រុមប្រឹក្សាភិបាលធ្វើដំណើរ និងទេសចរណ៍ពិភពលោក (WTTC)** ដែលបានធ្វើការសិក្សា និងវាយតម្លៃឥទ្ធិពលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ នេះបាននឹងកំពុងធ្វើឱ្យមានការបាត់បង់ការងារប្រមាណ **១៤២,៦ លានការងារ ស្មើនឹង ៤៣%** នៅក្នុងឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍សកលលោក និងប៉ះពាល់ដល់**ផលិតផលក្នុងស្រុកសកល** សរុបប្រមាណ **៣ ៨១៥ ប៊ីលានដុល្លារអាម៉េរិក**។ ការបាត់បង់ការងារនេះ បានធ្វើឱ្យមានការជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់វិស័យសេដ្ឋកិច្ច និងសង្គមជារួម តាមរយៈ**ឥទ្ធិពលដូមីណូ (Spillover Effect)** ដែលលើសពីឥទ្ធិពលអវិជ្ជមាននៅក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ជាសកល។

**(៤)**. ដោយឡែក យោងតាមរបាយការណ៍របស់ **អង្គការពលកម្មអន្តរជាតិ (ILO)** កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ បានព្យាករណ៍ពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ដែលអាចបណ្ដាលឱ្យបាត់បង់ម៉ោងការងារសរុបប្រមាណ **៨,៨%** ស្មើនឹងប្រមាណ **២៥៥ លានការងារ** (ការងារពេញម៉ោង) **នៅឆ្នាំ២០២០**។

**(៥)**. ជារួមក្នុង**ឆ្នាំ២០២០** ចំនួនភ្ញៀវទេសចរសកលលោកបានធ្លាក់ចុះយ៉ាងគំហុកគួរឱ្យកត់សម្គាល់ និងមិនដែលមានពីមុនមក។ ក្រុមអ្នកជំនាញរបស់**អង្គការទេសចរណ៍ពិភពលោក**បានព្យាករណ៍ថាវិស័យទេសចរណ៍អាចនឹងត្រឡប់មកដូចឆ្នាំ២០១៩ វិញ ក្នុងចន្លោះពី **២ឆ្នាំកន្លះ ទៅ ៤ឆ្នាំ។**

## ខ- កម្រិតតំបន់ (អាស៊ីប៉ាស៊ីហ្វិក និងអាស៊ាន)

**(៦)**. នៅក្នុងកំលុងពេលវិបត្តិជំងឺកូវីដ-១៩ ប្រទេសនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងអាស៊ីភាគខាងកើត ក៏ដូចជាអាស៊ានបាននឹងកំពុងរងផលប៉ះពាល់យ៉ាងខ្លាំងលើវិស័យទេសចរណ៍។ យោងតាមរបាយការណ៍របស់**អង្គការទេសចរណ៍ពិភពលោក** បានបញ្ជាក់ពីផលប៉ះពាល់ដែលបណ្តាលមកពីជំងឺកូវីដ-១៩ ថា តំបន់អាស៊ីប៉ាស៊ីហ្វិកទទួលបានចំនួនភ្ញៀវទេសចរប្រមាណ **៥៧ លាននាក់ ថយចុះ -៨៤%** ដែលជាតំបន់ទទួលរងឥទ្ធិពលខ្លាំងជាងគេ និងជាតំបន់ដែលមានការរឹតត្បិតខ្លាំងជាងគេ។

**(៧)**. នៅអាស៊ានផលប៉ះពាល់នៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងជាអវិជ្ជមានដល់វិស័យសេដ្ឋកិច្ចផ្លូវការ និងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ ជាពិសេសដល់ឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ច។ ជាក់ស្តែង ឆ្នាំ២០២០ ទេសចរអន្តរជាតិមកទស្សនាតំបន់អាស៊ាន**ថយចុះរហូតដល់ ៨០,៥%** (ទទួលបានតែ ២៥,៩៦ លាននាក់) និងចំណូលពីទេសចរណ៍**ថយចុះរហូតដល់ ៧៥,៨%**។ ស្មើរតែមួយភាគបួន ឬ ២១,៥% នៃភ្ញៀវទេសចរមកទស្សនាអាស៊ាន គឺមកពីប្រទេសចិន ហើយការបិទប្រទេស និងការលុបចោលជើងហោះហើរបានប៉ះពាល់យ៉ាងខ្លាំងដល់តំបន់នេះ។ បន្ថែមពីនេះ ការភ័យខ្លាចនៃការឆ្លងរីករាលដាល ការរឹតត្បិតការធ្វើដំណើរត្រូវបានដាក់អនុវត្តដោយរដ្ឋជាសមាជិកអាស៊ានបានប៉ះពាល់ និងរារាំងការធ្វើដំណើរបន្ថែមទៀត។

**(៨)**. វិស័យដឹកជញ្ជូនតាមផ្លូវអាកាសកំពុងជួបវិបត្តិធំបំផុតក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនជាមួយនឹងតម្រូវការធ្វើដំណើរបន្តធ្លាក់ចុះខ្លាំងដោយសារការរីករាលដាលយ៉ាងលឿននៃជំងឺកូវីដ-១៩ ការរឹតត្បិតការធ្វើដំណើរដោយរដ្ឋាភិបាលនីមួយៗ ការបិទព្រំដែន និងការធ្លាក់ចុះនូវទំនុកចិត្តក្នុងការធ្វើអាជីវកម្ម។ ជាទូទៅ វិស័យទេសចរណ៍អាស៊ានតែងតែងើបឡើងវិញ និងស្តារឡើងវិញបន្ទាប់ពីមានការប៉ះទង្គិចធ្ងន់ធ្ងរនាពេលកន្លងមក ដូចជា ការផ្ទុះឡើងនៃជំងឺសារនៅឆ្នាំ២០០៣ និងវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ២០០៨-២០០៩ ប៉ុន្តែការរីករាលដាលនៃជំងឺកូវីដ-១៩ នាពេលនេះគឺមិនធ្លាប់មាន និងវិវឌ្ឍន៍យ៉ាងលឿនដែលធ្វើឱ្យវិស័យទេសចរណ៍នៅតែប្រឈមភាពមិនច្បាស់លាស់។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសជាសមាជិកអាស៊ានបានដាក់ចេញនូវគោលនយោបាយ និងវិធានការមួយចំនួនដើម្បីគាំទ្រដល់វិស័យទេសចរណ៍ និងវិស័យពាក់ព័ន្ធនឹងទេសចរណ៍សម្រាប់ដំណាក់កាលចំពោះមុខក៏ដូចជាផែនការសម្រាប់ដំណាក់កាលស្តារឡើងវិញ។ ជាមួយនឹងភាពមិនប្រាកដប្រជាជុំវិញការផ្ទុះឡើងនៃជំងឺកូវីដ-១៩ និងការព្រួយបារម្ភកាន់តែខ្លាំងឡើងនៃផលប៉ះពាល់បន្ថែមទៀតលើសេដ្ឋកិច្ច-សង្គម ប្រទេសសមាជិកអាស៊ានបានដាក់ចេញកញ្ចប់ជំរុញសេដ្ឋកិច្ចជាច្រើនចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ។

## គ- កម្រិតថ្នាក់ជាតិ (កម្ពុជា)

**(៩)**.វិស័យទេសចរណ៍កម្ពុជាឆ្នាំ២០២០ នេះបាននឹងកំពុងជួបប្រទះឥទ្ធិពលអវិជ្ជមានថ្មីមួយទៀតដែលបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩ ដែលបានកំពុងជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំង ជាក់ស្តែង នៅក្នុងឆ្នាំ២០២០

កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិចំនួន **១,៣ លាននាក់ ថយចុះ -៨០,២%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៩។ នៅក្នុងឆ្នាំ២០២០ ការធ្លាក់ភ្ញៀវទេសចរនេះមានផលប៉ះពាល់ជាច្រើនដល់ដំណើរការអាជីវកម្មទេសចរណ៍។

**(១០)**. ទោះបីជាវិស័យទេសចរណ៍អន្តរជាតិបាននឹងកំពុងទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីវិបត្តិជំងឺកូវីដ-១៩ ក៏ដោយ យើងសង្កេតឃើញចំនួនភ្ញៀវទេសចរក្នុងស្រុកមានផលប៉ះពាល់តិចតួច នៅក្នុងឆ្នាំ២០២០ នេះ ដោយភ្ញៀវទេសចរក្នុងស្រុកដែលបានធ្វើដំណើរកម្សាន្តទូទាំងប្រទេសមានចំនួនសរុប **៩,០៤ លាននាក់ ថយចុះ -២០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។**

## ២- ចក្ខុវិស័យ

**(១១)**. ផែនទីចង្អុលផ្លូវកំណត់នូវចក្ខុវិស័យក្នុងការប្រែក្លាយការគំរាមកំហែងពីវិបត្តិជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់ការកែទម្រង់ក្នុងវិស័យទេសចរណ៍កម្ពុជាក្លាយជាគោលដៅទេសចរណ៍គុណភាព សុវត្ថិភាព និងនិរន្តរភាព ដោយយកមកវិញនូវ**ចំនួនភ្ញៀវទេសចរអន្តរជាតិប្រមាណ ៧លាននាក់ យ៉ាងយូរនៅឆ្នាំ២០២៥ និងភ្ញៀវទេសចរក្នុងស្រុកចំនួន ១១លាននាក់ នៅឆ្នាំ២០២៣។**

## ៣- គោលបំណង និងគោលដៅ

### ក- គោលបំណង

**(១២)**. ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ផែនទីចង្អុលផ្លូវនេះកំណត់នូវ**គោលបំណង** ដូចខាងក្រោម÷

- ស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយជំងឺកូវីដ-១៩
- កាត់បន្ថយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ លើឧស្សាហកម្មទេសចរណ៍កម្ពុជាឱ្យបានជាអតិបរមា
- ទាញយកផលប្រយោជន៍ បង្កើតការងារថ្មីៗពីផលិតផល និងសេវាកម្មទេសចរណ៍មួយចំនួនដែលមានសក្តានុពលក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ-១៩
- ជំរុញឧត្តមភាពប្រកួតប្រជែងទេសចរណ៍លើឆាកតំបន់ និងអន្តរជាតិ
- លើកកម្ពស់កិត្យានុភាពកម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយសុវត្ថិភាពក្រោយវិបត្តិជំងឺកូវីដ-១៩។

### ខ- គោលដៅ

**(១៣)**. ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ផែនទីចង្អុលផ្លូវនេះបានដាក់ចេញជា **គោលដៅ** ដូចខាងក្រោម÷

- អភិវឌ្ឍន៍ផលិតផលទេសចរណ៍ និងសេវាកម្មទេសចរណ៍ថ្មីៗប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍
- ពង្រឹងគុណភាពសេវាកម្មទេសចរណ៍ឱ្យស្របតាមស្តង់ដាថ្នាក់ជាតិ និងថ្នាក់តំបន់
- ជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ជំនាញបន្ថែម និងជំនាញថ្មីៗឱ្យស្របតាមតម្រូវការទីផ្សារក្រោយវិបត្តិជំងឺកូវីដ-១៩
- សម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ឱ្យមានភាពបត់បែន និងងាយស្រួល

- ពង្រឹងសមត្ថភាពផ្សព្វផ្សាយទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ និងតំបន់ក្រោយវិបត្តិជំងឺកូវីដ-១៩ តាមរយៈការរៀបចំ និងលើកកម្ពស់ការផ្សព្វផ្សាយព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗឱ្យកាន់តែមានភាពទាក់ទាញ ការវិនិយោគលើទីផ្សារទេសចរណ៍សំខាន់ៗ និងក៏ដូចជាការផ្សព្វផ្សាយទេសចរណ៍តាមបែបទំនើបស្របតាមបរិបទបដិវត្តន៍ឧស្សាហកម្មទី៤
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យទេសចរណ៍
- ដាក់ចេញគោលនយោបាយពិសេសចាំបាច់មួយចំនួនបម្រើឱ្យការទាក់ទាញវិស័យទេសចរណ៍កម្ពុជាក្នុងបរិបទថ្មី
- ពង្រឹងយន្តការអភិបាលកិច្ចទេសចរណ៍ឡើងវិញស្របតាមបរិបទនៃរបៀបការងារ និងធុរកិច្ចក្នុងបរិបទថ្មី។

# ជំពូកទី១

# សេណារីយ៉ូនៃការអភិវឌ្ឍទេសចរណ៍កម្ពុជា ក្រោយវិបត្តិជំងឺកូវីដ-១៩

១- ផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងការវិភាគ SWOT លើវិស័យទេសចរណ៍កម្ពុជា

២- ជម្រើសសេណារីយ៉ូនៃការអភិវឌ្ឍទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩

# ជំពូកទី១: សេណារីយ៉ូនៃការអភិវឌ្ឍទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩

## ១- ផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងការវិភាគ SWOT លើវិស័យទេសចរណ៍កម្ពុជា

### ក- ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ លើវិស័យទេសចរណ៍កម្ពុជា

**(១៤)**. ស្ថានភាពនៃវិស័យទេសចរណ៍កម្ពុជានៅឆ្នាំ២០២០ កំពុងស្ថិតក្នុងដំណាក់កាល "**បញ្ហាប្រឈមផង និងកាលានុវត្តភាពផង**"។ ជាក់ស្តែង សម្រាប់**វិស័យទេសចរណ៍កម្ពុជាក្នុងឆ្នាំ២០២០** គឺ÷

- **ទេសចរអន្តរជាតិ**

**(១៥)**. ក្នុងឆ្នាំ២០២០ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិ **ចំនួន ១,៣១ លាននាក់ ថយចុះ -៨០,២%** ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៩។ ស្ថិតក្នុងស្ថានភាពមិនច្បាស់នៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ កម្ពុជាទទួលរងផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ មានដូចជា÷

(១). ខាតបង់ចំណូលទេសចរណ៍អន្តរជាតិប្រមាណ **៣ ប៊ីលានដុល្លារអាម៉េរិក** (ប៉ាន់ស្មាន)

(២). រួមចំណែកក្នុង**ផលិតផលក្នុងស្រុកសរុប** អាចថយចុះជាង **១៣%** មកក្រោម **១០%** (ប៉ាន់ស្មាន)

(៣). មូលដ្ឋានអាជីវកម្មទេសចរណ៍ **៣ ៤២៩ ទីតាំង** ត្រូវបានបិទ និងផ្អាកដំណើរការ រួមមានសណ្ឋាគារ ផ្ទះភ្ញៀវ ភោជនីយដ្ឋាន ម៉ាស្សា-ស្ប៉ា ទីភ្នាក់ងារទេសចរណ៍ កីឡាទេសចរណ៍ និងអាជីវកម្មខារ៉ាអូខេ រង្គសាល ឌីស្កូតែក បៀហ្គាឌិន

(៤). បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ជាង **៥៤ ២៥៣ នាក់** (ស្មើប្រមាណ **៤៣,៧%**) ត្រូវបានបញ្ឈប់ការងារ។

- **ទេសចរក្នុងស្រុក**

**រូបភាពទី១ : ស្ថិតិភ្ញៀវទេសចរក្នុងស្រុក**




*(ប្រភព : ក្រសួងទេសចរណ៍)*

(**១៦**). យោងតាមទិន្នន័យរបស់ក្រសួងទេសចរណ៍ បានបង្ហាញថាចលនានៃភ្ញៀវទេសចរក្នុងស្រុក ក្នុង **រយៈពេល២ខែដំបូង នៃឆ្នាំ២០២០** (ខែមករា ដល់ខែកុម្ភៈ) ស្ថានភាពទេសចរណ៍នៅមានសភាពជាធម្មតានៅឡើយ ខណៈដែលជំងឺកូវីដ-១៩ នៅមិនទាន់មានការកើនឡើងនៅក្នុងប្រទេស ក្នុងនោះមានភ្ញៀវជាតិមាន **ចំនួន ១ ៦០៣៩៣១នាក់** ថយចុះ **-១,៦%** និងភ្ញៀវទេសចរបរទេសដែលរស់នៅក្នុងស្រុកមាន**ចំនួន ១ ១៦៧ ៥៥៦នាក់** ថយចុះ **-២០,២%** ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៩។

(**១៧**). មិនត្រឹមតែប៉ុណ្ណោះ ក្នុងខែមេសា ឆ្នាំ២០២០ ភ្ញៀវទេសចរក្នុងស្រុក មានការធ្លាក់ចុះយ៉ាងគំហុក ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ នេះ ដែលមានការកើនឡើងនៃករណីនាំចូលមកក្នុងប្រទេស ដោយមានភ្ញៀវទេសចរជាតិត្រឹមចំនួន ១០៦ ៤០៧នាក់ ថយចុះ -៩៣,២% និងភ្ញៀវទេសចរបរទេសដែលរស់នៅក្នុងស្រុកមានចំនួន ២៤ ៨៥៤នាក់ ថយចុះ -៩៦,២% ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៩។ ឆ្លើយតបនឹងការធ្លាក់ចុះនៃភ្ញៀវទេសចរក្នុងស្រុក និងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក្នុងវិស័យទេសចរណ៍ ក្រសួងទេសចរណ៍បានដាក់ចេញនូវវិធានសុវត្ថិភាពទេសចរណ៍ ប្រព័ន្ធចុះបញ្ជីស្នាក់នៅ ការបណ្តុះបណ្តាលបុគ្គលិកក្នុងសេវាកម្មទេសចរណ៍ និងយុទ្ធនាការនានា ដើម្បីជាការផ្តល់នូវទំនុកចិត្តដល់ភ្ញៀវទេសចរ និងឈានដល់ការកសាងទំនុកចិត្តពីភ្ញៀវទេសចរអន្តរជាតិនាពេលអនាគត។ ដោយមានការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ប្រកបដោយប្រសិទ្ធភាព និងស្របតាមវិធានសុវត្ថិភាពរបស់ក្រសួងសុខាភិបាល ក៏ដូចជាការដាក់ចេញនូវគោលនយោបាយអន្តរាគមន៍ និងការអនុវត្តបានយ៉ាងមានប្រសិទ្ធភាព យើងសង្កេតឃើញថាកំណើនភ្ញៀវទេសចរក្នុងស្រុក មានការកើនឡើងមកវិញចាប់ពីខែឧសភា ដល់ខែកក្កដា ឆ្នាំ២០២០។

(**១៨**). គិតត្រឹមខែឧសភា ឆ្នាំ២០២០ សម្រាប់ភ្ញៀវទេសចរក្នុងស្រុក ក្នុងនោះមានភ្ញៀវទេសចរជាតិមានចំនួន ២ ៥៨៤ ៣១៨នាក់ ថយចុះមកត្រឹម -៥០,១% និងភ្ញៀវទេសចរបរទេសដែលរស់នៅក្នុងស្រុកមានចំនួន ១ ៥០៦ ០៣០នាក់ ថយចុះ -៦២,២% ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៩។

(**១៩**). សម្រាប់រយៈពេលពីរសប្តាហ៍ដើមខែកក្កដា ឆ្នាំ២០២០ ភ្ញៀវទេសចរក្នុងស្រុកដែលបានធ្វើដំណើរកម្សាន្តនៅតាមគោលដៅទេសចរណ៍នានាទូទាំងប្រទេស មានចំនួនសរុបប្រមាណ ៣១៣ ៣០០នាក់ កើនឡើងប្រមាណ ១,៦៧% ធៀបនឹងរយៈពេលពីរសប្តាហ៍ចុងខែមិថុនាកន្លងមក ក្នុងនោះ ភ្ញៀវទេសចរជាតិមានចំនួន ៣០៧ ៨០៩នាក់ កើនឡើង ២,៥៤% និងភ្ញៀវទេសចរបរទេសដែលរស់នៅក្នុងស្រុកមានចំនួន ៥ ៤៩១នាក់ ថយចុះប្រមាណ -៣០,៨៩%។ ចំនួនភ្ញៀវទេសចរក្នុងស្រុកហាក់បានមកដល់ចំណុចថេរមួយដែលកើនឡើង ឬថយចុះក្នុងរង្វង់ប្រមាណ ៥% ហើយចំនួនភ្ញៀវទេសចរសរុបស្ថិតក្នុងរង្វង់ ៦០-៦៥ម៉ឺននាក់ ក្នុងមួយខែ ឬស្មើនឹង ៦០%-៦៥% នៃភ្ញៀវទេសចរក្នុងស្រុកសរុបមុនស្ថានភាពមានវិបត្តិកូវីដ-១៩ ថយចុះប្រមាណ -៣៥ ទៅ -៤០% ប្រៀបធៀបមុនវិបត្តិជំងឺកូវីដ-១៩។

(**២០**). ទោះជាយ៉ាងណាក៏ដោយ យើងសង្កេតឃើញថា ការកើនឡើងនេះមានកម្រិតថេរ ដែលបណ្តាលមកពីខេត្តសៀមរាបដែលធ្លាប់ជាគោលដៅទេសចរណ៍សំខាន់ នៅមិនទាន់អាចទាក់ទាញភ្ញៀវទេសចរដូចស្ថានភាពដើម។ ក្នុងករណីនេះ បើសិនខេត្តសៀមរាប ងើបឡើងប្រហាក់ប្រហែលនឹងខេត្តផ្សេង នោះចំនួនភ្ញៀវទេសចរក្នុងស្រុកអាចនឹងហក់ឡើងមកដលចំណុច ៨៥%-៩០%។

(**២១**). ជាក់ស្តែង បន្ទាប់ពីឈប់សម្រាកសងនៃពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ រយៈពេលចំនួន ០៥ ថ្ងៃ (ថ្ងៃទី១៧-២១ ខែសីហា ឆ្នាំ២០២០) ភ្ញៀវទេសចរដែលបានធ្វើដំណើរកម្សាន្តនៅតាមគោលដៅទេសចរណ៍នានាទូទាំងប្រទេស មានចំនួនស្ទុះឡើងគួរឱ្យគត់សម្គាល់ប្រមាណ ១,៤៥លាននាក់ (ភ្ញៀវទេសចរជាតិ ១,៤៤លាននាក់ និងភ្ញៀវទេសចរបរទេសដែលរស់នៅក្នុងស្រុក ១៤ម៉ឺននាក់)។ ដោយឡែកបើគិតត្រឹមរយៈពេល៩ថ្ងៃ (សៅរ៍-អាទិត្យ មុននិងក្រោយ នៃថ្ងៃសងពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ) មានចំនួនប្រមាណ ២លាននាក់។

(**២២**). បន្ថែមពីនេះ តាមរយៈការចំណាយរបស់ភ្ញៀវទេសចរ ដោយក្នុងរយៈពេល ០៥ថ្ងៃ នេះ ការចំណាយសរុបជាមធ្យម របស់ភ្ញៀវទេសចរ មានដូចជាការទិញសំបុត្រ ការដឹកជញ្ជូន ការស្នាក់នៅ ការហូបចុក និងចំណាយផ្សេងៗទៀត មានចំនួនប្រមាណ ១០៣ លានដុល្លារអាម៉េរិក ក្នុងនោះ: ចំពោះភ្ញៀវទេសចរជាតិ ចំណាយសរុបប្រមាណ ១០០លានដុល្លារអាម៉េរិក (៧០$/ម្នាក់), ភ្ញៀវទេសចរបរទេសដែលរស់នៅក្នុងស្រុក ចំណាយសរុបប្រមាណ ២,៨២លានដុល្លារអាម៉េរិក (២០០$/ម្នាក់)។

(**២៣**). នេះបញ្ជាក់ពីផលវិជ្ជមាននៃទេសចរណ៍ក្នុងស្រុក ដែលជួយលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ ។

- ## ផលប៉ះពាល់លើអាជីវកម្មទេសចរណ៍

(**២៤**). គិតត្រឹមខែមីនា-ខែកញ្ញា ឆ្នាំ២០២០ អាជីវកម្មបិទទ្វារសរុបចំនួន ២ ៨៣៨ទីតាំង ស្មើនឹង ២៩,៦% និងប៉ះពាល់ការងារផ្ទាល់ក្នុងវិស័យទេសចរណ៍ចំនួន ៥០ ៩៩៦នាក់ ស្មើនឹង ៤៥,២%។

(**២៥**). គិតត្រឹមខែធ្នូ ឆ្នាំ២០២០ យើងឃើញថាអាជីវកម្មនៅតែបន្តបិទ/ផ្អាកដំណើរសរុបចំនួន ៣ ៤២៩ ទីតាំង ស្មើនឹង ៣៣,១% និងប៉ះពាល់ការងារផ្ទាល់ក្នុងវិស័យទេសចរណ៍សរុបចំនួន ៥៤ ២៥៣នាក់ ស្មើនឹង ៤៣,៧%។

(**២៦**). ក្នុងដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ ក្រុមហ៊ុនភាគច្រើនមិនមានលទ្ធភាពក្នុងការបង់ពន្ធ និងមួយចំនួនទៀតមានលទ្ធភាពតិចតួច។ យោងតាមរបាយការណ៍ ស្តីពី ការស្ទង់មតិ ស្ថានភាពអាជីវកម្មទេសចរណ៍នៅក្នុងកំលុងពេលវិបត្តិជំងឺកូវីដ-១៩[1] ដែលបានសិក្សាលើផលប៉ះពាល់នៃអាជីវកម្មក្នុងកំលុងពេលកូវីដ-១៩ និងផលប៉ះពាល់លើហិរញ្ញវត្ថុ ក្រុមហ៊ុនភាគច្រើនជួបបញ្ហាលើលទ្ធភាពការចំណាយលើប្រាក់ខែបុគ្គលិក (ក្រុមហ៊ុនចំនួន ៤៩% មិនមានលទ្ធភាពចំណាយលើប្រាក់ខែបុគ្គលិក និងតែ ៨% ប៉ុណ្ណោះដែលមានលទ្ធភាពចំណាយលើប្រាក់ខែបុគ្គលិក) ថ្លៃជួលទីតាំង (ក្រុមហ៊ុនចំនួន ៤៣% មិនមានលទ្ធភាពចំណាយលើថ្លៃជួលទីតាំង និងតែ ១៤% ប៉ុណ្ណោះដែលមានលទ្ធភាពចំណាយលើថ្លៃជួលទីតាំង) ថ្លៃអគ្គិសនី (ក្រុមហ៊ុនចំនួន ២៦% មិនមានលទ្ធភាពចំណាយលើថ្លៃបង់អគ្គិសនី, ២២% ដែលមានលទ្ធភាពចំណាយលើថ្លៃជួលទីតាំង និង៥១% មានលទ្ធភាពតិចតួចចំណាយលើថ្លៃបង់អគ្គិសនី) និងមិនមានលទ្ធភាពសងប្រាក់កម្ចី (ក្រុមហ៊ុនចំនួន ៤៥% មិនមានលទ្ធភាពចំណាយលើថ្លៃបង់ប្រាក់កម្ចី, ៧% ដែលមានលទ្ធភាពចំណាយលើថ្លៃបង់ប្រាក់កម្ចី និង៤៣% មានលទ្ធភាពតិចតួចចំណាយលើថ្លៃបង់ប្រាក់កម្ចី)។

[1] អាជីវកម្មទេសចរណ៍ដែលចូលរួមស្ទង់មតិសរុបមានចំនួន ១៩៥អាជីវកម្ម។

***រូបភាពទី២ : លទ្ធភាពរបស់ក្រុមហ៊ុនលើបញ្ហាហិរញ្ញវត្ថុក្នុងដំណាក់កាលរីករាលដាលជំងឺកូវីដ-១៩***




*(ប្រភព : អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍)*

(**២៧**). មូលហេតុចំបងនៃបញ្ហានេះគឺ **រំហូរសាច់ប្រាក់** ដែលក្រុមហ៊ុន**ចំនួន ៩៧%** បាននឹងកំពុងជួបប្រទះក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ ដែលបណ្តាលមកពីការលក់ធ្លាក់ចុះយ៉ាងគំហុកនាំឱ្យ**បាត់បង់ប្រាក់ចំណូល** និងបញ្ហាប្រឈមផ្សេងទៀតដែលក្រុមហ៊ុនបាននិងកំពុងជួបប្រទះមានដូចជា ការបាត់បង់ភ្ញៀវដោយសារការផ្អាកការធ្វើដំណើរ ឬពន្យារពេលធ្វើដំណើរដោយខ្លាចឆ្លងវីរុស (**ចំនួន ៦៨%**), ការពន្យារពេលបើកដំណើរការផលិតផល ឬសេវាកម្មថ្មី (**ចំនួន ៦៦%**), ផលិតភាពរបស់និយោជិត រងផលប៉ះពាល់អវិជ្ជមាន (**ចំនួន ៦៣%**), មិនអាចពន្យារ ឬចរចារឡើងវិញនូវកាតព្វកិច្ចហិរញ្ញប្បទាន បំណុល (**ចំនួន ៥៧%**)។

***រូបភាពទី៣ : បញ្ហាប្រឈមមុខ និងផលប៉ះពាល់ ដោយសារការផ្ទុះឡើងនៃ វីករាលដាលជំងឺកូវីដ-១៩***




*(ប្រភព : អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍)*

(**២៨**). ដូចនេះ បើវិបត្តិជំងឺកូវីដ-១៩ នៅតែបន្តក្នុងរយៈពេលវែង ក្រុមហ៊ុនរំពឹងថាវិធានការដែលជាអាទិភាពមានដូចជា ការចរចារជាមួយធនាគារ និងម្ចាស់បំណុលផ្តល់ជូននូវកាតព្វកិច្ចសងបំណុលសេវាកម្ម

**(ចំនួន ៨០%)**, អនុវត្តកាត់បន្ថយថ្លៃប្រតិបត្តិការ **(ចំនួន ៧០%)**, ស្នើសុំលើកលែងពន្ធពីរាជរដ្ឋាភិបាល **(ចំនួន ៦៥%)** និងស្នើសុំកាត់បន្ថយចំណាយថ្លៃភ្លើង-ទឹកពីរាជរដ្ឋាភិបាល **(ចំនួន ៦២%)**។

<u>**រូបភាពទី៤ : វិធានការអាទិភាពសម្រាប់ប្រតិបត្តិការអាជីវកម្ម**</u>




*(ប្រភព : អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍)*

**(២៩)**. ក្នុងនោះ បុគ្គលិកនៅតាមបណ្តាលមូលដ្ឋានអាជីវកម្មទទួលរងផលប៉ះពាល់ពីក្រុមហ៊ុន រួមមានផ្អាកការរើសបុគ្គលិកថ្មី **(ចំនួន ១៤%)**, ផ្អាកការឈប់សម្រាកដោយគ្មានការប្រាក់ឈ្នួល និងផ្អាកការបង្កើនប្រាក់ខែ **(ចំនួន ១២%)**, កាត់បន្ថយប្រាក់ខែដោយមិនមានផែនការសងត្រឡប់ **(ចំនួន ១១%)**, ការបន្ថយប្រាក់រង្វាន់ **(ចំនួន ១០%)** និងកាត់បន្ថយបុគ្គលិក **(ចំនួន ៩%)**។

<u>**រូបភាពទី៥ : លទ្ធភាពរបស់ក្រុមហ៊ុនលើបញ្ហាហិរញ្ញវត្ថុក្នុងដំណាក់កាលរីករាលដាលជំងឺកូវីដ-១៩**</u>




*(ប្រភព : អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍)*

**(៣០)**. ជារួមមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើហិរញ្ញវត្ថុជាប្រាក់ចំណូលនេះធៀបទៅនឹងឆ្នាំមុន គឺកំណើនអវិជ្ជមានដល់ទៅជាង ៥០% មាន **(ចំនួន ៨៥%)** នៃក្រុមហ៊ុន ដោយមានក្រុមហ៊ុនតែ **(ចំនួន**

៩%) ដែលមានកំណើនអវិជ្ជមានពី ២៥%ទៅ ៤៩%។ ដូចនេះ ប្រាក់ចំណេញរបស់ក្រុមហ៊ុនធ្លាក់ចុះយ៉ាងខ្លាំងដែរ (**ចំនួន ៨៤%**) នៃក្រុមហ៊ុនមានកំណើនអវិជ្ជមាននៃប្រាក់ចំណេញដល់ទៅលើសពី ៥០%។

***<u>រូបភាពទី៦: ផលប៉ះពាល់ដែលរំពឹងទុកលើកំណើនប្រាក់ចំណូល និងចំណេញរបស់ក្រុមហ៊ុនក្នុងដំណាក់កាលរីករាលដាលជំងឺកូវីដ-១៩</u>***




*(ប្រភព : អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍)*

(**៣១**). ក្នុងករណីនេះ វិធានការដែលក្រុមហ៊ុននឹងកំពុងអនុវត្ត ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ដែលបណ្តាលមកពីការផ្ទុះនៃវិបត្តិជំងឺកូវីដ-១៩ មានដូចជា ពង្រឹងអនុវត្តសុខភាព និងសុវត្ថិភាពដល់អតិថិជន (**ចំនួន ១១%**), ការលើកកម្ពស់ការអនុវត្តប្រកបដោយសុវត្ថិភាព និងសុវត្ថិភាពរបស់និយោជិក (**ចំនួន ១៣%**), អនុវត្តយុទ្ធសាស្ត្រកាត់បន្ថយចំណាយប្រតិបត្តិការ (**ចំនួន ១០%**), ចរចាជាមួយធនាគារ និងអ្នកផ្តល់បំណុលលើកាតព្វកិច្ចសងបំណុល (**ចំនួន ១០%**)។

***<u>រូបភាពទី៧ : វិធានការដែលក្រុមហ៊ុនកំពុងអនុវត្ត និងឆ្លើយតបទៅនឹងការរីករាលដាលជំងឺកូវីដ-១៩</u>***




*(ប្រភព : អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍)*

(**៣២**). **ក្នុងនោះវិស័យឯកជនស្នើឡើងនូវអនុសាសន៍មួយចំនួន÷**

- ចូលរួមជាមួយរដ្ឋាភិបាល ក្រសួងទេសចរណ៍ លើកកម្ពស់វិស័យទេសចរណ៍ ដូចជា ការផ្សព្វផ្សាយព័ត៌មាន អនុវត្តកម្មវិធីឌីជីថល ការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវ
- រៀបចំនយោបាយទីផ្សារប្រកបដោយនវានុវត្តន៍ និងទំនើបកម្ម
- រៀបចំកម្មវិធីជំរុញទំនាក់ទំនងល្អជាមួយអតិថិជន និងការពេញចិត្តរបស់អតិថិជន
- រៀបចំនយោបាយលើកទឹកចិត្តបុគ្គលិកដើម្បីបង្កើនផលិតភាព និងរក្សាបុគ្គលិក
- បង្កើនវិនិយោគលើបច្ចេកវិទ្យាបន្ថែម ដើម្បីបង្កើនទីផ្សារ និងប្រសិទ្ធភាពការងារ
- លទ្ធភាពអភិវឌ្ឍន៍ផលិតផល ឬសេវាកម្មប្រកបដោយនវានុវត្តន៍។

## ខ- ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងហានិភ័យនៃវិស័យទេសចរណ៍កម្ពុជាក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩

(**៣៣**). ឆ្នាំ២០២០ នេះបាននឹងកំពុងនាំមកនូវបញ្ហាប្រឈមយ៉ាងខ្លាំង ជះឥទ្ធិពលអវិជ្ជមានដល់វិស័យទេសចរណ៍កម្ពុជាមិនធ្លាប់មានក្នុងរយៈពេល ៣០ឆ្នាំ ចុងក្រោយ។ សកលលោកបាននឹងកំពុងជួបប្រទះឥទ្ធិពលអវិជ្ជមានជាច្រើនដែលបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩ ជាពិសេសដល់វិស័យទេសចរណ៍កម្ពុជា តំបន់ និងសកលលោក។ ប៉ុន្តែចំណុចនេះក៏បានឆ្លុះបញ្ចាំងឱ្យឃើញអំពីតួនាទីដ៏មានសារៈសំខាន់របស់វិស័យទេសចរណ៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ក៏ដូចជាឥទ្ធិពលដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាជាអន្តរវិស័យជាមួយបណ្តាវិស័យសេដ្ឋកិច្ច-សង្គមសំខាន់ៗដទៃទៀតរបស់ជាតិ។ ខាងក្រោមនេះគឺជាការវិភាគ និងឆ្លុះបញ្ចាំង អំពីចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងហានិភ័យ សម្រាប់វិស័យទេសចរណ៍កម្ពុជាក្នុងដំណាក់កាលទម្លាប់ថ្មី (New Normal)÷

**តារាងទី១ : ការវិភាគអំពីចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងហានិភ័យសម្រាប់វិស័យទេសចរណ៍កម្ពុជាក្នុងដំណាក់កាលទម្លាប់ថ្មី**

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • វិស័យរដ្ឋ និងឯកជនមានការប្តេជ្ញាចិត្តក្នុងការស្តារឧស្សាហកម្មទេសចរណ៍ឡើងវិញ<br>• ការផ្តល់ជូននូវសកម្មភាពទេសចរណ៍ និងផលិតផលទេសចរណ៍ប្រកបដោយគុណភាព និងគុណតម្លៃខ្ពស់សម្រាប់ទីផ្សារទេសចរណ៍អន្តរជាតិ<br>• ការដាក់អនុវត្តផែនការមេអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាប (២០២១-២០៣៥)<br>• វិស័យអេកូទេសចរណ៍ដែលផ្តល់ជាបទពិសោធន៍ថ្មី កំពុងត្រូវបានរៀបចំឡើង | • ការចូលរួមរវាងភាគីពាក់ព័ន្ធក្នុងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍មិនទាន់ខ្លាំងក្លានៅឡើយ<br>• កម្ពុជាមានកង្វះខាតលើការវិនិយោគ (ចំណាយ) លើការធ្វើទីផ្សារបើប្រៀបធៀបជាមួយបណ្តាប្រទេសនានា<br>• សម្បទាទេសចរណ៍ភាគច្រើនខ្ចីបំណុលពីធនាគារដើម្បីបើក ឬពង្រីកអាជីវកម្មរបស់ខ្លួន រីឯបុគ្គលិកបម្រើការងារមានមួយផ្នែកក៏ខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុ ដែលជាហេតុបង្កឱ្យផលប៉ះពាល់ខ្លាំងក្នុងពេលវិបត្តិនេះ<br>• ការផ្គត់ផ្គង់ការងារទេសចរណ៍នៅមានកម្រិត និងផលិតភាពការងាររបស់បុគ្គលិកនៅខ្សោយ<br>• ការសិក្សាទីផ្សារ និងផ្សព្វផ្សាយមិនទាន់មានដំណើរការដែលមានលក្ខណៈផ្អែកលើការអនុវត្តល្អបំផុតនៅឆាកអន្តរជាតិនៅឡើយ |

| | |
|---|---|
| • បទពិសោធន៍តាមរយៈសកម្មភាពទេសចរណ៍នៅតាមតំបន់ជនបទក្នុងលក្ខខណ្ឌជាតំបន់ទេសចរណ៍បែបផ្សងព្រេង និងផលិតផលដែលបន្ស៊ីទៅនឹងលក្ខខណ្ឌ (Soft Adventure)<br>• ប្រាង្គប្រាសាទក្នុងតំបន់អង្គរ ដែលមានកេរ្តិ៍ឈ្មោះល្បី និងជាប់ចំណាត់ថ្នាក់នៅក្នុង TripAdviser<br>• ម្ហូបអាហារខ្មែរ ដែលមានលក្ខណៈពិសេស និងភាពទាក់ទាញដ៏ល្អបំផុត<br>• ផលិតផលទេសចរណ៍ដែលប្រកបភាពទទួលខុសត្រូវខ្ពស់<br>• រមណីយដ្ឋានទេសចរណ៍ដ៏ប្រណិតលំដាប់ពិភពលោក<br>• តំបន់ទេសចរណ៍រាជធានីភ្នំពេញប្រកបដោយភាពរស់រវើក<br>• ជាតំបន់ទេសចរណ៍ដែលមានការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ក្នុងកម្រិតទាបជាងប្រទេសក្នុងតំបន់ និងសកលលោក<br>• ការដាក់ចេញអនុវត្តនូវវិធានការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ មានភាពខ្លាំងក្លា និងមុតស្រួច<br>• ជាតំបន់ទេសចរណ៍ប្រកបដោយភាពកក់ក្ដៅ និងប្រជាជនខ្មែរប្រកបដោយភាពស្វាគមន៍ (ប្រទេសតូច បេះដូងធំទូលាយ)<br>• ជាតំបន់ទេសចរណ៍ប្រកបដោយគុណតម្លៃ បើធៀបទៅនឹងតំបន់ទេសចរណ៍នៃប្រទេសជាច្រើន<br>• មានទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយប្រទេសចិន និងប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍<br>• មានការតភ្ជាប់ក្នុងកម្រិតតំបន់ល្អ (ប្រទេសសិង្ហបុរី / ទីក្រុងហុងកុង សម្រាប់ទីផ្សារហោះហើរចម្ងាយខ្លី)<br>• អនុវត្តទិដ្ឋាការអេឡិចត្រូនិក និងទិដ្ឋាការក្នុងពេលមកដល់<br>• ជាតំបន់ទេសចរណ៍ដែលមានភាពទាក់ទាញភ្ញៀវទេសចរប្រកបដោយភាពស្មោះស្ម័គ្រ និងសេចក្ដីស្រឡាញ់<br>• កម្ពុជាជាប់ចំណាត់ថ្នាក់ជាគោលដៅទេសចរណ៍ដែលមានសុវត្ថិភាពបំផុតក្នុងចំណោមគោលដៅទេសចរណ៍សុវត្ថិភាពបំផុតកំពូលទាំង ១០ យោងតាមក្រុមហ៊ុនទេសចរណ៍ Toulane នៃប្រទេសអាល្លឺម៉ង់ | • ការតភ្ជាប់ផ្លូវអាកាសទៅកាន់ទីផ្សារសំខាន់ៗ (ពិសេសខ្វះខាតជើងហោះហើរឆ្ងាយ) ដែលនឹងនាំឱ្យការស្តារឡើងវិញនៅក្រោយការរីករាលដាលនៃជំងឺកូវីដ-១៩មានការលំបាក<br>• ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើវិស័យទេសចរណ៍ដោយអវត្តមានការគាំទ្រពីផ្នែកសេដ្ឋកិច្ចបានច្រើនកម្រិតខ្ពស់ដូចបណ្ដាប្រទេសអភិវឌ្ឍផ្សេងៗទៀត<br>• កង្វះការអនុវត្តតាមស្តង់ដាសុវត្ថិភាពនៅតាមតំបន់ទេសចរណ៍មួយចំនួន (តួយ៉ាងលើផ្នែកទូក/ កប៉ាល់ទេសចរណ៍)<br>• ការយល់ឃើញតំបន់អភិរក្សអង្គរជាតំបន់ទេសចរណ៍លើសចំណុះ<br>• កេរ្តិ៍ឈ្មោះអវិជ្ជមាននៃតំបន់ទេសចរណ៍ខេត្តព្រះសីហនុ និងខេត្តសៀមរាបតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាកន្លងមក<br>• ការស្វែងរកព័ត៌មានពីទេសចរណ៍មានភាពទន់ខ្សោយ និងតិចតួច<br>• ការពឹងផ្អែកហួសហេតុតែលើការទស្សនាតំបន់អង្គរសម្រាប់ការធ្វើទីផ្សារទេសចរណ៍<br>• កម្ពុជាត្រូវបានចាត់ទុកថាជាតំបន់ទេសចរណ៍បន្ទាប់បន្សំ (ដោយការពឹងផ្អែកតែលើតំបន់អង្គរ)<br>• តម្លៃលើសេវាអាកាសយានដ្ឋានមានតម្លៃខ្ពស់បើប្រៀបធៀបជាមួយបណ្ដាប្រទេសជិតខាង<br>• តម្លៃជើងហោះហើរខ្ពស់សម្រាប់ការធ្វើដំណើរពីទីផ្សារទេសចរណ៍ចម្ងាយឆ្ងាយជាច្រើន<br>• ការរឹតបន្តឹងលើការផ្តល់ទិដ្ឋាការជាបណ្ដោះអាសន្នដែលអាចនឹងកាត់បន្ថយការលើកទឹកចិត្តក្នុងការធ្វើដំណើរនៅពេលខាងមុខ |
| **កាលានុវត្តភាព** | **ហានិភ័យ** |
| • ទាញយកមេរៀនពីវិបត្តិនេះ សារៈសំខាន់នៃវិស័យទេសចរណ៍ជាវិស័យអាទិភាពសម្រាប់សេដ្ឋកិច្ច-សង្គមកម្ពុជា<br>• ផ្សព្វផ្សាយ និងជំរុញការធ្វើដំណើរទេសចរណ៍ចម្ងាយខ្លី ក្នុងតំបន់រវាងគោលដៅទេសចរណ៍សំខាន់ៗ ពិសេសចលនាទេសចរណ៍ក្នុងស្រុក និងទេសចរណ៍ផ្ទៃក្នុងអាស៊ានឱ្យកាន់តែខ្លាំង | • ភ្ញៀវទេសចរធ្លាក់ចុះ ដូចនេះ ក្នុងករណីមិនមានផែនការចង្អុលផ្លូវ និងស្តារឡើងវិញនៃវិស័យទេសចរណ៍នឹងចំណាយរយៈពេលយូរក្នុងការស្តារឡើងវិញ<br>• ការមិនចូលរួមក្នុងការសហការអនុវត្តនូវវិធានសុវត្ថិភាពទេសចរណ៍នឹងធ្វើឱ្យមានហានិភ័យកើនឡើងខ្ពស់ |

| | |
|---|---|
| • បង្កើតយុទ្ធនាការថ្មីៗ និងលើកកម្ពស់កិត្តិនាមម៉ាកយីហោទេសចរណ៍នៃប្រទេសកម្ពុជា "កម្ពុជា : ក្រៅពីប្រាសាទ (Cambodia: Beyond the Temples)"<br>• ពន្លឿនកិច្ចការងារដែលបាននឹងកំពុងអនុវត្តឱ្យអនុវត្តកាន់តែប្រសើរជាងមុន ដូចជាចលនាទេសចរណ៍បែបផ្សងព្រេង ការធ្វើដំណើរឱ្យកាន់តែមានសុវត្ថិភាពនិងអនាម័យជាងមុន<br>• បង្កើតវត្តមានប្រព័ន្ធឌីជីថល និងបច្ចេកវិទ្យាក្នុងវិស័យទេសចរណ៍នៅប្រទេសកម្ពុជា ដូចជាការចុះឈ្មោះអនឡាញ<br>• ទាញយកវិបត្តិនេះធ្វើជាកត្តាជំរុញដើម្បីពង្រឹងការធ្វើទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ - ឆ្ពោះទៅរកអភិក្រមដើម្បីពង្រឹងមធ្យោបាយហិរញ្ញវត្ថុក្នុងទម្រង់ភាពជាដៃគូរវាងរដ្ឋ-ឯកជន<br>• ពង្រឹងមធ្យោបាយក្នុងការធ្វើទីផ្សារ និងផ្សព្វផ្សាយរួមគ្នាជាមួយផ្នែកឯកជន: គ្រឹះស្ថានសាធារណៈរដ្ឋបាលមានលក្ខណៈសេដ្ឋកិច្ច<br>• ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមផ្សារភ្ជាប់នឹង "ឯក-អគ្គរាជទូតសុឆន្ទៈទេសចរណ៍"<br>• ប្រើប្រាស់វិបត្តិនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដើម្បីបង្រួបបង្រួមមូលនិធីអភិវឌ្ឍន៍ពីដៃគូអភិវឌ្ឍអន្តរជាតិសម្រាប់ការស្តារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជា<br>• ពិនិត្យឡើងវិញនូវអភិក្រមស្តីពីការផ្តល់មូលនិធិដល់ការអនុវត្តយុទ្ធសាស្ត្រធ្វើទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍<br>• ប្រើប្រាស់ "ពេលវេលានៃការធ្លាក់ចុះយ៉ាងគំហុក" ជាការអនុវត្តលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងភាពស្អាត (ឧ. ហេដ្ឋារចនាសម្ព័ន្ធផ្លូវក្នុងក្រុងសៀមរាប និងកែលម្អសម្បទាទេសចរណ៍នានា)<br>• កែលម្អបទពិសោធន៍ប្រាសាទអង្គរវត្ត ឈានទៅការអនុវត្តមិនប្រើប្រាស់ប្លាស្ទិកនៅក្នុងតំបន់អង្គរ ប្រើប្រាស់តែផលិតផលក្នុងស្រុក និងកិច្ចអនុវត្តនានាក្នុងលក្ខខណ្ឌប្រកប ដោយចីរភាពឱ្យបានប្រសើរជាងមុន<br>• ជាឱកាសក្នុងការបញ្ឈប់ការអនុវត្តកញ្ចប់ទេសចរណ៍ "ថ្លៃសូន្យ" ដោយចាប់ផ្តើមអនុវត្តជាមួយមធ្យោបាយចាប់យកទីផ្សារពីគោលដៅភ្ញៀវទេសចរចិនល្អៗ និងប្រកបដោយគុណភាព<br>• រៀបចំបង្កើតយុទ្ធនាការផ្សព្វផ្សាយសម្រាប់គោលដៅទីផ្សារអឺរ៉ុបប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងទីផ្សារចិន។ | • ភាពធ្លាក់ចុះនូវភ្ញៀវទេសចរ ធ្វើឱ្យប៉ះពាល់ដល់ការវិនិយោគក្នុងវិស័យទេសចរណ៍<br>• ការអនុវត្តគម្រោង "ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព" និងមានហានិភ័យខ្ពស់ប្រសិនបើមិនមានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ |

*(ប្រភព : គម្រោងពង្រឹងសមត្ថភាព TCBP (AFD)-លោក Gavin Bell អ្នកជំនាញការប្រចាំក្រសួងទេសចរណ៍ និងក្រុមការងារនៃលេខាធិការដ្ឋាននៃក្រុមការងារកូវីដ-១៩ ក្នុងវិស័យទេសចរណ៍)*

## ២- ជម្រើសសេណារីយ៉ូនៃការអភិវឌ្ឍទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩

**(៣៤)**. បើមើលពីនិន្នាការភ្ញៀវទេសចរអន្តរជាតិ និងភ្ញៀវទេសចរក្នុងស្រុក**មកកម្ពុជាចាប់តាំងពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩** បង្ហាញថាវិស័យទេសចរណ៍កម្ពុជាមានអត្រាកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងនោះភ្ញៀវទេសចរអន្តរជាតិកើនជាមធ្យម **១២%** និងភ្ញៀវទេសចរក្នុងស្រុកកើនជាមធ្យម **៤,៦%**។

**(៣៥)**. ដោយឡែកសម្រាប់ឆ្នាំ២០២០ ទេសចរណ៍កម្ពុជាទទួលឥទ្ធិពលរងផលប៉ះពាល់ដែលបណ្តាលមកពីជំងឺកូវីដ-១៩ ដែលបណ្តាលឱ្យទេសចរធ្លាក់ចុះយ៉ាងគំហុក។

**តារាងទី២ : និន្នាការនៃភ្ញៀវទេសចរក្នុងស្រុក និងភ្ញៀវទេសចរអន្តរជាតិមកកម្ពុជា (២០១០ ដល់ ២០២០):**

| ឆ្នាំ | ភ្ញៀវទេសចរអន្តរជាតិ | អត្រាកំណើន | ភ្ញៀវទេសចរក្នុងស្រុក | អត្រាកំណើន | សរុប | អត្រាកំណើន |
|---|---|---|---|---|---|---|
| **២០១០** | ២ ៥០៨ ២៨៩ | ១៦,០% | ៧ ៥៦២ ៦៩៩ | - | ១០ ០៧០ ៩៨៨ | - |
| **២០១១** | ២ ៨៨១ ៨៦២ | ១៤,៩% | ៧ ៨១១ ០៦៥ | ៣,៣% | ១០ ៦៩២ ៩២៧ | ៦,២% |
| **២០១២** | ៣ ៥៨៤ ៣០៧ | ២៤,៤% | ៨ ២៥៣ ៨៦០ | ៥,៧% | ១១ ៨៣៨ ១៦៧ | ១០,៧% |
| **២០១៣** | ៤ ២១០ ១៦៥ | ១៧,៥% | ៨ ៥១៨ ៧៥៣ | ៣,២% | ១២ ៧២៨ ៩១៨ | ៧,៥% |
| **២០១៤** | ៤ ៥០២ ៧៧៥ | ៧,០% | ៩ ០០៤ ៤៣៧ | ៥,៧% | ១៣ ៥០៧ ២១២ | ៦,១% |
| **២០១៥** | ៤ ៧៧៥ ២៣១ | ៦,១% | ៩ ៦៧៨ ៩៩២ | ៧,៥% | ១៤ ៤៥៤ ២២៣ | ៧,០% |
| **២០១៦** | ៥ ០១១ ៧១២ | ៥,០% | ១០ ៦៤២ ០៨១ | ១០,០% | ១៥ ៦៥៣ ៧៩៣ | ៨,៣% |
| **២០១៧** | ៥ ៦០២ ១៥៧ | ១១,៨% | ១០ ៨៦៤ ៣៦៨ | ២,១% | ១៦ ៤៦៦ ៥២៥ | ៥,២% |
| **២០១៨** | ៦ ២០១ ០៧៧ | ១០,៧% | ១១ ០៥៩ ៦៣៣ | ១,៨% | ១៧ ២៦០ ៧១០ | ៤,៨% |
| **២០១៩** | **៦ ៦១០ ៥៩២** | **៦,៦%** | **១១ ៣១៩ ៥២៣** | **២,៣%** | **១៧ ៩៣០ ១១៥** | **៣,៩%** |
| **២០២០** | **១ ៣០៦ ១៤៣** | **-៨០,២%** | **៩ ០៤១ ៥៩៥** | **-២០,១%** | **១០ ៣៤៧ ៧៣៨** | **-៤២,៣%** |

*(ប្រភព : សៀវភៅស្ថិតិទេសចរណ៍, ក្រសួងទេសចរណ៍)*

**(៣៦)**. **យោងតាមអង្គការទេសចរណ៍ពិភពលោក** ការធ្វើដំណើរទេសចរណ៍អន្តរជាតិបានធ្លាក់ចុះ**ក្នុងអត្រាប្រមាណ -៧៤% នៅឆ្នាំ២០២០**។ ហើយ**អង្គការទេសចរណ៍ពិភពលោក** បានធ្វើការវិភាគ និងព្យាករណ៍ស្ថានភាពទេសចរណ៍អន្តរជាតិក្រោយឆ្នាំ២០២០ នេះ តាម**សេណារីយ៉ូចំនួន ០៣** ដើម្បីឆ្លុះបញ្ចាំងអនាគតវិស័យទេសចរណ៍នាពេលខាងមុខ÷

**សេណារីយ៉ូទី១ :** ភ្ញៀវទេសចរអន្តរជាតិនឹងងើបឡើងវិញនៅឆ្នាំ២០២១ ហើយបន្តកើនឡើង ដោយត្រឡប់ទៅរកភាពដើមវិញដូចកាលពីឆ្នាំ២០១៩ ក្នុងរយៈពេល **២ឆ្នាំកន្លះ (ពាក់កណ្តាលឆ្នាំ ២០២៣)**។ នេះដោយសារឥទ្ធិពលនៃវ៉ាក់សាំងកូវីដ-១៩ បានរុញដោលឱ្យកំណើនតម្រូវការនៃការធ្វើដំណើរមានការកើនឡើងខ្លាំងយ៉ាងគំហុក ព្រមជាមួយការដកគោលនយោបាយរឹតត្បិតពីប្រទេសនានា និងការផ្តល់ទំនុកចិត្តដល់អ្នកដំណើរឡើងវិញ ជាដើម នៅពាក់កណ្តាលឆ្នាំ២០២១។

**សេណារីយ៉ូទី២ :** ភ្ញៀវទេសចរអន្តរជាតិនឹងងើបឡើងវិញនៅឆ្នាំ២០២១ តែមានការអូសបន្លាយរហូតដល់**៣ឆ្នាំ ទើបត្រឡប់ទៅកម្រិតឆ្នាំ ២០១៩ (នៅចុងឆ្នាំ ២០២៣)**។

**សេណារីយ៉ូទី៣ :** ភ្ញៀវទេសចរអន្តរជាតិនឹងងើបឡើងវិញនៅឆ្នាំ២០២១ តែមានភាពយឺតយ៉ាវជាងសេណារីយ៉ូទី១ និងសេណារីយ៉ូទី២ ដោយការដកគោលនយោបាយរឹតត្បិតនានានៅមានកម្រិតនៅឡើយ ដែលធ្វើឱ្យសេណារីយ៉ូនេះទទួលបានភ្ញៀវទេសចរអន្តរជាតិត្រឡប់ទៅរកកម្រិតឆ្នាំ២០១៩វិញនៅក្នុងរយៈពេល**៤ឆ្នាំ (នៅចុងឆ្នាំ ២០២៤)**។

## ក. ការព្យាករសេណារីយ៉ូនៃការអភិវឌ្ឍទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩

**(៣៧)**. ដោយឡែក សម្រាប់ការព្យាករសេណារីយ៉ូនៃការអភិវឌ្ឍទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ត្រូវបានវាយតម្លៃ(ក្នុងរយៈពេល០៧ឆ្នាំ ខាងមុខចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៧) ដោយផ្អែកលើការគិតគូរពីប្រសិទ្ធភាពរបស់អន្តរាគមន៍ពីរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងអន្តរាគមន៍គាំពារវិស័យទេសចរណ៍កម្ពុជា និងឥទ្ធិពលពីខាងក្រៅនៃទេសចរណ៍តំបន់ និងពិភពលោក។ ក្រសួងទេសចរណ៍ស្នើឡើងនូវសេណារីយ៉ូ**ចំនួន៣** ក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាឡើងវិញ ដែលការព្យាករកំណើន**ភ្ញៀវទេសចរអន្តរជាតិមានទម្រង់ជាអក្សរ “U” និងភ្ញៀវទេសចរក្នុងស្រុកមានទម្រង់ជាអក្សរ “V”**។

- ទេសចរអន្តរជាតិ : (ក្រោមទម្រង់អក្សរ “U”)
  - **សេណារីយ៉ូទី១ (ប្រើរយៈពេល ៣ឆ្នាំ)** ករណីមានវ៉ាក់សាំងនៅឆ្នាំ២០២០ និងការដាក់ចេញវិធានការគោលនយោបាយអន្តរាគមន៍ជាមួយអត្រាប្រែប្រួល: -៨០,២% (២០២០), ៩៧,៤% (២០២១), ៦០% (២០២២) និង ៧០% (២០២៣)
  - **សេណារីយ៉ូទី២ (ប្រើរយៈពេល ៥ឆ្នាំ)** ករណីមានវ៉ាក់សាំងឆ្នាំ២០២១ និងមានការដាក់ចេញវិធានការគោលនយោបាយអន្តរាគមន៍ជាមួយអត្រាប្រែប្រួល : -៨០,២% (២០២០), -២៣,១%(២០២១), ១០០% (២០២២), ១២៥% (២០២៣), ៤០% (២០២៤) និង ១២% (២០២៥)
  - **សេណារីយ៉ូទី៣ (ប្រើរយៈពេល ៧ឆ្នាំ)** ករណីវ៉ាក់សាំងមិនច្បាស់លាស់ និងមានវិធានការបិទប្រទេស និងរបាំងនានាមិនច្បាស់លាស់ ជាមួយអត្រាប្រែប្រួល: -៨០,២% (២០២០), -៥៩,៥% (២០២១), ៦០% (២០២២), ៩៥% (២០២៣) និង ៤៤% (២០២៤-២០២៧)។

**តារាងទី៣ : សេណារីយ៉ូអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩**

| | សេណារីយ៉ូទី ១ (មានវ៉ាក់សាំងឆ្នាំ២០២០ និងមានវិធានការគោលនយោបាយអន្តរាគមន៍) | | សេណារីយ៉ូទី ២ (មានវ៉ាក់សាំងឆ្នាំ២០២១ និងមានវិធានការគោលនយោបាយអន្តរាគមន៍) | | សេណារីយ៉ូទី ៣ (វ៉ាក់សាំងមិនច្បាស់លាស់ និងមានវិធានការបិទប្រទេស និងរបាំងនានាមិនច្បាស់លាស់) | |
|---|---|---|---|---|---|---|
| **ឆ្នាំ** | **ភ្ញៀវទេសចរអន្តរជាតិ** | **អត្រាកំណើន** | **ភ្ញៀវទេសចរអន្តរជាតិ** | **អត្រាកំណើន** | **ភ្ញៀវទេសចរអន្តរជាតិ** | **អត្រាកំណើន** |
| **២០១៩** | ៦ ៦១០ ៥៩២ | ៦,៦% | ៦ ៦១០ ៥៩២ | ៦,៦០% | ៦ ៦១០ ៥៩២ | ៦,៦០% |
| **២០២០** | ១ ៣០៦ ១៤៣ | -៨០,២% | ១ ៣០៦ ១៤៣ | -៨០,២% | ១ ៣០៦ ១៤៣ | -៨០,២% |
| **២០២១** | ២ ៥៧៨ ១៣១ | ៩៧,៤% | ១ ០០៤ ៨១០ | -២៣,១% | ៥២៨ ៨៤៧ | -៥៩,៥% |
| **២០២២** | ៤ ១២៥ ០០៩ | ៦០,០% | ២ ០០៩ ៦២០ | ១០០,០% | ៨៤៦ ១៥៦ | ៦០,០% |
| **២០២៣** | **៧ ០១២ ៥១៦** | ៧០,០% | ៤ ៥២១ ៦៤៥ | ១២៥,០% | ១ ៦៥០ ០០៤ | ៩៥,០% |
| **២០២៤** | ៧ ៧១៣ ៧៦៨ | ១០,០% | ៦ ៣៣០ ៣០៣ | ៤០,០% | ២ ៣៧៦ ០០៥ | ៤៤,០% |
| **២០២៥** | ៨ ៤៨៥ ១៤៤ | ១០,០% | **៧ ០៨៩ ៩៣៩** | ១២,០% | ៣ ៤២១ ៤៤៨ | ៤៤,០% |
| **២០២៦** | ៩ ៣៣៣ ៦៥៩ | ១០,០% | ៧ ៧៩៨ ៩៣៣ | ១០,០% | ៤ ៩២៦ ៨៨៥ | ៤៤,០% |
| **២០២៧** | ១០ ២៦៧ ០២៥ | ១០,០% | ៨ ៥៧៨ ៨២៦ | ១០,០% | **៧ ០៩៤ ៧១៤** | ៤៤,០% |

យោងតាមសេណារីយ៉ូលើកឡើងខាងលើបានបង្ហាញដូចខាងក្រោម÷

១- អត្រាកំណើនភ្ញៀវទេសចរអន្តរជាតិធ្លាក់ចុះខ្លាំងក្នុងឆ្នាំ២០២០ រហូតដល់ **-៨០,២%** ទាំង ៣ សេណារីយ៉ូ ដោយវិបត្តិជំងឺកូវីដ-១៩។

២- **ឆ្នាំ២០២១** ទេសចរណ៍កម្ពុជាត្រូវបានព្យាករណ៍ថានឹងមានកំណើនឡើងវិញប្រមាណ **៩៧,៤%** ក្នុងសេណារីយ៉ូទី១ (មានវ៉ាក់សាំងឆ្នាំ២០២០ និងមានវិធានការគោលនយោបាយអន្តរាគមន៍), **-២៣,១%** ក្នុងសេណារីយ៉ូទី២ (មានវ៉ាក់សាំងឆ្នាំ២០២១ និងមានវិធានការគោលនយោបាយអន្តរាគមន៍), និង **-៥៩,៥%** ក្នុងសេណារីយ៉ូទី៣ ករណីអាក្រក់បំផុត (វ៉ាក់សាំងមិនច្បាស់លាស់ និងមានវិធានការបិទប្រទេស និងរបាំងនានាមិនច្បាស់លាស់)។

៣- **ឆ្នាំ២០២២** ទេសចរណ៍កម្ពុជាត្រូវបានព្យាករណ៍ថានឹងមានកំណើនក្នុងចន្លោះពី **៦០%** (សេណារីយ៉ូទី១), **១០០%** (សេណារីយ៉ូទី២) និង **៦០%** (សេណារីយ៉ូទី៣) ដោយសារស្ថានភាពអាចត្រឡប់មកប្រក្រតីភាពវិញ ភ្ញៀវទេសចរអន្តរជាតិបន្តកើនឡើងជាងឆ្នាំ២០២១ និងករណីសេណារីយ៉ូទី៣ ជាករណីអាក្រក់បំផុត ដែលអត្រាភ្ញៀវធ្លាក់ចុះរហូតដល់ទៅ ២ឆ្នាំ ជាប់គ្នា ប៉ុន្តែចាប់ពីឆ្នាំ២០២២ នឹងមានកំណើនយ៉ាងគំហុកជាបន្តបន្ទាប់។

៤- កម្ពុជារៀបចំធ្វើម្ចាស់ផ្ទះព្រឹត្តិការណ៍កីឡា SEA GAME **ឆ្នាំ២០២៣** ដែលនេះជាព្រឹត្តិការណ៍ទាក់ទាញទេសចរយ៉ាងធំ។ ដូច្នេះ ទេសចរអន្តរជាតិត្រូវបានព្យាករណ៍ថានឹងរក្សានូវកំណើនល្អ **៧០%** (សេណារីយ៉ូទី១), **១២៥%** (សេណារីយ៉ូទី២) និង **៩៥%** (សេណារីយ៉ូទី៣)។

- ## ទេសចរក្នុងស្រុក : (ក្រោមទម្រង់អក្សរ “V”)

**(៣៨)**. ទេសចរក្នុងស្រុកបានជួយសម្រួល និងទប់ទល់ឥទ្ធិពលអវិជ្ជមានពីវិបត្តិជំងឺកូវីដ-១៩ ហើយក្រសួងទេសចរណ៍បាននឹងកំពុងជំរុញចលនាទេសចរណ៍ក្នុងស្រុកនេះបន្ថែមទៀត។ អត្រាកំណើនរបស់ទេសចរក្នុងស្រុក : **-២០% (២០២០), ១០,២% (២០២១), ១០% (២០២២) និង ៥,៥% (២០២៣-២០២៥)**។

**<u>តារាងទី៤ : ការព្យាករភ្ញៀវទេសចរក្នុងស្រុក (២០២០ ដល់ ២០២៥)</u>**

| ឆ្នាំ | ភ្ញៀវទេសចរក្នុងស្រុក | អត្រាកំណើន |
|---|---|---|
| **២០១៩** | ១១ ៣១៩ ៥២៣ | ២,៣% |
| **២០២០** | ៩ ០៤១ ៥៩៥ | -២០,១% |
| **២០២១** | ៩ ៩៦១ ១៨០ | ១០,២% |
| **២០២២** | ១០ ៩៥៧ ២៩៨ | ១០,០% |
| **២០២៣*** | **១១ ៥៥៩ ៩៥០** | **៥,៥%** |
| **២០២៤** | ១២ ១៩៥ ៧៤៧ | ៥,៥% |
| **២០២៥** | ១២ ៨៦៦ ៥១៣ | ៥,៥% |

****សម្គាល់ :*** ទេសចរក្នុងស្រុកអាចនឹងងើបឡើងវិញយ៉ាងឆាប់រហ័សក្រោម**ទម្រង់អក្សរ** “V” និងមកកាន់ស្ថានភាពដើមវិញនៅឆ្នាំ២០២៣ ដែលក្នុងឆ្នាំនេះមានព្រឹត្តិការណ៍ SEA Game (2023) និងបង្កើនចលនាទេសចរណ៍ក្នុងស្រុកកាន់តែខ្លាំង។

**(៣៩)**. នៅឆ្នាំ២០២០ **ភ្ញៀវទេសចរក្នុងស្រុក** ធ្លាក់ចុះប្រមាណ **-២០%** ដោយវិបត្តិជំងឺកូវីដ-១៩ ប៉ុន្តែផ្អែកលើការព្យាករខាងលើ ភ្ញៀវទេសចរក្នុងស្រុកនឹងមានកំណើនមកវិញជាបន្តបន្ទាប់ដោយ**មានគោលនយោបាយអន្តរាគមន៍ច្បាស់លាស់របស់ក្រសួងទេសចរណ៍ និងរាជរដ្ឋាភិបាល**។

ដូច្នេះ យើងរំពឹងថាការស្តារវិស័យទេសចរណ៍កម្ពុជាឡើងវិញដោយអាចនឹងទទួលបាន**ភ្ញៀវទេសចរអន្តរជាតិប្រមាណ ៧លាននាក់** ត្រលប់មកវិញនៅឆ្នាំ២០២៥ **(សេណារីយ៉ូទី២)**[2] ស្ថិតក្រោម**ទម្រង់អក្សរ “U”** និងរីឯ**ភ្ញៀវទេសចរក្នុងស្រុកអាចរំពឹងថានឹងទទួលបានចំនួន ១១លាននាក់ វិញនៅត្រឹមឆ្នាំ២០២៣** ស្ថិតក្រោម**ទម្រង់អក្សរ** “V” ។

## ខ- អភិក្រមនៃផែនទីចង្អុលផ្លូវ

**(៤០)**. ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ចាំបាច់គឺត្រូវដាក់ចេញជាដំណាក់កាលឆ្លើយតបនឹងការវិវត្តជាក់ស្តែងស្ថានភាពនៃការគ្រប់គ្រងជំងឺកូវីដ-១៩ ក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក។ ផ្អែកលើវិធានការឆ្លើយតបនិងយន្តការជួយវិស័យទេសចរណ៍ក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ របស់អង្គការ

[2] យោងតាមសេចក្តីប្រកាសរបស់អង្គការសុខភាពពិភពលោក (WHO) នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ បានប្រកាស : វ៉ាក់សាំងកូវីដ-១៩ ដំបូង អាចនឹងដាក់ឱ្យប្រើប្រាស់នៅខែមីនា ឆ្នាំ២០២១។

ទេសចរណ៍ពិភពលោក[3] និងអនុសាសន៍ក្នុងការតៀមលក្ខណៈសម្បត្តិដើម្បីស្តារវិស័យទេសចរណ៍ឡើងវិញ ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍ភ្នំពេញស្តីពី ទេសចរណ៍អាស៊ានប្រកបដោយនិរន្តរភាព បរិយាបន្ន និងរឹងមាំ (Phnom Penh Declaration on a More Sustainable, Inclusive and Resilient ASEAN Tourism)[4] ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ មាន**គោលដៅយុទ្ធសាស្ត្រចំនួន ០៣ និងសសរស្តម្ភចំនួន ០៤** ដូចខាងក្រោម÷

- **គោលដៅយុទ្ធសាស្ត្រចំនួន ០៣ សម្រាប់ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា÷**
  - **គោលដៅយុទ្ធសាស្ត្រទី១ -សេដ្ឋកិច្ច និងការងារ :** សំដៅដល់ការផ្តល់កិច្ចគាំពារ ស្តារ និងជំរុញប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច និងការងារនៅក្នុងឧស្សាហកម្មទេសចរណ៍ ទាំងក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ប្រកបដោយភាពធន់ និងភាពប្រកួតប្រជែងខ្ពស់
  - **គោលដៅយុទ្ធសាស្ត្រទី២ - ការជំរុញទីផ្សារទេសចរណ៍ :** សំដៅជំរុញទាក់ទាញទីផ្សារទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ ទាំងក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩
  - **គោលដៅយុទ្ធសាស្ត្រទី៣ - ការរៀបចំយន្តការអភិបាលកិច្ចទេសចរណ៍ឡើងវិញ :** សំដៅដល់ការពង្រឹងយន្តការស្ថាប័ន និងភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាប្រកបដោយភាពម្ចាស់ការ។

**(៤១)**. សកម្មភាពយុទ្ធសាស្ត្រដែលត្រូវដាក់ចេញក្នុងគោលដៅយុទ្ធសាស្ត្រនីមួយៗ គឺត្រូវពឹងផ្អែកលើសសរស្តម្ភចំនួន ០៤ ដែលជាចំណុចខ្លាំង និងជាសក្តានុពលទេសចរណ៍របស់កម្ពុជា។

---

[3] **អង្គការទេសចរណ៍ពិភពលោក** បាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋជាសមាជិករបស់ខ្លួន **អង្គការសុខភាពពិភពលោក** និងអង្គការអន្តរជាតិផ្សេងៗទៀត ដើម្បីធានាឱ្យមានការឆ្លើយតប និងដាក់ចេញយន្តការជួយវិស័យទេសចរណ៍ក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ នេះ។ **ក្នុងនោះ អង្គការទេសចរណ៍ពិភពលោក** បានដាក់ចេញនូវ**អាទិភាពចំនួន ៧ សម្រាប់ការស្តារទេសចរណ៍ឡើងវិញ រួមមាន (ទី១).** ផ្តល់នូវការធានានូវសាច់ប្រាក់ (Liquidity) និងធានាបាននូវមុខរបរ, **(ទី២).** បង្កើនភាពជឿជាក់ឡើងវិញតាមរយៈសន្តិសុខ និងសុវត្ថិភាព, **(ទី៣).** កិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងវិស័យឯកជនសម្រាប់ការបើកដំណើរការឡើងវិញប្រកបដោយប្រសិទ្ធភាព, **(ទី៤).** ការបើកចំហព្រំដែនប្រកបដោយទំនួលខុសត្រូវ, **(ទី៥).** សម្របសម្រួលលើពិធីសារ និងនីតិវិធីនានា **(ទី៦).** បង្កើនតម្លៃបន្ថែមលើការងារតាមរយៈការប្រើបច្ចេកវិទ្យាថ្មីៗ, និង **(ទី៧).** ការជំរុញនវានុវត្តន៍ និងការអភិវឌ្ឍប្រកបដោយចីរភាពសារជាថ្មី។ ក្រៅពីនេះ **អង្គការទេសចរណ៍ពិភពលោក ក៏បានដាក់ចេញគោលការណ៍ណែនាំជាសកល** ទៅលើភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍មានដូចជា **(ទី១).** ការគ្រប់គ្រងព្រំដែនប្រកបដោយសុវត្ថិភាព និងទំនួលខុសត្រូវ (ការធ្វើដំណើរតាមផ្លូវអាកាស ផ្លូវទឹក និងផ្លូវគោក), **(ទី២).** វិស័យឯកជន (Crosscutting), **(ទី៣).** ការធ្វើដំណើរតាមផ្លូវអាកាសប្រកបដោយសុវត្ថិភាព, **(ទី៤).** ការធ្វើបដិសណ្ឋារកិច្ច, **(ទី៥).** ការីទេសចរណ៍ និងទីភ្នាក់ងារទេសចរណ៍, **(ទី៦).** ការប្រជុំ និងការរៀបចំព្រឹត្តិការណ៍, **(ទី៧).** កន្លែងទាក់ទាញទេសចរណ៍ និងឧទ្យានកម្សាន្ត និង **(ទី៨).** ការធ្វើផែនការ និងការគ្រប់គ្រងគោលដៅទេសចរណ៍។

[4] អនុម័តនៅកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ានលើកទី២៤ និងកិច្ចប្រជុំពាក់ព័ន្ធតាមរយៈប្រព័ន្ធវីឌីអូ នៅថ្ងៃទី ៤-៥ ខែកុម្ភៈ ឆ្នាំ២០២១ រាជធានីភ្នំពេញ។

- ## សសរស្តម្ភចំនួន ០៤ សម្រាប់ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា÷

(៤២). ផ្អែកលើសក្តានុពលនៃព្រះរាជាណាចក្រកម្ពុជា ការរៀបចំសកម្មភាពយុទ្ធសាស្ត្រនៃផែនទីចង្អុលផ្លូវដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ត្រូវផ្អែកលើ**សសរស្តម្ភអភិវឌ្ឍន៍ចំនួន** ០៤ ដើម្បីឆ្ពោះទៅការស្តារឡើងវិញប្រកបដោយប្រសិទ្ធភាព÷

**សសរស្តម្ភទី១. បេតិកភណ្ឌវប្បធម៌** (Cultural Heritage)

**សសរស្តម្ភទី២. អេកូទេសចរណ៍** (Eco-Tourism)

**សសរស្តម្ភទី៣. ទេសចរណ៍ឆ្នេរ** (Cambodia's Bay)

**សសរស្តម្ភទី៤. ភាពជាខ្មែរ** (Cambodianess)។

**<u>រូបភាពទី៨: គោលដៅយុទ្ធសាស្ត្រ និងសសរស្តម្ភសម្រាប់ស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩</u>**




## - សសរស្តម្ភទី១: បេតិកភណ្ឌវប្បធម៌

(៤៣). ប្រទេសកម្ពុជាមានប្រាសាទអង្គរវត្តដ៏ល្បីល្បាញ និងប្រាសាទបុរាណដទៃទៀតជាច្រើន លាតសន្ធឹងលើផ្ទៃដី ៤០០ គីឡូម៉ែត្រការ៉េ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដោយអង្គការយូណេស្កូនៅឆ្នាំ១៩៩២ ព្រមជាមួយនឹងសម្បត្តិធនធានដ៏វិសេសវិសាលដទៃទៀតបង្កប់ទៅដោយប្រពៃណីទំនៀមទម្លាប់ជាមួយនឹងកំណើននៃមូលដ្ឋានអាជីវកម្មដែលបម្រើឱ្យវិស័យទេសចរណ៍ ដូចជាសណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញ។

(៤៤). ដើម្បីអាចដើរតាមទស្សនៈវិស័យនៃការអភិវឌ្ឍប្រកបដោយចីរភាពបាន ផែនទីចង្អុលផ្លូវបានកំណត់ វិសាលភាពរួម គឺរួមបញ្ចូលទាំងទេសចរណ៍វប្បធម៌ និងបេតិកភណ្ឌខ្មែរ តាមរយៈការសិក្សា និងកំណត់ឱ្យបាននូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីបង្កើនភាពទាក់ទាញ តាមរយៈការទស្សនា

ប្រាសាទផ្សារភ្ជាប់ជាមួយសកម្មភាពកម្សាន្តដ៏សម្បូរបែបបន្ថែមនូវសកម្មភាព និងព្រឹត្តិការណ៍កម្សាន្តនានា ស្របតាមគោលការណ៍អភិរក្ស និងប្រើប្រាស់គុណសម្បត្តិបេតិកភណ្ឌវប្បធម៌ទាំងនេះឱ្យបានអតិបរមា ដើម្បីបង្កើនភាពពេញចិត្ត ភាពទាក់ទាញដល់ភ្ញៀវទេសចរ និងអាចបង្កើនរយៈពេលស្នាក់នៅកាន់តែយូរ និងបង្កើនចំណាយរបស់ភ្ញៀវចូលក្នុងសេដ្ឋកិច្ចជាតិ។

## - សសរស្តម្ភទី២: អេកូទេសចរណ៍

(**៤៥**). កម្ពុជាសម្បូរទៅដោយធនធានធម្មជាតិ និងជីវចម្រុះដ៏សម្បូរបែប ពិសេសប្រមូលផ្តុំនៅតាមតំបន់ការពារធម្មជាតិចំនួន ៥៧កន្លែង ស្មើនឹងផ្ទៃដី ៧ ៤៣៩ហិកតា (មានឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង និងតំបន់រ៉ាមសារ តំបន់បេតិកភណ្ឌធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ), តំបន់ការពារព្រៃឈើចំនួន ៩កន្លែង ព្រៃកោងកាង ព្រៃត្រពិក ជួរភ្នំក្រវាញដែលសម្បូរទៅដោយពពួកសត្វកម្រចុងក្រោយនៅតំបន់អាស៊ី ហើយបច្ចុប្បន្នតំបន់នេះត្រូវបានដាក់បញ្ចូលទៅក្នុងតំបន់អេកូទេសចរណ៍ល្បីៗទាំង១០ នៅក្នុងពិភពលោក ព្រមទាំងរុក្ខជាតិ សត្វសមុទ្រ និងជីវៈចម្រុះជាច្រើន ពិសេសព្រៃកោងកាងធំជាងគេនៅអាស៊ីអាគ្នេយ៍ គ្របដណ្តប់លើផ្ទៃដី ៥០ ០០០ ហិកតា និងផ្កាថ្ម ៧០ ប្រភេទ ស្ថិតក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា និងនៅតំបន់ភាគឦសានក៏មានសក្តានុពលយ៉ាងធំធេងជាមួយនឹងតំបន់ខ្ពង់រាប ឧទ្យានជាតិទេសភាពទន្លេមេគង្គ សមុទ្រព្រៃឈើ ទឹកជ្រោះ សត្វផ្សោតទន្លេមេគង្គ ពពួកសត្វកម្រ និងជីវៈចម្រុះផ្សេងៗទៀត ពិសេសសហគមន៍ ជនជាតិភាគតិចថែមទៀតផង។ ជារួម ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ពិសេសអេកូទេសចរណ៍ដែលជាទម្រង់មួយនៃទេសចរណ៍ប្រកបដោយនិរន្តរភាព និងផ្តល់ផលចំណេញដល់សេដ្ឋកិច្ច-សង្គមមូលដ្ឋាន, ចូលរួមដល់កិច្ចគាំពារបរិស្ថានប្រកបដោយប្រសិទ្ធភាព និងដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកតម្កើងឧត្តមភាពប្រកួតប្រជែង នៃវិស័យទេសចរណ៍កម្ពុជា។

## - សសរស្តម្ភទី៣: ទេសចរណ៍ឆ្នេរ

(**៤៦**). ឆ្នេរសមុទ្រកម្ពុជាក៏មានសក្តានុពលធំធេងផងដែរ ដែលលាតសន្ធឹងលើប្រវែង ៤៤០ គីឡូម៉ែត្រ និងបានចូលជាសមាជិកក្លិបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ចាប់តាំងពីឆ្នាំ២០១១មក រួមចំណែកក្នុងការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍តាមបណ្តាខេត្តតំបន់ឆ្នេរសមុទ្រទាំងនោះ និងគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរប្រកបដោយនិរន្តរភាព។

(**៤៧**). ភាពសម្បូរបែបសម្រាប់ការលំហែកាយនៅតាមបណ្តាឆ្នេរសមុទ្រ និងកោះនានា គឺជាឧត្តមភាពប្រកួតប្រជែងក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ និងបានធ្វើឱ្យតំបន់ឆ្នេរសមុទ្រកម្ពុជាកំពុងទទួលស្វាគមន៍កំណើនភ្ញៀវទេសចរជាតិ-អន្តរជាតិ។

## - សសរស្តម្ភទី៤: ភាពជាខ្មែរ

(**៤៨**). ក្រៅពីសក្តានុពលទេសចរណ៍បេតិកភណ្ឌវប្បធម៌ អេកូទេសចរណ៍ និងទេសចរណ៍តំបន់ឆ្នេរ ចំណុចខ្លាំងនៃភាពទាក់ទាញទេសចរណ៍របស់កម្ពុជាមួយទៀតគឺ ភាពជាខ្មែរ។ កន្លងមក កម្ពុជាត្រូវបានទទួលស្គាល់ជាប្រទេសដែលមានប្រជាជនផ្តល់បដិសណ្ឋារកិច្ចល្អ និងទទួលស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិជាមួយនឹងស្នាមញញឹមពោរពេញដោយភាពកក់ក្តៅ។ ជាក់ស្តែង នៅខែកញ្ញាថ្មីៗនេះ គេហទំព័ររបស់

My International Movers[5] បានកំណត់ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ១ ក្នុងចំណោមប្រទេសចំនួន១០ ផ្សេងទៀត ដែលមានបដិសណ្ឋារកិច្ចល្អបំផុតចំពោះជនបរទេស និងភ្ញៀវទេសចរក្នុងឆ្នាំ២០២០ នេះ។

(**៤៩**). វិបត្តិជំងឺកូវីដ-១៩ ក៏បានបង្ហាញពីគុណធម៌ និងសីលធម៌កម្រិតជាសកលរបស់កម្ពុជាផងដែរ។ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ កម្ពុជាបានអនុញ្ញាតឱ្យ**នាវាទេសចរណ៍ MS Westerdam** មកចុះចតនៅកំពង់ផែខេត្តព្រះសីហនុ ខណៈដែលនាវាទេសចរណ៍ខ្នាតធំនេះត្រូវបានបដិសេធក្នុងការចូលចតពីបណ្ដាប្រទេសជាច្រើន។ កាយវិការនេះត្រូវបានពិភពលោកទទួលស្គាល់ និងវាយតម្លៃថាប្រទេសកម្ពុជា “**ប្រទេសតូច បេះដូងទូលាយ - Small Country But Big Heart**”។ ភាពក្លាហានរបស់ **សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការទទួលភ្ញៀវចូលចតនាវានេះ ត្រូវទទួលការអរគុណ និងការកោតសរសើរពី**លោកប្រធានាធិបតីរបស់សហរដ្ឋអាម៉េរិក Donald Trump** និងអង្គការអន្តរជាតិនានា ជាអាទិ៍**អង្គការសុខភាពពិភពលោក (WHO) និងអង្គការទេសចរណ៍ពិភពលោក (UNWTO)**។

**រូបភាពទី៩ : កម្ពុជាប្រទេសតូចតែចិត្តទូលាយ**



*(ប្រភព : F.B Page សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)*

(**៥០**). ដើម្បីចាប់យកកាលានុវត្តភាពនេះ ក្រោយវិបត្តិជំងឺកូវីដ-១៩ ដើម្បីស្ដារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា គឺត្រូវផ្សព្វផ្សាយទេសចរណ៍កម្ពុជា ដែលឈរលើទស្សនៈ “**ភាពជាខ្មែរ & ប្រជាជនពោរពេញដោយធម៌**” ដែលជាសក្ដានុពលទេសចរណ៍ ដែលមិនចេះរីងស្ងួតសម្រាប់ទេសចរណ៍កម្ពុជាក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

(**៥១**). ដូច្នេះ ការស្ដារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ ត្រូវផ្សារភ្ជាប់នឹងមនុស្ស (**គឺភាពជាខ្មែរ**) ស្របនឹងគោលគំនិត “3Cs”[6] ដែលបានលើកឡើង អំពីគោលគំនិតមូលដ្ឋានសម្រាប់អនាគតកម្ពុជា ដែលត្រូវតម្រង់ទិសឆ្ពោះទៅរកជោគវាសនាតែមួយ រួមមាន (C1)-**ភាពជាខ្មែរ (C2)-ប្រជាជនប្រកបដោយសមត្ថភាព និង (C3)-ប្រជាជនពោរពេញដោយធម៌** ដែលចលនានេះគួរត្រូវបន្តបំផុសឱ្យទៅជា**ចលនាជាតិមួយ**។

**រូបភាពទី១០ : គោលគំនិត “3Cs”**



[5] យោងតាមវេបសាយអន្តរជាតិ My International Movers (https://myinternationalmovers.com) បានផ្ដល់ចំណាត់ថ្នាក់ព្រះរាជាណាចក្រកម្ពុជាជាប់ថ្នាក់លេខ ០១ ក្នុងចំណោមប្រទេសទាំង ១០ ដែលមានបដិសណ្ឋារកិច្ចល្អបំផុតចំពោះជនបរទេស និងភ្ញៀវទេសចរក្នុងឆ្នាំ ២០២០។

[6] គោលគំនិត “3Cs” របស់**ឯកឧត្តម ហ៊ុន ម៉ានី ប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា**

# ជំពូកទី២

# ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩

**១- ដំណាក់កាលទី១ : ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (២០២០-២០២១)**

- យុទ្ធសាស្ត្រចំនួន ០៣ សកម្មភាពយុទ្ធសាស្ត្រចំនួន ២៣ និងសកម្មភាពយុទ្ធសាស្ត្រលម្អិតចំនួន ៩៧

**២- ដំណាក់កាលទី២ : ការស្តារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២២-២០២៣)**

- យុទ្ធសាស្ត្រចំនួន ០៣ សកម្មភាពយុទ្ធសាស្ត្រចំនួន ១៧ និងសកម្មភាពយុទ្ធសាស្ត្រលម្អិតចំនួន ៥៤

**៣- ដំណាក់កាលទី៣ : ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា (២០២៤-២០២៥)**

- យុទ្ធសាស្ត្រចំនួន ០៣ សកម្មភាពយុទ្ធសាស្ត្រចំនួន ០៩ និងសកម្មភាពយុទ្ធសាស្ត្រលម្អិតចំនួន ២៩

## ជំពូកទី២ : ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩÷

- **ភាពធន់** (Resilience & Restart)
- **ការងើបឡើងវិញ** (Recovery)
- **និងការដំណើរការឡើងវិញ** (Relaunch)

**(៥២)**. ថ្វីត្បិតតែស្ថានភាពជំងឺកូវីដ-១៩ មិនមានសភាពធ្ងន់ធ្ងរ និងពុំមានការបាត់បង់ជីវិតដោយជំងឺកូវីដ-១៩ នេះនៅកម្ពុជាក៏ដោយ ក៏ផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ នេះធ្វើឱ្យវិស័យសេដ្ឋកិច្ច-សង្គមដាំក្បាលចុះ ជាពិសេសវិស័យទេសចរណ៍បានធ្លាក់ចុះយ៉ាងគំហុក តាមរយៈចំនួនភ្ញៀវទេសចរអន្តរជាតិបានធ្លាក់ចុះយ៉ាងគំហុកធ្វើឱ្យចំណូលវិស័យទេសចរណ៍ចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិធ្លាក់ចុះ និងការបាត់បង់ការងារក្នុងវិស័យទេសចរណ៍។

**(៥៣)**. ដូចនេះ ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍អាស្រ័យលើក្របខ័ណ្ឌ/ពេលវេលានៃការដាក់ចេញវិធានការគោលនយោបាយអន្តរាគមន៍ទាន់ពេល និងភាពឆាប់រហ័សនៃការរកឃើញវ៉ាក់សាំង។ តាមការសិក្សាវិភាគសេណារីយ៉ូ ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ រំពឹងថានឹងស្ថិតក្នុងជម្រើសសេណារីយ៉ូទី២។ ក្នុងន័យនេះ ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ត្រូវរៀបចំឡើងជា “**០៣ ដំណាក់កាល**” គ្របដណ្តប់លើចិរវេលា (២០២០-២០២៥)÷

១- **ដំណាក់កាលទី១ (ភាពធន់) :** ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ

២- **ដំណាក់កាលទី២ (ការងើបឡើងវិញ) :** ការជំរុញ និងការស្តារឡើងវិញនៃវិស័យទេសចរណ៍

៣- **ដំណាក់កាលទី៣ (ការដំណើរការឡើងវិញ) :** ការរៀបចំផ្លោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា។

**(៥៤)**. ការរៀបចំផែនការយុទ្ធសាស្ត្រក្នុងដំណាក់កាលនីមួយៗត្រូវបានផ្អែកលើ**សសរស្តម្ភទាំង៤ គឺ បេតិកភណ្ឌវប្បធម៌ ទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍ និងភាពជាខ្មែរ** ដោយផ្តោតលើ**គោលដៅយុទ្ធសាស្ត្រចំនួន (០៣)** ក្នុងនោះ **(ទី១).** សេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍ **(ទី២).** ការជំរុញទីផ្សារទេសចរណ៍ និង **(ទី៣).** ការរៀបចំយន្តការអភិបាលកិច្ចក្នុងវិស័យទេសចរណ៍ឡើងវិញ។

# ដំណាក់កាលទី១: ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (២០២០-២០២១)

- យុទ្ធសាស្ត្រទី១: ជំនួយផ្នែកសេដ្ឋកិច្ចចំពោះវិស័យឯកជន និងការងារ
- យុទ្ធសាស្ត្រទី២: ជំរុញទេសចរណ៍ក្នុងស្រុក និងត្រៀមទទួលភ្ញៀវទេសចរអន្តរជាតិ
- យុទ្ធសាស្ត្រទី៣: រៀបចំយន្តការអភិបាលកិច្ចទេសចរណ៍ឡើងវិញ
- ផែនការសកម្មភាពសម្រាប់ដំណាក់កាលទី១: ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (២០២០-២០២១)

## ១- ដំណាក់កាលទី១ : ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (២០២០-២០២១)

**(៩៥)**. តាមបទពិសោធន៍កន្លងមក ចំណុចគន្លឹះសំខាន់បំផុតសម្រាប់សកលលោកវិលត្រឡប់ទៅរកប្រក្រតីភាពនៃការធ្វើដំណើរចេញក្រៅរបស់ភ្ញៀវទេសចរនោះគឺ **ការរកឱ្យឃើញនូវវ៉ាក់សាំងការពារ និង/ឬ ថ្នាំព្យាបាលជំងឺកូវីដ-១៩** នេះ។ ក្នុងន័យនេះ យើងអាចវាយតម្លៃបានថា **ពីពេលបច្ចុប្បន្នរហូតដល់ពេលរកឃើញវ៉ាក់សាំង គឺជារយៈពេលនៃ "ទម្លាប់ថ្មី"** ដែលស្ថានភាពនៃសេដ្ឋកិច្ច-សង្គម អាចចាប់ផ្តើមវិលត្រឡប់ទៅរកសកម្មភាពជាធម្មតាជាបណ្តើរៗក្នុង **ឥរិយាបថថ្មី, ទម្លាប់ថ្មី និងការផ្តល់សេវាកម្មបែបថ្មី**។ ដំណាក់កាលទី១ នេះគឺជាដំណាក់កាល**រក្សាភាពធន់** និង**ការចាប់ផ្តើមឡើងវិញ** នៃឧស្សាហកម្មទេសចរណ៍ ស្របតាមយុទ្ធសាស្ត្រ "**មួយពេលរស់សិន កុំឱ្យស្លាប់**"[7] ពោលគឺរក្សាជីវិតឱ្យគង់វង្ស ដើម្បីមានពេលស្តារសេដ្ឋកិច្ចឡើងវិញតាមក្រោយ។

### ក- យុទ្ធសាស្ត្រទី១: ជំនួយផ្នែកសេដ្ឋកិច្ចចំពោះវិស័យឯកជន និងការងារ

**(៩៦)**. គិតមកដល់ពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់នូវវិធានការអន្តរាគមន៍ (រួមទាំងវិស័យទេសចរណ៍ និងសេវាកម្ម) ចំនួន ០៧ជុំ រួចមកហើយ ដោយមានវិធានការគាំទ្រគោលសំខាន់ៗជាសង្ខេប ដូចជាមិនបង់ពន្ធប្រចាំខែ មិនធ្វើសវនកម្មពេញលេញសម្រាប់ឆ្នាំ២០២០ មិនចាំបាច់បង់ប្រាក់ភាគទានធានារ៉ាប់រងរបបហានិភ័យការងារ និងថែទាំសុខភាព(ប.ស.ស) សម្របសម្រួលជាមួយម្ចាស់អគារទីតាំងអាជីវកម្មឱ្យជួយសម្រួលដល់ភាគីអ្នកជួល លើកលែងការបង់ថ្លៃបន្តអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទ អនុញ្ញាតការពន្យារពេលនៃការទូទាត់ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារ ផ្តល់ប្រាក់ឧបត្ថម្ភដល់បុគ្គលិកក្នុងវិស័យទេសចរណ៍ និងរៀបចំកម្មវិធីបណ្តុះបណ្តាលពង្រឹងជំនាញដែលមានស្រាប់ (Re-skilling) និងបណ្តុះបណ្តាលជំនាញថ្មី (Upskilling)។ ក្នុងនោះ ក្រសួងទេសចរណ៍បានដាក់ចេញ និងកំពុងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ **(ទី១)**.វិធានសុវត្ថិភាពទេសចរណ៍ **(ទី២)**.ការជំរុញចលនាទេសចរណ៍ក្នុងស្រុក និង **(ទី៣)**.ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍តាមអនឡាញ។

**(៩៧)**. **ក្នុងជំហានទី១** ក្រសួងទេសចរណ៍បានរៀបចំវិធានសុវត្ថិភាពទេសចរណ៍ និងដាក់ឱ្យអនុវត្តរួមមាន **១.**រមណីយដ្ឋានទេសចរណ៍ **២.** សហគមន៍ទេសចរណ៍ **៣.**ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ **៤.**សេវាកម្មស្នាក់នៅទេសចរណ៍ **៥.**ដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក **៦.** ដឹកជញ្ជូនទេសចរណ៍ផ្លូវគោក **៧.** កាស៊ីនូទេសចរណ៍ក្នុងស្រុក និង **៨.** មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត។ ដើម្បីវាយតម្លៃសម្រេចផ្តល់ឱ្យឡាបិលវិធានសុវត្ថិភាពទេសចរណ៍ ក្រសួងទេសចរណ៍បានរៀបចំគោលការណ៍ណែនាំកំណត់អំពីលក្ខខណ្ឌអប្បបរមា។

**(៩៨)**. **ដោយឡែកក្នុងជំហានទី២** ក្រសួងទេសចរណ៍គ្រោងរៀបចំវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មទេសចរណ៍ រួមមាន **១.**កីឡាទេសចរណ៍ **២.**សេវាកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (បៀហ្គាឌិន ខារ៉ាអូខេ រង្គសាល និងឌីស្កូតែក) **៣.** សេវាកម្មស្ប៉ា និងម៉ាស្សា **៤.**សេវាកម្មម៉ាយ (MICE)[8] បន្ទប់ប្រជុំ **៥.**សេវាកម្មព្រឹត្តិការណ៍ទេសចរណ៍ និង **៦.**កាស៊ីនូទេសចរណ៍នាំភ្ញៀវចូល។

---

[7] សៀវភៅជំនួយស្មារតី ស្តីពី វិធានការរាជរដ្ឋាភិបាល និងកម្រងសារសម្រាប់បញ្ជ្រាបដល់ស្រទាប់មហាជននៅតាមមូលដ្ឋានក្នុងដំណាក់កាលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ របស់គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល ខែសីហា ឆ្នាំ២០២០។

[8] ទេសចរណ៍ម៉ាយ (MICE) គឺជាប្រភេទទេសចរណ៍ផ្អែកលើព្រឹត្តិការណ៍សន្និសីទ និងកិច្ចប្រជុំនានា។

(**៥៩**). យន្តការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ មានដូចជា(**ទី១).** យន្តការស្ថាប័នថ្នាក់ជាតិ ដោយការបង្កើតអនុក្រុមការងារដើម្បីជំរុញ និងតាមដានការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ (ជំហានទី១) ចំណុះឱ្យក្រុមការងារជំរុញ និងលើកស្ទួយវិស័យទេសចរណ៍ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ និងថ្នាក់ក្រោមជាតិអនុវត្តសម្រេចផ្តល់ជូននូវឡាបិលវិធានសុវត្ថិភាពទេសចរណ៍នីមួយៗត្រូវបានពិនិត្យ និងផ្តល់ឱ្យ (**ទី២).** រៀបចំជាក្រមប្រតិបត្តិ និងគោលការណ៍ណែនាំ ដោយផ្តោតលើការណែនាំឱ្យរៀបចំទីតាំងអាជីវកម្មស្របតាមការណែនាំថ្មីក្នុងបរិបទទម្លាប់ថ្មី និងណែនាំលើការប្រាស្រ័យទាក់ទងគ្នាក្នុងរបៀបថ្មី រវាងភ្ញៀវ និងបុគ្គលិក និង (**ទី៣).** រៀបចំយន្តការគាំទ្រតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងភ្ញៀវក្នុងដំណាក់កាលជំងឺកូវីដ-១៩ គឺប្រព័ន្ធបច្ចេកវិទ្យាចុះបញ្ជីវត្តមានភ្ញៀវទេសចរតាមរយៈ (Telegram BOT) ដើម្បីគ្រប់គ្រងទិន្នន័យ និងដំណើរការរបស់ភ្ញៀវទេសចរ ដែលអាចឆ្លើយតបបានទាន់ពេលវេលាក្នុងការគ្រប់គ្រងស្ថានភាពក្នុងដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ និងប្រព័ន្ធចុះបញ្ជីស្នាក់នៅទេសចរណ៍ (www.accommodationregistrar.net) ដើម្បីគ្រប់គ្រងលំហូរភ្ញៀវទេសចរក្នុងស្រុក និងភ្ញៀវទេសចរអន្តរជាតិ សម្រួលដល់ការចុះបញ្ជីស្នាក់នៅតាមប្រព័ន្ធអនឡាញ និងដើម្បីរក្សាទិន្នន័យរាល់ការស្នាក់នៅរបស់ភ្ញៀវទេសចរតាមអាជីវកម្មស្នាក់នៅទេសចរណ៍នីមួយៗ។

(**៦០**). ទន្ទឹមនឹងនេះ ក្រសួងទេសចរណ៍បានដាក់ចេញកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍តាមប្រព័ន្ធអនឡាញក្នុងនោះមាន (**ទី១).** ប្រព័ន្ធបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍តាមប្រព័ន្ធអនឡាញ (https://www.tptd.org) មានជំនាញដូចជា សហគ្រិនភាពក្នុងវិស័យទេសចរណ៍ ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពជាមួយសហការីនិងអតិថិជន បដិសណ្ឋារកិច្ចនិងការគួរសមភ្ញៀវ និងការលើកកម្ពស់គុណភាពសេវាកម្មសម្រាប់សេវាកម្មសណ្ឋាគារ និងភោជនីយដ្ឋាន (**ទី២).** ប្រព័ន្ធបណ្តុះបណ្តាលពង្រឹងសមត្ថភាព (Refreshment) ជំនាញមគ្គុទ្ទេសក៍ទេសចរណ៍តាមអនឡាញ (www.cambodia-touristguide.com) និង (**ទី៣).** ប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ (E-Certificate) (www.tourismecertificate.org)។

(**៦១**). ដូច្នេះ ក្នុងយុទ្ធសាស្ត្រទី១ ដែលជាបរិបទនៃទម្លាប់ថ្មីនេះនឹងត្រូវអនុវត្តតាម**សកម្មភាពយុទ្ធសាស្ត្រចំនួន ១០ ធំៗ រួមមាន÷**

១- ការអនុវត្តវិធានទ្រទ្រង់សេដ្ឋកិច្ចសំដៅការកាត់បន្ថយផលប៉ះពាល់ទៅលើឧស្សាហកម្មទេសចរណ៍
២- បន្តតាមដានផលប៉ះពាល់ពីជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ចទេសចរណ៍ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩
៣- ការផ្តល់កិច្ចគាំពារអាជីវកម្មទេសចរណ៍ខ្នាតតូច និងខ្នាតមធ្យម
៤- ការសម្រួចឡើងវិញនូវខ្សែចង្វាក់តម្លៃទេសចរណ៍ ឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការប្រើប្រាស់ផលិតផលក្នុងស្រុក “បង្កើតអន្តរសកម្មរវាងវិស័យទេសចរណ៍ កសិកម្ម សិប្បកម្ម និងវត្ថុអនុស្សាវរីយ៍ និងឧស្សាហកម្មច្នៃប្រឌិត”
៥- ជំរុញការអនុវត្ត និងផ្សព្វផ្សាយពីវិធានសុវត្ថិភាពទេសចរណ៍ “ទម្លាប់ថ្មីនៃទេសចរណ៍ និងការធ្វើដំណើរ” ក្រោមយុទ្ធនាការ “ការធ្វើដំណើរទេសចរណ៍សុវត្ថិភាព - Safe Travel”
៦- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងឧស្សាហកម្មទេសចរណ៍ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ និងបង្កើនផលិតភាពនៃការផ្តល់សេវាកម្មទេសចរណ៍
៧- ជំរុញការក្តាប់យកភាពជាម្ចាស់ការលើដំណើរការស្តារវិស័យទេសចរណ៍ឡើងវិញ ដោយប្រើប្រាស់ទេពកោសល្យ និងធនធានដែលមានស្រាប់នៅក្នុងវិស័យទេសចរណ៍
៨- រៀបចំកម្មវិធីប្រកួតប្រជែងធុរកិច្ចថ្មីៗ (Startups) ក្នុងវិស័យទេសចរណ៍ដែលមានសក្តានុពល

៩- ការត្រៀមលក្ខណៈសម្បត្តិឱ្យបុគ្គលិកក្នុងឧស្សាហកម្មទេសចរណ៍ត្រៀមខ្លួនឆ្ពោះទៅដំណាក់កាលស្តារឡើងវិញ (តាមរយៈការពង្រឹងជំនាញវិជ្ជាជីវៈ និងសមត្ថភាពខ្លួន)

១០- សិក្សារៀបចំមូលនិធិលើកស្ទួយវិស័យទេសចរណ៍កម្ពុជា។

## ខ- យុទ្ធសាស្ត្រទី២: ជំរុញទេសចរណ៍ក្នុងស្រុក និងត្រៀមទទួលភ្ញៀវទេសចរអន្តរជាតិ÷ "ទេសចរពិសេសស្ថិតក្រោមការគ្រប់គ្រង"

(**៦២**). ក្រៅពីការធានាបាននៅភាពរស់រានឡើងនៃអាជីវកម្មទេសចរណ៍ហើយនិងការងារ គឺត្រូវមានការគិតអំពីការជំរុញឱ្យមានតម្រូវការដែលអាចធ្វើទៅកើតនៅក្នុងដំណាក់កាលនេះ។ ដូច្នេះ យុទ្ធសាស្ត្រទី២ នេះត្រូវបានចែកចេញជា **០២ចំណុច**សំខាន់ៗ រួមមាន÷

**ចំណុចទី១). យុទ្ធនាការជំរុញ "ទេសចរណ៍ក្នុងស្រុក"**

១- បង្កើតយន្តការបង្កលក្ខខណ្ឌងាយស្រួលដល់សកម្មភាពដំណើរកម្សាន្ត និងទេសចរណ៍ក្នុងស្រុក (ក្នុងដំណាក់កាលទម្លាប់ថ្មី) ដោយយោងលទ្ធផលនៃការអង្កេតរបស់**មជ្ឈមណ្ឌលកម្ពុជា ៤.០**[9] *"ប្រជាពលរដ្ឋភាគច្រើន នៅតែមានតម្រូវការខ្ពស់ក្នុងការធ្វើដំណើរកម្សាន្តនៅតាមគោលដៅរាជធានី-ខេត្តទូទាំងប្រទេស ជាពិសេសនៅពេលសភាពការណ៍នៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ហាក់មានភាពស្ងប់ស្ងាត់។ ក្នុងន័យនេះ គួរត្រៀមរៀបចំកញ្ចប់ដំណើរកម្សាន្តថ្មីៗ ប្លែកៗនៅតាមតំបន់ទេសចរណ៍នានា ដែលមានប្រជាប្រិយភាពខ្លាំង ហើយដែលមានភាពទាក់ទាញជាពិសេសសម្រាប់ក្រុមទេសចរយុវវ័យ ដែលអាចជាប្រភេទទីផ្សារទេសចរណ៍ដើបឆាប់រហ័សជាងគេ"*។

២- យុទ្ធនាការផ្សព្វផ្សាយគោលដៅ និងរមណីយដ្ឋានទេសចរណ៍នានាតាមប្រព័ន្ធឌីជីថល

៣- ការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ផ្លូវ ជាអាទិភាព) និងបញ្ចូលទឹក ភ្លើង លូ និងការគ្រប់គ្រងបរិស្ថាន (ជាពិសេសម្រាម) ដើម្បីជំរុញទេសចរណ៍ក្នុងស្រុក និងត្រៀមការងើបឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាប្រកបដោយនិរន្តរភាព។

**ចំណុចទី២). ការត្រៀមលក្ខណៈសម្បត្តិទទួលស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិ (កម្រិតតំបន់)**

១- យុទ្ធនាការទំនាក់ទំនងសាធារណៈជាសារ "**កម្ពុជាកំពុងរង់ចាំអ្នក - Cambodia is waiting for you**" និងការផ្តល់នូវព័ត៌មានជាក់លាក់ និងគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងវិធានការរឹតត្បិតការធ្វើដំណើរ

២- ការផ្សព្វផ្សាយកម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយសុវត្ថិភាព: ការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនង និងបង្កើតយន្តការច្បាស់លាស់ដើម្បីកសាងភាពជឿទុកចិត្ត និងភាពជឿជាក់ពីភ្ញៀវទេសចរ (Build Trust and Confidence)។ ត្រង់ចំណុចនេះ យុទ្ធនាការផ្សព្វផ្សាយនេះ ត្រូវធ្វើឱ្យបានខ្លាំងចាប់ពីចុងដំណាក់កាលទី១ (ឆ្នាំ២០២១) ដើម្បីចាប់យកកាលានុវត្តភាព ស្របពេលដែលកម្ពុជាត្រូវបានពិភពលោកវាយតម្លៃ និងទទួលស្គាល់ថាជាប្រទេសជាប់ចំណាត់ថ្នាក់**លេខ១ នៅលើពិភពលោក (ក្នុងចំណោម ១៦៦ប្រទេស) "ជាប្រទេសដែលគ្រប់គ្រងជំងឺឆ្លង និងផលប៉ះពាល់ពីជំងឺកូវីដ-១៩ បានល្អជាងគេ"**[10]។

---

[9] លទ្ធផលនៃការវិភាគលើការស្ទង់មតិ ស្តីពី "**ផលប៉ះពាល់នៃការរីករាលដាលសកលជំងឺកូវីដ-១៩ លើទិដ្ឋភាពបច្ចេកវិទ្យា និងវិស័យសេដ្ឋកិច្ចសង្គម**"។

[10] យោងតាមរបាយការណ៍របស់ Le Bureau de Prospective Economique (BPE) du Senegal ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០។

៣- រៀបចំយុទ្ធនាការកម្ពុជាជា “**គោលដៅទេសចរណ៍ស្អាត បៃតង និងសុវត្ថិភាព (Clean, Green and Safety)**” និងបន្តជំរុញចលនាប្រឡងប្រណាំង “**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**” ពីព្រោះថា “**ភាពស្អាត**” នឹងក្លាយជាទម្លាប់ថ្មីសម្រាប់វិស័យទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩

៤- សិក្សា និងរៀបចំគម្រោងទេសចរណ៍ប្រភេទ “**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព - One way and Closed-Loop Chartered Planes/Travel Bubble/Safe Travel Pass**” ជាមួយប្រទេសក្នុងតំបន់អាស៊ាន និងអាស៊ានបូកបី (ចិន ជប៉ុន កូរ៉េ ថៃ វៀតណាម សិង្ហបុរី)

៥- សិក្សា និងរៀបចំយន្តការធ្វើដំណើរដោយខ្លួនឯង (Self-driving Tour) ជាមួយប្រទេសជិតខាង

៦- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឆ្ពោះទៅការស្តារវិស័យទេសចរណ៍ឡើងវិញ និងជំរុញទាក់ទាញប្រភេទទេសចរពិសេស (ទេសចរគុណភាព) ស្ថិតក្រោមការគ្រប់គ្រង ដោយបង្កើតឱ្យមានទិដ្ឋាការពិសេស (Special Tourist Visa) ឬគោលនយោបាយនានាសម្រាប់ទេសចរបរទេសដែលធ្វើដំណើរមកទស្សនាកម្ពុជារយៈពេលយូរ

៧- កំណត់ និងសិក្សាអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ដែលកម្ពុជាមានសក្តានុពលក្រោយវិបត្តិជំងឺកូវីដ-១៩។

## គ. យុទ្ធសាស្ត្រទី៣: រៀបចំយន្តការអភិបាលកិច្ចទេសចរណ៍ឡើងវិញ÷

**(៦៣).** ក្នុងយុទ្ធសាស្ត្រទី៣នេះ ផែនទីចង្អុលផ្លូវស្នើដាក់ចេញនូវសកម្មភាពសំខាន់ៗចំនួន **៣ចំណុច** ដើម្បីរៀបចំអភិបាលកិច្ចទេសចរណ៍ឡើងវិញ រួមមាន÷

**ចំណុចទី១). សិក្សា និងរៀបចំយន្តការអភិបាលកិច្ចទេសចរណ៍ (ថ្នាក់ជាតិ)**

- ពង្រឹងរចនាសម្ព័ន្ធឆ្លើយតបដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩ ។

**ចំណុចទី២). ពង្រឹងយន្តការអភិបាលកិច្ចទេសចរណ៍ក្នុងកម្រិតថ្នាក់រាជធានី-ខេត្ត**

- ការរៀបចំបង្កើតអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (DMOs) តាមរាជធានី-ខេត្ត និងគោលដៅទេសចរណ៍សំខាន់ៗ។

**ចំណុចទី៣). ពង្រឹងអភិបាលកិច្ចទេសចរណ៍ក្នុងកម្រិតប្រតិបត្តិករទេសចរណ៍**

- ការរៀបចំផែនការពង្រឹងគុណភាពផលិតផលទេសចរណ៍ល្អៗផ្សារភ្ជាប់នឹងសុវត្ថិភាព និងបង្កើនបទពិសោធន៍ល្អៗនៅតាមរមណីយដ្ឋានទេសចរណ៍នានា ដោយយោងតាមស្មារតីរបស់**កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ានលើកទី២៤ និងកិច្ចប្រជុំពាក់ព័ន្ធ**តាមរយៈប្រព័ន្ធវីឌីអូ នៅថ្ងៃទី ៤-៥ ខែកុម្ភៈ ឆ្នាំ២០២១ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ រដ្ឋមន្ត្រីទេសចរណ៍អាស៊ានបានឯកភាព និងបានលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតលើភាគីពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន ពិសេសវិស័យឯកជននៅកម្រិតសហគមន៍ និងរមណីយដ្ឋានតែម្តងក្នុងការអភិវឌ្ឍវិស័យទេសចរណ៍[11]។

[11] យោងសេចក្តីប្រកាសព័ត៌មានរួម របស់កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ានលើកទី២៤ និងកិច្ចប្រជុំពាក់ព័ន្ធតាមរយៈប្រព័ន្ធវីឌីអូ នៅថ្ងៃទី ៤៥ ខែកុម្ភៈ ឆ្នាំ២០២១ រាជធានីភ្នំពេញ (ទំព័រទី៤ កថាខណ្ឌទី១៩)

# ផែនការសកម្មភាពអនុវត្តសង្ខេបនៃដំណាក់កាលទី១ : ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (២០២០-២០២១)

| **យុទ្ធសាស្ត្រ** | **១.១- ជំនួយផ្នែកសេដ្ឋកិច្ចចំពោះវិស័យឯកជន និងការងារ** | **១.២- ជំរុញទេសចរណ៍ក្នុងស្រុក និងត្រៀមទទួលភ្ញៀវទេសចរអន្តរជាតិ “ទេសចរពិសេសស្ថិតក្រោមការគ្រប់គ្រង”** | **១.៣- រៀបចំយន្តការអភិបាលកិច្ចទេសចរណ៍ឡើងវិញ** |
|---|---|---|---|
| **ដំណាក់កាលទី១** (Resilience and Restart) (ឆ្នាំ២០២០-២០២១) | ១.១.១- ការអនុវត្តវិធានទ្រទ្រង់សេដ្ឋកិច្ចសំដៅការកាត់បន្ថយផលប៉ះពាល់ទៅលើឧស្សាហកម្មទេសចរណ៍ | **១.២.១ យុទ្ធនាការជំរុញ “ទេសចរណ៍ក្នុងស្រុក”** | **១.៣.១- សិក្សា និងរៀបចំយន្តការអភិបាលកិច្ចទេសចរណ៍ (ថ្នាក់ជាតិ)** |
| | ១.១.២- បន្តតាមដានផលប៉ះពាល់ពីជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ចទេសចរណ៍ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ | ១.២.១.១- បង្កើតយន្តការបង្កលក្ខខណ្ឌងាយស្រួលដល់សកម្មភាពដំណើរកម្សាន្ត និងទេសចរណ៍ក្នុងស្រុក (ក្នុងដំណាក់កាលទម្លាប់ថ្មី) | ១.៣.១.១- ពង្រឹងរចនាសម្ព័ន្ធឆ្លើយតបដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩ |
| | ១.១.៣- ការផ្តល់កិច្ចគាំពារអាជីវកម្មទេសចរណ៍ខ្នាតតូច និងខ្នាតមធ្យម | ១.២.១.២- យុទ្ធនាការផ្សព្វផ្សាយគោលដៅ និងរមណីយដ្ឋានទេសចរណ៍នានាតាមប្រព័ន្ធឌីជីថល | **១.៣.២- អភិបាលកិច្ចទេសចរណ៍ក្នុងកម្រិតថ្នាក់រាជធានី-ខេត្ត** |
| | ១.១.៤- ការសម្រួចឡើងវិញនូវខ្សែចង្វាក់តម្លៃទេសចរណ៍ ឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការប្រើប្រាស់ផលិតផលក្នុងស្រុក “បង្កើតអន្តរសកម្មរវាងវិស័យទេសចរណ៍ កសិកម្ម សិប្បកម្ម និងវត្ថុអនុស្សាវរីយ៍ និងឧស្សាហកម្មច្នៃប្រឌិត” | ១.២.១.៣- ការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ផ្លូវ ជាអាទិភាព) និងបញ្ចូលទឹក ភ្លើង លូ និងការគ្រប់គ្រងបរិស្ថាន (ជាពិសេសម្រាម) ដើម្បីជំរុញទេសចរណ៍ក្នុងស្រុក និងត្រៀមការងើបឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាប្រកបដោយនិរន្តរភាព | ១.៣.២.១- ការរៀបចំបង្កើតអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ តាមរាជធានី-ខេត្ត និងគោលដៅទេសចរណ៍សំខាន់ៗ |
| | ១.១.៥- ជំរុញការអនុវត្ត និងផ្សព្វផ្សាយពីវិធានសុវត្ថិភាពទេសចរណ៍ “ទម្លាប់ថ្មីនៃទេសចរណ៍ និងការធ្វើដំណើរ” ក្រោមយុទ្ធនាការ “ការធ្វើដំណើរទេសចរណ៍សុវត្ថិភាព” | **១.២.២- ការត្រៀមលក្ខណៈសម្បត្តិទទួលស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិ (កម្រិតតំបន់)** | **១.៣.៣- ពង្រឹងអភិបាលកិច្ចទេសចរណ៍ក្នុងកម្រិតប្រតិបត្តិករទេសចរណ៍** |
| | ១.១.៦- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងឧស្សាហកម្មទេសចរណ៍ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ និងបង្កើនផលិតភាពនៃការផ្តល់សេវាកម្មទេសចរណ៍ | ១.២.២.១- យុទ្ធនាការទំនាក់ទំនងសាធារណៈជាសារ “កម្ពុជាកំពុងរង់ចាំអ្នក - Cambodia is waiting for you” និងការផ្តល់នូវព័ត៌មានជាក់លាក់ និងគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងវិធានការរឹតត្បិតការធ្វើដំណើរ | ១.៣.៣.១- ការរៀបចំផែនការពង្រឹងគុណភាពផលិតផលទេសចរណ៍ល្អៗផ្សារភ្ជាប់នឹងសុវត្ថិភាព និងបង្កើនបទពិសោធន៍ល្អៗនៅតាមរមណីយដ្ឋានទេសចរណ៍នានា។ |
| | ១.១.៧- ជំរុញការក្តាប់យកភាពជាម្ចាស់ការលើដំណើរការស្តារវិស័យទេសចរណ៍ឡើងវិញដោយប្រើប្រាស់ទេពកោសល្យ និងធនធានដែលមានស្រាប់នៅក្នុងវិស័យទេសចរណ៍ | ១.២.២.២- ការផ្សព្វផ្សាយកម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយសុវត្ថិភាពៈ ការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនង និងបង្កើតយន្តការច្បាស់លាស់ដើម្បីកសាងភាពជឿទុកចិត្ត និងភាពជឿជាក់ពីភ្ញៀវទេសចរ | |
| | ១.១.៨- រៀបចំកម្មវិធីប្រកួតប្រជែងធុរកិច្ចថ្មីៗ (Startups) ក្នុងវិស័យទេសចរណ៍ដែលមានសក្តានុពល | ១.២.២.៣- រៀបចំយុទ្ធនាការកម្ពុជាជា “គោលដៅទេសចរណ៍ស្អាត បៃតង និងសុវត្ថិភាព” និងបន្តជំរុញចលនាប្រឡងប្រណាំង “ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ” ពីព្រោះថា “ភាពស្អាត” នឹងក្លាយជាទម្លាប់ថ្មីសម្រាប់វិស័យទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩ | |
| | ១.១.៩- ការត្រៀមលក្ខណៈសម្បត្តិឱ្យបុគ្គលិកក្នុងឧស្សាហកម្មទេសចរណ៍ត្រៀមខ្លួនឆ្ពោះទៅដំណាក់កាលស្តារឡើងវិញ (តាមរយៈការពង្រឹងជំនាញវិជ្ជាជីវៈ និងសមត្ថភាពខ្លួន) | ១.២.២.៤- សិក្សា និងរៀបចំគម្រោងទេសចរណ៍ប្រភេទ “ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព - One way and Closed-Loop Chartered Planes/Travel Bubble/Safe Travel Pass” ជាមួយប្រទេសក្នុងតំបន់អាស៊ាន និងអាស៊ានបូកបី (ចិន ជប៉ុន កូរ៉េ ថៃ វៀតណាម សិង្ហបុរី) | |
| | ១.១.១០- សិក្សារៀបចំមូលនិធិលើកស្ទួយវិស័យទេសចរណ៍កម្ពុជា | ១.២.២.៥- សិក្សា និងរៀបចំយន្តការធ្វើដំណើរដោយខ្លួនឯង (Self-driving Tour) ជាមួយប្រទេសជិតខាង | |
| | | ១.២.២.៦- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឆ្ពោះទៅការស្តារវិស័យទេសចរណ៍ឡើងវិញ និងជំរុញទាក់ទាញប្រភេទទេសចរពិសេស (ទេសចរគុណភាព) ស្ថិតក្រោមការគ្រប់គ្រង ដោយបង្កើតឱ្យមានទិដ្ឋាការពិសេស ឬគោលនយោបាយនានាសម្រាប់ទេសចរបរទេសដែលធ្វើដំណើរមកទស្សនាកម្ពុជារយៈពេលយូរ | |
| | | ១.២.២.៧- កំណត់ និងសិក្សាអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ដែលកម្ពុជាមានសក្តានុពលក្រោយវិបត្តិជំងឺកូវីដ-១៩ | |

# ផែនការសកម្មភាពអនុវត្តលម្អិតសម្រាប់ដំណាក់កាលទី១ : ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (ឆ្នាំ២០២០-២០២១)

| ផែនការសកម្មភាពស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ | | | | |
|---|---|---|---|---|
| **ល.រ.** | **សកម្មភាពយុទ្ធសាស្ត្រ** | **សកម្មភាពយុទ្ធសាស្ត្រលម្អិត** | **ទឡ្ហីករណ៍** | **អង្គភាពទទួលខុសត្រូវ** |
| **ដំណាក់កាលទី១ : ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (ឆ្នាំ២០២០-២០២១)** | | | | |
| **១.១- ជំនួយផ្នែកសេដ្ឋកិច្ចចំពោះវិស័យឯកជន និងការងារ** | | | | |
| **១.១.១-** | ការអនុវត្តវិធានទ្រទ្រង់សេដ្ឋកិច្ចសំដៅការកាត់បន្ថយផលប៉ះពាល់ទៅលើឧស្សាហកម្មទេសចរណ៍ | • សិក្សា និងរៀបចំវិធានការទ្រទ្រង់សេដ្ឋកិច្ច ដើម្បីគាំទ្រដល់វិស័យទេសចរណ៍ក្នុងដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩<br>• បច្ចុប្បន្នភាព**កញ្ចប់ថវិកាសង្គ្រោះ**របស់រាជរដ្ឋាភិបាលឱ្យស្របទៅតាមស្ថានភាពជាក់ស្តែងដើម្បីការពារឧស្សាហកម្មទេសចរណ៍កម្ពុជា និងការងារក្នុងវិស័យទេសចរណ៍<br>• រៀបចំ**កញ្ចប់ថវិកាអន្តរាគមន៍ពិសេស (Intervention Package)** សម្រាប់តំបន់ដែលរងគ្រោះខ្លាំងជាងគេ ដូចជាខេត្តសៀមរាប | រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការទ្រទ្រង់សេដ្ឋកិច្ចដើម្បីគាំទ្រដល់ឧស្សាហកម្មទេសចរណ៍ និងការងារក្នុងវិស័យទេសចរណ៍ក្រោមស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ (បាន ០៧ជុំ រួចហើយ)។ ជាពិសេសខេត្តសៀមរាប ដែលកំពុងរងគ្រោះយ៉ាងខ្លាំង ដោយប្រជាជនប្រមាណជា ៨០% ដែលទទួលសេដ្ឋកិច្ចពីវិស័យទេសចរណ៍។ បណ្តាអាជីវកម្មក្នុងវិស័យទេសចរណ៍មួយចំនួនត្រូវបានបិទទ្វារ ហើយអត្រាគ្មានការងាររបស់បុគ្គលិកបម្រើការងារក្នុងវិស័យនេះក៏មានការកើនឡើងផងដែរ។ វាចាំបាច់ត្រូវមានវិធានការដាក់ចេញផ្នែកសេដ្ឋកិច្ចសំខាន់មួយចំនួន ដែលផ្តល់ការគាំទ្រដល់ធុរកិច្ច និងអាជីវកម្មទេសចរណ៍ដែលទទួលផលពីសេដ្ឋកិច្ចទេសចរណ៍។<br>**ការីទេសចរណ៍** មិនរំពឹងថានឹងមានចលនាណានៃការកក់សំបុត្រ ណាមួយរហូតដល់រដូវកាលភ្ញៀវទេសចរច្រើននៅឆ្នាំ២០២១។ ការកក់សំបុត្រនេះរំពឹង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | | |
|---|---|---|---|---|
| | | | ថាមិនលើសពី ៣០% ទៅ៤០% ធៀបទៅនឹងរដូវកាលភ្ញៀវទេសចរច្រើនក្នុងរយៈពេលមុនវិបត្តិជំងឺកូវីដ-១៩ នាពេលកន្លងមក។ ការលើកលែងពន្ធសម្រាប់អាជីវកម្មទេសចរណ៍ (Tax Holiday) គួរតែត្រូវបានពន្យារពេលយ៉ាងហោចណាស់រហូតដល់ពាក់កណ្ដាលឆ្នាំ ២០២១ ។<br>រីឯសេដ្ឋកិច្ចទេសចរណ៍ក្រៅផ្លូវការ និងបុគ្គលិកដែលមានប្រាក់ខែទាបក៏អាចរងគ្រោះខ្លាំងផងដែរ ប្រសិនបើវិបត្តិជំងឺកូវីដ-១៩នេះនៅបន្តរយៈពេលតទៅទៀត។ ករណីនេះ**កញ្ចប់ហិរញ្ញវត្ថុគាំទ្រ** គួរសិក្សារៀបចំអនុវត្តដើម្បីជំនួយដល់អ្នកដែលងាយរងគ្រោះខ្លាំងបំផុត(ជាក់ស្ដែងបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញរួចហើយនូវ **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងកំលុងពេលជំងឺកូវីដ-១៩** ដល់ប្រជាពលរដ្ឋក្រីក្រដែលមានបណ្ណសមធម៌ (ក្រ-១ និងក្រ-២) ចំនួន ៥៦ម៉ឺនគ្រួសារ រួចហើយដែរ)។ | |
| **១.១.២-** | បន្តតាមដានផលប៉ះពាល់ពីជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ចទេសចរណ៍ ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ | • ការប្រមូលព័ត៌មានជាក់លាក់អំពី ផលប៉ះពាល់មកលើសេដ្ឋកិច្ចទេសចរណ៍កម្ពុជា÷<br>- ធ្វើការស្ទង់មតិនានា និងត្រូវសិក្សា ស្ដីពីផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុមកលើឧស្សាហកម្មទេសចរណ៍ និងខ្សែចង្វាក់តម្លៃក្នុងវិស័យទេសចរណ៍<br>- រៀបចំឱ្យមានការសិក្សាបន្ថែមដែលចាំបាច់ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងវិស័យទេស - | ដើម្បីដាក់ចេញនូវវិធានការសមស្របបំផុត ទិន្នន័យដ៏ត្រឹមត្រូវគឺមានសារៈសំខាន់ណាស់។ អង្គការជាច្រើនទាំងផ្នែករដ្ឋាភិបាល និងក្នុងចំណោមសហគមន៍អន្តរជាតិ បានធ្វើការស្ទង់មតិដោយពិនិត្យមើលផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើវិស័យផ្សេងៗគ្នានៃសេដ្ឋកិច្ចជាតិទាំងមូល។ ទាំងនេះគួរតែត្រូវបានយកមកវិភាគយ៉ាងស៊ីជម្រៅដោយអ្នកវិភាគសេដ្ឋកិច្ច និងទេសចរណ៍សម្រាប់ក្រសួងទេសចរណ៍។ | - ក្រសួងទេសចរណ៍<br>- សមាគមក្នុងឧស្សាហកម្មទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | | ចរណ៍ និងវិបត្តិជំងឺកូវីដ-១៩<br>- ត្រូវមានរបាយការណ៍ពីផលប៉ះពាល់ពីជំងឺកូវីដ-១៩ ទៅលើសេដ្ឋកិច្ចទេសចរណ៍ (ប្រចាំខែ)<br>- រៀបចំប្រព័ន្ធប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញ ឬបែបប្រពៃណី ជាប្រចាំ និងប្រព័ន្ធផ្តល់របាយការណ៍ផលប៉ះពាល់លើផ្នែកផ្គត់ផ្គង់ និងតម្រូវការក្នុងវិស័យទេសចរណ៍)<br>• បង្កើតឱ្យមានគណនីរណបទេសចរណ៍ (Tourism Satellite Account) | ដោយសារស្ថានភាព និងឥទ្ធិពលនៃជំងឺកូវីដ-១៩ មានការវិវត្តគួរឱ្យកត់សម្គាល់ និងរហូតមកដល់បច្ចុប្បន្ននេះមិនទាន់មានស្ថាប័ន ឬភាគីណាមួយអាចវាយតម្លៃដឹងពីជំងឺកូវីដ-១៩ នេះអាចបញ្ចប់បាននៅពេលណានោះទេ ដែលចំណុចនេះតម្រូវឱ្យកិច្ចចូលរួមសហការគ្នារវាងសមាគមឧស្សាហកម្មទេសចរណ៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវតាមដាន និងសិក្សាឱ្យបានជាប្រចាំអំពីផលប៉ះពាល់ និងឥទ្ធិពលនៃជំងឺកូវីដ-១៩ លើវិស័យទេសចរណ៍។<br>ក្នុងរយៈពេលវែង ចាំបាច់ត្រូវបំពាក់នូវហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយដល់ក្រសួងទេសចរណ៍ដើម្បីប្រមូលទិន្នន័យត្រឹមត្រូវ និងអាចវាយតម្លៃអំពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមក្នុងវិស័យទេសចរណ៍។ ដូច្នេះគួរតែពិចារណាបង្កើតគណនីរណបទេសចរណ៍សម្រាប់ការគ្រប់គ្រងនិងវិភាគទិន្នន័យដែលទាក់ទងនឹងវិស័យទេសចរណ៍ឱ្យបានឆាប់រហ័សជាទីបំផុត។ | |
| **១.១.៣-** | ការផ្តល់កិច្ចគាំពារអាជីវកម្មទេសចរណ៍ខ្នាតតូច និងខ្នាតមធ្យម | • ផ្ទេរសមត្ថកិច្ចជូនក្រសួងសាធារណការ និងដឹកជញ្ជូន ដែលជាស្ថាប័នតែមួយក្នុងការផ្តល់អាជ្ញាបណ្ណដឹកជញ្ជូនភ្ញៀវទេសចរ<br>• សហការជាមួយក្រសួងសុខាភិបាលក្នុងការដាក់បញ្ចូលការផ្តល់អាជ្ញាបណ្ណអាជីវកម្មភោជនីយដ្ឋាន និងវិញ្ញាបនបត្របញ្ជាក់អនាម័យភោជនីយដ្ឋាន និងអាហារដ្ឋាន ទៅក្នុងថ្នាលអនឡាញ CamDX<br>• សម្រួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ច្រើនប្រភេទ | សហគ្រាសខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍ ជាផ្នែកខ្លាំងមួយនៃសេដ្ឋកិច្ចទេសចរណ៍ក្នុងប្រទេសកម្ពុជា ប៉ុន្តែវាក៏ជាផ្នែកមួយ ដែលងាយរងគ្រោះបំផុតដោយសារវិបត្តិ។ នេះរួមបញ្ចូលទាំងសហគ្រាសសង្គមដែលគាំទ្រសហគ្រាសសហគមន៍ខ្នាតតូចជាច្រើន។ វិបត្តិជំងឺកូវីដ-១៩ នេះបានបង្ហាញនូវសារៈសំខាន់ និងតួនាទីនៃវិស័យទេសចរណ៍ ក្នុងសេដ្ឋកិច្ចកម្ពុជាយ៉ាងច្បាស់ ដែលទាមទារឱ្យមានការគិតគូរបន្ថែមទៀតលើ | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |

| | | | | |
|---|---|---|---|---|
| | | ចំពោះបុគ្គលស្នើសុំតែម្នាក់ចេញពីទីតាំងតែមួយតាមរយៈថ្នាលអនឡាញ CamDX<br>• ធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីកែសម្រួលប្រព័ន្ធចំណាត់ថ្នាក់ធុរកិច្ចទេសចរណ៍ដែលជាអាជីវកម្មទេសចរណ៍ធុនតូចនិងមធ្យម ពីលក្ខខណ្ឌតម្រូវមកជាលក្ខខណ្ឌស្ម័គ្រចិត្ត<br>• ត្រូវធ្វើការត្រួតពិនិត្យឡើងវិញឱ្យច្បាស់លាស់ លើតម្រូវការ និងទំហំនៃសហគ្រាសខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍ ព្រមទាំងសហគ្រាសដ៏ទៃទៀតដែលពាក់ព័ន្ធនៅក្នុងខ្សែចង្វាក់តម្លៃក្នុងវិស័យទេសចរណ៍ ។<br>• ផ្តល់កិច្ចគាំទ្រដល់អាជីវកម្មទេសចរណ៍ធុនតូច និងមធ្យមក្នុងវិស័យទេសចរណ៍ទទួលបាននូវការគាំទ្រពីកញ្ចប់ថវិកា/មូលនិធិរបស់រាជរដ្ឋាភិបាលដែលបច្ចុប្បន្ន។ រាជរដ្ឋាភិបាលមានកញ្ចប់ថវិកាសរុបចំនួន ៥០០លានដុល្លារ ក្នុងនោះ÷<br>- មូលនិធិធានាឥណទាន (Credit Guarantee Fund)÷ មានចំនួន ២០០លានដុល្លារ ដែលរាជរដ្ឋាភិបាលនឹងបង្កើតអង្គភាពមួយ ដែលមានការចូលរួមពីធនាគារជាដៃគូដើម្បីបង្កើតជាសារជីវកម្មធានាឥណទានដល់ម្ចាស់សហគ្រាសធុនតូច និងមធ្យម ដែលគ្មានទ្រព្យធានាដើម្បីខ្ចីលុយពីធនាគារ ហើយស្ថាប័ន | ខ្សែចង្វាក់តម្លៃបន្ថែមក្នុងវិស័យទេសចរណ៍។<br>ការសិក្សាអំពីខ្សែចង្វាក់តម្លៃនៃកម្មវិធីពង្រឹងសមត្ថភាពក្នុងវិស័យទេសចរណ៍ក្រោមគម្រោងហិរញ្ញប្បទាននៃគម្រោងពង្រឹងសមត្ថភាពរបស់ទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD) អាចផ្តល់ការយល់ដឹងបន្ថែមពីអន្តរសកម្មរវាងវិស័យកសិកម្ម សិប្បកម្ម និងវិស័យទេសចរណ៍ និងក៏ដូចជាពង្រឹងរចនាសម្ព័ន្ធនៃឧស្សាហកម្មទេសចរណ៍កម្ពុជាឡើងវិញឆ្លើយតបនឹងជំងឺកូវីដ-១៩។ សហគ្រាសខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍មានចំណែកធំក្នុងខ្សែចង្វាក់ផលិតកម្មទេសចរណ៍។ អាជីវកម្មធុនតូច និងមធ្យមមានសក្តានុពលខ្ពស់ក្នុងការផ្សព្វផ្សាយកម្ពុជា និងអាចផ្តល់ការស្វាគមន៍យ៉ាងកក់ក្តៅ ប្រកបដោយស្នាមញញឹមពិតប្រាកដដល់ភ្ញៀវទេសចរស្របតាមពាក្យស្លោក "**កម្ពុជាប្រទេសតូចបេះដូងទូលាយ**"។ | |

| | | | | |
|---|---|---|---|---|
| | | ធានាឥណទាននោះ ជាអ្នកធានាជំនួសឱ្យម្ចាស់អាជីវកម្មដែលខ្ចី។<br>- កិច្ចគាំទ្រហិរញ្ញប្បទាន (Financial Facility)៖ ជំហានបន្ទាប់ដែលរាជរដ្ឋាភិបាលបានគិតគូរក្នុងវិធានការជុំទី៤ ដែលនឹងផ្តល់ថវិកាចំនួន ៣០០លានដុល្លារទៀត ដើម្បីផ្តល់ឥណទានដល់ម្ចាស់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យនានា រួមមានវិស័យទេសចរណ៍ផងដែរដែលត្រូវការឥណទានយកទៅប្រើប្រាស់ដើម្បីចូលរួមស្តារសេដ្ឋកិច្ច ឱ្យបានងើបឈរឡើងវិញ ហើយបន្តដំណើរទៅមុខទៀតក្រោយវិបត្តិជំងឺកូវីដ-១៩។ ការងារនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងរៀបយន្តការ និងដាក់ឱ្យអនុវត្តឆាប់ៗខាងមុខ។ | | |
| | | • ការផ្តល់កិច្ចគាំទ្រផ្នែកសេដ្ឋកិច្ច ដើម្បីធានារក្សាឱ្យបានប្រភេទអាជីវកម្ម ឬគម្រោងទេសចរណ៍ក្នុងស្រុកមានលក្ខណៈ (Flagship tourism) : ក្រសួងទេសចរណ៍ត្រូវធ្វើការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីផ្តល់នូវអន្តរាគមន៍ផ្នែកសេដ្ឋកិច្ចក្នុងករណីចាំបាច់ ដើម្បីការពារ និងរក្សាឱ្យបាននូវប្រភេទអាជីវកម្ម ឬគម្រោងទេសចរណ៍ក្នុងស្រុកមានលក្ខណៈ (Flagship Tourism) មិនឱ្យដួលរលំក្នុងដំណាក់កាលនៃជំងឺកូវីដ-១៩ (ដូចជា កាត់បន្ថយ និងលើកលែងពន្ធ ថ្លៃភ្លើង ទឹក ការជួលទីតាំង ឬអត្រាការប្រាក់)។ | រូបភាពទេសចរណ៍ របស់កម្ពុជា បានមកពីភ្ញៀវទេសចរ និងប្រព័ន្ធផ្សព្វផ្សាយ ដែលពួកគេបានទទួលបទពិសោធន៍ផ្សេងៗគ្នា និងធ្វើការចែករំលែកទៅកាន់ពិភពលោក។ បទពិសោធន៍មួយចំនួន ទទួលបានពីផលិតផលទេសចរណ៍ក្នុងស្រុកផងដែរ។ ជាឧទាហរណ៍ដ៏សំខាន់មួយ គឺសិប្បករអង្គរ - Artisans d'Angkor ដែលជាសហគ្រាសសង្គមឈានមុខគេ និងជាផ្នែកមួយដ៏សំខាន់នៃការផ្តល់សេវាកម្មជូនភ្ញៀវទេសចរនៅក្នុងខេត្តសៀមរាប។ Artisans d'Angkor គឺជាសហ-គ្រាសក្នុងស្រុកធំមួយនៅក្នុងខេត្តសៀមរាប ហើយការ | |

| | | | | |
|---|---|---|---|---|
| | | | បិទទ្វាររបស់សហគ្រាសនេះនឹងប៉ះពាល់ដល់សហគមន៍ជាច្រើន។ Artisans d‘Angkor គឺជាកន្លែងទាក់ទាញមួយ និងល្បីល្បាញសម្រាប់ភ្ញៀវទេសចរអន្តរជាតិ។ ដូច្នេះ ក្នុងករណីចាំបាច់ត្រូវគាំពារប្រភេទគម្រោង ឬសហគ្រាសដែលមានលក្ខណៈ (Flagship Tourism) នេះឱ្យឆ្លងផុតពីដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ និងត្រៀមខ្លួនទៅរកការងើបឡើងវិញ។ | |
| **១.១.៤-** | ការសម្រួចឡើងវិញនូវខ្សែចង្វាក់តម្លៃទេស-ចរណ៍ ឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការប្រើប្រាស់ផលិតផលក្នុងស្រុក “បង្កើតអន្តរសកម្មរវាងវិស័យទេសចរណ៍ កសិកម្ម សិប្បកម្ម និងវត្ថុអនុស្សាវរីយ៍ និងឧស្សាហកម្មច្នៃប្រឌិត” | • កំណត់អត្តសញ្ញាណដៃគូសក្តានុពលដែលជាតួអង្គសំខាន់ៗក្នុងគម្រោងនេះ (សហគមន៍ជនបទ អង្គការក្រៅរដ្ឋាភិបាល។ ល។)<br>• បង្កើតអន្តរការីសម្របសម្រួល និងផ្គូរផ្គងរវាងប្រតិបត្តិករទេសចរណ៍ និងផលិតករក្នុងស្រុក<br>• បង្កើតបណ្តាញសិប្បករ និងកសិករដែលមានស្នាដៃឆ្នើមទទួលបានស្លាកសញ្ញាទេសចរណ៍បៃតង និងច្នៃប្រឌិត<br>• បង្កើតស្លាកសញ្ញាប្រើប្រាស់ផលិតផលក្នុងស្រុក **(កេរ្តិ៍)** ដែលទទួលស្គាល់គុណភាពពី បណ្តាស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងផ្សព្វផ្សាយស្លាកយីហោ **(កេរ្តិ៍)** នេះឱ្យកាន់តែខ្លាំង<br>• ពង្រឹងគម្រោងខ្សែក្រវាត់បៃតងក្នុងខេត្តគោលដៅទេសចរណ៍ធំៗ (រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ) | វិស័យទេសចរណ៍កម្ពុជាបានកំពុងដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូល-ដ្ឋានកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ការទាញយកផលប្រយោជន៍សេដ្ឋកិច្ចសង្គមពីឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាប នៅមានកម្រិត ក្នុងនោះសេដ្ឋកិច្ចប្រជាពលរដ្ឋមានភាពផ្ទុះធ្លាយសេដ្ឋកិច្ចក្នុងរង្វង់ប្រមាណ (២៥%-៣០%) នៅឡើយ។ ផ្ទុយទៅវិញកម្ពុជាមានសក្តានុពលខ្ពស់ក្នុងវិស័យកសិកម្មដែលអាចផ្គត់ផ្គង់ដល់ឧស្សាហកម្មទេសចរណ៍បានខ្ពស់ ប៉ុន្តែទាមទារឱ្យមានការគោរពស្តង់ដាគុណភាព និងនិយាមរបស់ឧស្សាហកម្មទេសចរណ៍។ល។ | - ក្រសួងទេសចរណ៍<br>- ក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ដៃគូអភិវឌ្ឍ |

| | | | | |
|---|---|---|---|---|
| | | • បង្កើតថ្នាល ដើម្បីផ្គូរផ្គងរវាងតម្រូវការក្នុងឧស្សាហកម្មទេសចរណ៍ និងការផ្គត់ផ្គង់ផលិតផលក្នុងស្រុក<br>• លើកទឹកចិត្តប្រតិបត្តិករទេសចរណ៍ឱ្យប្រើប្រាស់ផលិតផលក្នុងស្រុកតាមរយៈ ចលនាប្រឡងប្រណាំងរង្វាន់ **សម្តេចតេជោនាយករដ្ឋមន្ត្រី “សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍” (រង្វាន់ពិសេស)** ដល់ប្រតិបត្តិករទេសចរណ៍ដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលក្នុងស្រុក | | |
| **១.១.៥-** | ជំរុញការអនុវត្ត និងផ្សព្វផ្សាយពីវិធានសុវត្ថិភាពទេសចរណ៍ “**ទម្លាប់ថ្មីនៃទេសចរណ៍ និងការធ្វើដំណើរ**” ក្រោមយុទ្ធនាការ “**ការធ្វើដំណើរទេសចរណ៍សុវត្ថិភាព**” | • **ជំរុញការអនុវត្ត÷**<br>- ជំរុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ (ជំហានទី១)÷<br>❖ រមណីយដ្ឋានទេសចរណ៍<br>❖ សហគមន៍ទេសចរណ៍<br>❖ ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍<br>❖ សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍<br>❖ ដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក<br>❖ ដឹកជញ្ជូនទេសចរណ៍ផ្លូវគោក<br>❖ កាស៊ីនោ... ❖ កាវីទេសចរណ៍ក្នុងស្រុក<br>❖ មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត<br>- បន្តរៀបចំវិធានសុវត្ថិភាពទេសចរណ៍ (ជំហានទី២)÷ | ធានាឱ្យមានការអនុវត្តវិធានសុវត្ថិភាពឱ្យបានជាប់លាប់សម្រាប់ឧស្សាហកម្មទេសចរណ៍ ដើម្បីរក្សាអនាម័យ និងកសាងទំនុកចិត្តភ្ញៀវទេសចរ ដោយទាមទារការអនុវត្តគ្រប់ផ្នែកទាំងអស់ស្របតាមការណែនាំសុវត្ថិភាពរបស់ក្រសួងសុខាភិបាល។<br>ការធ្វើដំណើរក្នុងទម្លាប់ថ្មី គឺភ្ញៀវទេសចរផ្តោតសំខាន់លើការវាយតម្លៃអំពីសុវត្ថិភាពនៃគោលដៅទេសចរណ៍នោះ។ ការដាក់ឱ្យអនុវត្តនូវវិធានសុវត្ថិភាពទេសចរណ៍ថ្នាក់ជាតិ នឹងក្លាយជាកត្តាដ៏រឹងមាំក្នុងការស្តារទំនុកចិត្តរបស់ភ្ញៀវទេសចរឡើងវិញ និងក៏ដូចជាធានានូវសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរ និងភាគីពាក់ព័ន្ធទាំងអស់ ស្របតាមពាក្យស្លោក “**សុវត្ថិភាពរបស់អ្នក គឺជាសុវត្ថិភាពរបស់យើងខ្ញុំ**” “**សុវត្ថិភាពរបស់អ្នកគឺជា** | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត<br>- ក្រសួងសុខាភិបាល<br>- រដ្ឋបាលរាជធានី-ខេត្ត<br>- វិស័យឯកជន |

| | | | | |
|---|---|---|---|---|
| | | ❖ កីឡាទេសចរណ៍<br>❖ សេវាកម្មកម្សាន្តទេសចរណ៍មនុស្សពេញវ័យ<br>❖ សេវាកម្មស្ប៉ា និងម៉ាស្សា<br>❖ សេវាកម្មម៉ាយ បន្ទប់ប្រជុំ<br>❖ សេវាកម្មព្រឹត្តិការណ៍ទេសចរណ៍<br>❖ ការីទេសចរណ៍នាំភ្ញៀវចូល | **ការទទួលខុសត្រូវរបស់យើងខ្ញុំ”** | |
| | | - រៀបចំវិធានសុវត្ថិភាពទេសចរណ៍នៅតំបន់រមណីយដ្ឋានទេសចរណ៍ធំៗ និងតំបន់បេតិកភណ្ឌពិភពលោក ពិសេសតំបន់អង្គរ ដោយផ្សារភ្ជាប់នឹងការគ្រប់គ្រងលំហូរភ្ញៀវទេសចរ ការបំពាក់ឧបករណ៍ ឬមធ្យោបាយសុវត្ថិភាពចាំបាច់មួយចំនួន និងការបណ្តុះបណ្តាលមន្ត្រីបុគ្គលិក និងភ្នាក់ងារទេសចរណ៍ ឆ្លើយតបនឹងវិធានការដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងតំបន់អង្គរ | ការគិតគូររៀបចំវិធានសុវត្ថិភាពនៅតំបន់អង្គរគឺជាសកម្មភាពអាទិភាពសម្រាប់វិស័យទេសចរណ៍កម្ពុជា ដោយសារតែតំបន់អង្គរ គឺជាគោលទេសចរណ៍អាទិភាពចម្បងរបស់កម្ពុជា។ ដូច្នេះ យើងគួរគិតគូររៀបចំគោលការណ៍ប្រតិបត្តិស្តង់ដា វិធានសុវត្ថិភាពក្នុងតំបន់អង្គរមួយ អមជាមួយការសម្រួលការគ្រប់គ្រងលំហូរភ្ញៀវទេសចរ ការបំពាក់ឧបករណ៍ ឬមធ្យោបាយសុវត្ថិភាពចាំបាច់មួយចំនួន (ទឹកអាល់កុល ប្រដាប់វាស់កំដៅ ។ល។) និងការបណ្តុះបណ្តាលមន្ត្រីបុគ្គលិក និងភ្នាក់ងារទេសចរណ៍ ឆ្លើយតបនឹងវិធានសុវត្ថិភាពទេសចរណ៍ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងតំបន់អង្គរ។ | - អាជ្ញាធរជាតិអប្សរា<br>- គ្រឹះស្ថានអង្គរ<br>- ក្រសួងសុខាភិបាល |
| | | - បន្តជំរុញការអនុវត្តវិធានសុវត្ថិភាពនៅថ្នាក់ក្រោមជាតិ ក្រុង/ខណ្ឌ/សង្កាត់/ឃុំ នៅតាមរាជធានី-ខេត្ត | ការសម្រេចបានជោគជ័យនៃការអនុវត្តវិធានសុត្ថិភាពទេសចរណ៍ទាមទារឱ្យមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង-ស្ថាប័នពាក់ព័ន្ធផងដែរ។ ដូច្នេះ ត្រូវមានការរៀបចំយុទ្ធនាការប្រឡងប្រណាំងរាជធានី-ខេត្ត ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ឬ ក្រុង/ខណ្ឌ/សង្កាត់ ដែលមាន | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត<br>- រដ្ឋបាលរាជធានី-ខេត្ត |

| | | | | |
|---|---|---|---|---|
| | | | ស្នាដៃឆ្នើមក្នុងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍។ | |
| | | - ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធនាការ “**ការធ្វើដំណើរទេសចរណ៍សុវត្ថិភាព -Safe Travel**” | ការប្រើប្រាស់បច្ចេកវិទ្យាតាមរយៈ “**ប្រព័ន្ធចុះបញ្ជីស្នាក់នៅទេសចរណ៍**” ដែលមានគេហទំព័រ www.accommodationregistrar.net និងការគ្រប់គ្រងទិន្នន័យភ្ញៀវទេសចរតាម**ប្រព័ន្ធ Telegram BOT ក្នុងឧស្សាហកម្មទេសចរណ៍**នឹងចូលរួមដល់ការផ្តល់ព័ត៌មានពីការស្នាក់នៅរបស់ភ្ញៀវទេសចរ ឬវត្តមានភ្ញៀវនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ ព័ត៌មាននេះនឹងផ្តល់លក្ខណៈងាយស្រួលដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិធានការទប់ស្កាត់វិបត្តិជំងឺកូវីដ-១៩ (ការស្វែងរក និងកំណត់អត្តសញ្ញាណភ្ញៀវដែលសង្ស័យជាដើម)។ | - ក្រសួងទេសចរណ៍<br>- រដ្ឋបាលរាជធានី-ខេត្ត<br>- វិស័យឯកជន |
| | | • **ជំរុញការផ្សព្វផ្សាយ÷**<br>- រៀបចំកម្មវិធីផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងពីវិធានសុវត្ថិភាពទេសចរណ៍នៅលើប្រព័ន្ធផ្សព្វ-ផ្សាយបណ្តាញសារព័ត៌មាន Fresh News និងបណ្តាញសង្គម។ល។<br>- ជំរុញការអនុវត្ត និងបញ្ជ្រាបការយល់ដឹងពីវិធានសុវត្ថិភាព និងអនាម័យ ដល់បុគ្គលិកនៅតាមបណ្តាកន្លែងធ្វើការ ដើម្បីឱ្យចេះការពារខ្លួនពីការឆ្លងជំងឺកូវីដ-១៩ ក៏ដូចជាទប់ស្កាត់ការចម្លងដល់សហគមន៍÷<br>❖ បង្កើតយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីវិធានសុវត្ថិភាព និងអនាម័យនៅក្នុងកន្លែង | ក្នុងរយៈពេលដំបូងនៃវិបត្តិជំងឺកូវីដ-១៩ ក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍បានបង្កើតយុទ្ធនាការ និងសារអប់រំការយល់ដឹងជាសាធារណៈជាច្រើនដល់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងសាធារណៈជន។ ប៉ុន្តែដើម្បីធានាបាននូវប្រសិទ្ធិភាពយូរអង្វែងត្រូវមានការបណ្តុះបណ្តាល និងបង្កើតឱ្យមានជនបង្គោលពីយុទ្ធនាការនេះ “**មូលដ្ឋានអាជីវកម្មមួយ ជនបង្គោលយ៉ាងហោចណាស់មួយ**” រីឯសម្រាប់ភ្ញៀវទេសចរត្រូវអនុវត្តតាមក្រមប្រតិបត្តិស្តីពី “**វិធានការសុវត្ថិភាពទេសចរណ៍**” នៅតាមមូលដ្ឋានអាជីវកម្ម។ | - ក្រសួងទេសចរណ៍<br>- ក្រសួងព័ត៌មាន<br>- រដ្ឋបាលរាជធានី-ខេត្ត<br>- វិស័យឯកជន<br>- សហភាពសហព័ន្ធយុវ-ជនកម្ពុជា |

| | | | | |
|---|---|---|---|---|
| | | ការងារទេសចរណ៍ (ជាភាសាខ្មែរ និងភាសាអង់គ្លេស)<br>❖ បង្កើតយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីវិធានសុវត្ថិភាព និងអនាម័យដល់ភ្ញៀវទេសចរអំពីឥរិយាបថសុវត្ថិភាព (Do's and Don'ts) អមជាមួយការបង្កើតឱ្យមានក្រមប្រតិបត្តិ ស្តីពី"**វិធានការសុវត្ថិភាពទេសចរណ៍**" សម្រាប់អាជីវកម្មទេសចរណ៍នីមួយៗ។<br>❖ បង្កើតយុទ្ធនាការផ្សព្វផ្សាយផលិតផល/រមណីយដ្ឋានទេសចរណ៍ថ្មីៗដែលមាននវានុវត្តន៍ | | |
| **១.១.៦-** | ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងឧស្សាហកម្មទេសចរណ៍ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ និងបង្កើនផលិតភាពនៃការផ្តល់សេវាកម្មទេសចរណ៍ | • ប្រើប្រាស់បច្ចេកវិទ្យាក្នុងការផ្សព្វផ្សាយផលិតផល និងសេវាកម្មទេសចរណ៍<br>• ជំរុញការប្រើប្រាស់ការទូទាត់ប្រាក់តាមប្រព័ន្ធបាគង និង Alipay នៅក្នុងឧស្សាហកម្មទេសចរណ៍។ល។<br>• ជំរុញការប្រើប្រាស់បច្ចេកវិទ្យា និងការបង្កើតថ្មីៗ (ភាពច្នៃប្រឌិត និងនវានុវត្តន៍ភាព)<br>• ជំរុញការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល ដល់បុគ្គលិកក្នុងវិស័យទេសចរណ៍ដើម្បីបង្កើនផលិតភាពក្នុងឧស្សាហកម្មទេសចរណ៍ | ក្នុងបរិបទនៃសេដ្ឋកិច្ចឌីជីថល តួនាទីរបស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យទេសចរណ៍ ដែលស្គាល់ថាជា "**ទេសចរណ៍ឆ្លាតវៃ**" បំពេញនូវការពេញចិត្តភ្លាមៗ និងស្របទៅតាមបុគ្គលិកលក្ខណៈពិសេសរៀងៗខ្លួន និងបម្រើសេវាឱ្យទាន់សភាពការណ៍ ដែលនឹងជំរុញឱ្យការផ្សព្វផ្សាយផលិតផល និងសេវាកម្មទេសចរណ៍ដល់គោលដៅទីផ្សារឆាប់រហ័ស និងបានដល់គ្រប់ស្រទាប់ក្នុងតម្លៃសមរម្យ ក៏ដូចជាបង្កើនផលិតភាពការងារខ្ពស់ជាងមុនតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ឬការប្រើប្រាស់ផលិតផលទេសចរណ៍ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍។ | - ក្រសួងទេសចរណ៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- មជ្ឈមណ្ឌលតេជោធុរកិច្ចថ្មី<br>- មជ្ឈមណ្ឌលកម្ពុជា ៤.០ |
| **១.១.៧-** | ជំរុញការក្តាប់យកភាពជាម្ចាស់ការលើដំណើរការស្តារវិស័យទេសចរណ៍ឡើងវិញ | • បង្កើតការប្រកួតប្រជែង និងយុទ្ធនាការថ្នាក់ជាតិ ដើម្បីលើកកម្ពស់ការច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីគាំទ្រការស្តារឡើងវិញនៃវិស័យទេសចរណ៍ | ក្នុងកំលុងពេលវិបត្តិជំងឺកូវីដ-១៩ អ្នកដែលមានទេពកោសល្យ និងបញ្ញាវ័ន្តខ្មែរអាចប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍ក្នុងការបង្កើតសកម្មភាព/ | - ក្រសួងទេសចរណ៍<br>- មជ្ឈមណ្ឌលកម្ពុជា ៤.០ |

| | | | | |
|---|---|---|---|---|
| | ដោយប្រើប្រាស់ទេពកោសល្យ និងធនធានដែលមានស្រាប់នៅក្នុងវិស័យទេសចរណ៍ | | កម្មវិធីដែលមានភាពច្នៃប្រឌិត និងប្រកបដោយនវានុវត្តន៍ទ្រទ្រង់ដល់ការស្តារឡើងវិញនៃវិស័យទេសចរណ៍។ ធនធាននេះអាចត្រូវបានប្រើប្រាស់ដើម្បីជួយបង្កើតសកម្មភាពពាក់ព័ន្ធនានាដើម្បីគាំទ្រដល់ការស្តារវិស័យទេសចរណ៍ និងការអភិវឌ្ឍទេសចរណ៍កម្ពុជាក្នុងរយៈពេលវែង។<br>ការប្រកួតប្រជែងថ្នាក់ជាតិមួយគួរបង្កើតឡើង (អាចយកគំរូនៃកម្មវិធីរបស់អង្គការទេសចរណ៍ពិភពលោក-UNWTO/Healing Solutions for Tourism) និងផ្តល់ឱកាសក្នុងការប្រើប្រាស់ធនធាននេះដើម្បីផ្តល់នូវយន្តការចូលរួមជាវិជ្ជមានរបស់អ្នកដែលមានទេពកោសល្យខ្មែរក្នុងការស្វែងរកដំណោះស្រាយសម្រាប់ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា។ | - មជ្ឈមណ្ឌលតេជោធុរកិច្ចថ្មី<br>- សហគ្រិនខ្មែរ |
| **១.១.៨-** | រៀបចំកម្មវិធីប្រកួតប្រជែងធុរកិច្ចថ្មីៗ (Startups) ក្នុងវិស័យទេសចរណ៍ដែលមានសក្តានុពល | • លើកទឹកចិត្តដល់បុគ្គលដែលមានសមត្ថភាព និងគំនិតច្នៃប្រឌិតក្នុងការស្តារវិស័យទេសចរណ៍កម្ពុជាឡើងវិញក្រោយវិបត្តិកូវីដ-១៩។ បង្កើតការប្រកួតប្រជែង និងយុទ្ធនាការថ្នាក់ជាតិដើម្បីលើកកម្ពស់ការច្នៃប្រឌិត ក្នុងការស្តារឡើងវិញ ក្នុងនោះរួមមាន ÷<br>– ការប្រកួតប្រជែង "ធុរកិច្ចថ្មី" ក្នុងផ្នែកម្ហូបអាហារខ្មែរ<br>– ការប្រកួតប្រជែង "ធុរកិច្ចថ្មី" ក្នុងផ្នែកសហគមន៍ទេសចរណ៍/ អេកូទេសចរណ៍/ ទេសចរណ៍ជនបទ | ក្នុងកំលុងពេលនៃវិបត្តិជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ខ្សែចង្វាក់អាជីវកម្មក្នុងវិស័យទេសចរណ៍ជាហេតុធ្វើឱ្យមានភាពចាំបាច់ក្នុងការបង្កើតឱ្យមានភាពច្នៃប្រឌិត និងនវានុវត្តន៍តាមរយៈការបង្កើត និងបណ្តុះឱ្យមានធុរកិច្ចថ្មីៗក្នុងវិស័យទេសចរណ៍ ឬផ្នែកសំខាន់ៗនៃវិស័យទេសចរណ៍កម្ពុជា។ | - ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | | – ការប្រកួតប្រជែង “ធុរកិច្ចថ្មី” ក្នុងផ្នែកបដិសណ្ឋារកិច្ចល្អ។ល។ | | |
| **១.១.៩-** | ការត្រៀមលក្ខណៈសម្បត្តិឱ្យបុគ្គលិកក្នុងឧស្សាហកម្មទេសចរណ៍ត្រៀមខ្លួនឆ្ពោះទៅដំណាក់កាលស្តារឡើងវិញ (តាមរយៈការពង្រឹងជំនាញវិជ្ជាជីវៈ និងសមត្ថភាពខ្លួន) | • រៀបចំកម្មវិធីបណ្តុះបណ្តាលដល់កម្មករ-បុគ្គលិកដែលបាត់បង់ការងារនៅក្នុងវិស័យទេសចរណ៍ (បុគ្គលិកបម្រើការនៅតាមសណ្ឋាគារ ផ្ទះសំណាក់ និងទីភ្នាក់ងារទេសចរណ៍) តាមរយៈការរៀបចំឱ្យមាននូវវគ្គបណ្តុះបណ្តាលពង្រឹងជំនាញដែលមានស្រាប់ និងបណ្តុះបណ្តាលជំនាញថ្មី។<br>• បង្កើនជំនាញដល់បុគ្គលិកដែលមានស្រាប់ដើម្បីលើកកម្ពស់គុណភាពសេវាកម្ម និងត្រៀមលក្ខណៈសម្បត្តិលើកស្ទួយប្រទេសកម្ពុជាជាគោលដៅទេសចរណ៍ដែលមានគុណភាពខ្ពស់ក្នុងដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩។<br>• ពង្រឹងយន្តការផ្គត់ផ្គង់ទីផ្សារការងារក្នុងវិស័យទេសចរណ៍ ពិសេសពង្រឹងការស្រង់ទិន្នន័យ និងចុះបញ្ជីកម្លាំងពលកម្មបម្រើការនៅឧស្សាហកម្មទេសចរណ៍ | ផលប៉ះពាល់ខាងសេដ្ឋកិច្ចបានបណ្តាលឱ្យមានការបិទអាជីវកម្មទេសចរណ៍មួយចំនួន។ សូម្បីតែអាជីវកម្មទេសចរណ៍ដែលបិទទ្វារជាបណ្តោះអាសន្នក៏បានបញ្ឈប់ការងារបុគ្គលិករបស់ខ្លួនផងដែរ។ ការបាត់បង់ធនធានមនុស្សដែលមានសមត្ថភាពក្នុងជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ចគឺជាហានិភ័យដ៏ធំមួយនៅពេលដែលទេសចរណ៍ចាប់ផ្តើមបើកម្តងទៀត។ រដ្ឋាភិបាល និយោជិក និងអង្គការក្រៅរដ្ឋាភិបាល បានវិនិយោគយ៉ាងច្រើនក្នុងការបណ្តុះបណ្តាលមុនពេលមានវិបត្តិជំងឺកូវីដ-១៩ នេះ ។ សូម្បីតែបុគ្គលិកដែលមានជំនាញខាងសេវាកម្មអតិថិជន និងភាសាអន្តរជាតិនឹងអាចប្តូរទៅវិស័យការងារផ្សេងទៀត (ក្រៅពីទេសចរណ៍) ហើយប្រសិននៅពេលដែលបុគ្គលិកទាំងនោះមានការងារល្អ នោះពួកគេនឹងអាចមិនត្រលប់មកធ្វើការងារក្នុងវិស័យទេសចរណ៍វិញទេ។<br>ការធានាថាឱ្យមានធនធានមនុស្សគឺមានសារៈសំខាន់ណាស់ ដូច្នេះវិធានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពជំនាញវិជ្ជាជីវៈទេសចរណ៍ត្រូវបានលើកឡើងជាបន្តបន្ទាប់ក្នុងវិធានការសង្គ្រោះរបស់រាជរដ្ឋាភិបាលកម្ពុជា (ទាំង ០៧ជុំ) រួចមកហើយ និងក្រសួងទេសចរណ៍ក៏បានដាក់ចេញកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍តាមអនឡាញ (E-Learning) ផងដែរ។ | - ក្រសួងទេសចរណ៍<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | | |
|---|---|---|---|---|
| ១.១.១០- | សិក្សារៀបចំ**មូលនិធិលើកស្ទួយវិស័យទេសចរណ៍កម្ពុជា** | • បង្កើតនូវមូលនិធិទ្រទ្រង់សម្រាប់លើកស្ទួយវិស័យទេសចរណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ និងកៀរគរការចូលរួមពីបណ្តាដៃគូនានា | ដំណើរការនៃការជំរុញសកម្មភាពស្តារឡើងវិញនៃវិស័យទេសចរណ៍នឹងត្រូវការការវិនិយោគសាធារណៈ/ឯកជន ក្នុងកម្រិតគួរឱ្យកត់សម្គាល់។ ការចូលរួមពីផ្នែកឯកជននៅកម្ពុជានៅមានកម្រិត។ រយៈពេលនៃការស្តារឡើងវិញនឹងតម្រូវឱ្យមានធនធានសម្រាប់គាំទ្រដល់សកម្មភាពធ្វើការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ លើកកម្ពស់ការអភិវឌ្ឍផលិតផល ការគាំទ្រកម្មវិធីបណ្តុះបណ្តាលនានាដែលចាំបាច់ និងការដាក់ឱ្យដំណើរការយុទ្ធនាការ សំដៅបង្កើនទំនុកចិត្តពីសំណាក់ភ្ញៀវទេសចរចំពោះសុវត្ថិ-ភាពគោលដៅទេសចរណ៍កម្ពុជា ការរៀបចំ និងចូលរួមព្រឹត្តិការណ៍ទេសចរណ៍ជាតិ និងអន្តរជាតិ ការលើកទឹកចិត្តក្នុងការធ្វើដំណើរទេសចរណ៍ក្នុងស្រុក។ ដូច្នេះត្រូវការសិក្សាបង្កើតឱ្យមានមូលនិធិលើកស្ទួយវិស័យទេសចរណ៍កម្ពុជា មួយសម្រាប់ដំណាក់កាលទី២ និងទី៣ នៃផែនទីចង្អុលផ្លូវនេះ ឬប្រើប្រាស់មូលនិធិដែលមានស្រាប់សម្រាប់វិស័យទេសចរណ៍ ចាត់ចែងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។<br>វិធានការនេះក៏ស្របទៅនឹងវិធានការគោលនយោបាយរបស់ប្រទេសផ្សេងៗដែលបានយកមកអនុវត្តផងដែរ។ ឧទាហរណ៍ ក្រុងហុងកុង បានផ្តល់ជំនួយមូលនិធិហិរញ្ញវត្ថុចំនួន ៥១លានដុល្លារអាម៉េរិក ដើម្បីគាំទ្រដល់សកម្មភាពទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ប្រទេសជប៉ុនក៏បានប្តេជ្ញាចិត្តបង្កើតមូលនិធិវត្ថុចំនួន | - ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍<br>- ដៃគូអភិវឌ្ឍ |

| | | | | |
|---|---|---|---|---|
| | | | ១២ប៊ីលានដុល្លារ ដើម្បីជំរុញវិស័យទេសចរណ៍ក្នុងស្រុក។ ប្រទេសអេហ្ស៊ីប ក៏បានប្រកាសកញ្ចប់ថវិកាសម្រាប់សកម្មភាពជំរុញក្នុងការស្តារឡើងវិញក្នុងទឹកប្រាក់ចំនួន ៨ប៊ីលានដុល្លារ និងថវិកាចំនួន ៣,៨ប៊ីលានដុល្លារ ត្រូវបានបម្រុងទុកសម្រាប់ឧស្សាហកម្មទេសចរណ៍ដោយផ្ទាល់ហើយនឹងត្រូវបានប្រើប្រាស់ដើម្បីសង្គ្រោះ និងរក្សាឧស្សាហកម្មផ្នែកសណ្ឋាគារ និងភោជនីយដ្ឋានឱ្យមានដំណើរការក្នុងពេលជួបវិបត្តិក្នុងដំណាក់កាលស្តារឡើងវិញផងដែរ។ | |
| **១.២- ជំរុញទេសចរណ៍ក្នុងស្រុក និងត្រៀមទទួលភ្ញៀវទេសចរអន្តរជាតិ “ទេសចរពិសេសស្ថិតក្រោមការគ្រប់គ្រង”** | | | | |
| **១.២.១- យុទ្ធនាការជំរុញ “ទេសចរណ៍ក្នុងស្រុក”** | | | | |
| **១.២.១.១-** | បង្កើតយន្តការបង្កលក្ខខណ្ឌងាយស្រួលដល់សកម្មភាពដំណើរកម្សាន្ត និងទេសចរណ៍ក្នុងស្រុក (ក្នុងដំណាក់កាលទម្លាប់ថ្មី) | • រៀបចំរមណីយដ្ឋានទេសចរណ៍ និងគោលដៅទេសចរណ៍ឱ្យមានសុវត្ថិភាពសម្រាប់ទទួលភ្ញៀវទេសចរក្នុងស្រុក<br>• គម្រោងលើកទឹកចិត្តជំរុញសកម្មភាពទេសចរណ៍ក្នុងស្រុក ដូចជាកម្មវិធីបញ្ចុះតម្លៃ និងបណ្ណបញ្ចុះតម្លៃ (បណ្ណដំណើរកម្សាន្តដែលមានតម្លៃសមរម្យសម្រាប់សាស្ត្រាចារ្យ សិស្ស និស្សិត កម្មករ កម្មការិនី ផ្សារភ្ជាប់នឹងប្រភេទកញ្ចប់ទស្សនកិច្ចសិក្សា<br>• សិក្សាបង្កើតកម្មវិធីលើកទឹកចិត្តដំណើរកម្សាន្តដល់បុគ្គលិកមន្ត្រីរាជការ (ឧទាហរណ៍ Cheque de Vacances, Cheque-Restaurant)<br>• បង្កើតនូវលិខិតបណ្ណសរសើរកម្រិតថ្នាក់ជាតិដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ ដែលបានចូលរួម | នៅក្នុងរយៈពេលនៃការស្តារឡើងវិញនៃវិស័យទេសចរណ៍ចលនាទេសចរណ៍ផ្ទៃក្នុង និងទេសចរណ៍ក្នុងស្រុកនឹងមានឥទ្ធិពលខ្លាំងក្នុងការគាំទ្រដល់សេដ្ឋកិច្ចសង្គមកម្ពុជា។ ភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិ ដែលរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានរំពឹងថាជាប្រភពទីផ្សារទេសចរណ៍ដំបូងគេដែលធ្វើដំណើរម្តងទៀត និងបង្កើននូវតម្រូវការ។<br>ក្រសួងទេសចរណ៍មានផែនការផ្សព្វផ្សាយសម្រាប់ទីផ្សារទេសចរណ៍នេះ និងរៀបចំនូវការលើកទឹកចិត្តនានាដែលនឹងជំរុញដល់ការធ្វើដំណើរក្នុងស្រុក និងទេសចរណ៍ផ្ទៃក្នុង ព្រមទាំងលើកទឹកចិត្តឱ្យមានការស្នាក់នៅកាន់តែយូរ។ ផែនការដាក់ចេញអាចរួមមាន យុទ្ធសាស្ត្រតម្លៃឱ្យមានភាពប្រកួតប្រជែង ការ | - ក្រសួងទេសចរណ៍<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- វិស័យឯកជន |

| | | | | |
|---|---|---|---|---|
| | | អនុវត្តយន្តការបញ្ចុះតម្លៃ ឬលើកទឹកចិត្តដល់ការធ្វើដំណើរទេសចរណ៍ក្នុងស្រុក | ផ្សព្វផ្សាយពិសេស ឬការលើកទឹកចិត្តការធ្វើដំណើរជាដើម។<br>បណ្តាប្រទេសផ្សេងទៀតបានឆ្លើយតបទៅនឹងតម្រូវការនេះ ដោយការណែនាំនូវបណ្ណទេសចរណ៍ដែលឧបត្ថម្ភធនដោយរដ្ឋ។ ឧទាហរណ៍នៅប្រទេសរ៉ូម៉ានីបានផ្តល់បណ្ណទេសចរណ៍ដល់បុគ្គលិកផ្នែកអប់រំ និងគ្រូពេទ្យរដ្ឋទាំងអស់។ ការចំណាយបន្ថែមតាមរយៈបណ្ណទេសចរណ៍នេះ បានចាក់បញ្ចូលចំណូលយ៉ាងខ្លាំងទៅក្នុងចរន្តសេដ្ឋកិច្ចជាតិ។<br>ប្រទេសជប៉ុនបានប្តេជ្ញាចិត្តអនុវត្តចំពោះវិធីសាស្ត្រនេះ ដោយផ្តល់ការបញ្ចុះតម្លៃ និងបណ្ណគូប៉ុងសម្រាប់ប្រើប្រាស់ក្នុងការទិញសេវាកម្មទេសចរណ៍/សកម្មភាពទេសចរណ៍នានាក្នុងស្រុក។<br>នៅក្នុងរយៈពេលនៃការស្តារឡើងវិញនៃវិស័យទេសចរណ៍ ចលនាទេសចរណ៍ផ្ទៃក្នុង និងទេសចរណ៍ក្នុងស្រុកនឹងមានឥទ្ធិពលខ្លាំងក្នុងការគាំទ្រដល់សេដ្ឋកិច្ច-សង្គមកម្ពុជា។ ភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានរំពឹងថាជាប្រភពទីផ្សារទេសចរណ៍ដំបូងគេដែលធ្វើដំណើរម្តងទៀតនិងបង្កើននូវតម្រូវការ។<br>សម្រាប់កម្ពុជាក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ ក្រសួងទេសចរណ៍សហការជាមួយស្ថាប័នពាក់ព័ន្ធនានា និងវិស័យឯកជន រៀបចំបណ្ណលើកទឹកចិត្ត និង/ឬ បង្កើតជាកម្មវិធីទស្សនកិច្ចសិក្សានានា ឬបណ្ណ | |

| | | | | |
|---|---|---|---|---|
| | | | ដំណើរកម្សាន្តដែលមានតម្លៃសមរម្យ ក្រោមពាក្យស្លោក “**ទាំងអស់គ្នាអាចធ្វើដំណើរកម្សាន្តបាន** Everyone Can Go” ពោលគឺដើរកម្សាន្តឱ្យបានយ៉ាងហោចណាស់បានម្តងក្នុង១ឆ្នាំ។ | |
| **១.២.១.២-** | យុទ្ធនាការផ្សព្វផ្សាយគោលដៅ និងរមណីយដ្ឋានទេសចរណ៍នានាតាមប្រព័ន្ធឌីជីថល | • ពង្រឹងការផ្តល់ព័ត៌មាននៅតាមមណ្ឌលព័ត៌មានទេសចរណ៍រាជធានី-ខេត្ត<br>• ប្រកួតប្រជែងរូបភាពទេសចរណ៍ឆ្នើមនៅតាមរាជធានី-ខេត្ត<br>• ប្រកួតប្រជែងរមណីយដ្ឋានទេសចរណ៍ដែលទទួលបានការពេញនិយម និងពេញចិត្តជាងគេដោយភ្ញៀវទេសចរក្នុងស្រុក | ក្នុងពេលបច្ចុប្បន្ននេះ ការរីកចម្រើននៃបច្ចេកវិទ្យាបានផ្លាស់ប្តូរយ៉ាងរហ័សនូវទម្រង់ការផ្សព្វផ្សាយទេសចរណ៍នៅលើពិភពលោក។ ស្របតាមការវិវត្តនៃបដិវត្តន៍ឧស្សាហកម្ម៤.០ សកម្មភាពផ្សព្វផ្សាយទេសចរណ៍តាមបែបទំនើបមានលក្ខណៈកាន់តែទូលំទូលាយ និងរហ័សជាងមុនទាមទារឱ្យការផ្សព្វផ្សាយទេសចរណ៍ក្នុងស្រុកត្រូវចាប់យកការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថលអាចតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ជាអាទិ៍ Facebook របស់ក្រសួងទេសចរណ៍ និងត្រូវបង្កើនផ្សព្វផ្សាយទេសចរណ៍ក្នុងស្រុកក្នុងប្រព័ន្ធផ្សព្វ-ផ្សាយឌីជីថល តាមរយៈ Visit Cambodia។ លើសពីនេះទៀតដោយត្រូវបង្កើនសកម្មភាពបែបការអប់រំការយល់ដឹង និងទំនាក់ទំនងសាធារណៈ ឱ្យកាន់តែខ្លាំងថែមទៀត។ | - ក្រសួងទេសចរណ៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងព័ត៌មាន<br>- ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ |
| **១.២.១.៣-** | ការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្លូវ ជាអាទិភាព) និងបញ្ចូលទឹក ភ្លើង លូ និងការគ្រប់គ្រងបរិស្ថាន (ជាពិសេសម្រាម) ដើម្បីជំរុញទេសចរណ៍ក្នុងស្រុក និងត្រៀមការងើបឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាប្រកបដោយនិរន្តរភាព | • កំណត់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាក់ទងនឹងវិស័យទេសចរណ៍ភ្ជាប់ទៅនឹងរមណីយដ្ឋានទេសចរណ៍អាទិភាព និងថ្មីៗ<br>• ជំរុញការស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទឹក ភ្លើង បណ្តាញទូរគមនាគមន៍ចូលដល់គោលដៅទេសចរណ៍មូលដ្ឋាន(ដោយបច្ចុប្បន្នរាជរដ្ឋាភិបាល | ស្របពេលដែលសេដ្ឋកិច្ចជាតិកំពុងទទួលរងគ្រោះពីជំងឺកូវីដ-១៩ ការវិនិយោគអភិវឌ្ឍន៍ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្តនឹងគាំទ្រដល់ការកែលម្អភាពទាក់ទាញនៃគោលដៅទេសចរណ៍ ហើយក្នុងពេលតែមួយក៏អាចជួយដល់វិស័យផ្សេងទៀតដែលរងផលប៉ះពាល់ដូចជាវិស័យសំណង់ ដោយមានការផ្គត់ផ្គង់ | - ក្រសួងទេសចរណ៍<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

| | | | | |
|---|---|---|---|---|
| | | កំពុងអនុវត្តគម្រោងនេះស្រាប់រួចទៅហើយ ដោយក្នុងនេះការសាងសង់ផ្លូវក្រុងចំនួន ៣៤ខ្សែ នៅខេត្តព្រះសីហនុ និងគម្រោងសាងសង់ផ្លូវ ៣៨ខ្សែ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប ដែលប្រកាសជាផ្លូវការដោយ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០។ គម្រោងសាងសង់នេះនឹងចាប់ផ្តើមសាងសង់នៅឆ្នាំ២០២០នេះ និងអាចបញ្ចប់នៅចុងឆ្នាំ២០២១<br>• បង្កើនការវិនិយោគទេសចរណ៍លើសម្បទាទេសចរណ៍សំខាន់ៗមួយចំនួនដែលមានលក្ខណៈទាក់ទាញបម្រើឱ្យទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ (ឧទាហរណ៍ កំពុងផែទេសចរណ៍ចុងឃ្នាសការកែលម្អរមណីយដ្ឋានគូលែន កោះរ៉ុង)<br>• កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវតភ្ជាប់ទៅកាន់រមណីយ-ដ្ឋានទេសចរណ៍វប្បធម៌ ឬធម្មជាតិទាក់ទាញនានា និងត្រូវជួសជុលកែលម្អផ្លូវតភ្ជាប់គោលដៅទេសចរណ៍ (ករណីខូចខាតដោយសារទឹកជំនន់ឆ្នាំ២០២០) | សម្ភារៈដឹកជញ្ជូន និងការធ្វើការងារធម្មតា។ល។ នេះនឹងគាំទ្រដល់ការងើបឡើងវិញនៃវិស័យទាំងនោះ នឹងផ្តល់អត្ថ-ប្រយោជន៍នៃឥទ្ធិពលហិរញ្ញវត្ថុជាវិជ្ជមានទៅក្នុងសេដ្ឋកិច្ចជាតិ។ ឧទាហរណ៍ ក្នុងវិបត្តិសេដ្ឋកិច្ចសកលលោក នៅឆ្នាំ1930s មានការវិនិយោគទេសចរណ៍លើការបង្កើតឧទ្យានជាតិរបស់សហរដ្ឋអាម៉េរិក (ដោយប្រើកម្មវិធីផ្តល់ជាអាហារសម្រាប់កម្លាំងពលកម្មដល់យុវជនដែលគ្មានការងារធ្វើក្នុងគម្រោងនេះ)។<br>នៅក្នុងតំបន់ទេសចរណ៍សំខាន់ៗ ដូចជាខេត្តសៀមរាបដែលវាគឺជាពេលវេលាដ៏ល្អដើម្បីធ្វើការវិនិ-យោគលើការកែលម្អតំបន់ទីក្រុង និងជាពិសេសផ្លូវថ្នល់ដែលបច្ចុប្បន្នស្ថិតនៅក្នុងស្ថានភាពខូចខាតដែលនេះនឹងផ្តល់នូវឱកាសក្នុងការត្រៀមទទួលស្វាគមន៍ទេសចរនៅក្រោយវិបត្តិជំងឺកូវីដ-១៩។ | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- គណៈកម្មាធិការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរកម្ពុជា<br>- គណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងអនុវត្តគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន៣៨ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប<br>- រដ្ឋាករទឹកស្វយ័ត<br>- អគ្គិសនីកម្ពុជា<br>- វិស័យឯកជន |
| **១.២.២- ត្រៀមលក្ខណៈសម្បត្តិទទួលស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិ (កម្រិតតំបន់)** | | | | |
| **១.២.២.១-** | យុទ្ធនាការទំនាក់ទំនងសាធារណៈជាសារ “**កម្ពុជាកំពុងរង់ចាំអ្នក-Cambodia is waiting** | • បង្កើត**យុទ្ធនាការ “សារ”** សម្រាប់ប្រើនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីផ្សព្វផ្សាយសារ**កម្ពុជា** | ជំងឺកូវីដ-១៩ បានផ្លាស់ប្តូរគំរូនៃការធ្វើដំណើរជាសកល។ ទំនុកចិត្តក្នុងការធ្វើដំណើរនឹងមាន | - ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | for you” និងការផ្តល់នូវព័ត៌មានជាក់លាក់ និងគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងវិធានការរឹតត្បិតការធ្វើដំណើរ | **កំពុងរង់ចាំអ្នក**<br>• បង្កើតសារ និងព័ត៌មានច្បាស់លាស់ និងជឿជាក់អំពីវិធានសុវត្ថិភាព ការរឹតបន្តឹង និងអំពីស្ថានភាពបច្ចុប្បន្នលើការធ្វើដំណើរមកកាន់ប្រទេសកម្ពុជារបស់ភ្ញៀវទេសចរ ដែលមានភាពងាយស្រួលរក និងអាចជឿទុកចិត្ត (ប្រើប្រាស់គេហទំព័រ និងកម្មវិធីទូរសព្ទរបស់ Kingdom of Wonder) | កម្រិតទាបក្នុងរយៈពេលនៃវិបត្តិនេះ។<br>ខណៈពេលដែលការរឹតត្បិតការធ្វើដំណើរក្នុងបណ្តាប្រទេសមួយចំនួនត្រូវបានដាក់ចេញដែលបាននាំមកនូវឥទ្ធិពលជាអវិជ្ជមានដល់ការទាក់ទងប្រភពទីផ្សារទេសចរណ៍សំខាន់ៗ។ ការរៀបចំ**យុទ្ធនាការ “សារ”** និងយុទ្ធនាការ នេះមានសារៈសំខាន់ក្នុងការស្តារវិស័យទេសចរណ៍ក្នុងរយៈពេលខ្លី ព្រោះមានជនជាតិអាម៉េរិក អាល្លឺម៉ង់ បារាំង អេស្ប៉ាញ និងអ៊ីតាលី/អឺរ៉ុប ដែលរស់នៅក្នុងតំបន់ជាច្រើន ក៏ដូចជាហុងកុង សិង្ហបុរី និងបាងកកដែលអាចជួយដល់ការស្តារវិស័យទេសចរណ៍ឡើងវិញតាមរយៈការធ្វើដំណើរមកកម្សាន្តប្រទេសកម្ពុជានៅថ្ងៃឈប់សម្រាក។ ទន្ទឹមនឹងនេះ ការត្រៀមចាប់យកទីផ្សារទេសចរណ៍អាស៊ានបូកបី ក៏ចាំបាច់ត្រូវមានសារ “**កម្ពុជាកំពុងរង់ចាំអ្នក - Cambodia is waiting for you**” ផងដែរ។<br>ការរឹតបន្តឹង និងតម្រូវការក្នុងការធ្វើដំណើរប្រកបដោយសុវត្ថិភាពគួរតែអនុវត្តចំពោះអ្នកធ្វើដំណើរចូលទាំងអស់ដោយមិនគិតពីប្រភពដើម (គោរពតាមគោលការណ៍គ្មានការរើសអើង)។ ក្នុងការជំរុញការងើបឡើងវិញ ភាពច្បាស់លាស់ និងភាពងាយស្រួលក្នុងការទទួលបានព័ត៌មាននឹងមានសារៈសំខាន់ក្នុងការជះឥទ្ធិពលលើការសម្រេចចិត្តរបស់ភ្ញៀវទេសចរនាពេលអនាគត។ ធានាថាព័ត៌មាននៃការរឹតត្បិតការធ្វើដំណើរ ដោយអាចចូលមើលបានព័ត៌មានច្បាស់លាស់ | - ក្រុមប្រឹក្សាភិបាលសិក្សា និងផ្សព្វផ្សាយទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | | | និងអាចទុកចិត្តបាន។ ព័ត៌មាននេះគួរតែត្រូវបានចែករំលែកជាមួយវិស័យឯកជន និងអ្នកប្រើប្រាស់តាមរយៈបណ្តាញទំនាក់ទំនងផ្សេងៗទៀត។ | |
| ១.២.២.២- | ការផ្សព្វផ្សាយកម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយសុវត្ថិភាព ការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនង និងបង្កើតយន្តការច្បាស់លាស់ដើម្បីកសាងភាពជឿទុកចិត្ត និងភាពជឿជាក់ពីភ្ញៀវទេសចរ | • បង្កើតយុទ្ធសាស្ត្រទំនាក់ទំនងដើម្បីផ្សព្វផ្សាយប្រទេសកម្ពុជាជាមួយសារវិជ្ជមាន "**កម្ពុជាជាគោលដៅទេសចរណ៍សុវត្ថិភាពឈានមុខគេ**"។ ក្នុងនោះ កម្ពុជាដឹកនាំអាស៊ានក្នុងការងាររៀបចំស្តង់ដា "**សុវត្ថិភាពទេសចរណ៍អាស៊ាន**" ជាដើម។<br>• បង្កើតក្រុមទំនាក់ទំនងទេសចរណ៍មួយប្រកបដោយជំនាញក្នុងក្រសួងទេសចរណ៍។<br>• ផ្សព្វផ្សាយសារអំពីការឆ្លើយតបទៅនឹងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងស្ថានភាពទាក់ទងនឹងទេសចរណ៍ជាតិ និងអន្តរជាតិ (ឧទាហរណ៍ ការអនុវត្តវិធានសុវត្ថិភាព)។<br>• បង្កើតវីដេអូផ្សព្វផ្សាយទីផ្សារខ្លីសម្រាប់ប្រព័ន្ធផ្សព្វផ្សាយសង្គមអន្តរជាតិដែលបង្ហាញថាប្រទេសកម្ពុជាទទួលបានជោគជ័យយ៉ាងខ្លាំងក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលមានករណីទាប និងមិនមានអ្នកស្លាប់ ដែលនេះជាសារបញ្ជាក់ថាកម្ពុជា ជាគោលដៅទេសចរណ៍ដែលមានសុវត្ថិភាព។ | បច្ចុប្បន្ន ការផ្សព្វផ្សាយជាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងជំងឺកូវីដ-១៩ គឺត្រូវបានធ្វើឡើងជាលក្ខណៈផ្ទៃក្នុង (ភាគច្រើនមានតែជាភាសាខ្មែរប៉ុណ្ណោះ) ដែលនេះគឺជាភាពទន់ខ្សោយមួយក្នុងការផ្សព្វផ្សាយទៅកាន់អន្តរជាតិ។ ដូច្នេះជាការឆ្លើយតបទៅនឹងវិបត្តិនេះ ត្រូវគិតគូរបង្កើតយន្តការ Proactive សម្រាប់ការចែករំលែករឿងរ៉ាវវិជ្ជមានជាច្រើននៅក្នុងប្រទេសកម្ពុជា រឿងរ៉ាវដែលអាចឆ្លុះបញ្ចាំងពីភាពខ្លាំងនៃព្រះរាជាណាចក្រអច្ឆរិយៈ និងបង្កើនភាពទាក់ទាញទេសចរណ៍កម្ពុជា។<br>ក្នុងន័យនេះ កម្ពុជា ទទួលបានលទ្ធផលល្អប្រសើរដោយមានចំនួនអ្នកឆ្លងកូវីដ-១៩ ទាប ហើយមកដល់ពេលនេះ ប្រទេសកម្ពុជានៅមិនទាន់មានអ្នកស្លាប់ដោយសារជំងឺនេះ គឺជារឿងវិជ្ជមាន។ កត្តាវិជ្ជមានទាំងនេះត្រូវតែបង្កើនការផ្សព្វផ្សាយទៅកាន់អន្តរជាតិដើម្បីប្រែក្លាយរូបភាព "**កម្ពុជាគឺជាគោលដៅទេសចរណ៍សុវត្ថិភាព**"។ ពិតប្រាកដណាស់ ពិភពលោកកំពុងរស់នៅជាមួយនឹងការគំរាមកំហែងនៃជំងឺកូវីដ-១៩ និងហានិភ័យនៃការឆ្លងមេរោគដែលអាចកើតមានគ្រប់ពេល នោះគោលដៅទេសចរណ៍ដែលមានហានិ-ភ័យទាប និងក្លាយជាគោលដៅទេសចរណ៍កាន់តែទាក់ | - ក្រសួងទេសចរណ៍<br>- ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | | | ទាញ។ ដូច្នេះ ការផ្ដល់ "**ព័ត៌មានពិត និងជាក់ស្ដែង**" ពិតជាមានសារៈសំខាន់ណាស់ ដល់ភ្ញៀវទេសចរ ស្របតាមទស្សនៈ "**កសាងការទុកចិត្តងាយនឹងបាត់បង់ ប៉ុន្តែពិបាកក្នុងការកសាងជំនឿទុកចិត្តឡើងវិញ**"។<br>ទន្ទឹមនឹងនេះ ត្រូវបង្កើតក្រុមទំនាក់ទំនងសាធារណៈ ដែលមានជំនាញច្បាស់លាស់ ក្នុងការគ្រប់គ្រង និងផ្សព្វផ្សាយសារតាមបណ្ដាញសារព័ត៌មានទាំងថ្នាក់ជាតិ និងអន្តរជាតិ។ | |
| **១.២.២.៣-** | រៀបចំយុទ្ធនាការកម្ពុជាជា "**គោលដៅទេសចរណ៍ស្អាត បៃតង និងសុវត្ថិភាព**" និងបន្តជំរុញចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**" ពីព្រោះថា "**ភាពស្អាត**" នឹងក្លាយជាទម្លាប់ថ្មីសម្រាប់វិស័យទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩ | • ធ្វើការកំណត់អាទិភាពកម្មវិធីសម្អាតនៅតាមតំបន់រមណីយដ្ឋានទេសចរណ៍សំខាន់ៗ និងបង្កើតយុទ្ធនាការ "**រមណីយដ្ឋានស្អាត គ្មានសំណល់ថង់ប្លាស្ទិក**" និង "**រមណីយដ្ឋានស្អាតបន្ទប់ទឹកស្អាត**"<br>• អនុវត្តគោលការណ៍មិនប្រើប្រាស់ថង់ប្លាស្ទិកនៅរមណីយដ្ឋានទេសចរណ៍ធំៗ (តំបន់បេតិកភណ្ឌអង្គរ កោះរ៉ុង។ល។)<br>• ការពង្រឹងការគ្រប់គ្រងសម្រាមសំណល់រឹងនៅតំបន់ទីប្រជុំជនធានាបាននូវផ្លូវដើរស្អាត<br>• រៀបចំ**យុទ្ធនាការ** "**ស្រុកស្អាត**" ពិសេសស្រុកដែលស្ថិតនៅក្នុងផ្លូវទស្សនាទេសចរណ៍ធំៗរបស់ព្រះរាជាណាចក្រកម្ពុជា។<br>• ពិនិត្យឡើងវិញពីគំនិតផ្ដួចផ្ដើមទីក្រុងស្អាតនៅក្នុងបរិបទថ្មីមួយទៀត<br>• ដាក់ចេញ**យុទ្ធនាការ** "**កម្ពុជាស្អាត**" (ខេត្តមួយ | ត្រូវតែបន្តកែលម្អការគ្រប់គ្រងសម្រាមសំណល់រឹងនៅទូទាំងប្រទេស ដែលជាតម្រូវការចាំបាច់សម្រាប់ការយល់ឃើញ និងការពិតរបស់ប្រទេសកម្ពុជាជាទិសដៅមានសុវត្ថិភាព និងស្អាតរួមជាមួយការគាំទ្រសុខមាលភាពរបស់ប្រជាជន។<br>ការរិះគន់ពីមុនមកលើប្រទេសកម្ពុជាដែលបានបង្កើតការយល់ឃើញអវិជ្ជមានគឺកម្រិតនៃសំរាមនៅតាមទីតាំងសំខាន់ៗជាពិសេសការចោលប្លាស្ទិកនៅមុខប្រាសាទអង្គរវត្ត។ ការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរមកទស្សនា និងកម្សាន្តនាពេលបច្ចុប្បន្ន គឺជាឱកាសក្នុងការសម្អាតទីតាំងកន្លែងកម្សាន្តឱ្យបានស្អាត និងការកែលម្អទីតាំងឱ្យស្អាតជាងមុន។<br>រាជធានីភ្នំពេញ កំពុងធ្វើឱ្យប្រសើរឡើងនូវការប្រមូលសំរាមបន្ទាប់ពីមានការផ្លាស់ប្ដូរគោលនយោបាយកាលពីឆ្នាំមុន (ការគ្រប់គ្រងសម្រាមដោយរដ្ឋាករស្វយ័តសំរាមរាជធានីភ្នំពេញ) ការវិនិយោគ | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលរាជធានី-ខេត្ត |

| | | | | |
|---|---|---|---|---|
| | | ត្រូវមានកាតព្វកិច្ចអនុវត្តយុទ្ធនាការសម្អាតឱ្យបានយ៉ាងតិច១ដង ក្នុង១ខែ)<br>• បន្តអនុវត្តយុទ្ធនាការ "**ទេសចរម្នាក់ ដើមឈើមួយដើម**"<br>• ពង្រឹងយុទ្ធនាការអនាម័យស្អាតនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ និងស្តង់ដាបៃតង<br>• ពង្រឹងយុទ្ធនាការ "**សុវត្ថិភាពម្ហូបអាហារ**" នៅតាមសណ្ឋាគារ ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍<br>• ពង្រឹងការផ្តល់សេវាកម្មប្រកបដោយបដិសណ្ឋារកិច្ចល្អ និងផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ<br>• ភាពស្អាតក្លាយជាទម្លាប់ថ្មីក្រោយកូវីដ-១៩ ដូច្នេះស្នើបន្តបំផុសចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**"<br>• ជំរុញ និងលើកទឹកចិត្តក្នុងការអនុវត្តបរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍ "**ទេសចរណ៍គ្មានផ្សែងបារី ផ្តល់ផលចំណេញដល់យើងទាំងអស់គ្នា**"<br>– លើកកម្ពស់ការយល់ដឹងអំពី បរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍នៅតាមបណ្តាមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍រាជធានីខេត្ត<br>– លើកទឹកចិត្តឱ្យមានការអនុវត្ត បរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍ និងប្រគល់ពាន "**បរិស្ថានគ្មានផ្សែងបារីក្នុង** | បន្ថែមគួរតែត្រូវបានធ្វើឡើងរួមទាំងការបំពាក់ធុងសំរាមដើម្បីកាត់បន្ថយការបោះចោលសម្រាមនៅតាមចិញ្ចើមថ្នល់ ពង្រឹងយន្តការសម្អាត។ ល។<br>ការដាក់ឱ្យអនុវត្តយន្តការមិនប្រើប្រាស់ប្លាស្ទិកនៅក្នុងតំបន់អង្គរ និងតំបន់ទេសចរណ៍សំខាន់ៗដទៃទៀតគួរតែត្រូវបានបន្ត ប៉ុន្តែត្រូវយកចិត្តទុកដាក់ដើម្បីធានាថាដំណោះស្រាយស្របតាមតម្រូវការនៃការបង្កើនកម្រិតអនាម័យ និងភាពសមស្របដើម្បីទទួលបានទំនុកចិត្តពីភ្ញៀវទេសចរ។<br>គំនិតផ្តួចផ្តើមរបស់ទីក្រុងស្អាតនៃក្រសួងទេសចរណ៍ អាចត្រូវរួមគ្នាពង្រឹងអនុវត្ត ដើម្បីបង្កើនប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានផ្នែកបរិស្ថាន។<br>បន្តជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាតលើកទី៣ ចលនាប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍លើកទី២ ចលនាប្រឡងប្រណាំងបង្គន់ស្អាតលើកទី៣ និងប្រឡងប្រណាំងធុរ-កិច្ចបៃតងក្នុងវិស័យទេសចរណ៍លើកទី៤។<br>បរិស្ថានគ្មានផ្សែងបារីគឺជាបរិបទមួយដែលពិភពលោកនិងតំបន់យកចិត្តទុកដាក់ក្នុងការចូលរួមចំណែកការពារសុខភាពប្រជាពលរដ្ឋនិងភ្ញៀវទេសចរក្នុងការអនុវត្តច្បាប់ និងទប់ស្កាត់ការខាតបង់សេដ្ឋកិច្ច។ តាមការស្រាវជ្រាវរបស់អង្គការ UNDP និងលេខាធិការដ្ឋាន FCTC (Framework Convention | |

| | | | | |
|---|---|---|---|---|
| | | **វិស័យទេសចរណ៍**” ដល់ម្ចាស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ដែលមានស្នាដៃឆ្នើម<br>– ផ្តួចផ្តើម និងជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមបង្កើតទីក្រុងទេសចរណ៍គ្មានផ្សែងបារីតាមបណ្តារាជធានី-ខេត្ត<br>• គាំទ្រកម្មវិធីចាក់វ៉ាក់សាំងសម្រាប់បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ ពិសេសបុគ្គលិកបម្រើការងារជួរមុខ ដែលត្រូវជួបប្រាស្រ័យទាក់ទងផ្ទាល់ជាមួយភ្ញៀវ | on Tobacco Control) របស់អង្គការសុខភាពពិភពលោក (WHO) បានឱ្យដឹងថា ការប្រើប្រាស់ថ្នាំជក់នៅកម្ពុជាក្នុងឆ្នាំ២០១៩ កន្លងទៅនេះ បានធ្វើឱ្យខាតបង់ផលិតភាពសេដ្ឋកិច្ចប្រមាណ ៣% នៃផលិតផលក្នុងស្រុកសរុប។ ទេសចរណ៍គ្មានផ្សែងបារីជួយសហគមន៍ចំណេញផ្នែកសេដ្ឋកិច្ចដោយកាត់បន្ថយបន្ទុកចំណាយលើសុខភាពដែលរងផលប៉ះពាល់ពីផ្សែងបារី និងហានិភ័យនៃការឆ្លងជំងឺកូវីដ១៩ (ការជក់បារីបង្កើតឱកាសនៃការយកដៃមិនស្អាតប៉ះមាត់ និងច្រមុះ ព្រមទាំងធ្វើឱ្យខូចសួត និងផ្នែកផ្សេងទៀតនៃរាងកាយ)។ ការបង្កើតបរិស្ថានគ្មានផ្សែងបារីនៅក្នុងវិស័យទេសចរណ៍នឹងជួយបង្កើនភាពទាក់ទាញ និងផាសុកភាពដល់ប្រជាពលរដ្ឋនិងភ្ញៀវទេសចរ សំដៅបង្កើនចំណូល និងពង្រឹងភាពខ្លាំងនៃមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍។ | |
| **១.២.២.៤-** | សិក្សា និងរៀបចំគម្រោងទេសចរណ៍ប្រភេទ “**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព**” ជាមួយប្រទេសក្នុងតំបន់អាស៊ាន និងអាស៊ានបូកបី (ចិន ជប៉ុន កូរ៉េ ថៃ វៀតណាម សិង្ហបុរី) | • រៀបចំឯកសារគោលការណ៍ប្រតិបត្តិស្តង់ដាកញ្ចប់គម្រោងទេសចរណ៍ប្រភេទ “**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព**”<br>• បង្កើតក្រុមការងារអន្តរក្រសួង ដើម្បីអនុវត្តគម្រោងនេះ<br>• រៀបចំកិច្ចព្រមព្រៀងរវាងភាគីកម្ពុជា និងបណ្តាប្រទេសផ្សេងៗក្នុងតំបន់<br>• រៀបចំជា Fast Track Lane នៅតាមព្រលានយន្តហោះ និងច្រកទ្វារអន្តរជាតិ | គម្រោងទេសចរណ៍ប្រភេទ “**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព**” (One way and Closed-Loop Chartered Planes/Travel Bubble /Safe Travel Pass) គឺជាទម្រង់នៃការធ្វើដំណើរដែលក្រុមទេសចរត្រូវបានជ្រើសរើសពីប្រទេសណាមួយដែលគ្មានករណីឆ្លងកូវីដ-១៩ ឬប្រទេសដែលអាចគ្រប់គ្រងស្ថានភាពវីរុសនេះបាន អាចធ្វើដំណើរដោយសេរីទៅប្រទេសមួយទៀតដែលមានស្ថានភាពដូចគ្នា។ បណ្តាប្រទេសដែលយល់ព្រមអនុវត្តគម្រោងទាំងនេះ | - ក្រសួងទេសចរណ៍<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងសុខាភិបាល<br>- អគ្គនាយកដ្ឋានអន្តោប្រវេសន៍<br>- វិស័យឯកជន |

| | | | | |
|---|---|---|---|---|
| | | • រៀបចំបង្កើត និងកំណត់ឱ្យមានតំបន់ សម្រាប់កញ្ចប់ទស្សនាចរប្រភេទ "**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព**"<br>• បង្កើតប្រព័ន្ធគ្រប់គ្រងកញ្ចប់ទស្សនាចរ "**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព**"<br>• បង្កើតគេហទំព័រ និងកម្មវិធីទូរសព្ទសម្រាប់គម្រោង "**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព**" ដើម្បីជួយសម្រួលអ្នកធ្វើដំណើរបរទេស (ភ្ញៀវក្នុងតំបន់ និង អាស៊ានបូកបី) ក្នុងការចុះឈ្មោះ និងទទួលបានព័ត៌មានលក្ខខណ្ឌស្ដីអំពីតម្រូវការមុនពេលមកដល់ប្រទេសកម្ពុជា<br>• តម្រូវរាល់ការធ្វើដំណើររបស់ភ្ញៀវទេសចរត្រូវមានការបញ្ជាក់ថាគ្មានកូវីដ-១៩ និងបានចាក់វ៉ាក់សាំង (Vaccination Passport) | (អាចជាទម្រង់ទ្វេភាគី ឬត្រីភាគី) ត្រូវបើកចំហរព្រំដែនរបស់ខ្លួនទៅកាន់ប្រទេសមួយទៀតដោយរក្សាការបិទព្រំដែន ឬការកំណត់លក្ខខណ្ឌតម្រូវ ចំពោះប្រទេសផ្សេងទៀតដែលស្ថិតនៅក្រៅគម្រោង។ កិច្ចព្រមព្រៀងនៃគម្រោងនេះ ត្រូវបានរៀបចំឡើងរវាងប្រទេសជាប់ព្រំដែន ឬប្រទេសដែលនៅជិតៗក្នុងតំបន់ ដោយបញ្ជាក់ពីភាពរឹងមាំរបស់រដ្ឋាភិបាលប្រទេសនីមួយៗក្នុងការគ្រប់គ្រង និងប្រឆាំងការរីករាលដាលនៃជំងឺកូវីដ-១៩ តាមព្រំដែននៃប្រទេសនីមួយៗ | |
| **១.២.២.៥-** | សិក្សា និងរៀបចំយន្តការធ្វើដំណើរដោយខ្លួនឯង (Self-driving Tour) ជាមួយប្រទេសជិតខាង | • រៀបចំឯកសារគោលការណ៍ប្រតិបត្តិស្តង់ដាទេសចរណ៍ប្រភេទការធ្វើដំណើរដោយខ្លួនឯង<br>• សិក្សារៀបចំ**មណ្ឌលជំនួយទេសចរណ៍** នៅច្រកទ្វារអន្តរជាតិផ្លូវគោក | បច្ចុប្បន្ន ភ្ញៀវទេសចរនិយមការធ្វើដំណើរតាមដងផ្លូវផ្សារភ្ជាប់ជាមួយនឹងការកម្សាន្តទេសចរណ៍នៅតាមដងផ្លូវ ដោយភ្ញៀវទេសចរអាចថតរូបលេងកម្សាន្ត និងអាចឈានចូលលេងតំបន់រមណីយដ្ឋាននៅតាមតំបន់គោលដៅបានយ៉ាងសប្បាយរីករាយ ដូចនេះផែនទីចង្អុលផ្លូវស្នើឱ្យជំរុញការសម្រួលឱ្យមានការធ្វើដំណើរសម្រាប់ភ្ញៀវទេសចរមកពីប្រទេសជិតខាង ពិសេសតាមផ្លូវគោកដល់ភ្ញៀវទេសចរមកពីប្រទេសអាស៊ានដោយសម្រួលឱ្យប្រើប្រាស់រថយន្ត ចេញ-ចូល ព្រះរាជាណាចក្រកម្ពុជាឱ្យ | - គណៈកម្មការសម្រួលការធ្វើដំណើរដឹកជញ្ជូនទេសចរណ៍<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |

| | | | | |
|---|---|---|---|---|
| | | | បានកាន់តែងាយស្រួលអមជាមួយការសម្រួលដល់ទិដ្ឋាការនៃការធ្វើដំណើរដោយអាចប្រើប្រាស់បណ្ណឆ្លងកាត់ព្រំដែន និងអាចបើកបររថយន្តដោយខ្លួនឯងបាន។ | |
| ១.២.២.៦- | ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឆ្ពោះទៅការស្តារវិស័យទេសចរណ៍ឡើងវិញ ជំរុញទាក់ទាញប្រភេទទេសចរពិសេស (ទេសចរគុណភាព) ស្ថិតក្រោមការគ្រប់គ្រង ដោយបង្កើតឱ្យមានទិដ្ឋាការពិសេស ឬគោលនយោបាយនានាសម្រាប់ទេសចរបរទេសដែលធ្វើដំណើរមកទស្សនាកម្ពុជារយៈពេលយូរ | • ដើម្បីឆ្លើយតបនឹងការដោះស្រាយផលប៉ះពាល់វិបត្តិជំងឺកូវីដ-១៩ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ានមានមុំយុទ្ធសាស្ត្រចំនួន ០៤÷ (១). សម្រេចការងារជាការទទួលខុសត្រូវរបស់កម្ពុជាចំពោះអាស៊ាន (២). សម្រេចការងារអនុតំបន់ (AMECS, CLV, CLMV,..) ជាការទទួលខុសត្រូវរបស់កម្ពុជា (៣).ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និង (៤). ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការទេសចរណ៍ពិភពលោក ដើម្បីស្តារទេសចរណ៍ឡើងវិញ។<br>• បង្កើតយន្តការសម្របសម្រួលមួយដល់អ្នកធ្វើដំណើរបរទេសមកកម្ពុជារយៈពេលយូរ<br>• ផ្សព្វផ្សាយទិដ្ឋាការពិសេសនេះឱ្យបានទូលំទូលាយទៅកាន់អន្តរជាតិ<br>• ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការតាមដានទីតាំងរបស់ភ្ញៀវទេសចរ (ឧទាហរណ៍ កម្មវិធីតាមដានការធ្វើដំណើររបស់ភ្ញៀវទេសចរ Track App) | នៅឆ្នាំ២០២១ ត្រៀមរៀបចំជាម្ចាស់ផ្ទះវេទិកាទេសចរណ៍អាស៊ាន ឆ្នាំ២០២២ ហើយកម្ពុជាក៏ជាប្រធានកិច្ចប្រជុំនានាកំលុងឆ្នាំ២០២១ (ថ្នាក់ស្ថាប័នទេសចរណ៍ជាតិ - NTOs) ឆ្លើយតបនឹងការគាំទ្ររបស់ UNWTO ដែលផ្ញើសារជូន**សម្តេចតេជោ** ករណី MS Westerdam និងភាពជោគជ័យនៃការបើកឡើងវិញនៃទេសចរណ៍ក្នុងស្រុក ក្រសួងទេសចរណ៍នឹងសហការជាមួយប្រទេសសមាជិក UNWTO ផ្សេងទៀតអនុវត្តនូវគោលការណ៍នានាដែលដាក់ចុះដោយ UNWTO ដើម្បីស្តារវិស័យទេសចរណ៍ឡើងវិញ និងធ្វើឱ្យវិស័យទេសចរណ៍កាន់តែរឹងមាំនាថ្ងៃអនាគត ក្នុងនោះUNWTO ជួយកម្ពុជាក្នុងការដោះស្រាយផលប៉ះពាល់កូវីដ-១៩ ជំរុញការអភិវឌ្ឍធនធានមនុស្ស ជំរុញសហគ្រិនវ័យក្មេង និងនវានុវត្តន៍ ជំរុញទេសចរណ៍ម្ហូបអាហារជាដើម។ ក្នុងក្របខ័ណ្ឌអនុតំបន់ កម្ពុជានឹងជាប្រធានកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ ACMECS និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ដើម្បីរៀបចំផែនការស្តារ វិស័យទេសចរណ៍តំបន់ ACMECS ស្របតាមការចង្អុលបង្ហាញនៃកិច្ចប្រជុំកំពូល ACMECS កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០។ កិច្ចសហប្រតិបត្តិការអនុតំបន់ផ្សេងៗទៀត (CLMV, CLV, MLV) និងកិច្ចសហប្រតិបត្តិការទ្វេភាគីដទៃទៀត | - ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរ-ជាតិ<br>- ក្រសួងសុខាភិបាល |

| | | | | |
|---|---|---|---|---|
| | | | ត្រូវបានផ្តោតលើការស្តារវិស័យទេសចរណ៍ឡើងវិញ និងភាពរឹងមាំនៃវិស័យទេសចរណ៍នាថ្ងៃអនាគត។<br>ការផ្តល់ទិដ្ឋាការពិសេស នឹងផ្តល់ភាពងាយស្រួលដល់អ្នកដំណើរបរទេសទាំងអស់ដែលបានគ្រោងធ្វើដំណើរមកកាន់ប្រទេសកម្ពុជារយៈពេលយូរ។ ជាក់ស្តែង ប្រទេសថៃបានដាក់ចេញនូវគោលនយោបាយទិដ្ឋាការពិសេសសម្រាប់សម្រួលដល់ភ្ញៀវទេសចរដែលមានបំណងស្នាក់នៅយូរសម្រាប់រយៈពេលនៃវិបត្តិជំងឺកូវីដ-១៩ នេះរហូតដល់ថ្ងៃ៣០ ខែកញ្ញា ឆ្នាំ២០២១។ ការដាក់ចេញប្រភេទទិដ្ឋាការនេះក្នុងគោលបំណងទាក់ទាញភ្ញៀវទេសចរគុណភាព (ចំណាយខ្ពស់) និងស្នាក់នៅយូរ និងការដាក់ចេញប្រភេទទិដ្ឋាការនេះសង្ឃឹមថានឹងអាចចាក់បញ្ចូលក្នុងចរន្តសេដ្ឋកិច្ចថៃប្រមាណ ៣៨០ លានដុល្លារ ក្នុងមួយឆ្នាំ។ | |
| **១.២.២.៧-** | កំណត់ និងសិក្សាអភិវឌ្ឍន៍ផលិតផលទេស-ចរណ៍ថ្មីៗ ដែលកម្ពុជាមានសក្តានុពលក្រោយវិបត្តិជំងឺកូវីដ-១៩ | • សិក្សាលទ្ធភាពគម្រោងរៀបចំវិថីម្ហូបអាហារនៅខេត្តកំពត ខេត្តកែប ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ<br>• សិក្សាប្លង់ស្លាបត្យកម្មសួនទេសចរណ៍ Westerdam នៅខេត្តព្រះសីហនុ<br>• កំណត់ប្រភេទផលិតផលទេសចរណ៍ថ្មីៗដែលកម្ពុជាមានសក្តានុពលសម្រាប់ត្រៀមទទួលភ្ញៀវទេសចរក្រោយវិបត្តិជំងឺកូវីដ-១៩<br>• សិក្សាលទ្ធភាពហិរញ្ញប្បទានគាំទ្រអាចក្រោមទម្រង់ PPP ឬ មូលនិធិលើកស្ទួយវិស័យទេសចរណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ | កិច្ចការសំខាន់សម្រាប់កម្ពុជាក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ នោះ គឺការកំណត់អត្តសញ្ញាណវិស័យទេសចរណ៍កម្ពុជា “**កម្ពុជា : ក្រៅពីប្រាសាទ**”។<br>កិត្តិនាមម៉ាកយីហោថ្មីរបស់កម្ពុជាដែលមានភាពខ្លាំងក្លា និងមានភាពចម្រុះនោះ គឺត្រូវផ្តោតលើការអភិវឌ្ឍលើសសរស្តម្ភចំនួន ០៤ គឺ ភាពជាខ្មែរ បេតិកភណ្ឌវប្បធម៌ ទេសចរណ៍ឆ្នេរ និងអេកូទេសចរណ៍។ ប្រទេសកម្ពុជាមានសក្តានុពលធំធេងលើសសរទាំងបួននេះ យុទ្ធនាការផ្សព្វផ្សាយនេះនឹងផ្តោតលើប្រភព | - ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | | • ត្រូវដាក់ស្នើបញ្ចូលក្រុងបាត់ដំបងជាទីក្រុងបេតិក-ភណ្ឌពិភពលោករបស់អង្គការ UNESCO | ទីផ្សារទេសចរណ៍ខុសៗគ្នាសម្រាប់ទីផ្សារទេសចរណ៍លោកខាងលិច និងទីផ្សារទេសចរណ៍អាស៊ី។<br>ភាគច្រើននៃផលិតផលដែលមានសក្តានុ-ពលកម្ពុជាមានរួចស្រាប់ទៅហើយ និងបានកំពុងយកទៅប្រើប្រាស់ និងផ្សព្វផ្សាយដោយវិស័យឯកជន។ ជាការសំខាន់ គួរមានការពិនិត្យឡើងវិញនូវផលិតផលទេសចរណ៍ស្របតាមសសរស្តម្ភទាំងបួន និងបញ្ចូលខ្លឹមសារនេះទៅក្នុងយុទ្ធសាស្ត្រផ្សព្វផ្សាយទេសចរណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩។<br>រីឯការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗមានសារៈសំខាន់ក្នុងការស្តារវិស័យទេសចរណ៍ឡើងវិញ ដូច្នេះ គួរពិចារណាលើយន្តការគាំទ្រដោយមូលនិធិលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ ពិសេសវិស័យអេកូទេសចរណ៍ ដែលមានសារៈ-សំខាន់ណាស់ក្នុងការបង្កើនឱកាសដល់ផលិតផលកម្រិតខ្ពស់/គុណភាពខ្ពស់។ យើងបានរំពឹងទុកថាក្នុងរយៈពេលមធ្យម និងវែង និងមានតម្រូវការកាន់តែច្រើនសម្រាប់ផលិតផលទេសចរណ៍ប្រភេទនេះក្នុងចំណោមប្រភពទីផ្សារទេសចរណ៍ថ្មីៗ ជាជាងប្រភេទទីផ្សារទេសចរណ៍ បែបសាកាដូដែលមានការចំណាយទាប។<br>ខណៈដែលភ្ញៀវទេសចរកម្រិតខ្ពស់គឺនៅមានចំនួនទាប រីឯការចំណាយរបស់ពួកគេគឺកាន់តែច្រើន ហើយមានឥទ្ធិពលខ្ពស់ដល់សេដ្ឋកិច្ចក្នុងតំបន់ | |

| | | | | |
|---|---|---|---|---|
| | | | និងគ្រប់ខ្សែចង្វាក់ផលិតកម្មទេសចរណ៍។ ការផ្តោតដ៏សំខាន់សម្រាប់វិស័យទេសចរណ៍កម្ពុជានោះ គឺការអភិវឌ្ឍផលិតផល និងសេវាកម្មទេសចរណ៍ដែលមានគុណភាព/មានតម្លៃខ្ពស់ ដូច្នេះគួរពិចារណាលើការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍផលិតផលទេសចរណ៍ដែលបានអនុវត្តស្របតាមស្តង់ដាគុណភាព ឬស្តង់ដាបៃតងនានា។ | |
| **១.៣- រៀបចំយន្តការអភិបាលកិច្ចទេសចរណ៍ឡើងវិញ** | | | | |
| **១.៣.១- សិក្សា និងរៀបចំយន្តការអភិបាលកិច្ចទេសចរណ៍ (ថ្នាក់ជាតិ)** | | | | |
| **១.៣.១.១-** | ពង្រឹងរចនាសម្ព័ន្ធឆ្លើយតបដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩ | • ពង្រឹងភាពជាដៃគូរវាងរដ្ឋ-វិស័យឯកជន (PPP) ក្នុងការអភិវឌ្ឍ និងផ្សព្វផ្សាយទេសចរណ៍ និងពង្រឹងសមត្ថភាពនៃក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា<br>• ពង្រឹងសមត្ថភាពនៃគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>• ធ្វើបច្ចុប្បន្នភាព **ច្បាប់ ស្តីពី "ទេសចរណ៍"**<br>• ធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ (២០១២-២០២០) ទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ (២០២១-២០៣៥)<br>• រៀបចំផែនការយុទ្ធសាស្ត្រផ្សព្វផ្សាយទេសចរណ៍កម្ពុជា (២០២១-២០២៥) ក្រោយវិបត្តិជំងឺកូវីដ-១៩<br>• សិក្សា និងរៀបចំគោលនយោបាយពិសេសសម្រាប់ | ក្រសួងទេសចរណ៍ គួរពិនិត្យឡើងវិញស្តីពីការធ្វើបច្ចុប្បន្នភាពច្បាប់ និងផែនការអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា រួមមានដូចខាងក្រោម៖<br>**ទី១.** ស្នើឱ្យធ្វើបច្ចុប្បន្នភាពច្បាប់ ស្តីពី "ទេសចរណ៍" ដែលចេញដោយព្រះរាជក្រម លេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០០៩ ត្រូវមានចំណុចបន្ថែមមួយចំនួន ដូចជា អេកូទេសចរណ៍ សហគមន៍ទេសចរណ៍ ទេសចរណ៍សមុទ្រ ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ ការផ្សព្វផ្សាយទេសចរណ៍ក្រោមទម្រង់ភាពជាដៃគូ។ល។<br>**ទី២.** ធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ (២០១២-២០២០) ទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ (២០២១-២០៣៥)។ ទន្ទឹមនឹងនេះត្រូវដាក់ចេញ ផែនការមេអភិវឌ្ឍន៍តំបន់ទេសចរណ៍នៅតំបន់ ឬប៉ូលទេសចរណ៍ | - ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | | ការលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ ។<br>• ធ្វើវិសោធកម្មច្បាប់ស្ដីពីសារពើពន្ធលើការលក់ទំនិញ Duty-Free ជូនភ្ញៀវទេសចរអន្តរជាតិ<br>• រៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍រាជធានីភ្នំពេញ (២០២១-២០៣៥)<br>• រៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា<br>• សិក្សាលទ្ធភាពនៃគម្រោងបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅខេត្តសៀមរាប និងខេត្តមណ្ឌលគិរី | សំខាន់ៗ។<br>**ទី៣.** ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពហិរញ្ញវត្ថុនៃក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជាក្រោមទម្រង់ភាពជាដៃគូ។<br>**ទី៤.** រៀបចំផែនការយុទ្ធសាស្ត្រផ្សព្វផ្សាយ និងសិក្សាទីផ្សារទេសចរណ៍កម្ពុជា ( ២០២១-២០២៥) ក្រោយកូវីដ-១៩: វាពិតជាមានសារៈសំខាន់ខ្លាំងក្នុងការរៀបចំយុទ្ធសាស្ត្រទីផ្សារទេសចរណ៍កម្ពុជា (២០២១-២០២៥) ដែលទាមទារឱ្យមានការរៀបចំនូវយុទ្ធសាស្ត្រទីផ្សារទេសចរណ៍មួយដ៏មានប្រសិទ្ធភាពសមស្របទៅនឹងសកលភាវូបនីយកម្ម និងនិន្នាការថ្មីៗរបស់ពិភពលោក ដើម្បីធ្វើឱ្យកម្ពុជាជាគោលដៅទេសចរណ៍វប្បធម៌ និងធម្មជាតិលំដាប់ពិភពលោកដែលមានឧត្តមភាពប្រកួតប្រជែង ទាក់ទាញក្នុងតំបន់ និងសកលលោក។<br>**ទី៥.** រៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍តាមតំបន់គោលដៅអាទិភាព: រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅទេសចរណ៍សំខាន់ៗរបស់កម្ពុជាត្រូវតែអភិវឌ្ឍន៍ឱ្យស្របតាមទិសដៅយុទ្ធសាស្ត្រអត្តសញ្ញាណ និងសក្ដានុពលនៃតំបន់របស់ខ្លួនមានដូចខាងក្រោម÷<br>(១) តំបន់សៀមរាប និងតំបន់ជុំវិញ: គឺជា “គោលដៅទេសចរណ៍បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ និងជាបណ្ដុំ សម្រាប់តំបន់ភាគពាយ័ព្យ”<br>(២) តំបន់ភ្នំពេញ និងជុំវិញ: គឺជា “គោល | |

| | | | | |
|---|---|---|---|---|
| | | | ដៅទេសចរណ៍ចម្រុះលំដាប់ខ្ពស់ និងប្រណិត”<br>(៣) តំបន់ឆ្នេរសមុទ្រកម្ពុជា គឺ “ជាគោលដៅទេសចរណ៍តំបន់ឆ្នេរ និងអេកូទេសចរណ៍”<br>(៤) តំបន់ឦសាន គឺជា “ គោលដៅអេកូទេសចរណ៍ និងទេសចរណ៍បែបផ្សងព្រេង ”<br>ដូច្នេះរាជរដ្ឋាភិបាលបានប្រគល់ឱ្យក្រសួងទេសចរណ៍ដឹកនាំគណៈកម្មការអន្តរក្រសួង រៀបចំកសាងផែនការមេចំនួន (០៣) គឺ ផែនការមេសម្រាប់អភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២១-២០៣៥) ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប (២០២១-២០៣៥),ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី(២០២១-២០៣៥)។<br>**ទី៦.** ត្រូវ**រៀបចំគោលនយោបាយទេសចរណ៍ពិសេស**អមជាមួយសិក្សា និងរៀបចំបង្កើត **តំបន់ទេសចរណ៍ពិសេស** ដើម្បីរៀបចំខ្លួនចូលរួមស្តារវិស័យទេសចរណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ តំបន់ទេសចរណ៍ពិសេសគួរសិក្សា និងរៀបចំឡើងតាមរយៈការផ្តល់នូវការលើកទឹកចិត្តដល់ការទាក់ទាញវិនិយោគទេសចរណ៍ ការទាក់ទាញទេសចរណ៍ផ្ទះទី២ ដែលជាទេសចរណ៍ស្នាក់នៅយូរ និងប្រភេទជាគោលនយោបាយទាក់ទាញភ្ញៀវទេសចរ (ឧទាហរណ៍ ការបង្កើតឱ្យមានទិដ្ឋាការពិសេសសម្រាប់ការស្នាក់នៅយូររបស់ភ្ញៀវទេសចរមកកម្សាន្តក្នុងតំបន់នេះ។ តំបន់ទេសចរណ៍ពិសេសនេះនឹងលើកកម្ពស់ឧត្តមភាពប្រកួតប្រជែងទេសចរណ៍កម្ពុជាចាប់យកឱកាស និងចំណែកទីផ្សារទេសចរណ៍គុណភាព | |

| | | | | |
|---|---|---|---|---|
| | | | ក្រោយជំងឺកូវីដ-១៩។ ក្នុងដំណាក់កាលនេះ ក្រសួងទេសចរណ៍ត្រូវរៀបចំគោលនយោបាយសម្រាប់ទាក់ទាញប្រភេទភ្ញៀវទេសចរមកកាន់តំបន់ទេសចរណ៍ពិសេសនេះអមជាមួយការបង្កើតច្បាប់ ឬព្រះរាជក្រឹត្យ។<br>**ទី៧.** ធ្វើវិសោធកម្មច្បាប់ស្តីពីសារពើពន្ធដើម្បីសម្រួលដល់ការទិញទំនិញ (Duty-Free) របស់ភ្ញៀវទេសចរនៅកម្ពុជា ស្របតាមស្មារតីនៃកិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រីនៅថ្ងៃទី២៣ តុលា ឆ្នាំ ២០២០។ | |
| **១.៣.២- អភិបាលកិច្ចទេសចរណ៍ក្នុងកម្រិតថ្នាក់រាជធានី-ខេត្ត** | | | | |
| **១.៣.២.១-** | ការរៀបចំបង្កើតអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ តាមរាជធានី-ខេត្ត និងគោលដៅទេសចរណ៍សំខាន់ៗ | • ពង្រឹងរចនាសម្ព័ន្ធគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្តឱ្យក្លាយជាអង្គភាពគ្រប់គ្រងទេសចរណ៍នៅតាមរាជធានី-ខេត្ត (លើកលែងតែរាជធានី-ខេត្តដែលជាគោលដៅទេសចរណ៍ដែលមានលក្ខណៈពិសេស)<br>• រៀបចំយន្តការអង្គភាពគ្រប់គ្រងគោលដៅទេស-ចរណ៍សៀមរាប កែប និងមណ្ឌលគិរី ស្របតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍រៀងៗខ្លួន | ដើម្បី "**បង្កើនភាពប្រកួតប្រជែង និងធានានិរន្តរភាព**" ទាញចេញពីការអភិវឌ្ឍទេសចរណ៍នៅតំបន់ទេសចរណ៍អាទិភាពនីមួយៗ។ ការបង្កើតអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ គឺត្រូវផ្អែកលើអភិក្រមសិក្សាត្រឹមត្រូវ និងច្បាស់លាស់។<br>អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍បង្កើតឡើងដើម្បីប្រែក្លាយឱ្យគោលដៅទេសចរណ៍មួយដែលអាចផ្តល់សេវាកម្ម ការកម្សាន្តប្រកបដោយការពេញចិត្តដែលមានការចងចាំដល់ភ្ញៀវទេសចរ និងធានាបាននូវនិរន្តរភាព គឺតម្រូវឱ្យមានការគិតគូរដល់ការអភិវឌ្ឍមួយដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ (រដ្ឋ-វិស័យឯកជន និងសហគមន៍មូលដ្ឋាន ឬដៃគូអភិវឌ្ឍ)។ | - ក្រសួងទេសចរណ៍ |
| **១.៣.៣- ពង្រឹងអភិបាលកិច្ចទេសចរណ៍ក្នុងកម្រិតប្រតិបត្តិករទេសចរណ៍** | | | | |

| | | | | |
|---|---|---|---|---|
| ១.៣.៣.១- | ការរៀបចំផែនការពង្រឹងគុណភាពផលិតផលទេសចរណ៍ល្អៗផ្សារភ្ជាប់នឹងសុវត្ថិភាព និងបង្កើនបទពិសោធន៍ល្អៗនៅតាមរមណីយដ្ឋានទេសចរណ៍នានា។ | • ការពិនិត្យឡើងវិញនៃការគ្រប់គ្រងភ្ញៀវទេសចរនៅរមណីយដ្ឋានសំខាន់ៗដើម្បីអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ផ្សារភ្ជាប់នឹងការបង្កើនបទពិសោធន៍ល្អៗ<br>• អភិវឌ្ឍន៍ការបណ្តុះបណ្តាល និងសមត្ថភាពក្នុងការបង្កើនគុណភាពនៃបទពិសោធន៍ល្អៗដល់ភ្ញៀវទេសចរនៅតាមរមណីយដ្ឋាននានា<br>• ប្រើពេលវេលាដែលគ្មានភ្ញៀវនេះជាឱកាសដើម្បីធ្វើការកែលម្អសម្បទាទេសចរណ៍នៅរមណីយដ្ឋានទេសចរណ៍សំខាន់នីមួយៗឱ្យប្រសើរឡើង<br>• ត្រូវរៀបចំឱ្យមានបន្ទប់ទឹកស្អាតនៅតាមរមណីយដ្ឋានទេសចរណ៍<br>• ត្រូវធានាឱ្យមានកន្លែងលាងដៃ និងអនាម័យជាអចិន្ត្រៃយ៍ នៅតាមគោលដៅបេតិកភណ្ឌ និងតំបន់ទេសចរណ៍ដទៃទៀត | ការបង្កើតឱ្យមានការអនុវត្តគម្លាតសង្គមទាមទារឱ្យមានការពិនិត្យឡើងវិញនូវវិធានការក្នុងការគ្រប់គ្រងភ្ញៀវទេសចរនៅក្នុងគោលដៅទេសចរណ៍/រមណីយដ្ឋាន ពិសេសតំបន់បេតិកភណ្ឌទេសចរណ៍ដែលមានភ្ញៀវទស្សនាច្រើន។ នេះអាចរាប់បញ្ចូលទាំងការកំណត់ចំនួនអ្នកទស្សនា ការកំណត់ពេលវេលាសម្រាប់ការចូលជាក្រុមធំៗ ការកែប្រែតម្លៃការលក់សំបុត្រដើម្បីពង្រឹងការគ្រប់គ្រងការផ្ទុកចំនួនភ្ញៀវទេសចរ។<br>ត្រូវបង្កើនការបណ្តុះបណ្តាលថ្មីៗ ដើម្បីលើកកម្ពស់ស្តង់ដាគុណភាពសេវាកម្មជាពិសេសការធ្វើវិក្រឹត្យការមគ្គុទ្ទេសក៍ទេសចរណ៍។<br>ក្នុងកំលុងពេលនេះ គឺពិតជាមានសារៈសំខាន់ សម្រាប់ឧស្សាហកម្មទេសចរណ៍ក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្ថែមទៀតដល់បុគ្គលិក (ដូចជាការបង្កើនសមត្ថភាពភាសាបន្ថែមសម្រាប់ទីផ្សារគោលដៅទេសចរណ៍សំខាន់ៗ។ល។ | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលរាជធានី-ខេត្ត |

# ដំណាក់កាលទី២ ៖ ការស្តារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២២-២០២៣)

- **យុទ្ធសាស្ត្រទី១: ការស្តារឡើងវិញផ្នែកសេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍**
- **យុទ្ធសាស្ត្រទី២: ការស្តារឡើងវិញទីផ្សារទេសចរណ៍អន្តរជាតិ (តំបន់) និងបន្តជំរុញទេសចរណ៍ក្នុងស្រុក**
- **យុទ្ធសាស្ត្រទី៣: ដាក់ឱ្យអនុវត្តយន្តការអភិបាលកិច្ចទេសចរណ៍ថ្មី**
- **ផែនការសកម្មភាពក្នុងដំណាក់កាលទី២: ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២២ - ២០២៣)**

## ២- ដំណាក់កាលទី២ : ការស្តារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២២-២០២៣)

(**៦៤**). យោងតាមការព្យាករសេណារីយ៉ូទី២ នៅឆ្នាំ២០២៥ ចំនួនភ្ញៀវទេសចរនឹងកើនឡើងទៅរកភាពដើមវិញ។ ក្នុងន័យនេះ ផែនទីចង្អុលផ្លូវបានដាក់ចេញនូវយុទ្ធសាស្រ្តដូចខាងក្រោម÷

### ក- យុទ្ធសាស្រ្តទី១: ការស្តារឡើងវិញផ្នែកសេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍÷

(**៦៥**). ក្នុងដំណាក់កាលទី២នេះ **សកម្មភាពយុទ្ធសាស្រ្តរបស់យុទ្ធសាស្រ្តទី១** មានចំនួន **០៤ ចំណុច** ត្រូវបានលើកឡើង រួមមាន÷

១- បន្តអនុវត្តកម្មវិធីគាំពារអាជីវកម្មទេសចរណ៍ខ្នាតតូច និងខ្នាតមធ្យម

២- លើកកម្ពស់ផលិតភាពក្នុងឧស្សាហកម្មទេសចរណ៍ (តាមរយៈពង្រឹងជំនាញថ្មីៗ និងបច្ចេកវិទ្យា)

៣- ពង្រឹងការអភិវឌ្ឍជំនាញទេសចរណ៍ក្នុងបរិការណ៍ថ្មី (ក្រោយវិបត្តិកូវីដ-១៩)

៤- រៀបចំប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍទេសចរណ៍ឆ្លាតវៃ។

### ខ- យុទ្ធសាស្រ្តទី២: ការស្តារឡើងវិញទីផ្សារទេសចរណ៍អន្តរជាតិ (តំបន់) និងបន្តជំរុញទេសចរណ៍ក្នុងស្រុក÷

(**៦៦**). ក្នុងយុទ្ធសាស្រ្តទី២នេះ **សកម្មភាពយុទ្ធសាស្រ្តចំនួន០៩** ត្រូវបានលើកឡើង រួមមាន÷

១- ទំនើបកម្មកិត្តិនាមម៉ាកយីហោ (Branding) វិស័យទេសចរណ៍កម្ពុជា “**កម្ពុជា: ក្រៅពីប្រាសាទ**” ក្រោមយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ “**កម្ពុជា: ព្រះរាជាណាចក្រអច្ឆរិយៈ**”

២- ការធ្វើពិពិធកម្មផលិតផលទេសចរណ៍ប្រកបដោយនវានុវត្តន៍ និងច្នៃប្រឌិតផ្សារភ្ជាប់ជាមួយនឹងសសរស្តម្ភ “ភាពជាខ្មែរ” ស្របនឹងគោលគំនិត “3Cs”

៣- ការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់តាមផ្លូវអាកាសនៃប្រទេសកម្ពុជា

៤- ការសិក្សាពីនិន្នាការទីផ្សារទេសចរណ៍ថ្មីៗ និងអាកប្បកិរិយាទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩

៥- បង្កើតភាពទាក់ទាញកម្ពុជាជាគោលដៅទេសចរណ៍ម៉ាយៈ ទេសចរណ៍ម្ហូបអាហារ អេកូទេសចរណ៍ និងទេសចរណ៍ផ្សងព្រេង

៦- រៀបចំយុទ្ធសាស្រ្តទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ទៅកាន់ទីផ្សារទេសចរណ៍សំខាន់ៗតាមប្រព័ន្ធឌីជីថល (E-Reputation)

៧- បន្តសហការជាមួយទីផ្សារទេសចរណ៍ក្នុងតំបន់ និងក្នុងបណ្តាប្រទេសអាស៊ាន និងអាស៊ានបូកបី ក្នុងការរៀបចំយន្តការ “**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព**” ក្នុងតំបន់ និងការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង

៨- បន្តជំរុញចលនាទេសចរណ៍ក្នុងស្រុក

៩- បង្កើនភាពទាក់ទាញ និងផ្សព្វផ្សាយ “**កម្ពុជាជាគោលដៅទេសចរណ៍កីឡា**” តាមរយៈព្រឹត្តិការណ៍ SEA Game 2023។

### គ- យុទ្ធសាស្ត្រទី៣: ដាក់ឱ្យអនុវត្តយន្តការអភិបាលកិច្ចទេសចរណ៍ថ្មី÷

(**៦៧**). ក្នុងយុទ្ធសាស្ត្រទី៣ នេះ **សកម្មភាពយុទ្ធសាស្ត្រចំនួន០៤** ត្រូវបានលើកឡើង រួមមាន÷

១- ពង្រឹងយន្តការដៃគូរវាងរដ្ឋ-វិស័យឯកជន (PPP) ក្នុងការសិក្សាទីផ្សារ និង ផ្សព្វផ្សាយទេសចរណ៍កម្ពុជា

២- ពង្រឹងសមត្ថភាពសម្រាប់រដ្ឋបាលទំនើបក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍

៣- អនុវត្តផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា (២០២១-២០៣៥) និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប មណ្ឌលគិរី និងកែប

៤- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទេសចរណ៍។

# ផែនការសកម្មភាពអនុវត្តសង្ខេបនៃដំណាក់កាលទី២ : ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២២ - ២០២៣)

| យុទ្ធសាស្ត្រ | ២.១- ការស្តារឡើងវិញផ្នែកសេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍ | ២.២- ការស្តារឡើងវិញទីផ្សារទេសចរណ៍អន្តរជាតិ (តំបន់) និងបន្តជំរុញទេសចរណ៍ក្នុងស្រុក | ២.៣- ដាក់ឱ្យអនុវត្តយន្តការអភិបាលកិច្ចទេសចរណ៍ថ្មី |
|---|---|---|---|
| ដំណាក់កាលទី២ (Recovery) (២០២២ - ២០២៣) | ២.១.១- បន្តអនុវត្តកម្មវិធីគាំពារអាជីវកម្មទេសចរណ៍ខ្នាតតូច និងខ្នាតមធ្យម | ២.២.១- ទំនើបកម្មកិត្តិនាមម៉ាកយីហោ (Branding) វិស័យទេសចរណ៍កម្ពុជា **"កម្ពុជា: ក្រៅពីប្រាសាទ"** ក្រោមយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ **"កម្ពុជា : ព្រះរាជាណាចក្រអច្ឆរិយៈ"** | ២.៣.១- ពង្រឹងយន្តការដៃគូរវាងរដ្ឋ-វិស័យឯកជន (PPP) ក្នុងការសិក្សាទីផ្សារ និង ផ្សព្វផ្សាយទេសចរណ៍កម្ពុជា |
| | ២.១.២- លើកកម្ពស់ផលិតភាពក្នុងឧស្សាហកម្មទេសចរណ៍ (តាមរយៈពង្រឹងជំនាញថ្មីៗ និងបច្ចេកវិទ្យា) | ២.២.២- ការធ្វើពិពិធកម្មផលិតផលទេសចរណ៍ប្រកបដោយនវានុវត្តន៍ និងច្នៃប្រឌិតផ្សារភ្ជាប់ជាមួយនឹងសសរស្តម្ភ "ភាពជាខ្មែរ" ស្របនឹងគោលគំនិត "3Cs" | ២.៣.២- ពង្រឹងសមត្ថភាពសម្រាប់រដ្ឋបាលទំនើបក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ |
| | ២.១.៣- ពង្រឹងការអភិវឌ្ឍជំនាញទេសចរណ៍ក្នុងបរិការណ៍ថ្មី (ក្រោយវិបត្តិកូវីដ-១៩) | ២.២.៣- ការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់តាមផ្លូវអាកាសនៃប្រទេសកម្ពុជា | ២.៣.៣- អនុវត្តផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា (២០២១-២០៣៥) និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប មណ្ឌលគីរី និងកែប |
| | ២.១.៤- រៀបចំប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍទេសចរណ៍ឆ្លាតវៃ | ២.២.៤- ការសិក្សាពីនិន្នាការទីផ្សារទេសចរណ៍ថ្មីៗ និងអាកប្បកិរិយាទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩ | ២.៣.៤- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទេសចរណ៍ |
| | | ២.២.៥- បង្កើតភាពទាក់ទាញកម្ពុជាជាគោលដៅទេសចរណ៍ម៉ាយ ទេសចរណ៍ម្ហូបអាហារ អេកូទេសចរណ៍ និងទេសចរណ៍ផ្សងព្រេង | |
| | | ២.២.៦- រៀបចំយុទ្ធសាស្ត្រទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ទៅកាន់ទីផ្សារទេសចរណ៍សំខាន់ៗតាមប្រព័ន្ធឌីជីថល (E-Reputation) | |
| | | ២.២.៧- បន្តសហការជាមួយទីផ្សារទេសចរណ៍ក្នុងតំបន់ និងក្នុងបណ្តាប្រទេសអាស៊ាន និងអាស៊ានបូកបី ក្នុងការរៀបចំយន្តការ **"ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព"** ក្នុងតំបន់ និងការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង | |
| | | ២.២.៨- បន្តជំរុញចលនាទេសចរណ៍ក្នុងស្រុក | |
| | | ២.២.៩- បង្កើនភាពទាក់ទាញ និងផ្សព្វផ្សាយ **"កម្ពុជាជាគោលដៅទេសចរណ៍កីឡា"** តាមរយៈព្រឹត្តិការណ៍ SEA-Game 2023 | |

# ផែនការសកម្មភាពអនុវត្តលម្អិតនៃដំណាក់កាលទី២ : ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២២ - ២០២៣)

| ផែនការសកម្មភាពស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ | | | | |
|---|---|---|---|---|
| ល.រ. | សកម្មភាពយុទ្ធសាស្ត្រ | សកម្មភាពយុទ្ធសាស្ត្រលម្អិត | ទឡ្ហីករណ៍ | អង្គភាពទទួលខុសត្រូវ |
| **ដំណាក់កាលទី២: ការស្តារ និងលើកស្ទួយឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២២-២០២៣)** | | | | |
| **២.១- ការស្តារឡើងវិញផ្នែកសេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍** | | | | |
| **២.១.១-** | បន្តអនុវត្តកម្មវិធីគាំពារអាជីវកម្មទេសចរណ៍ខ្នាតតូច និងខ្នាតមធ្យម | • បន្តគាំទ្រលើកម្មវិធីគាំពារផ្នែកសេដ្ឋកិច្ច ដូចជា បន្តគាំទ្រហិរញ្ញប្បទានលើកទឹកចិត្តដល់អាជីវកម្មទេសចរណ៍ធុនតូច និងមធ្យម ក្នុងវិស័យទេសចរណ៍ ក្នុងករណីចាំបាច់<br>• បន្តការពិនិត្យ និងលើកទឹកចិត្តផ្នែកពន្ធដារ និងការលើកទឹកចិត្តនានាដែលបម្រើឱ្យមានការរស់រាននៃអាជីវកម្មទេសចរណ៍ធុនតូច និងមធ្យម ក្រោយវិបត្តិជំងឺកូវីដ-១៩ នេះភ្លាមៗ។ | យោងតាមការវិភាគលើការស្ទង់មតិស្តីពី **"ផលប៉ះពាល់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ លើវិស័យទេសចរណ៍នៅកម្ពុជា"** បង្ហាញថា អាជីវកម្មដែលទាក់ទងនឹងវិស័យសេវាកម្មទេសចរណ៍ត្រូវបានមើលឃើញថាទទួលរងផលប៉ះពាល់ស្ទើរតែ (១០០%)។<br>តាមការរំពឹងទុក វិស័យទេសចរណ៍កម្ពុជាអាចនឹងត្រូវការរយៈពេលប្រហែលចន្លោះពី ០៤-០៥ ឆ្នាំ ដើម្បីវិលត្រឡប់មករកសភាពដើមវិញក្រោយពីវិបត្តិជំងឺកូវីដ-១៩ នេះ។ ដូច្នេះ ដើម្បីធានាភាពរស់រានរបស់វិស័យឯកជនទាំងអស់ និងរក្សានូវភាពធន់ ក្នុងចរន្តសេដ្ឋកិច្ច គួរដាក់ចេញវិធានការគាំទ្របន្តដល់អាជីវកម្មទេសចរណ៍ធុនតូច និងមធ្យមក្នុងវិស័យទេសចរណ៍ និងការលើកទឹកចិត្តនានាដូចជាអន្តរាគមន៍ជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលកម្ពុជា។ | - ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- វិស័យឯកជន |
| **២.១.២-** | លើកកម្ពស់ផលិតភាពក្នុងឧស្សាហកម្មទេសចរណ៍ (តាមរយៈពង្រឹងជំនាញថ្មីៗ និងបច្ចេកវិទ្យា) | • សម្រួលដល់ការផ្ទេរបច្ចេកវិទ្យាគាំទ្រដល់ការលើកកម្ពស់ផលិតភាពអាជីវកម្មទេសចរណ៍<br>• លើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗបម្រើឱ្យ | ដំណើរការនៃការជំរុញវិស័យទេសចរណ៍ឱ្យឆ្ពោះទៅរកបរិបទថ្មី នឹងត្រូវការការវិនិយោគក្នុងកម្រិតគួរឱ្យកត់សម្គាល់ពីស្ថាប័នរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍនានា។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នៅ | - ក្រសួងទេសចរណ៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

| | | | | |
|---|---|---|---|---|
| | | វិស័យ ទេសចរណ៍<br>• ពង្រឹងការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល និង ជំនាញឌីជីថល ក្នុងឧស្សាហកម្មទេសចរណ៍ | ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរដ្ឋសភា អាណត្តិទី៦នេះ ក្នុងការត្រៀមលក្ខណៈសម្បត្តិសម្រប ខ្លួន នឹងបដិវត្តន៍ឧស្សាហកម្មទី៤ ខណៈដែលបដិវត្តន៍ ឧស្សាហកម្មទី៤ កំពុងបង្ហាញពីការរីកចម្រើននៃបច្ចេក-វិទ្យានៅក្នុងពិភពលោក ដែលជះឥទ្ធិពលយ៉ាងខ្លាំងលើ ការកំណត់ឡើងវិញនូវកត្តាផលិតកម្ម ឥរិយាបថការប្រើ ប្រាស់ ពិសេសការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះ នឹងចូល រួមបង្កើនភាពប្រកួតប្រជែង និងផលិតភាពក្នុងឧស្សាហ-កម្មទេសចរណ៍។<br>ទន្ទឹមនឹងការរក្សាភាពធន់របស់វិស័យឯកជន សហគ្រិន/និយោជកគួរគិតគូរអំពីគំរូអាជីវកម្មប្រភេទថ្មី ដើម្បីសម្របទៅតាមស្ថានភាពសេដ្ឋកិច្ច-សង្គមជាក់ស្តែង ដោយក្នុងនោះ÷<br>ទី១)-អាជីវកម្មគួរអនុវត្តដំណោះស្រាយឌីជីថល តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ។<br>ទី២)- ត្រូវពង្រឹងសមត្ថភាព និងគុណភាព ពិសេសការបង្កើនផលិតភាព ដើម្បីត្រៀមខ្លួនរួចជាស្រេច សម្រាប់ការប្រកួតប្រជែងស្រួចស្រាល ទីផ្សារកាន់តែរួម ចង្អៀត ហើយខ្សែចង្វាក់ផ្គត់ផ្គង់កាន់តែបង្រួមខ្លី។<br>ការគិតគូរប្រើប្រាស់បច្ចេកវិទ្យាថ្មីៗក្នុង ប្រតិបត្តិការអាជីវកម្មទេសចរណ៍បានលុះត្រាតែម្ចាស់ អាជីវកម្មនោះយល់ដឹងច្បាស់លាស់ អំពីបច្ចេកវិទ្យា និង អក្ខរកម្មឌីជីថលមានកម្រិតសមរម្យ។ ដូច្នេះ ទាមទារ នូវការបណ្តុះបណ្តាលជំនាញឌីជីថលដល់ម្ចាស់អាជីវកម្ម | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>- វិស័យឯកជន<br>- មជ្ឈមណ្ឌលកម្ពុជា៤.០ |

| | | | | |
|---|---|---|---|---|
| | | | និងជនបង្គោលក្នុងវិស័យទេសចរណ៍នោះ។ ជាដំណាក់កាលដំបូង ក្រសួងទេសចរណ៍នឹងសហការជាមួយស្ថាប័នជំនាញក្នុងការរៀបចំវគ្គបណ្តុះបណ្តាលគ្រប់គ្រងអាជីវកម្មទេសចរណ៍តាមបែបឌីជីថលនានា ដូចជា ការបណ្តុះ-បណ្តាលអចល័ត ការបណ្តុះបណ្តាលចល័ត ការបណ្តុះ-បណ្តាលក្នុងក្រុមហ៊ុន ការបណ្តុះបណ្តាលនៅកន្លែងធ្វើការជាដើម។<br>ដូច្នេះ វិស័យទេសចរណ៍កម្ពុជាទាមទារនូវមូលនិធិសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ លើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗក្នុងវិស័យទេសចរណ៍ ក៏ដូចជាមធ្យោ-បាយសម្របសម្រួលផ្គត់ផ្គង់ឆ្ពោះទៅអភិវឌ្ឍន៍ពាណិជ្ជ-កម្មអេឡិចត្រូនិក ។ | |
| **២.១.៣-** | ពង្រឹងការអភិវឌ្ឍជំនាញទេសចរណ៍ក្នុងបរិការណ៍ថ្មី (ក្រោយវិបត្តិកូវីដ-១៩) | • បន្ទីជំនាញឌីជីថល ជាមួយនឹងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍<br>• ពង្រឹងការអភិវឌ្ឍជំនាញទេសចរណ៍ស្របតាមចក្ខុវិស័យ "**បុគ្គលិកម្នាក់ ជំនាញមួយ**" | ជំនាញឌីជីថលមាន ៣ កម្រិត រួមមាន÷<br>- **កម្រិតទី១.** ជំនាញឌីជីថលមូលដ្ឋាន: ជាជំនាញដែលមានតម្រូវការស្ទើរតែគ្រប់ការងារទាំងអស់ ជាជំនាញត្រូវការនូវការចេះប្រើប្រាស់បច្ចេកវិទ្យាអប្បបរមា សម្រាប់ជីវិត និងការងារប្រចាំថ្ងៃ។ ឧទាហរណ៍ ចេះប្រើប្រាស់ទូរសព្ទដៃឆ្លាត និងកម្មវិធីទូរសព្ទមួយចំនួន ដូចជា Google Maps, Telegram, Facebook ។ល។<br>- **កម្រិតទី២.** ជំនាញឌីជីថលកម្រិតមធ្យម : ជាជំនាញទាមទារចំណេះដឹងផ្នែកបច្ចេកវិទ្យាសម្រាប់បំពេញការងារ ឬប្រតិបត្តិការអាជីវកម្ម។ ឧទាហរណ៍ ប្រើប្រាស់កម្មវិធី Design ផ្សព្វផ្សាយអាជីវកម្មក្នុង | - ក្រសួងទេសចរណ៍<br>- សហភាពសហព័ន្ធយុវជនកម្ពុជា<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- មជ្ឈមណ្ឌលកម្ពុជា ៤.០ |

| | | | | |
|---|---|---|---|---|
| | | | គេហទំព័រ ឬ FaceBook, ជំនាញធ្វើទីផ្សារឌីជីថលក្នុងវិស័យទេសចរណ៍ជាដើម។<br>- **កម្រិតទី៣.** ជំនាញឌីជីថលកម្រិតខ្ពស់: ជាជំនាញសម្រាប់បុគ្គលជំនាញ ដែលពួកគេជាអ្នកបង្កើត គ្រប់គ្រង ធ្វើតេស្ត និងវិភាគលើបច្ចេកវិទ្យានោះ ដូចជា ការសរសេរកូដ ការបង្កើតគេហទំព័រ ការបង្កើតកម្មវិធីទូរសព្ទ អ្នកគ្រប់គ្រងប្រព័ន្ធ (Networking) អ្នកវិភាគទិន្នន័យមហាសាល អ្នកគ្រប់គ្រង់បច្ចេកវិទ្យាសុវត្ថិភាពតាមអ៊ីនធឺណិត (Cyber security) ។ល។ សម្រាប់អ្នកជំនាញជាន់ខ្ពស់។<br>ដូច្នេះ ក្រោយវិបត្តិជំងឺកូវីដ-១៩ នេះ នឹងមានដាក់ចេញយុទ្ធនាការពីរព្រមគ្នា ដើម្បីគាំទ្រដល់វិស័យឯកជនរបស់យើងក្នុងការចាប់យកឱកាសនៃបច្ចេកវិទ្យាឌីជីថលក្នុងការបង្កើនផលិតភាពរបស់ខ្លួន និងភាពប្រកួតប្រជែង គឺការដាក់យុទ្ធនាការ "**ជំនាញឌីជីថលក្នុងវិស័យទេសចរណ៍**" ដោយផ្តោតលើកម្រិតទី២ និងទី៣។ រីឯ កម្រិតទី១ មានសារៈសំខាន់សម្រាប់ភ្ញៀវទេសចរ និងមន្ត្រី ដែលត្រូវចេះជំនាញឌីជីថល និងឌីជីថលមូលដ្ឋាន គឺត្រូវដាក់ចេញយុទ្ធនាការ "**អក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍**"។<br>ក្នុងដំណាក់កាលនេះ ការអភិវឌ្ឍជំនាញវិជ្ជាជីវៈទេសចរណ៍មានសារៈសំខាន់ចាំបាច់ និងដើម្បីឱ្យស្របតាមចក្ខុវិស័យ "**បុគ្គលិកម្នាក់ ជំនាញមួយ**" នោះ | |

| | | | | |
|---|---|---|---|---|
| | | | ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអាចស្ថិតក្រោមទម្រង់ការបណ្តុះបណ្តាលផ្ទាល់ និងការបណ្តុះបណ្តាលតាមអនឡាញ (E-Learning)។ ដូច្នេះ **ការបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅប៉ូលទេសចរណ៍អាទិភាពទាំង ៤** គឺជាការចាំបាច់ (**រាជធានីភ្នំពេញ ខេត្តព្រះសីហនុ សៀមរាប និងមណ្ឌលគិរី**)។ | |
| **២.១.៤** | រៀបចំប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍទេសចរណ៍ឆ្លាតវៃ | • សិក្សាលើគម្រោងវិនិយោគសមស្របនានាដែលគាំទ្រដល់ការចាប់យកបច្ចេកវិទ្យាជាក់ស្តែងស្របតាមទស្សនទានទេសចរណ៍ឆ្លាតវៃ<br>• ដាក់ចេញនូវកម្មវិធីឌីជីថលនានាដែលគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍កម្ពុជា (ឧ.ផ្តល់កម្មវិធីទូរសព្ទមានមគ្គុទ្ទេសក៍ច្រើនភាសា និងងាយស្រួល សេវាកម្មធ្វើដំណើរ ការទូទាត់ប្រាក់លើប្រព័ន្ធអ៊ីនធឺណិត។ល។<br>• រៀបចំបណ្តាញ និងប្រព័ន្ធឌីជីថលគាំទ្រ ដែលមានដូចជា ការផ្តល់សេវាកម្ម Free Wi-Fi សម្រាប់ភ្ញៀវទេសចរនៅតាមគោលដៅទេសចរណ៍សំខាន់ៗ និងការចុះអាជ្ញាបណ្ណអាជីវកម្មទេសចរណ៍តាមប្រព័ន្ធអនឡាញ។ល។<br>• ផ្តល់ប្រព័ន្ធសុវត្ថិភាពខ្ពស់លើបណ្តាញអ៊ីនធឺណិត ទាំងសុវត្ថិភាពតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឯកជនភាព។ល។ | ការសម្រេចចិត្តដែលមានទិន្នន័យច្បាស់លាស់ និងការដាក់ចេញយុទ្ធសាស្ត្រ គឺមានសារៈសំខាន់ណាស់ ជាពិសេសនៅពេលមានវិបត្តិនេះ។ ដូច្នេះ ត្រូវចាប់យកការផ្លាស់ប្តូរឌីជីថល និងជំរុញការរៀបចំប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យា (Ecosystem) គាំទ្រដល់ដំណើរការឌីជីថលរូបនីយកម្ម ទាំងក្នុងស្ថាប័ន រដ្ឋ និងឯកជន ដូចជាការវិនិយោគលើទិន្នន័យ ការវិភាគទិន្នន័យ និងការសហការជាមួយដៃគូក្នុងការផ្ទេរបច្ចេកវិទ្យា (Transformation Technology) បម្រើឱ្យការអភិវឌ្ឍទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩ ។ | - ក្រសួងទេសចរណ៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- មជ្ឈមណ្ឌលកម្ពុជា ៤.០<br>- វិស័យឯកជន<br>- ដៃគូអភិវឌ្ឍ |

| | | | | |
|---|---|---|---|---|
| **២.២- ការស្តារឡើងវិញទីផ្សារទេសចរណ៍អន្តរជាតិ (តំបន់) និងបន្តជំរុញទេសចរណ៍ក្នុងស្រុក** | | | | |
| **២.២.១-** | ទំនើបកម្មកិត្តិនាមម៉ាកយីហោវិស័យទេសចរណ៍កម្ពុជា“**កម្ពុជា: ក្រៅពីប្រាសាទ**” ក្រោមយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ “**កម្ពុជា: ព្រះរាជាណាចក្រអច្ឆរិយៈ**” | • បង្កើតម៉ាកយីហោទេសចរណ៍ថ្មី មានលក្ខណៈទាក់ទាញ និងមានភាពចម្រុះ ដោយផ្អែកលើសសសរស្តម្ភចំនួន ០៤គឺ ភាពជាខ្មែរ បេតិកភណ្ឌវប្បធម៌ ទេសចរណ៍ឆ្នេរ និងអេកូទេសចរណ៍។<br>• រៀបចំការត្រួតពិនិត្យឡើងវិញលើកិត្តិនាមម៉ាកយីហោ ទេសចរណ៍កម្ពុជា ដោយធ្វើការជាមួយអ្នកជំនាញការជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីធ្វើទំនើបកម្មកិត្តិនាមម៉ាកយីហោទេសចរណ៍កម្ពុជា ដោយត្រូវរំលេចជាសំខាន់នូវសសរស្តម្ភ “ភាពជាខ្មែរ” ដែលជាសក្តានុពលដ៏ធំសម្រាប់កម្ពុជា | កិត្តិនាមម៉ាកយីហោថ្មីរបស់កម្ពុជាដែលមានភាពខ្លាំងក្លា និងមានភាពចម្រុះនោះ គឺត្រូវផ្តោតលើការអភិវឌ្ឍលើសសរស្តម្ភចំនួន ០៤ គឺ ភាពជាខ្មែរ បេតិកភណ្ឌវប្បធម៌ ទេសចរណ៍ឆ្នេរ និងអេកូទេសចរណ៍។ ប្រទេសកម្ពុជាមានសក្តានុពលធំធេងលើសសរស្តម្ភទាំង ៤ នេះ ហើយត្រូវបានទទួលស្គាល់ពិតប្រាកដពីវិស័យឯកជនក្នុងវិស័យទេសចរណ៍កម្ពុជា។ យុទ្ធនាការផ្សព្វផ្សាយនេះនឹងត្រូវផ្តោតលើប្រភពទីផ្សារទេសចរណ៍ខុសៗគ្នា (ទាំងសម្រាប់ទីផ្សារទេសចរណ៍លោកខាងលិច និងទីផ្សារទេសចរណ៍តំបន់អាស៊ី)។ ដំបូងយុទ្ធនាការនេះគួរត្រូវបានបង្កើតឡើងជាបឋមសម្រាប់: ទីផ្សារទេសចរណ៍ចិន ទីផ្សារទេសចរណ៍ក្នុងតំបន់អាស៊ាន និងទីផ្សារទេសចរណ៍ប្រទេសដែលប្រើប្រាស់ភាសាអង់គ្លេស។<br>ចំពោះការរៀបចំ កិត្តិនាមម៉ាកយីហោនេះ គួរសិក្សា និងរៀបចំឡើងដោយក្រុមហ៊ុនសេវាទីប្រឹក្សាជំនាញ ដែលមានឯកទេសខ្ពស់លើការរៀបចំយុទ្ធនាការម៉ាកយីហោទេសចរណ៍ និងមានបទពិសោធន៍លើកិច្ចការងារនេះ និងឧបត្ថម្ភហិរញ្ញប្បទានដោយគម្រោងពង្រឹងសមត្ថភាពទេសចរណ៍ (TCBP) របស់ទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD)។ | - ក្រសួងទេសចរណ៍ |
| **២.២.២-** | ការធ្វើពិពិធកម្មផលិតផលទេសចរណ៍ប្រកបដោយនវានុវត្តន៍ និងច្នៃប្រឌិត ផ្សារភ្ជាប់ | • អភិវឌ្ឍន៍ផលិតផលទេសចរណ៍ថ្មីៗ ទាក់ទាញ និងគុណភាពនៅខេត្តសៀមរាប និងតំបន់ជុំវិញ រួមមាន៖<br>– ដាក់អនុវត្តផែនការសកម្មភាពចំពោះមុខ | វិស័យទេសចរណ៍ក្នុងបរិបទថ្មីក្រោយវិបត្តិកូវីដ-១៩ នេះនឹងផ្តល់ឱកាសឱ្យ**កម្ពុជាក្លាយជាគោលដៅទេសចរណ៍ ដែលអាចផ្តល់នូវផលិតផលទេសចរណ៍** | - ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | | | | |
|---|---|---|---|---|
| | ជាមួយនឹងសសរស្តម្ភ “ភាពជាខ្មែរ” ស្របនឹងគោលគំនិត “3Cs” | អភិវឌ្ឍន៍វិស័យទេសចរណ៍<br>– ពង្រឹងការគ្រប់គ្រងគុណភាពវត្ថុអនុស្សាវរីយ៍<br>– ទេសចរណ៍ម្ហូបអាហារ “**បង្កើតភូមិម្ហូបអាហារ នៅតំបន់បុរីវប្បធម៌**”<br>– តម្លៃសំបុត្រអង្គរមាន ៣ប្រភេទ (សម្រាប់ភ្ញៀវពីអាយុ១២ឆ្នាំឡើង) គួរសិក្សាពិនិត្យឡើងវិញលើគោលនយោបាយតម្លៃសំបុត្រអង្គរដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩ (សំបុត្រ ៣៧ដុល្លារ ឱ្យចូលបានច្រើនថ្ងៃសម្រាប់ឆ្នាំ២០២០)<br>• អភិវឌ្ឍន៍ផលិតផលទេសចរណ៍ថ្មីៗ ទាក់ទាញ និងគុណភាពនៅរាជធានីភ្នំពេញ និងតំបន់ជុំវិញ រួមមាន÷<br>– បង្កើនការផ្សព្វផ្សាយគោលដៅទេសចរណ៍ថ្មីៗដែលទើបបង្កើតឡើង (Prince Minor, Grand Waterpark..។ល។)<br>– ជំរុញភ្ជាប់រាជធានីភ្នំពេញទៅតំបន់ជុំវិញ ដូចជារមណីយដ្ឋានឧដុង្គ កោះដាច់ ភូមិចម្លាក់ប្រាក់នៅកំពង់ហ្លួង<br>– ត្រៀមរៀបចំព្រឹត្តិការទេសចរណ៍ផ្សេងៗ ទាំងជាតិ និងអន្តរជាតិ<br>– ផ្ទាំងទស្សនីយភាពសិល្បៈ វប្បធម៌កម្រិតខ្ពស់ប្រចាំសប្តាហ៍ និងការអភិវឌ្ឍទេសចរណ៍កម្សាន្តតាមដងទន្លេ | **សក្តានុពលសំខាន់ៗ (Niche Products)**។ ឧទាហរណ៍ ទេសចរណ៍បែបសុខភាព សុខុមាលភាព សកម្មភាពយ៉ូហ្គា និងសុវត្ថិភាព។ ក្នុងនោះ ទេសចរណ៍បែបសាសនា និងជំនឿ ក៏អាចក្លាយជាផលិតផលមួយដែលអាចផ្តល់បទពិសោធន៍ទេសចរណ៍ផងដែរ។<br>នេះបើកឱកាសសម្រាប់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍផលិតផលពិសេសបន្ថែមទៀតដែលឆ្លើយតបនឹងតម្រូវការទាំងនេះដែលកម្ពុជាមានផលិតផលទេសចរណ៍ជាច្រើនរួចស្រាប់ទៅហើយ ដូចជា ស្ប៉ា សកម្មភាពយ៉ូហ្គា ទេសចរណ៍បែបសុខភាព និងព្រឹត្តិការណ៍សាសនា។<br>ដើម្បីកសាងប្រទេសកម្ពុជាទៅជាគោលដៅទេសចរណ៍ប្រកបដោយភាពចម្រុះ និងលើកទឹកចិត្តកម្ពុជាឱ្យក្លាយជាគោលដៅទេសចរណ៍ដ៏ទាក់ទាញមួយក្នុងតំបន់ គឺមិនអាចមើលរំលងពីការអភិវឌ្ឍវិស័យទេសចរណ៍នៅប៉ូលទេសចរណ៍អាទិភាពទាំង ៤ គឺ សៀមរាប និងតំបន់ជុំវិញ ព្រះសីហនុ និងតំបន់ជុំវិញ តំបន់ឦសាន និងតំបន់ជុំវិញ និងភ្នំពេញ និងតំបន់ជុំវិញ។<br>តំបន់ឆ្នេរសមុទ្រកម្ពុជា: ជាចំណុចដ៏ទាក់ទាញដល់ភ្ញៀវទេសចរកម្រិតខ្ពស់ក្នុងតំបន់ និងទីផ្សារទេសចរណ៍លោកខាងលិច។ ការប្រកាស “**ខេត្តកែបជាគោលដៅទេសចរណ៍លំដាប់ខ្ពស់**” ឬ ការកំណត់ និងជ្រើសរើសទីតាំងទេសចរណ៍ក្នុងតំបន់ឆ្នេរណាមួយ ឬកោះណាមួយ (ឧទាហរណ៍ កោះរ៉ុង) ទៅតាមចំណុចចាប់ផ្តើមអាទិភាព គឺជាការគួរដើម្បីលើកទឹកចិត្តឱ្យមាន | - ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលខេត្តសៀមរាប<br>- រដ្ឋបាលរាជធានីភ្នំពេញ<br>- គណៈកម្មការសម្រួលការ-ធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍<br>- គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា<br>- អាជ្ញាធរជាតិអប្សរា<br>- គ្រឹះស្ថានអង្គរ |

| | | | | |
|---|---|---|---|---|
| | | – រៀបចំឱ្យមានតំបន់ទេសចរណ៍ថ្មីរជើង<br>– ដាក់ចេញទីផ្សារទេសចរណ៍ម៉ាយសម្រាប់ទីផ្សារអន្តរជាតិ<br>• អភិវឌ្ឍន៍ផលិតផលទេសចរណ៍ថ្មីៗ ទាក់ទាញ និងគុណភាពនៅខេត្តព្រះសីហនុ និងតំបន់ជុំវិញ រួមមាន÷<br>– បង្កើតព្រឹត្តិការណ៍ទេសចរណ៍ និងបង្កើនភាពទាក់ទាញទេសចរណ៍នៅខេត្តព្រះសីហនុ<br>– បង្កើត “**សួនទេសចរណ៍ តេជោ Westerdam**” នៅខេត្តព្រះសីហនុ<br>– ពង្រឹងមធ្យោបាយដឹកជញ្ជូនទេសចរណ៍ផ្លូវទឹកក្នុងខេត្តតំបន់ឆ្នេរ<br>– ជំរុញការកសាងកំពង់ផែទេសចរណ៍នៅខេត្តកំពត<br>– ជំរុញកិច្ចសហការទេសចរណ៍ច្រករបៀងខាងត្បូង<br>– ជំរុញរៀបចំផ្សព្វផ្សាយការទាក់ទាញទេស-ចរណ៍នាវា<br>– សិក្សាតម្លៃទិដ្ឋាការជូនភ្ញៀវទេសចរមកតាមនាវា<br>• អភិវឌ្ឍន៍ផលិតផលទេសចរណ៍ថ្មីៗ ទាក់ទាញ និងគុណភាពនៅតំបន់ភូមិភាគឥសាន្ត និងតំបន់ជុំវិញ រួមមាន÷<br>– បង្កើតកញ្ចប់ទស្សនកិច្ចតភ្ជាប់កម្ពុជា-ថៃ- | ការបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងទេសចរណ៍កម្ពុជាជារួម។<br>ផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្ហាញឱ្យឃើញថាសារៈសំខាន់នៃវិស័យទេសចរណ៍សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងតម្រូវការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃរំហូរភ្ញៀវទេសចរហួសកម្រិត និងផលប៉ះពាល់បរិស្ថានជាដើម។ ដូច្នេះ ក្នុងការស្តារវិស័យទេសចរណ៍កម្ពុជាឡើងវិញ កត្តានិរន្តរភាព និងការគិតគូរអំពី**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល (SDGs)** ត្រូវតែជាគោលគំនិតគ្រឹះក្នុងការអភិវឌ្ឍទេសចរណ៍ ដើម្បីធានាថាទេសចរណ៍នឹងមានដំណើរការប្រកបដោយនិរន្តរភាពនាពេលអនាគតសម្រាប់យុវជនជំនាន់ក្រោយផងដែរ។ | |

| | | | | |
|---|---|---|---|---|
| | | ឡាវ (កាត់តាមភូមិភាគឦសាន)<br>– ពង្រឹងការអភិវឌ្ឍអេកូទេសចរណ៍ និងសហគមន៍ទេសចរណ៍<br>• ជំរុញអភិវឌ្ឍន៍ផលិតផលទេសចរណ៍គាំទ្រក្នុងនោះរួមមាន÷<br>– រៀបចំអភិវឌ្ឍន៍ផលិតផលកសិ-ទេសចរណ៍ដោយកំណត់ជាខ្សែទស្សនកិច្ច នៅតាមភូមិស្រុកដែលមានសក្តានុពល<br>– ជំរុញអភិវឌ្ឍន៍សហគមន៍ទេសចរណ៍/ អេកូ-ទេសចរណ៍/ ទេសចរណ៍សាសនា និងជំនឿ/ សកម្មភាពយ៉ូហ្គា<br>– ជំរុញអភិវឌ្ឍន៍ និងផ្សព្វផ្សាយពីសក្តានុពលក្រុង Secondary Cities (បាត់ដំបង ក្រចេះ កែប កំពត មណ្ឌលគិរី)<br>– បង្កើនផលិតផល និងព្រឹត្តិការណ៍កីឡា វប្បធម៌នៅតាមបណ្តារាជធានី-ខេត្ត<br>– រៀបចំសម្រាប់ទីផ្សារទេសចរណ៍ថ្មីៗ ជាពិសេសទេសចរណ៍បែបសុខភាព និងសុខុមាលភាព<br>– សិក្សា និងការបង្កើតតំបន់ទេសចរណ៍ពិសេសនៅតាមប៉ូលទេសចរណ៍អាទិភាព<br>• សហការជាមួយក្រុមហ៊ុនជំនាញដើម្បីសិក្សា និងផ្សព្វផ្សាយពីរមណីយដ្ឋានទេសចរណ៍សក្តានុពលបន្ថែម រួមទាំងសហការបង្កើតរមណីយដ្ឋាន | | |

| | | | | |
|---|---|---|---|---|
| | | ទេសចរណ៍កែច្នៃផងដែរ ដើម្បីបង្កើនភាពទាក់ទាញដល់ភ្ញៀវទេសចរអន្តរជាតិឱ្យស្នាក់នៅកម្ពុជាបានយូរជាងមុន | | |
| ២.២.៣- | ការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់តាមផ្លូវអាកាសនៃប្រទេសកម្ពុជា | • បង្កើតភាពជាដៃគូអាជីវកម្មជាមួយក្រុមហ៊ុនអាកាសចរណ៍ដើម្បីស្តារឡើងវិញជើងហោះហើរតាមផ្លូវអាកាស ដែលមានស្រាប់ឱ្យដំណើរការឡើងវិញ និងបង្កើតឱ្យមានផ្លូវអាកាសថ្មីបន្ថែម<br>• បង្កើតកញ្ចប់លើកទឹកចិត្តសម្រាប់តម្លៃចុះចតតាមព្រលានយន្តហោះនៃប្រទេសកម្ពុជា ។ល។<br>• បន្តពង្រឹងយន្តការសុវត្ថិភាពសុខាភិបាលនៅតាមក្រុមហ៊ុនអាកាសចរ និងនៅតាមព្រលានយន្តហោះ (ភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ)<br>• ផ្តល់ភាពងាយស្រួល និងឆាប់រហ័សដល់ការមកដល់ភ្ញៀវជាតិ និងអន្តរជាតិ<br>• ធានាលើសុវត្ថិភាពដល់ភ្ញៀវទេសចរដែលនឹងមកដល់កម្ពុជា ជាពិសេសក្នុងពេលវិបត្តិកូវីដ-១៩<br>• ធានាតម្លាភាពថ្លៃនៃសេវាកម្មដឹកជញ្ជូនភ្ញៀវដូចជាតាក់ស៊ី ម៉ូតូរ៉ឺម៉កជាដើម តាមរយៈសមាគម<br>• ភាពរួសរាយរាក់ទាក់ ជួយយកអាសារ ដែលជាផ្នែកមួយទាក់ទាញភ្ញៀវទេសចរប្រកបដោយបដិសណ្ឋារកិច្ចល្អនៅតាមច្រកទ្វារអន្តរជាតិ។ | មុនពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះកម្ពុជាបានទាក់ទាញជាបន្តបន្ទាប់ឱ្យមានការតភ្ជាប់ត្រង់មកកាន់ព្រះរាជាណាចក្រកម្ពុជា (ឧទាហរណ៍ ការហោះហើរត្រង់ពីកាតា មកកាន់ខេត្តសៀមរាប)។<br>ភាពងាយស្រួលក្នុងការធ្វើដំណើរ គឺជាកត្តាសំរេចចិត្តដ៏សំខាន់មួយសម្រាប់ភ្ញៀវទេសចរដែលធ្វើដំណើរចម្ងាយឆ្ងាយ នៅក្រោយការរីករាលដាលនៃជំងឺកូវីដ-១៩។ សូម្បីតែភ្ញៀវទេសចរថ្មីៗ ដែលចាប់ផ្តើមធ្វើដំណើរដំបូង ពួកគេក៏នឹងកាត់បន្ថយហានិភ័យដោយជៀសវាងការធ្វើដំណើរដែលមានការឆ្លងកាត់ច្រើនកន្លែងដើម្បីកាត់បន្ថយផលប៉ះពាល់ មានន័យថា ការធ្វើដំណើរឆ្លងកាត់ អាចថយចុះ។<br>ក្រុមហ៊ុនអាកាសចរជាច្រើនកំពុងជួបបញ្ហាក្ស័យធនផ្នែកហិរញ្ញវត្ថុនាពេលបច្ចុប្បន្នហើយពួកគេកំពុងស្វែងរកគំរូអាជីវកម្មរឹងមាំ សម្រាប់ការបើកជើងហោះហើរឡើងវិញ។<br>រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ គួរបង្កើតយុទ្ធសាស្រ្តរួមគ្នា និងភ្ជាប់ទំនាក់ទំនងជាមួយក្រុមហ៊ុនអាកាសចរសំខាន់ៗដើម្បីបើកការតភ្ជាប់ហោះហើរត្រង់មកកាន់ព្រះរាជាណាចក្រ | - រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា<br>- ក្រុមហ៊ុនអាកាសចរណ៍ និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ |

| | | | | |
|---|---|---|---|---|
| | | | កម្ពុជា ទាំងរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ។<br>ដូច្នេះ ត្រូវបង្កើតកញ្ចប់លើកទឹកចិត្តដ៏គួរឱ្យទាក់ទាញ (ទាក់ទងនឹងថ្លៃដើមចុះចត)។ ទន្ទឹមនឹងនេះ គួរពង្រឹងសមត្ថភាពក្រុមហ៊ុនអាកាសចរជាតិ ដើម្បីត្រៀមខ្លួនទទួលភ្ញៀវទេសចរឱ្យកាន់ច្រើនក្រោយវិបត្តិជំងឺកូវីដ-១៩។ | |
| ២.២.៤- | ការសិក្សាពីនិន្នាការទីផ្សារទេសចរណ៍ថ្មីៗ និងអាកប្បកិរិយាទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩ | • ធ្វើការវិនិយោគទៅលើសកម្មភាពប្រមូលទិន្នន័យ និងប្រព័ន្ធតាមដានទេសចរណ៍ប្រកបដោយភាពឆ្លាតវៃដើម្បីតាមដាននូវអាកប្បកិរិយា និងនិន្នាការដែលអាចវាយតម្លៃ និងព្យាករទេសចរណ៍ ព្រមទាំងអាចកែតម្រូវការរៀបចំផលិតផលទេសចរណ៍ឡើងវិញ និងយុទ្ធសាស្ត្រទីផ្សារឱ្យបានសមស្រប។<br>• រៀបចំបញ្ចូលបច្ចេកវិទ្យាថ្មីៗពាក់ព័ន្ធនឹងការប្រមូល និងវិភាគទិន្នន័យទីផ្សារទេសចរណ៍ ដូចជា Big Data, AI, Cloud System ជាដើម។<br>• សហការជាមួយស្ថាប័នរដ្ឋ និងឯកជន អង្គការជំនាញនានា ដោះដូរចំណេះដឹង និងបទពិសោធន៍ដល់មន្ត្រី បុគ្គលិក(រដ្ឋ និងឯកជន) ក្នុងការងារទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ | ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ លើវិស័យទេសចរណ៍ និងការធ្វើដំណើរពិភពលោក គឺមានទំហំធំបំផុតដែលមិនធ្លាប់មានក្នុងរយៈពេល ៣០ឆ្នាំ ចុងក្រោយ។ ផលប៉ះពាល់នេះបានធ្វើឱ្យការធ្វើដំណើរបញ្ឈប់ស្ទើរតែទាំងស្រុង និងឥទ្ធិពលលើផ្នត់គំនិត និងកត្តាចិត្តសាស្ត្ររបស់ភ្ញៀវទេសចរដែលមិនធ្លាប់មានពីមុនផងដែរ។<br>នៅពេលវិស័យទេសចរណ៍ និងការធ្វើដំណើរចាប់ផ្តើមស្តារឡើងវិញ និងមានការផ្លាស់ប្តូរនូវអាកប្បកិរិយារបស់ទីផ្សារទេសចរណ៍ និងផ្នត់គំនិតរបស់ភ្ញៀវទេសចរសម្រាប់ពិចារណាក្នុងការធ្វើដំណើរក្នុងទម្លាប់ថ្មី។ ស្ថានការណ៍បានវិវត្តយ៉ាងឆាប់រហ័ស ពិសេសវិស័យទេសចរណ៍ដែលការសិក្សា និងការយល់ដឹងពីទីផ្សារទេសចរណ៍ពីមុនស្ទើរតែលែងប្រើការបាន។<br>ការសិក្សាយល់ដឹង**អំពី "វិស័យទេសចរណ៍ក្នុងដំណាក់កាលទម្លាប់ថ្មី"** និងសិក្សាអំពីចំណង់ចំណូលចិត្ត ឬអាកប្បកិរិយារបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិក្រោយពេលមានវិបត្តិ គឺមានសារៈសំខាន់សម្រាប់ការ | - ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | | | រៀបចំដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ និងផ្សព្វផ្សាយទេសចរណ៍ឱ្យចំគោលដៅទីផ្សារអាទិភាពនានា។ | |
| **២.២.៥-** | បង្កើតភាពទាក់ទាញកម្ពុជាជាគោលដៅទេសចរណ៍ម៉ាយ ទេសចរណ៍ម្ហូបអាហារ អេកូទេសចរណ៍ និងទេសចរណ៍ផ្សងព្រេង | • បង្កើតយុទ្ធសាស្ត្រសម្រាប់ពង្រីងវិស័យទេសចរណ៍ម៉ាយ ទេសចរណ៍ម្ហូបអាហារ អេកូទេសចរណ៍ និងទេសចរណ៍ផ្សងព្រេង នៅកម្ពុជា<br>• រៀបចំយុទ្ធសាស្ត្រសិក្សាទីផ្សារ និងផ្សព្វផ្សាយសម្រាប់ទេសចរណ៍ទាំងនេះ ដែលបម្រើឱ្យទាំងទីផ្សារក្នុងស្រុក និងអន្តរជាតិ<br>• រៀបចំផែនការលើកទឹកចិត្ត/ឧបត្ថម្ភធនដើម្បីបង្កើនភាពទាក់ទាញដល់ប្រទេសកម្ពុជាជាគោលដៅទេសចរណ៍ម៉ាយ<br>• យុទ្ធនាការ "**ទិញទំនិញ Duty-Free**" នៅកម្ពុជាសម្រាប់ភ្ញៀវទេសចរអន្តរជាតិ | គួរតែជំរុញការទទួលការរៀបចំការប្រជុំសន្និសីទ និងការតាំងពិព័រណ៍ / ការប្រជុំជាអន្តរជាតិទាក់ទងនឹងឧស្សាហកម្មទេសចរណ៍ ដែលមានឥទ្ធិពលសម្រាប់លើកកម្ពស់ព្រះរាជាណាចក្រ។<br>សកម្មភាពនៃការរៀបចំការប្រជុំ គឺជាធាតុសំខាន់នៅក្នុងកំណើនសេដ្ឋកិច្ចពិភពលោកនាពេលអនាគត និងជាពិសេសដោយសារតែកិច្ចប្រជុំតែងតែបាននាំមកនូវប្រភេទភ្ញៀវទេសចរធុរកិច្ចជន ដែលតែងតែចំណាយច្រើនជាងភ្ញៀវទេសចរទូទៅ។<br>រាជធានីភ្នំពេញ និងខេត្តសៀមរាប មានលទ្ធភាពដ៏ល្អឥតខ្ចោះសម្រាប់ភាពជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍អន្តរជាតិធំៗ ជាកម្មវិធីដាច់ដោយឡែក ឬកម្មវិធីសហការរួមគ្នា។ គោលដៅទេសចរណ៍ទាំងពីរ គឺមានសមត្ថភាពគ្រប់គ្រាន់ បើគិតក្នុងផ្នែកសណ្ឋាគារក្នុងកំលុងខែភ្ញៀវតិច ចាប់ពីខែមេសា ដល់ខែតុលា និងជាកន្លែងដែលសមនឹងតម្រូវការទេសចរណ៍បែបម៉ាយ នេះ។ ទន្ទឹមនឹងនេះ កម្ពុជាក៏បានត្រៀមរៀបចំព្រឹត្តិការណ៍ធំៗ នៅឆ្នាំ ២០២២ ដូចជា ASEAN Summit ការរៀបចំវេទិកាទេសចរណ៍អាស៊ាន (ATF) ការរៀបចំសន្និបាតក្លិបឆ្នេរសមុទ្រដែលស្អាតជាងគេបំផុតលើសកលលោក និងការរៀបចំព្រឹត្តិការណ៍ប្រណាំងកង់តំបន់ឆ្នេរជាដើម។ | - ក្រសួងទេសចរណ៍<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |

| | | | | |
|---|---|---|---|---|
| | | | ព្រឹត្តិការណ៍ទេសចរណ៍ម៉ាយនឹងផ្តល់នូវសក្តានុពលខ្លាំងដែលដល់ការអភិវឌ្ឍសេដ្ឋកិច្ចទេសចរណ៍ (មុន និងក្រោយ) ព្រឹត្តិការណ៍។<br>ប៉ុន្តែប្រភេទទេសចរណ៍ម៉ាយ នេះត្រូវការមានការលើកទឹកចិត្តសម្រាប់ការទាក់ទាញក្រុមហ៊ុនរៀបចំកិច្ចប្រជុំ/សន្និសីទអន្តរជាតិនានា ដែលមានសក្តា-នុពល តាមរយៈការឧបត្ថម្ភធន ឬកញ្ចប់បញ្ចុះតម្លៃដែលទាក់ទាញនានាសម្រាប់ការរៀបចំកម្មវិធីលៀងសាយភោជន៍ នៅជាប់តំបន់វប្បធម៌បេតិកភណ្ឌជាដើម តាមរយៈការគាំទ្រ និងសម្របសម្រួលពីអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍។ រីឯភ្ញៀវទេសចរដែលមកទស្សនាអាចមានការលើកទឹកចិត្ត (ពិសេសក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ នេះគួរមានការរៀបចំជាទិដ្ឋាការពិសេសដែលបានស្នើក្នុងដំណាក់កាលទី១)។ | |
| **២.២.៦-** | រៀបចំយុទ្ធសាស្ត្រទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ទៅកាន់ទីផ្សារទេសចរណ៍សំខាន់ៗ តាមប្រព័ន្ធឌីជីថល (E-Reputation) | • បង្កើតយុទ្ធនាការទីផ្សារទេសចរណ៍ឌីជីថលប្រកបដោយភាពច្នៃប្រឌិត និងទំនើបសម្រាប់ទីផ្សារគោលដៅបម្រើឱ្យការស្តារឡើងវិញសម្រាប់រយៈពេលមធ្យម និងវែង<br>• ពង្រឹង និងផ្សព្វផ្សាយគេហទំព័រ និងកម្មវិធីទូរសព្ទរបស់ Visit Cambodia ឱ្យកាន់តែល្អប្រសើរ | ការធ្វើទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍តាមប្រព័ន្ធឌីជីថលដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដែលអាចតាមដានលើការចុចចូលមើល (Track Clicks) និងឈានទៅដល់ការកក់។ ដើម្បីគាំទ្រនូវកិច្ចការងារនេះ គម្រោងពង្រឹងសមត្ថភាពទេសចរណ៍ (TCBP) របស់ទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD) នឹងជួយរៀបចំបច្ចេកទេសបង្កើតយុទ្ធនាការទេសចរណ៍ឌីជីថលនេះ។<br>យុទ្ធនាការឌីជីថល ដែលត្រូវបានរចនាយ៉ាងល្អដោយប្រើវេទិកាទំនាក់ទំនងឌីជីថលជាច្រើន គឺ | - ក្រសួងទេសចរណ៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងព័ត៌មាន<br>- ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទីផ្សារទេសចរណ៍កម្ពុជា |

| | | | | |
|---|---|---|---|---|
| | | | មានប្រសិទ្ធភាពសម្រាប់ទាក់ទាញឱ្យមានការចូលរួម។ ទន្ទឹមនឹងនេះ គួរបង្កើតឱ្យមាន "**ឯកអគ្គរដ្ឋទូតទេសចរណ៍**" ជាតិ និងអន្តរជាតិដែលមានសេចក្តីស្រឡាញ់ចំពោះកម្ពុជា និងវិស័យទេសចរណ៍កម្ពុជា និងលើកទឹកចិត្តពួកគេឱ្យចែករំលែកនូវរឿងរ៉ាវ រូបភាព និងវីដេអូផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថលទាំងអស់នោះ។ ចំណុចសំខាន់ គឺមតិ-យោបល់របស់ភ្ញៀវទេសចរ ដែលផ្តល់សារវិជ្ជមានត្រឡប់មកវិញនឹងក្លាយទៅជា ឧបករណ៍ដែលមានឥទ្ធិពលខ្ពស់ក្នុងការលើកកម្ពស់ភាពជឿទុកចិត្ត និងភាពជឿជាក់របស់ភ្ញៀវទេសចរក្នុងការសម្រេចចិត្តមកទស្សនាកម្ពុជា។ ដូច្នេះ គួរក៏សាងនូវកិត្តិនាមអេឡិចត្រូនិក (E-Reputation) សម្រាប់ទេសចរណ៍កម្ពុជាដែលជាអាទិភាពសម្រាប់ក្រោយវិបត្តិជំងឺកូវីដ-១៩។ | |
| **២.២.៧-** | បន្តសហការជាមួយទីផ្សារទេសចរណ៍ក្នុងតំបន់ និងក្នុងបណ្តាប្រទេសអាស៊ាន និងអាស៊ានបូកបី ក្នុងការអនុវត្តយន្តការ "**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព**" ក្នុងតំបន់ និងការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង | • បន្តសហការជាមួយដៃគូអាស៊ាន និងអាស៊ាន +៣ លើយន្តការគ្រប់គ្រងសុវត្ថិភាព (គម្រោង "**ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព**")<br>• រៀបចំបង្កើតយុទ្ធនាការទីផ្សារគោលដៅទេសចរណ៍សម្រាប់ទីផ្សារអាស៊ាន និងអាស៊ាន +៣<br>• រៀបចំ និងកែសម្រួលយុទ្ធសាស្ត្រសម្រាប់ការចាប់យកទីផ្សារទេសចរណ៍ចិន<br>• ការជំរុញការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯងជាមួយប្រទេសជិតខាង (ថៃ វៀតណាម និងឡាវ) | តំបន់ធ្វើដំណើររួមគ្នាមួយ (Joint Travel Zone) គួរតែត្រូវបានដាក់ឱ្យដំណើរការនៅពេលដែលអាចធានាបាននូវសុវត្ថិភាព និងមានការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ការដឹកជញ្ជូនទេសចរណ៍ និងវិធានផ្សេងទៀតត្រូវបានបង្កើត និងឆ្លើយតបដើម្បីធានាការការពារសុខភាពសាធារណៈ។<br>ប្រទេសកម្ពុជាគួរតែផ្តោតលើការពង្រឹងជំហររបស់ខ្លួនចំពោះទីផ្សារទេសចរណ៍ជាគោលដៅចម្ងាយខ្លី/មធ្យម រួមមាន ចិន ជប៉ុន កូរ៉េ សិង្ហបុរី និងហុងកុង។ល។ ជាមួយនឹងការផ្តល់ជូនដែលមានលក្ខណៈពិពិធកម្មដោយផ្អែកលើសសរស្តម្ភទាំងបួន និងផ្តោតលើ | - ក្រសួងទេសចរណ៍<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទីផ្សារទេសចរណ៍កម្ពុជា |

| | | | | |
|---|---|---|---|---|
| | | | ការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ផ្លូវអាកាសជាមួយគោលដៅទាំងនោះ។ ប្រទេសកម្ពុជាអាចក្លាយជាគោលដៅទេសចរណ៍សម្រាករយៈពេលខ្លីសម្រាប់ទេសចរទាំងនោះ។<br>បច្ចុប្បន្ន ក្រសួងសាធារណការ និងដឹកជញ្ជូនបាននឹងកំពុងរៀបចំសំណើគម្រោង "ការធ្វើឱ្យប្រសើរឡើងនូវច្រកទ្វារព្រំដែនអន្តរជាតិ បាវិត-ម៉ុកបៃ ប៉ោយប៉ែត-អារញ្ញប្រាថេត ស្ទឹងបត់-បាណងអៀន និងព្រៃវល្លិ៍-ប៊ិញហៀប" ដើម្បីសម្រួលបញ្ហាកកស្ទះចរាចរណ៍នៅច្រកព្រំដែនកម្ពុជា-វៀតណាម និងកម្ពុជា-ថៃ ទាំងផ្នែករឹង និងផ្នែកទន់។ គម្រោងនេះ នឹងជួយជំរុញចលនានៃការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង ជាមួយប្រទេសជិតខាង។ | |
| **២.២.៨-** | បន្តជំរុញចលនាទេសចរណ៍ក្នុងស្រុក | • ចលនាឱ្យមានការរៀបចំប្រជុំ និងសន្និសីទនានារបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅតាមរាជធានី-ខេត្ត។<br>• រៀបចំព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗឱ្យកាន់តែមានភាពទាក់ទាញ ដូចជាព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ពិធីបុណ្យសមុទ្រ,បុណ្យទន្លេ។ល។ | ពិនិត្យលទ្ធភាពក្នុងការរៀបចំព្រឹត្តិការណ៍នានា ដែលបានគ្រោងទុកក្នុងផែនការកាលពីដើមឆ្នាំ ២០២០ ជាអាទិ៍ព្រឹត្តិការណ៍កីឡាម៉ារ៉ាតុង អង្គរសង្ក្រាន្ត ព្រឹត្តិការណ៍ Mozart....... ។ | - ក្រសួងទេសចរណ៍ |
| **២.២.៩-** | បង្កើនភាពទាក់ទាញ និងផ្សព្វផ្សាយ "**កម្ពុជាជាគោលដៅទេសចរណ៍កីឡា**" តាមរយៈព្រឹត្តិការណ៍ SEA Game 2023 | • លើកកម្ពស់ការផ្សព្វផ្សាយព្រឹត្តិការណ៍ស៊ីហ្គេម (SEA Game 2023)<br>• លើកកម្ពស់ការផ្សព្វផ្សាយកីឡាផ្សេងៗទៀត | នៅឆ្នាំ២០២៣ ក៏នឹងមាននូវការត្រៀមរៀបចំព្រឹត្តិការណ៍ដ៏សំខាន់បំផុតមួយសម្រាប់កម្ពុជា គឺការទទួលជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ស៊ីហ្គេមលើកទី៣២ ដែលនឹងអាចទាក់ទាញអ្នកទស្សនាបានជាច្រើនផងដែរ។ ដូច្នេះគួរមានការផ្សព្វ ផ្សាយទេសចរណ៍កម្ពុជាគ្រប់មធ្យោបាយ និងគ្រប់រូបភាព ពិសេសការផ្សព្វផ្សាយ | - ក្រសួងទេសចរណ៍<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ស្ថាប័នពាក់ព័ន្ធ<br>- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា |

| | | | | |
|---|---|---|---|---|
| | | | តាមបែបទំនើប ដូចជាការរៀបចំវីឌីអូផ្សព្វផ្សាយ និងឯកសារផ្សព្វផ្សាយទេសចរណ៍កម្ពុជា និងសហការជាមួយក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងអន្តរជាតិដែលធ្វើដំណើរមកកម្ពុជា ដើម្បីដាក់បញ្ចូលវីឌីអូផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍សំខាន់ៗនៅកម្ពុជា ដោយផ្សារភ្ជាប់ជាមួយព្រឹត្តិការណ៍ស៊ីហ្គេម។ | |
| **២.៣- ដាក់ឱ្យអនុវត្តយន្តការអភិបាលកិច្ចទេសចរណ៍ថ្មី** | | | | |
| **២.៣.១-** | ពង្រឹងយន្តការដៃគូរវាងរដ្ឋ-វិស័យឯកជន (PPP) ក្នុងការសិក្សាទីផ្សារ និង ផ្សព្វផ្សាយទេសចរណ៍កម្ពុជា | • ពង្រឹងសមត្ថភាពផ្សព្វផ្សាយទីផ្សារកម្ពុជា | ក្នុងបរិបទក្រោយវិបត្តិជំងឺកូវីដ-១៩ វិស័យទេសចរណ៍ត្រូវការយន្តការសម្រាប់ការសិក្សាទីផ្សារ និងផ្សព្វផ្សាយដែលមានទម្រង់ខ្លីជាងមុនក្រោមទម្រង់ជាអង្គភាពគ្រប់គ្រង និងផ្សព្វផ្សាយគោលដៅទេសចរណ៍ក្រោមកិច្ចសហការភាពជាដៃគូ ដែលមានតួនាទី និងភារៈកិច្ចជាចម្បងសម្រាប់ការធ្វើទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍។ ដើម្បីឆ្លើយតបនឹងវិបត្តិ និងដើម្បីគិតគូរសម្រាប់រយៈពេលវែង ត្រូវបន្តពង្រឹងក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា អមជាមួយការបង្កើតឱ្យមានយន្តការក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា សាលារាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ ដែលទាមទារឱ្យមានការចូលរួមទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ពីផ្នែកឯកជនសំខាន់ៗឱ្យបានខ្លាំងជាងមុន។ | - ក្រសួងទេសចរណ៍<br>- ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទីផ្សារទេសចរណ៍កម្ពុជា |
| **២.៣.២-** | ពង្រឹងសមត្ថភាពសម្រាប់រដ្ឋបាលទំនើបក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ | • សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីផ្លាស់ប្តូរទិន្នន័យសម្រួលដល់ការវិនិយោគ និងអភិវឌ្ឍន៍<br>• ពង្រឹងការផ្តល់សេវាសាធារណៈតាមអនឡាញ | បច្ចុប្បន្ន ការផ្សព្វផ្សាយជាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងជំងឺកូវីដ-១៩ គឺត្រូវបានធ្វើឡើងជាលក្ខណៈផ្ទៃក្នុង (ភាគច្រើនមានតែជា | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | | • រៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបឌីជីថលសម្រាប់គ្រប់គ្រងទេសចរណ៍<br>• បណ្តុះបណ្តាលមន្ត្រី ស្តីពី រដ្ឋបាលឌីជីថល | ភាសាខ្មែរប៉ុណ្ណោះ) ដែលនេះគឺជាភាពទន់ខ្សោយមួយក្នុងការផ្សព្វផ្សាយទៅកាន់អន្តរជាតិ។ ដូច្នេះជាការឆ្លើយតបទៅនឹងវិបត្តិនេះ ត្រូវគិតគូរបង្កើតយន្តការ (Proactive) សម្រាប់ការចែករំលែករឿងរ៉ាវវិជ្ជមានជាច្រើននៅក្នុងប្រទេសកម្ពុជា រឿងរ៉ាវដែលអាចឆ្លុះបញ្ចាំងពីភាពខ្លាំងនៃព្រះរាជាណាចក្រអច្ឆរិយៈ និងបង្កើនភាពទាក់ទាញទេសចរណ៍កម្ពុជា។<br>ក្នុងន័យនេះ កម្ពុជា ទទួលបានលទ្ធផលល្អប្រសើរដោយមានចំនួនអ្នកឆ្លងកូវីដ-១៩ ទាប ហើយមកដល់ពេលនេះ ប្រទេសកម្ពុជានៅមិនទាន់មានអ្នកស្លាប់ដោយសារជំងឺនេះ គឺជារឿងវិជ្ជមាន។ កត្តាវិជ្ជមានទាំងនេះត្រូវតែបង្កើនការផ្សព្វផ្សាយទៅកាន់អន្តរជាតិ ដើម្បីប្រក្លាយរូបភាព “កម្ពុជាគឺជាគោលដៅទេសចរណ៍សុវត្ថិភាព”។ ពិតប្រាកដណាស់ ពិភពលោកកំពុងរស់នៅជាមួយនឹងការគំរាមកំហែងនៃជំងឺកូវីដ-១៩ និងហានិភ័យនៃការឆ្លងមេរោគដែលអាចកើតមានគ្រប់ពេលនោះគោលដៅទេសចរណ៍ដែលមានហានិភ័យទាប និងងក្លាយជាគោលដៅទេសចរណ៍កាន់តែទាក់ទាញ។ ដូច្នេះការផ្តល់ “ព័ត៌មានពិត និងជាក់ស្តែង” ពិតជាមានសារៈសំខាន់ណាស់ ដល់ភ្ញៀវទេសចរ ស្របតាមទស្សនៈ “កសាងការទុកចិត្តងាយនឹងបាត់បង់ - ប៉ុន្តែពិបាកក្នុងការកសាងជំនឿទុកចិត្តឡើងវិញ”។<br>ទន្ទឹមនឹងនេះ ត្រូវបង្កើតក្រុមទំនាក់ទំនងសាធារណៈ ដែលមានជំនាញច្បាស់លាស់ ក្នុងការ | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

| | | | | |
|---|---|---|---|---|
| | | | គ្រប់គ្រង និងផ្សព្វផ្សាយសារតាមបណ្ដាញសារព័ត៌មានទាំងថ្នាក់ជាតិ និងអន្តរជាតិ។ | |
| **២.៣.៣-** | អនុវត្តផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា (២០២១-២០៣៥) និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប មណ្ឌលគិរី និងកែប | • បង្កើនកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់: រដ្ឋ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍដើម្បីជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ជាតិ (២០២១-២០៣៥)<br>• បង្កើនការសហការជាមួយមូលដ្ឋានអាជីវកម្មឯកជន និងអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប មណ្ឌលគិរី និងកែប។<br>• បង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប ដើម្បីឆ្លើយតបនឹងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា (២០២១-២០៣៥) និងផែនការ-មេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប។ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ជាតិ (២០២១-២០៣៥) និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្ត គឺជាឯកសារក្របខ័ណ្ឌផែនការយុទ្ធសាស្ត្ររួម ដែលកំណត់អំពីចក្ខុវិស័យ គោលការណ៍ គោលដៅជាយុទ្ធសាស្ត្រ វិធានការ និងផែនការសំខាន់ៗសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ។<br>ទន្ទឹមនឹងនេះ កិច្ចការដ៏សំខាន់ផងដែរនោះ គឺការបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅតាមខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ។ | - ក្រសួងទេសចរណ៍ |
| **២.៣.៤-** | ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទេសចរណ៍ | • ពង្រឹងកិច្ចសហការទេសចរណ៍ទ្វេភាគី និងពហុភាគី<br>• ពង្រឹងកិច្ចសហការជាមួយអន្តរជាតិ<br>• ពង្រឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយដៃគូអភិវឌ្ឍនានា។ | ដើម្បីឆ្លើយតបនិងដោះស្រាយវិបត្តិជំងឺកូវីដ-១៩ ចាំបាច់ត្រូវពង្រឹង និងបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការកម្រិតទ្វេភាគី ពហុភាគី កម្រិតតំបន់អាស៊ាន, អាស៊ាន+៣ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា។ | - ក្រសួងទេសចរណ៍<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |

# ដំណាក់កាលទី៣: ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា (២០២៤-២០២៥)

- យុទ្ធសាស្ត្រទី១: ជំរុញកំណើនសេដ្ឋកិច្ច និងការងារសមរម្យក្នុងវិស័យទេសចរណ៍
- យុទ្ធសាស្ត្រទី២: ភាពរឹងមាំនៃទេសចរណ៍ក្នុងស្រុក និងពង្រីកទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ
- យុទ្ធសាស្ត្រទី៣: អភិបាលកិច្ចទេសចរណ៍នៅពេលអនាគត
- ផែនការសកម្មភាពសម្រាប់ដំណាក់កាលទី៣: ការរៀបចំឆ្ពោះទៅអនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា (២០២៤-២០២៥)

## ៣- ដំណាក់កាលទី៣ : ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា (២០២៤-២០២៥)

**(៦៨)**. ស្ថានភាពវិស័យទេសចរណ៍កម្ពុជាអាចនឹងត្រឡប់មកភាពដើមវិញនៅក្រោយឆ្នាំ២០២៣ ដែលជាដំណាក់កាលវិស័យទេសចរណ៍គួរចាប់ផ្តើមកសាងនៅអនាគតថ្មីដែលបានដាក់ក្នុងចក្ខុវិស័យ **"ប្រែក្លាយបញ្ហាប្រឈមទៅជាឱកាស"** ឱ្យកាន់តែមានគុណភាព និងនិរន្តរភាពជាងមុន និងឱ្យកាន់តែមានសុវត្ថិភាពខ្ពស់ជាងមុន ដោយត្រូវពង្រឹងសមត្ថភាព គុណភាព និងបង្កើនផលិតភាពក្នុងស្រុកតាមរយៈការជំរុញការបណ្តុះបណ្តាលជំនាញថ្មីៗ និងការចាប់យកបច្ចេកវិទ្យាឌីជីថល។ល។

**(៦៩)**. ទេសចរណ៍កម្ពុជានឹងត្រូវរៀបចំខ្លួនបើកទ្វារទទួលភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិពិសេសគឺការប្រែក្លាយគោលដៅទេសចរណ៍កម្ពុជាជា**គោលដៅទេសចរណ៍ប្រកបដោយគុណភាព**។

ក្នុងន័យនេះ ផែនទីចង្អុលផ្លូវបានស្នើឱ្យដាក់ចេញនូវ**យុទ្ធសាស្ត្រ** ចំនួន **០៣ចំណុច** រួមមាន÷

### ក. យុទ្ធសាស្ត្រទី១: ជំរុញកំណើនសេដ្ឋកិច្ច និងការងារសមរម្យក្នុងវិស័យទេសចរណ៍÷

**(៧០)**. ក្នុង**យុទ្ធសាស្ត្រទី១ នេះ សកម្មភាពយុទ្ធសាស្ត្រចំនួន០៣** ត្រូវបានលើកឡើង រួមមាន÷

១- ជំរុញ និងលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍ឆ្លាតវៃ ឆ្លើយតបនឹងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ ខណៈដែលការស្ទង់មតិមួយនាពេលថ្មីៗនេះ បានបង្ហាញថា÷ ***"៩៤% យល់ស្របពីម្ចាស់អាជីវកម្មក្នុងវិស័យទេសចរណ៍, ៩១% បុគ្គលិកឯកជន និង ៩៧% បុគ្គលិករដ្ឋ យល់ស្របចំពោះ ទស្សនៈវិស័យរបស់អនាគតបច្ចេកវិទ្យានៅកម្ពុជា ជាពិសេសនៅពេលដែលវិបត្តិនៃជំងឺកូវីដ-១៩ ផុតរលត់ទៅបច្ចេកវិទ្យានឹងមានភាពរីកចម្រើន និងតម្រូវការកាន់តែខ្លាំងថែមមួយកម្រិតទៀត"***[12] ។

២- ការធ្វើពិពិធកម្មផលិតផលទេសចរណ៍ថ្មីៗប្រកបដោយភាពទាក់ទាញ និងគុណភាព

៣- ការអនុវត្តបន្តនូវការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ឱ្យស្របតាមទិសដៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍។

### ខ. យុទ្ធសាស្ត្រទី២: ភាពរឹងមាំនៃទេសចរណ៍ក្នុងស្រុក និងពង្រីកទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ÷

**(៧១)**. ក្នុង**យុទ្ធសាស្ត្រទី២ នេះ សកម្មភាពយុទ្ធសាស្ត្រចំនួន០៤** ត្រូវបានលើកឡើង រួមមាន÷

១- ការវិនិយោគបន្តលើយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍នានា

២- ជំរុញទីផ្សារទេសចរណ៍ផ្លូវឆ្ងាយ (Long-haul) មកកាន់កម្ពុជា

៣- ការរៀបចំ និងលើកកម្ពស់ការផ្សព្វផ្សាយព្រឹត្តិការណ៍អន្តរជាតិធំៗ (ព្រឹត្តិការណ៍កីឡាទេសចរណ៍បៃតងព្រមទាំងព្រឹត្តិការណ៍វប្បធម៌)

---

[12] យោងលទ្ធផលនៃការវិភាគលើការស្ទង់មតិ ស្តីពី **"ផលប៉ះពាល់នៃការរីករាលដាលសកលជំងឺកូវីដ-១៩ លើទិដ្ឋភាពបច្ចេកវិទ្យា និងវិស័យសេដ្ឋកិច្ចសង្គម"** របស់មជ្ឈមណ្ឌលកម្ពុជា ៤.០។

៤- ការពង្រឹងចលនាទេសចរណ៍ក្នុងស្រុក ឱ្យមាននិរន្តរភាព។

## គ. យុទ្ធសាស្ត្រទី៣: អភិបាលកិច្ចទេសចរណ៍នៅពេលអនាគត÷

(**៧២**). ក្នុង**យុទ្ធសាស្ត្រទី៣ នេះ សកម្មភាពយុទ្ធសាស្ត្រចំនួន០២** ត្រូវបានលើកឡើង រួមមាន÷

១- ការពង្រឹងអភិបាលកិច្ចសម្រាប់ទ្រទ្រង់វិស័យទេសចរណ៍គ្រប់កម្រិត ដោយបន្តនូវយន្តការអភិបាលកិច្ចថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ (ឆ្ពោះទៅរដ្ឋាភិបាលឌីជីថល) អមជាមួយពង្រឹងយន្តការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ នៅតាមគោលដៅទេសចរណ៍អាទិភាពឱ្យមាននិរន្តរភាព

២- ការរៀបចំយន្តការកសាងភាពធន់ និងឆ្លើយតបបន្ទាន់ទៅនឹងវិបត្តិផ្សេងៗក្នុងវិស័យទេសចរណ៍ ដោយរៀបចំត្រួតពិនិត្យវាយតម្លៃឡើងវិញនៃដំណើរការអនុវត្តនានាក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ និងបង្កើតឱ្យមានផែនការសម្រាប់ការឆ្លើយតប (Crisis Management) ឱ្យកាន់តែប្រសើរឡើងនៅពេលជួបប្រទះនឹងវិបត្តិទៅថ្ងៃអនាគត។

## ផែនការសកម្មភាពអនុវត្តសង្ខេបនៃដំណាក់កាលទី៣ (Relaunch): ការរៀបចំឆ្ពោះទៅអនាគតថ្មី (២០២៤-២០២៥)

| យុទ្ធសាស្ត្រ | ៣.១- ជំរុញកំណើនសេដ្ឋកិច្ច និងការងារសមរម្យក្នុងវិស័យទេសចរណ៍ | ៣.២- ភាពរឹងមាំនៃទេសចរណ៍ក្នុងស្រុក និងពង្រីកទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ (Beyond 2023) | ៣.៣- អភិបាលកិច្ចទេសចរណ៍នៅពេលអនាគត |
|---|---|---|---|
| ដំណាក់កាលទី៣ (Relaunch) (ឆ្នាំ២០២៤ - ឆ្នាំ២០២៥) | ៣.១.១- ជំរុញ និងលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍ឆ្លាតវៃ ឆ្លើយតបនឹងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ | ៣.២.១- ការវិនិយោគបន្តលើយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍នានា | ៣.៣.១- ការពង្រឹងអភិបាលកិច្ចសម្រាប់ទ្រទ្រង់វិស័យទេសចរណ៍គ្រប់កម្រិត ដោយបន្តនូវយន្តការអភិបាលកិច្ចថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ (ឆ្ពោះទៅរដ្ឋាភិបាលឌីជីថល) អមជាមួយពង្រឹងយន្តការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ នៅតាមគោលដៅទេសចរណ៍អាទិភាពឱ្យមាននិរន្តរភាព |
| | ៣.១.២- ការធ្វើពិពិធកម្មផលិតផលទេសចរណ៍ថ្មីៗប្រកបដោយភាពទាក់ទាញ និងគុណភាព | ៣.២.២- ជំរុញទីផ្សារទេសចរណ៍ផ្លូវឆ្ងាយ (Long-haul) មកកាន់កម្ពុជា | ៣.៣.២- ការរៀបចំយន្តការកសាងភាពធន់ និងឆ្លើយតបបន្ទាន់ទៅនឹងវិបត្តិផ្សេងៗក្នុងវិស័យទេសចរណ៍ ដោយរៀបចំត្រួតពិនិត្យវាយតម្លៃឡើងវិញនៃដំណើរការអនុវត្តនានាក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ និងបង្កើតឱ្យមានផែនការសម្រាប់ការឆ្លើយតប (Crisis Management) ឱ្យកាន់តែប្រសើរឡើងនៅពេលជួបប្រទះនឹងវិបត្តិទៅថ្ងៃអនាគត |
| | ៣.១.៣- ការអនុវត្តបន្តនូវការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ឱ្យស្របតាមទិសដៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ | ៣.២.៣- ការរៀបចំ និងលើកកម្ពស់ការផ្សព្វផ្សាយព្រឹត្តិការណ៍អន្តរជាតិធំៗ (ព្រឹត្តិការណ៍កីឡាទេសចរណ៍បៃតង ព្រមទាំងព្រឹត្តិការណ៍វប្បធម៌) | |
| | | ៣.២.៤- ការពង្រឹងចលនាទេសចរណ៍ក្នុងស្រុក ឱ្យមាននិរន្តរភាព | |

# ផែនការសកម្មភាពអនុវត្តលម្អិតនៃដំណាក់កាលទី៣: ការរៀបចំឆ្ពោះទៅអនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា (២០២៤-២០២៥)

| ផែនការសកម្មភាពស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ | | | | |
|---|---|---|---|---|
| **ល.រ.** | **សកម្មភាពយុទ្ធសាស្រ្ត** | **សកម្មភាពយុទ្ធសាស្រ្តលម្អិត** | **ទម្ហីករណ៍** | **អង្គភាពទទួលខុសត្រូវ** |
| **ដំណាក់កាលទី៣ : ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា (២០២៤ - ២០២៥)** | | | | |
| **៣.១- ជំរុញកំណើនសេដ្ឋកិច្ច និងការងារសមរម្យក្នុងវិស័យទេសចរណ៍កម្ពុជា** | | | | |
| **៣.១.១-** | ជំរុញ និងលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍ឆ្លាតវៃ ឆ្លើយតបនឹងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ | • ធ្វើទំនើបកម្មវិធីសាស្រ្តក្នុងការចងក្រងប្រមូលទិន្នន័យដើម្បីឱ្យការអភិវឌ្ឍទេសចរណ៍ផ្សារភ្ជាប់នឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព<br>• រៀបចំគោលដៅទេសចរណ៍សំខាន់ៗ (ជាអាទិ៍ តំបន់អង្គរ តំបន់ភ្នំពេញ តំបន់ក្រុងព្រះសីហនុជាគោលដៅទេសចរណ៍ឆ្លាតវៃ<br>• ជំរុញការធ្វើឌីជីថលរូបនីយកម្ម សម្រាប់សហគ្រាសទេសចរណ៍ | ការធ្វើសមាហរណកម្មនៃបច្ចេកវិទ្យាទំនើបមានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងគំរូថ្មី។ ការប្រើប្រាស់ទស្សនទាន “**ទេសចរណ៍ ៤.០**” នឹងផ្តល់ឱ្យនូវដំណោះស្រាយជាច្រើនគាំទ្រដល់ការអនុវត្តនូវវិធានការស្តារវិស័យទេសចរណ៍ឡើងវិញ។<br>ទេសចរណ៍ ៤.០ នឹងផ្តល់នូវដំណោះស្រាយបច្ចេកវិទ្យា ដើម្បីប្រែក្លាយឧស្សាហកម្មទេសចរណ៍ឱ្យមានការច្នៃប្រឌិតជាងមុន បង្កើនបទពិសោធន៍ល្អៗតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា។<br>ពាក្យថាទេសចរណ៍ ៤.០ មានប្រភពចេញពីយុគសម័យទំនើបកម្មនៅក្នុងបរិបទឧស្សាហកម្ម ៤.០ និងមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវតម្លៃបន្ថែមដល់វិស័យទេសចរណ៍តាមរយៈការច្នៃប្រឌិត ចំណេះ-ដឹង បច្ចេកវិទ្យា និងការបង្កើតថ្មី។ វិធីសាស្រ្តនេះអាចជះឥទ្ធិពលលើគ្រប់វិស័យ។ ចំណេះដឹង ការរំពឹងទុក និងបទពិសោធន៍ល្អៗអាចផ្តល់ឱ្យរបស់ភ្ញៀវទេសចរតាមរយៈការបកស្រាយពន្យល់ដោយប្រើប្រាស់បច្ចេក- | - ក្រសួងទេសចរណ៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្មវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍<br>- មជ្ឈមណ្ឌលកម្ពុជា ៤.០ |

| | | | | |
|---|---|---|---|---|
| | | | វិទ្យា។ ដូច្នេះបច្ចេកវិទ្យាអាចបង្កើននូវសេវាកម្មទេសចរណ៍ថ្មី និងផលិតផលទេសចរណ៍ថ្មីដែលអាចបង្កើនការពេញចិត្តដល់ភ្ញៀវទេសចរ។ | |
| **៣.១.២-** | ការធ្វើពិពិធកម្មផលិតផលទេសចរណ៍ថ្មីៗប្រកបដោយភាពទាក់ទាញ និងគុណភាព | • ពង្រឹង និងពង្រីកផលិតផលទេសចរណ៍ដើម្បីផ្គត់ផ្គង់តាមតម្រូវការទីផ្សារសមស្រប តាមរយៈការធ្វើពិពិធកម្មផលិតផលទេសចរណ៍<br>• អភិវឌ្ឍន៍ផលិតផលទេសចរណ៍តាមតំបន់អាទិភាពនីមួយៗ ដោយកំណត់ប្រភេទសក្តានុពលផលិតផលទេសចរណ៍ និងតាមច្រករបៀងទេសចរណ៍ប្រកបដោយភាពទាក់ទាញ<br>• បង្កើតឱ្យមានតំបន់ទេសចរណ៍ពិសេសនៅប៉ូលទេសចរណ៍អាទិភាព<br>• រៀបចំអភិវឌ្ឍន៍ផលិតផលកសិទេសចរណ៍ ដោយកំណត់ជាខ្សែដំណើរទស្សនកិច្ច នៅតាមភូមិស្រុកដែលមានសក្តានុពល<br>• ជំរុញអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ / អេកូទេសចរណ៍<br>• បន្តជំរុញអភិវឌ្ឍន៍ និងផ្សព្វផ្សាយពីសក្តានុពលក្រុង Secondary Cities បន្ថែម (ស្ទឹងត្រែង និងរតនៈគិរី)<br>• បង្កើនផលិតផល និងព្រឹត្តិការណ៍កីឡា វប្បធម៌ នៅតាមបណ្តារាជធានី-ខេត្ត | ការបង្កើតផលិតផលថ្មីៗ គឺជាកត្តាចាំបាច់ដើម្បីផ្តល់ជម្រើសសម្រាប់ការទស្សនារបស់ភ្ញៀវទេសចរឱ្យបានច្រើន និងក៏ដូចជាចូលរួមដល់ការពន្យារពេលស្នាក់នៅ ការចំណាយរបស់ភ្ញៀវទេសចរឱ្យបានច្រើនចូលរួមជំរុញកំណើនការងារ និងសេដ្ឋកិច្ចកម្ពុជា។ | - ក្រសួងទេសចរណ៍ |
| **៣.១.៣-** | ការអនុវត្តបន្តនូវការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ឱ្យស្របតាមទិសដៅ | • ដាក់ឱ្យដំណើរការសាលាជាតិវិជ្ជាជីវៈនៅប៉ូលទេសចរណ៍អាទិភាព<br>• សហការជាមួយសាកលវិទ្យាល័យ សាលាវិជ្ជាជីវៈ | ក្រសួងទេសចរណ៍បានរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ (២០១៧-២០២៥) ដើម្បីជាផែនទីតម្រង់ទិសក្នុងការ | - ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ | ទេសចរណ៍ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិស័យឯកជនបន្តពង្រឹងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈតាមគ្រប់រូបភាព<br>• ពង្រឹងការប្រើប្រាស់មូលនិធិបណ្តុះបណ្តាល សម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។ | អភិវឌ្ឍ ជំនាញ និងមូលធនមនុស្សក្នុងវិស័យទេសចរណ៍ដោយបានកំណត់ចក្ខុវិស័យច្បាស់លាស់ ព្រមទាំងដាក់ចេញទិសដៅ និងសកម្មភាពជាយុទ្ធសាស្ត្រ សំដៅចូលរួមបង្កើតការងារយូរអង្វែងដល់យុវជនបញ្ចប់ការសិក្សា ផ្តល់ការអភិវឌ្ឍជំនាញបន្ថែមដល់អ្នកកំពុងបម្រើការងារ បង្កើនកាលានុវត្តភាពការងារក្នុង និងក្រៅប្រទេសឱ្យស្របតាមកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន (ASEAN MRA)។ | |
| **៣.២- ភាពរឹងមាំនៃទេសចរណ៍ក្នុងស្រុក និងពង្រីកទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ** | | | | |
| **៣.២.១-** | បន្តវិនិយោគលើយុទ្ធនាការនានាផ្សព្វផ្សាយទេសចរណ៍ | • ក្រសួងទេសចរណ៍ / ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ត្រូវបន្តធ្វើការវិនិយោគទៅក្នុងយុទ្ធនាការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍។<br>• ចូលរួមពិពណ៌ទេសចរណ៍អន្តរជាតិរបស់ទីផ្សារទេសចរណ៍សំខាន់ៗដើម្បីធ្វើការសហការដោយផ្ទាល់ជាមួយក្រុមហ៊ុនធ្វើដំណើរអន្តរជាតិធំៗ<br>• រៀបចំសកម្មភាពផ្សព្វផ្សាយ Roadshows សម្រាប់ទីផ្សារទេសចរណ៍សំខាន់ៗ | នៅពេលដែលមានការបើកដំណើរការនូវច្រកអន្តរជាតិឡើងវិញ ការសិក្សា និងផ្សព្វផ្សាយទេសចរណ៍ដើរតួនាទីសំខាន់ក្នុងការបង្កើនភាពប្រកួតប្រជែងវិស័យទេសចរណ៍។ ដូច្នេះត្រូវពង្រឹងតួនាទីនៃក្រុមប្រឹក្សាភិបាល សិក្សា និងផ្សព្វផ្សាយទេសចរណ៍ និងស្ថានតំណាងទេសចរណ៍នៅក្រៅប្រទេសឱ្យមានប្រសិទ្ធភាពខ្ពស់។<br>រីឯការចូលរួមផ្សព្វផ្សាយនៅពិព័រណ៍នៅពិព័រណ៍ធំៗជាអាទិ៍ ( ITB, WTM,.......) គួរតែត្រូវបានគេយកចិត្តទុកដាក់ និងបង្កើតយុទ្ធសាស្ត្រថ្មី បង្កើតនូវរូបភាពថ្មីដែលល្អ និងទាក់ទាញជាងមុន។ យុទ្ធសាស្ត្រថ្មីនេះគួរផ្តោតសំខាន់លើវប្បធម៌ សកម្មភាពនានាទាក់ទងនឹងម្ហូបអាហារ តន្ត្រី និងប្រពៃណីជាដើម។ | - ក្រសួងទេសចរណ៍<br>- ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ |
| **៣.២.២-** | ជំរុញទីផ្សារទេសចរណ៍ផ្លូវឆ្ងាយ (Long-haul) មកកាន់កម្ពុជា | • ការធ្វើឱ្យប្រសើរឡើងនូវការមកដល់តាមផ្លូវអាកាសនៃប្រទេសកម្ពុជា÷<br>- បង្កើនលទ្ធភាពនៃក្រុមហ៊ុនអាកាសចរណ៍ជាតិ | ភាពងាយស្រួលក្នុងការធ្វើដំណើរ គឺជាការសំរេចចិត្តដ៏សំខាន់មួយសម្រាប់ភ្ញៀវទេសចរដែលធ្វើដំណើររយៈចម្ងាយឆ្ងាយ។ ក្រោយជំងឺកូវីដ-១៩ | - ក្រសួងទេសចរណ៍<br>- ក្រុមហ៊ុនអាកាសចរណ៍ |

| | | | | |
|---|---|---|---|---|
| | | ក្នុងការតភ្ជាប់ការហោះហើរទៅកាន់ទីផ្សារគោលដៅមួយចំនួន<br>- ពង្រឹងលទ្ធភាពនៃការហោះហើរអាកាសចរក្នុងស្រុក ការហោះក្នុងស្រុក និងភ្ជាប់ទៅទីផ្សារក្នុងតំបន់<br>- ពង្រឹង និងពង្រីកការហោះហើរត្រង់ទៅកាន់ទីផ្សារទេសចរណ៍សំខាន់ៗ នៅក្នុងតំបន់ និងផ្តល់លទ្ធភាពក្នុងការបើកជើងហោះហើរជាមួយក្រុមហ៊ុនអាកាសចរ តភ្ជាប់តំបន់សៀមរាប និងខេត្តព្រះសីហនុ។ | (ក្រោយឆ្នាំ២០២៣) ត្រូវបង្កើនភាពទាក់ទាញទេសចរណ៍មកពីផ្លូវឆ្ងាយ (បន្ថែមពីលើភាពទាក់ទាញភ្ញៀវទេសចរតំបន់អាស៊ាន និងអាស៊ានបូកបី)។ | |
| ៣.២.៣- | ការរៀបចំ និងលើកកម្ពស់ការផ្សព្វផ្សាយព្រឹត្តិការណ៍អន្តរជាតិធំៗ (ព្រឹត្តិការណ៍កីឡាទេសចរណ៍បៃតង ព្រមទាំងព្រឹត្តិការណ៍វប្បធម៌) | • បង្កើតព្រឹត្តិការណ៍កីឡាទេសចរណ៍ និងទេសចរណ៍វប្បធម៌<br>• ផ្សព្វផ្សាយព្រឹត្តិការណ៍ និងធ្វើទីផ្សារឱ្យកាន់តែទូលំ-ទូលាយដល់ទីផ្សារអន្តរជាតិ<br>• ផ្តល់ការលើកទឹកចិត្តដើម្បីបង្កើនភាពទាក់ទាញដល់ប្រទេសកម្ពុជាជាគោលដៅទេសចរណ៍សម្រាប់ព្រឹត្តិការណ៍ម៉ាយ | ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាបាននិងកំពុងបង្កើនសមត្ថភាព និងកំណត់ត្រារបស់ខ្លួនក្នុងការរៀបចំព្រឹត្តិការណ៍អន្តរជាតិ និងព្រឹត្តិការណ៍វប្បធម៌សំខាន់ៗ ដូចជាព្រឹត្តិការណ៍រត់ម៉ារ៉ាតុងអង្គរ ព្រឹត្តិការណ៍ប្រណាំងកង់ ព្រឹត្តិការណ៍ Ultra-trails និងការប្រគំតន្ត្រីនានា។ ដោយសារវិបត្តិជំងឺកូវីដ-១៩បានផ្ទុះឡើង ការធ្វើទីផ្សារ និងការផ្សព្វផ្សាយទេសចរណ៍នានាត្រូវបានផ្អាក ការផ្សព្វផ្សាយទៅកាន់ប្រទេសជិតខាង និងមិនត្រូវបានពង្រីកទៅជាការ-ផ្សព្វផ្សាយជាលក្ខណៈអន្តរជាតិ។<br>ការផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍នាពេលអនាគតគួរតែមាននិរន្តរភាព - ប្រទេសកម្ពុជាមានសក្តានុពលដែលមិនគួរឱ្យជឿសម្រាប់ការប្រារព្ធព្រឹត្តិការណ៍កីឡាបែបអេកូ និងសកម្មភាពវប្បធម៌នានានៅក្នុងប្រទេស។ | - ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ<br>- គណៈកម្មាធិការជាតិអូឡាំ-ពិក<br>- វិស័យឯកជន |

| | | | | |
|---|---|---|---|---|
| | | | ទោះបីជាមានការរឹតត្បិតនូវការធ្វើដំណើរតាមផ្លូវអាកាសពីបណ្ដាភ្ញៀវទេសចរអន្តរជាតិ ដោយសារបញ្ហាវិបត្តិជំងឺកូវីដ-១៩ ប៉ុន្តែការចូលរួមពីបណ្ដាភ្ញៀវទេសចរអន្តរជាតិកាន់តែច្រើននឹងនាំមកនូវឱកាសដល់ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់រូបភាពវិជ្ជមានរបស់ប្រទេសកម្ពុជាបានកាន់តែប្រសើរ។ | |
| ៣.២.៤- | ការពង្រឹងចលនាទេសចរណ៍ក្នុងស្រុក ឱ្យមាននិរន្តរភាព | • បន្តជំរុញការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ក្នុងស្រុក និងទេសចរណ៍ផ្ទៃក្នុង<br>• រៀបចំកញ្ចប់ទស្សនកិច្ចក្នុងស្រុក មានការរៀបចំទុកជាមុន និងមានតម្លៃសមរម្យ<br>• បណ្ដាធ្វើដំណើរកម្សាន្តក្នុងស្រុក<br>• លើកកម្ពស់ទេសចរណ៍ក្នុងស្រុក និងទេសចរណ៍ផ្ទៃក្នុងកម្រិតខ្ពស់ | វិស័យទេសចរណ៍ក្នុងស្រុក និងទេសចរណ៍ផ្ទៃក្នុងរំពឹងថានឹងចូលរួមបង្កើតចំណូលចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិ តាមរយៈភ្ញៀវទេសចរជាតិមកកម្សាន្តតំបន់គោលដៅទេសចរណ៍ជនបទ ដែលមិនទាន់អភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ ឬមិនទាន់បានផ្សព្វផ្សាយទូលំទូលាយ។ ទន្ទឹមនឹងនេះ ចលនាទេសចរណ៍ក្នុងស្រុកបានជួយលើកកម្ពស់ការអប់រំដល់សាធារណៈជនឱ្យមានមនសិការស្រឡាញ់ជាតិ ស្របតាមទស្សនទាន **“ស្រឡាញ់ជាតិ ត្រូវស្គាល់ទឹកដី”**។ ចលនាទេសចរក្នុងស្រុកក៏អាចបណ្ដុះ និងបង្កើនសាមគ្គីភាព និងការចេះយកធុរៈគ្នាទៅវិញទៅមក ស្របតាមទស្សនទាននៃចលនាសាមគ្គីសង្គម។ វិស័យទេសចរណ៍ក្នុងស្រុក ពិតជាមានសក្ដានុពលខ្លាំងក្នុងការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា។ | - ក្រសួងទេសចរណ៍<br>- រដ្ឋបាលរាជធានី-ខេត្ត |
| **៣.៣- អភិបាលកិច្ចទេសចរណ៍នៅពេលអនាគត** | | | | |
| ៣.៣.១- | ការពង្រឹងអភិបាលកិច្ចសម្រាប់ទ្រទ្រង់វិស័យទេសចរណ៍គ្រប់កម្រិត ដោយបន្តនូវយន្តការអភិបាលកិច្ចថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ (ឆ្ពោះទៅ | • បន្តពង្រឹងយន្តការអភិបាលកិច្ចថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ (ឆ្ពោះទៅរដ្ឋាភិបាលឌីជីថល)<br>• ពង្រឹងយន្តការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ | យន្តការអភិបាលកិច្ចគឺជាទិសដៅយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ធានានិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍។ កម្ពុជាមានយន្តការទេសចរណ៍ជាច្រើននៅថ្នាក់ជាតិ | - ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| | រដ្ឋាភិបាលឌីជីថល) អមជាមួយពង្រឹងយន្តការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ នៅតាមគោលដៅទេសចរណ៍អាទិភាពឱ្យមាននិរន្តរភាព | នៅតាមគោលដៅទេសចរណ៍អាទិភាពឱ្យមាននិរន្តរភាព<br>• ពង្រីកសមត្ថភាពសហគមន៍ក្នុងឧស្សាហកម្មទេសចរណ៍ឱ្យមានប្រសិទ្ធភាព<br>• ពង្រឹងភាពជាដៃគូ (រដ្ឋ-ឯកជន) ក្នុងវិស័យទេសចរណ៍កម្ពុជា | ថ្នាក់តំបន់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែរដ្ឋបាលថ្នាក់ក្រោមជាតិមិនទាន់មានសកម្មភាពខ្លាំងក្លានៅឡើយ។ ទំនាក់ទំនងរវាងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ពិសេសជាមួយផ្នែកឯកជន និងសមាគមក្នុងវិស័យទេសចរណ៍ទៅលើសកម្មភាពមួយចំនួន គឺខ្លះមានសកម្មភាព ខ្លះគ្មានសកម្មភាព រីឯខ្លះទៀតមិនរលូននិងមិនទាន់ស៊ីចង្វាក់គ្នា ដែលចាំបាច់ត្រូវពង្រឹងភាពជិតស្និតជាមួយអ្នកពាក់ព័ន្ធទាំងឡាយ នៅក្រោមឆត្រនៃកិច្ចសហប្រតិបត្តិការចតុភាគី។<br>ទន្ទឹមនឹងនេះ ក្នុងដំណាក់កាលនេះ អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ នៅតាមតំបន់ទេសចរណ៍សំខាន់ៗ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍នៅតំបន់នោះ ត្រូវការពង្រឹងឱ្យកាន់តែសកម្ម និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីធានាឱ្យបានការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តភាព បរិយាបន្ននៅតាមតំបន់ទេសចរណ៍អទិភាពៗ។ | |
| ៣.៣.២- | ការរៀបចំយន្តការកសាងភាពធន់ និងឆ្លើយតបបន្ទាន់ទៅនឹងវិបត្តិផ្សេងៗក្នុងវិស័យទេសចរណ៍ ដោយរៀបចំត្រួតពិនិត្យវាយតម្លៃឡើងវិញនៃដំណើរការអនុវត្តនានាក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ និងបង្កើតឱ្យមានផែនការសម្រាប់ការឆ្លើយតប និងគ្រប់គ្រងវិបត្តិ ឱ្យកាន់តែប្រសើរឡើងនៅពេលជួបប្រទះនឹងវិបត្តិទៅថ្ងៃអនាគត | • រៀបចំត្រួតពិនិត្យវាយតម្លៃឡើងវិញនៃដំណើរការអនុវត្តនានាក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ និងបន្ទាប់មកត្រូវបង្កើតឱ្យមានផែនការសម្រាប់ការឆ្លើយតប និងគ្រប់គ្រងវិបត្តិ ឱ្យកាន់តែប្រសើរឡើងនៅពេលជួបប្រទះនឹងវិបត្តិទៅថ្ងៃអនាគត | មេរៀនជាច្រើនពីវិបត្តិជំងឺកូវីដ-១៩ នេះពិតជាមានសារៈសំខាន់ ដែលវិស័យទេសចរណ៍កម្ពុជាត្រូវចាប់យកឱកាសនេះរៀបចំឱ្យមានជាផែនការការគ្រប់គ្រងវិបត្តិដ៏មានប្រសិទ្ធភាពសម្រាប់ដោះស្រាយវិបត្តិផ្សេងៗទៀតនាពេលអនាគត។ | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ |

# ជំពូកទី៣

# យន្តការស្ថាប័ន និងគម្រោងកម្មវិធីអាទិភាព (២០២០-២០២៥)

១- រចនាសម្ព័ន្ធនៃយន្តការស្ថាប័ន

២- ភារកិច្ច និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ

៣- គម្រោងកម្មវិធីអាទិភាព (២០២០-២០២៥)

៤- ហិរញ្ញប្បទានគ្រប់គ្រាន់

៥- យន្តការតាមដាន និងត្រួតពិនិត្យ (M&E)

## ជំពូកទី៣ : យន្តការស្ថាប័ន និងគម្រោងកម្មវិធីអាទិភាព (២០២០-២០២៥)

**(៧៣)**. យោងស្មារតីនៃកិច្ចប្រជុំរបស់ក្រសួងទេសចរណ៍ និងគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍ នៃរដ្ឋសភា កាលពី**ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០** ដែលបានលើកឡើងដោយ **ឯកឧត្តម ហ៊ុន ម៉ានី ប្រធានគណៈកម្មការទី៧ នៃរដ្ឋសភា** "ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក៏ដូចជាការស្តារឡើងវិញវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ គឺតម្រូវឱ្យមានការចូលរួម និងកិច្ចសហប្រតិបត្តិការទាំងកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ក្រោមទម្រង់ជាអន្តរវិស័យ អន្តរស្ថាប័ន និងភាពជាដៃគូរវាងរដ្ឋ និងឯកជន [...]" ការអនុវត្តផែនទីចង្អុលផ្លូវនេះ ទាមទារប្រើប្រាស់**អភិក្រមនៃការចូលរួម (Participatory Approach)** តម្រូវឱ្យមានការ **"រួមគិត រួមធ្វើ រួមទទួលខុសត្រូវ"** ពីគ្រប់ភាគីពាក់ព័ន្ធ **"ចតុភាគី (4Ps): រដ្ឋ-ឯកជន-ប្រជាពលរដ្ឋ-ដៃគូអភិវឌ្ឍ"**។

**<u>រូបភាពទី១១: អភិក្រមនៃការចូលរួម (Participatory Approach): រដ្ឋ-ឯកជន-ប្រជាពលរដ្ឋ-ដៃគូអភិវឌ្ឍ</u>**




*ប្រភព : កិច្ចប្រជុំក្រសួងទេសចរណ៍ (ដឹកនាំដោយ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍) និងគណៈកម្មការទី៧ នៃរដ្ឋសភា (ដឹកនាំដោយ ឯកឧត្តម ហ៊ុន ម៉ានី ប្រធានគណៈកម្មការទី៧ នៃរដ្ឋសភា) កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០*

## ១- រចនាសម្ព័ន្ធនៃយន្តការស្ថាប័ន

**(៧៤)**. ដើម្បីអនុវត្ត និងតាមដានផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ផែនទីចង្អុលផ្លូវ ស្នើឱ្យមានរចនាសម្ព័ន្ធមួយជាក្រុមការងារអន្តរស្ថាប័ន ក្រោមទម្រង់ភាពជាដៃគូ (4P) មួយ ដែលមានឈ្មោះថា**ក្រុមការងាររាជរដ្ឋាភិបាល និងឯកជនដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩** ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងទេសចរណ៍ (ដូចមានក្នុងរូបភាពខាងក្រោម)។ ក្រុមការងារនេះស្ថិតក្រោមឆត្ររបស់**គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍** និងត្រូវបង្កើតឡើងដោយ**សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា**។ ក្រុមការងារនេះមានអនុក្រុមការងារ**ចំនួន០៣** រួមមាន÷

**(១)**. អនុក្រុមការងារគាំពារសហគ្រាស និងការងារក្នុងវិស័យទេសចរណ៍

**(២)**. អនុក្រុមការងារជំរុញ និងលើកកម្ពស់ទីផ្សារទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ

**(៣)**. អនុក្រុមការងារពង្រឹងសមត្ថភាព និងអភិបាលកិច្ចទេសចរណ៍។

<u>រូបភាពទី១២: រចនាសម្ព័ន្ធនៃយន្តការស្ថាប័ន÷</u>




## ២- ភារកិច្ច និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ

**(៧៥)**. ដើម្បីស្តារ និងលើកស្ទួយវិស័យកម្ពុជាក្រោយកូវីដ-១៩ ការធានាបាននូវទំនុកចិត្ត និងភាពជឿជាក់ក្នុងគ្រប់ខ្សែសង្វាក់នៃផលិតកម្មក្នុងវិស័យទេសចរណ៍ គឺជាចំណុចគន្លឹះអាទិភាពដោយត្រូវ**គិតពីដើមខ្សែដល់ចុងខ្សែ** និងដោយរាប់គិតចាប់ពីចេញព្រលានយន្តហោះនៃប្រទេសដែលភ្ញៀវទេសចរបានចាកចេញរហូតដល់ព្រលានយន្តហោះរបស់ប្រទេសកម្ពុជា និងបន្តដល់សេវាកម្មស្នាក់នៅ ហូបចុក ធ្វើដំណើរ និងត្រឡប់ទៅប្រទេសខ្លួនវិញ។ សូម

បញ្ជាក់ថា ក្នុងខ្សែចង្វាក់ផលិតកម្មក្នុងវិស័យទេសចរណ៍មានបែងចែកជា**ខ្សែចង្វាក់៣** ក្នុងនោះ **ខ្សែចង្វាក់ទី១.** ការគ្រប់គ្រងច្រកទ្វារអន្តរជាតិប្រកបដោយសុវត្ថិភាព និងងាយស្រួល (ក្រុមហ៊ុនយន្តហោះ និងអាកាសយានដ្ឋាន) **ខ្សែចង្វាក់ទី២.** ការផ្តល់សេវាទេសចរណ៍ប្រកបដោយសុវត្ថិភាពរបស់វិស័យឯកជន (ការីទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន សម្បទាទេសចរណ៍ និងការធ្វើដំណើរ) **និងខ្សែចង្វាក់ទី៣.** ការអនុវត្តក្រមប្រតិបត្តិ និងក្រមសីលធម៌ក្នុងវិស័យទេសចរណ៍ដំណាក់កាលកូវីដ-១៩។

**(៧៦)**. ទន្ទឹមនឹងនេះ ស្ថាប័នរដ្ឋ ឯកជន (បុគ្គលិក និងភ្ញៀវទេសចរទាំងអស់ត្រូវមានការ**ចូលរួមប្រកបដោយការទទួលខុសត្រូវ**ទៅលើការអនុវត្តវិធានសុវត្ថិភាពដែលដាក់ចេញដោយក្រសួងសុខាភិបាល ក៏ដូចជាអង្គការសុខភាពពិភពលោក។

**<u>រូបភាពទី១៣: ការសាងទំនុកចិត្ត និងភាពជឿជាក់ (Trust & Confidence)</u>**




## ក- ខ្សែចង្វាក់ទី១. ការគ្រប់គ្រងច្រកទ្វារអន្តរជាតិប្រកបដោយសុវត្ថិភាព និងភាពងាយស្រួល

### (១.) ច្រកទ្វារអន្តរជាតិផ្លូវអាកាសប្រកបដោយសុវត្ថិភាព

- **កាតព្វកិច្ចនៃក្រុមហ៊ុនអាកាសចរណ៍**
  - អនុវត្តនីតិវិធីត្រួតពិនិត្យសុខភាពស្របតាមការវាយតម្លៃកម្រិតនៃហានិភ័យ។
  - ផ្តល់នូវតារាងកក់សំបុត្រយន្តហោះ កម្មវិធីហោះហើរ និងបញ្ជីអ្នកដំណើរជិះយន្តហោះជាមុនជូនអាជ្ញាធរ សុខាភិបាល និងមានការបែងចែកភារកិច្ច និងការទទួលខុសត្រូវក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅលើយន្តហោះ ដោយអនុវត្តទៅតាមគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់គ្រប់គ្រង និងអនុវត្តការងារនៅក្នុងមណ្ឌលត្រួតពិនិត្យសុខភាពនៅតាមព្រំដែនអាកាសចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ នៅតាមព្រលានយន្ត

ហោះអន្តរជាតិ និងទីកន្លែងពាក់ព័ន្ធនឹងត្រូវធ្វើការផ្សព្វផ្សាយគោលការណ៍ប្រតិបត្តិស្តង់ដានេះផងដែរ។

- ពង្រីក និងបង្កើនការសម្អាតយន្តហោះ និងកាប៊ីន ឱ្យបានញឹកញាប់។
- ផ្តល់របាំងមុខសម្រាប់អ្នកដំណើរ និងនាវិក ហើយត្រូវរក្សាសុវត្ថិភាព និងអនាម័យជាប់ជានិច្ច ក្នុងកំលុងពេលហោះហើរទាំងស្រុង។
- អនុវត្តការឡើង និងចុះពីយន្តហោះតាមវិធីដែលកាត់បន្ថយការប៉ះពាល់ជាមួយនឹងអ្នកដំណើរ ឬនាវិក (ប្រើទ្វារខាងមុខ និងខាងក្រោយ) ដោយគោរពតាមគោលការណ៍រក្សាគម្លាតសង្គម។
- ដាក់កម្រិតការធ្វើចលនារបស់អ្នកដំណើរ និងបុគ្គលិកនៅលើយន្តហោះក្នុងពេលហោះហើរ។
- សម្រួលដល់ការផ្តល់ម្ហូបអាហារ និងនីតិវិធីនានាដែលអាចកាត់បន្ថយការបម្លាស់ទីរបស់បុគ្គលិក និងទំនាក់ទំនងជាមួយអ្នកដំណើរ។
- ជួយសម្រួលដល់អ្នកដំណើរកុំឱ្យអង្គុយនៅក្បែរគ្នា តាមលទ្ធភាពដែលអាចធ្វើទៅបាន។
- ផ្តល់នូវក្រដាសអនាម័យក្នុងជើងហោះហើរដល់អ្នកដំណើរ និងបុគ្គលិក។
- កាត់បន្ថយចំនួនសម្ភារៈនៅក្នុងកាប៊ីន (សម្ភារៈបោះពុម្ព និងវត្ថុអនុស្សាវរីយ៍នានា) និងកំណត់កាបូបយួរដៃជាដើម។

• **អាកាសយានដ្ឋាន (អាកាសយានដ្ឋានប្រទេសដើមរបស់ភ្ញៀវទេសចរ និងអាកាសយានដ្ឋានកម្ពុជា)៖**

- **ការគ្រប់គ្រងច្រកទ្វារផ្លូវអាកាសប្រកបដោយសុវត្ថិភាព និងភាពងាយស្រួល**
  - ~ ធ្វើការរឹតបន្តឹងការត្រួតពិនិត្យសុខភាពនៅតាមច្រកចេញចូលអន្តរជាតិ ដោយរៀនសូត្រពីបទពិសោធន៍ការងារចាត់ចែងគ្រប់គ្រងអ្នកដំណើរ និងដាក់ចេញនូវដំណោះស្រាយលើបញ្ហាមួយចំនួនដូចជាការរកទីកន្លែងសម្រាប់ដាក់ធ្វើចត្តាឡីស័ក ការបង់ថ្លៃស្នាក់នៅ និងចំណីអាហារដោយសាមីអ្នកដំណើរ ក្នុងកំលុងពេលស្នាក់នៅធ្វើចត្តាឡីស័ក តម្រូវការឱ្យមានវិញ្ញាបនបត្រសុខភាពបញ្ជាក់ពីភាពគ្មានកូវីដ-១៩ ចំនួន៧២ម៉ោង មុនថ្ងៃចេញដំណើរ និងការធានា រ៉ាប់រងសុខភាពក្នុងចំនួនទឹកប្រាក់ទៅតាមការកំណត់ (សម្រាប់ជនបរទេស)។
  - ~ ត្រូវពង្រឹងការងារគន្លឹះ**ពីរយ៉ាង: មុនពេលអ្នកដំណើរឡើងយន្តហោះ** និងពេល**អ្នកដំណើរមកដល់ព្រលានយន្តហោះជាចាំបាច់** ដោយមានការចូលរួមពីក្រសួងជំនាញដូចជា (**១**). ការអនុវត្តនូវលក្ខខណ្ឌខាងលើសម្រាប់អ្នកដំណើរ (**២**). រៀបចំយន្តការគ្រប់គ្រងអ្នកដំណើរចូលទៅតាមព្រលានយន្តហោះឱ្យបានហ្មត់ចត់។

- ពិនិត្យឡើងវិញនូវការដាក់ការរឹតបន្តឹង និងពិធីសារធ្វើដំណើរជាប្រចាំដោយប្រើព័ត៌មានល្អៗ ពីអាជ្ញាធរសុខភាពអន្តរជាតិ ដើម្បីធានា និងកាត់បន្ថយការគំរាមកំហែងលើសុខភាពសាធារណៈ និងហានិភ័យក្នុងស្រុក។
- បង្កើនការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការធ្វើដំណើរប្រកបដោយសុវត្ថិភាព រលូន និងគ្មានការប៉ះពាល់។
- ផ្តល់ព័ត៌មានរហ័ស ងាយស្រួលស្វែងរក និងជាប្រចាំ អំពី ព័ត៌មាននៃការរឹតបន្តឹង ការធ្វើដំណើរ និងនិយាមការ (វិធានសុវត្ថិភាពទេសចរណ៍ និងវិធានសុខាភិបាល) ដល់វិស័យឯកជន និងអ្នកដំណើរ។
- សម្របសម្រួលលើគោលនយោបាយ និងវិធានការពាក់ព័ន្ធរវាងក្រសួងទេសចរណ៍ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងសាធារណការ និងដឹកជញ្ជូន។
- ធ្វើការរួមបញ្ចូលនូវលក្ខខណ្ឌតម្រូវ និងវិធានសុវត្ថិភាពទេសចរណ៍ក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ឱ្យស្របនឹងកម្រិតអន្តរជាតិ និងធ្វើការឆ្ពោះទៅរកការបង្កើតកម្មវិធីតាមដានរបស់ភ្ញៀវ។
- កាត់បន្ថយហានិភ័យនានានៅពេលចាកចេញ និងឬ/ពេលចូលក្នុងប្រទេស។

**(២.) ច្រកទ្វារអន្តរជាតិ ផ្លូវគោក និងផ្លូវទឹកប្រកបដោយសុវត្ថិភាព**

- **អ្នកផ្តល់សេវាដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោកត្រូវអនុវត្តតាមវិធានសុវត្ថិភាពទេសចរណ៍** សម្រាប់មធ្យោបាយផ្លូវគោក ដូចជា **សុវត្ថិភាពអនាម័យ នៅទីតាំងចំណត សុវត្ថិភាពអនាម័យក្នុងរថយន្តទេសចរណ៍ សុវត្ថិភាពទេសចរ និងអ្នកដំណើរ និងសុវត្ថិភាពសម្រាប់បុគ្គលិកផ្តល់សេវាកម្ម។**
- អ្នកផ្តល់សេវាដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកត្រូវអនុវត្តតាមវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវទឹក ដូចជា **សុវត្ថិភាពអនាម័យនៅទីតាំងចំណត សុវត្ថិភាពអនាម័យក្នុងកាណូតទេសចរណ៍ សុវត្ថិភាពទេសចរ និងអ្នកដំណើរនិងសុវត្ថិភាពសម្រាប់បុគ្គលិកផ្តល់សេវាកម្ម។**
- រីឯការគ្រប់គ្រងច្រកទ្វារអន្តរជាតិតាមផ្លូវទឹក និងផ្លូវគោកមានលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងដូចគ្នានឹងច្រកទ្វារអន្តរជាតិផ្លូវអាកាសដែរ។

### ខ- ខ្សែចង្វាក់ទី២ . ការផ្តល់សេវាទេសចរណ៍ប្រកបដោយសុវត្ថិភាព គឺជាកត្តាចាំបាច់បំផុត។

**(៧៧)**. ក្នុងដំណាក់កាលទម្លាប់ថ្មី ក្រសួងទេសចរណ៍បានបង្កើត**វិធានសុវត្ថិភាពទេសចរណ៍សំដៅធានាឱ្យបាននូវតុល្យភាពនៃប្រក្រតីភាពនៃសកម្មភាពអាជីវកម្មទេសចរណ៍ និងការធានាបាននូវសុវត្ថិភាពជូនភ្ញៀវទេសចរ បុគ្គលិក និងប្រជាពលរដ្ឋ។**

**(៧៨)**. វិធីសាស្ត្រក្នុងការរៀបចំវិធានសុវត្ថិភាពទេសចរណ៍នេះ ក្រសួងទេសចរណ៍បានបង្កើតនូវឯកសារជាមូលដ្ឋានចំនួន (០២) គឺ (១). ក្រមប្រតិបត្តិ និង (២). គោលការណ៍ណែនាំកំណត់ពីលក្ខខណ្ឌអប្បបរមា។

រូបភាពទី១៤: វិធានសុវត្ថិភាពទេសចរណ៍




*(ប្រភព: អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍)*

**(៧៩)**. ក្រសួងទេសចរណ៍បានអនុវត្តតាមស្មារតីនៃមាត្រាទី៤៨ នៃច្បាប់ស្តីពីទេសចរណ៍ចែងថា "**ប្រតិបត្តិករទេសចរណ៍ រួមទាំងភ្នាក់ងារ និយោជិក និងអ្នកជាប់កិច្ចសន្យាទាំងអស់ ត្រូវមានកាតព្វកិច្ចអនុវត្តតាមច្បាប់ និងបទបញ្ញត្តិជាធរមាន ដែលពាក់ព័ន្ធនឹងស្តង់ដាក្រមប្រតិបត្តិវិជ្ជាជីវៈ និងលក្ខខណ្ឌនានានៃអាជ្ញាបណ្ណទេសចរណ៍**" និងមាត្រាទី៥០ នៃច្បាប់ស្តីពីទេសចរណ៍ចែងថា "**ទេសចរ ឬអ្នកធ្វើដំណើរកម្សាន្តត្រូវមានកាតព្វកិច្ចគោរពច្បាប់ វិធានសុវត្ថិភាពទេសចរណ៍របស់ក្រសួងទេសចរណ៍ និងបទបញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា**"។ តាមការគ្រោងទុកវិធានសុវត្ថិភាពទេសចរណ៍នេះ នឹងដាក់ឱ្យអនុវត្តជា ២ជំហាន ដូចខាងក្រោម÷

## ➢ វិធានសុវត្ថិភាពទេសចរណ៍ក្នុងជំហានទី១

**(៨០)**. ក្នុងនោះ សេវាកម្មដែលបានសម្រេចដាក់អនុវត្តក្នុង**ជំហានទី១** រួមមាន **១.រមណីយដ្ឋានទេសចរណ៍ ២. សហគមន៍ទេសចរណ៍ ៣.ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ៤.សេវាកម្មស្នាក់នៅទេសចរណ៍ ៥.ដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក ៦. ដឹកជញ្ជូនទេសចរណ៍ផ្លូវគោក ៧. ការីទេសចរណ៍ក្នុងស្រុក និង ៨.មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត**។

រូបភាពទី១៥: ឡាបិលសម្គាល់អាជីវកម្មទេសចរណ៍ ក្នុងជំហានទី១÷




*(ប្រភព: ក្រសួងទេសចរណ៍)*

(**៨១**). ដើម្បីវាយតម្លៃសម្រេចផ្តល់ឱ្យ**ឡាបិលវិធានសុវត្ថិភាពទេសចរណ៍**ខាងលើ ក្រសួងទេសចរណ៍បានរៀបចំគោលការណ៍ណែនាំកំណត់អំពីលក្ខខណ្ឌអប្បបរមាដែលមានដូចខាងក្រោម÷

គោលការណ៍ណែនាំវិធានសុវត្ថិភាពទេសចរណ៍ជំហានទី១ រួមមាន÷

- **គោលការណ៍ណែនាំស្តីពី វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ⟶ (លក្ខខណ្ឌតម្រូវ =១៦)**
- **គោលការណ៍ណែនាំស្តីពី វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មដឹកជញ្ជូនទេសចរណ៍ផ្លូវគោក ក្នុងដំណាក់កាលកូវីដ-១៩ ⟶ (លក្ខខណ្ឌតម្រូវ =១៦)**
- **គោលការណ៍ណែនាំស្តីពី វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក ក្នុងដំណាក់កាលកូវីដ-១៩ ⟶ (លក្ខខណ្ឌតម្រូវ =១៦)**
- **គោលការណ៍ណែនាំស្តីពី វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេស-ចរណ៍ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ⟶ (លក្ខខណ្ឌតម្រូវ = ៣០)**
- **គោលការណ៍ណែនាំស្តីពី វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មភោជនីយដ្ឋាន និងអាហារ-ដ្ឋានទេសចរណ៍ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ⟶ (លក្ខខណ្ឌតម្រូវ = ៣០)**
- **គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មទេសចរណ៍ការីទេសចរណ៍ក្នុងស្រុក ⟶ (លក្ខខណ្ឌតម្រូវ =១៧)**
- **គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត ⟶ (កាតព្វកិច្ចអនុវត្ត = ៧)**

### ➢ វិធានសុវត្ថិភាពទេសចរណ៍ (ក្នុងជំហានទី២)÷

(**៨២**). **ក្នុងជំហានទី២** ក្រសួងទេសចរណ៍គ្រោងរៀបចំ**វិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មទេសចរណ៍** រួមមាន **១.កីឡាទេសចរណ៍ ២. សេវាមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (បៀហ្គាឌិន ខារ៉ាអូខេ រង្គសាល និងឌីស្កូតែក) ៣. សេវាកម្មស្ប៉ា និងម៉ាស្សា ៤.សេវាកម្មម៉ាយ បន្ទប់ប្រជុំ ៥. សេវាកម្មព្រឹត្តិការណ៍ទេសចរណ៍ និង ៦.ការីទេសចរណ៍នាំភ្ញៀវចូល។**

<u>រូបភាពទី១៦: ឡាបិលសម្គាល់អាជីវកម្មទេសចរណ៍ ក្នុងជំហានទី២</u>




*(ប្រភព : ក្រសួងទេសចរណ៍)*

## គ. ខ្សែចង្វាក់ទី៣. ការអនុវត្តក្រមប្រតិបត្តិ ក្រមសីលធម៌ក្នុងវិស័យទេសចរណ៍ដំណាក់កាលកូវីដ-១៩។

(៨៣). ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្រ្តបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងវិស័យទេសចរណ៍ ខ្សែចង្វាក់ចុងក្រោយនេះគឺជាការស្នើឱ្យភាគីពាក់ព័ន្ធទាំងអស់ត្រូវចូលរួមប្រកបដោយការទទួលខុសត្រូវ ពោលត្រូវអនុវត្ត**ក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈ** រៀងៗខ្លួន។

**១). ភ្ញៀវទេសចរ:** ត្រូវអនុវត្តតាមក្រមប្រតិបត្តិ និងក្រមសីលធម៌ក្នុងវិស័យទេសចរណ៍។

**ឧទារហណ៍÷**

- ត្រូវសហការផ្តល់ព័ត៌មានដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ដើម្បីចុះឈ្មោះតាម**ប្រព័ន្ធបច្ចេកវិទ្យាចុះបញ្ជីវត្តមានភ្ញៀវទេសចរតាមរយៈ(Telegram BOT)** ដើម្បីផ្តល់ទិន្នន័យ និងដំណើររបស់ខ្លួនដែលអាចឆ្លើយតបទាន់ពេលវេលាក្នុងការគ្រប់គ្រងស្ថានភាពក្នុងដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩
- ត្រូវចុះឈ្មោះលើ**ប្រព័ន្ធចុះបញ្ជីស្នាក់នៅទេសចរណ៍** (www.accommodationrgistrat.net) សម្រាប់ភ្ញៀវទេសចរក្នុងស្រុក និងភ្ញៀវទេសចរអន្តរជាតិ ដើម្បីរក្សាទិន្នន័យរាល់ការស្នាក់នៅរបស់ខ្លួនតាមអាជីវកម្មស្នាក់នៅទេសចរណ៍នីមួយៗ និងក្នុងបញ្ជីប្រព័ន្ធ Telegram BOT សម្រាប់សេវាកម្មផ្សេងៗទៀត។
- ត្រូវចូលរួមអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍នូវ**ប្រការគួរធ្វើ និងមិនគួរធ្វើ (Dos & Don'ts)**
- ត្រូវចូលរួមចាក់វ៉ាក់សាំងកូវីដ-១៩ (Vaccination Passport)។

**២). បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍:** ត្រូវចូលរួមអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដែលក្រសួងបានដាក់ចេញ និងត្រូវអនុវត្តតាមវិធានការផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ ពិសេសបុគ្គលិកបម្រើការងារជួរមុខត្រូវទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ បង្ការការឆ្លងជំងឺកូវីដ-១៩។

**៣). វិស័យឯកជន:** អនុវត្តក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈ ដោយអនុវត្តតាមវិធានសុវត្ថិភាពទេសចរណ៍ និងវិធានការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានដាក់ចេញ។

**៤). ដៃគូអភិវឌ្ឍ:** ដើម្បីចូលរួមស្តារ និងលើកស្ទួយវិស័យកម្ពុជា ត្រូវការចាំបាច់នូវការគាំទ្រពីដៃគូអភិវឌ្ឍនានាសម្រាប់ការអនុវត្តគម្រោងស្តារ និងលើកស្ទួយឡើងវិញនៃវិស័យទេសចរណ៍កម្ពុជា ជាអាទិ៍ UNWTO, PATA, WTTC, AFD, ADB, World Bank, JICA,..។ល។

**៥). កិច្ចសហប្រតិបត្តិការ:** ការពង្រឹងកិច្ចសហប្រតិបត្តិការគ្រប់កម្រិត ទាំងទ្វេភាគី និងពហុភាគីក្នុងវិស័យទេសចរណ៍រវាងកម្ពុជា និងបណ្តាប្រទេសនានាក្នុងតំបន់ និងសកលលោកព្រមជាមួយអង្គការជាតិ និងអន្តរជាតិ។

## ៣- គម្រោងកម្មវិធីអាទិភាព (២០២០-២០២៥)

### ក. គាំពារ និងលើកកម្ពស់ផ្នែកសេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍កម្ពុជា

**គម្រោងទី១:** "ទេសចរណ៍ប្រភេទ **ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព** - Travel Bubble និង One way/Two way Closed-loop Chartered Plane"

**គម្រោងទី២:** "យុទ្ធនាការកម្ពុជា÷ កម្មវិធីអនុវត្តយុទ្ធនាការ "វិធានសុវត្ថិភាពទេសចរណ៍" សម្រាប់ឆ្នាំ (២០២០-២០២៣)"

**គម្រោងទី៣:** "យុទ្ធនាការអក្ខរកម្មឌីជីថល និងជំនាញឌីជីថលក្នុងវិស័យទេសចរណ៍"

**គម្រោងទី៤:** "គម្រោងកាត់បន្ថយភាពផ្ទុះធ្លាយនៃសេដ្ឋកិច្ចពីវិស័យទេសចរណ៍"

**គម្រោងទី៥:** "គម្រោងបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍ (ខេត្តសៀមរាប និងមណ្ឌលគិរី)"

**គម្រោងទី៦:** "គម្រោងរៀបចំបង្កើតគណនីទេសចរណ៍រណប (TSA)"

### ខ. លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា

**គម្រោងទី៧:** "សិក្សាលទ្ធភាពរៀបចំតំបន់បេតិកភណ្ឌអង្គរ: គោលដៅទេសចរណ៍បែបឆ្លាតវៃ-Smart Destination"

**គម្រោងទី៨:** "គម្រោងកែលម្អកំពង់ផែទេសចរណ៍ចុងឃ្នាស"

**គម្រោងទី៩:** "គម្រោងរៀបចំតំបន់ថ្មើរជើងនៅខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ"

**គម្រោងទី១០:** "គម្រោងបង្កើតបណ្ណទេសចរណ៍កម្ពុជា (Cambodia Pass)"

**គម្រោងទី១១:** "គម្រោងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ផ្លូវជាអាទិភាព) និងបញ្ចូលទឹក ភ្លើង លូ និងការគ្រប់គ្រងបរិស្ថាន (ជាពិសេសសម្រាម) ដើម្បីជំរុញដល់ចលនាទេសចរណ៍ក្នុងស្រុកទៅកាន់រមណីយដ្ឋានទេសចរណ៍សំខាន់"

**គម្រោងទី១២:** "ការអភិវឌ្ឍទេសចរណ៍ដែលធ្វើដំណើរដោយខ្លួនឯង (Self-driving Tourism)"

**គម្រោងទី១៣:** "យុទ្ធនាការកម្ពុជាស្អាត: ឆ្ពោះទៅស្វាគមន៍ព្រឹត្តិការណ៍ SEA Game-2023"

**គម្រោងទី១៤:** "ពង្រឹងការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ក្នុងស្រុក និងការបង្កើតមណ្ឌលព័ត៌មានទេសចរណ៍នៅតាមរាជធានី-ខេត្ត"

**គម្រោងទី១៥:** "ឆ្នាំទស្សនាទេសចរណ៍កម្ពុជា (Visit Cambodia Years ២០២២-២០២៣)"

**គម្រោងទី១៦:** "គម្រោងទាក់ទាញទេសចរណ៍ម៉ាយ: កម្ពុជាគោលដៅទេសចរណ៍ម៉ាយ"

### គ. លើកកម្ពស់អភិបាលកិច្ចទេសចរណ៍

**គម្រោងទី១៧:** គម្រោងស្តីពី "គម្រោងកម្មវិធីពង្រឹងសមត្ថភាពក្នុងវិស័យទេសចរណ៍កម្ពុជា (២០២០-២០២៣)"

## ៤- ហិរញ្ញប្បទានទ្រទ្រង់

**(៨៤)**. យើងនឹងស្នើឡើងនូវកញ្ចប់ថវិកាសង្គ្រោះសម្រាប់អនុវត្តគម្រោង និងសកម្មភាពក្នុងការស្តារឡើងវិញនូវវិស័យទេសចរណ៍កម្ពុជា ដែលប្រភពថវិការួមមាន÷

### ក. កញ្ចប់ថវិកាសង្គ្រោះ (Stimulus Packages)

- **គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម (SME's Fund):** គម្រោង ហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ត្រូវបានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីដើមខែមេសា ក្នុងគោលបំណងផ្តល់ឥណទានមានការប្រាក់ទាប ដើម្បីជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព។ មូលនិធិក្រោមគម្រោង ហិរញ្ញប្បទាននេះ មានទំហំទឹកប្រាក់ **១០០លានដុល្លារអាមេរិក** និងមានដៃគូសហការបញ្ចេញប្រាក់កម្ចី គឺគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុចំនួន៣៣ ក្នុងនោះរួមមាន ធនាគារពាណិជ្ជចំនួន២៣ ធនាគារឯកទេសចំនួន៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ចំនួន៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន២។
- **មូលនិធិឥណទាន (Credit Guarantee Fund):** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំបង្កើត **មូលនិធិធានាឥណទាន (Credit Guarantee Fund)** ជាមួយថវិកា **២០០លានដុល្លារអាមេរិក**។ មូលនិធិនេះ អាចធានាឥណទានកម្ចី តាមរយៈធនាគារ និងមីក្រូហិរញ្ញវត្ថុ ដោយប្រើគោលការណ៍ទីផ្សារ ដើម្បីជួយសម្រាលសម្ពាធ រំហូរសាច់ប្រាក់ និងទុនបង្វិលរបស់អាជីវកម្ម-ធុរកិច្ចក្នុងគ្រប់វិស័យ បានយ៉ាងតិចចំនួន **២០០លានដុល្លារអាមេរិក**។
- **កិច្ចគាំទ្រហិរញ្ញប្បទាន (Financing Facility):** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងត្រៀមថវិកាសម្រាប់ហិរញ្ញប្បទានបន្ថែមចំនួន **៣០០លានដុល្លារអាមេរិក** ដើម្បីគាំទ្រ និង ដើរតួជាកាតាលីករជំរុញកំណើនតាមវិស័យសំខាន់ៗ ក្នុងកំលុងពេលវិបត្តិ និងក្រោយពេលវិបត្តិ។

### ខ. កញ្ចប់ថវិកាលើកស្ទួយសម្រាប់វិស័យទេសចរណ៍ (១៧ គម្រោង)

**(៨៥)**. ថវិកាដែលត្រូវអនុវត្តគម្រោងអាទិភាពទាំងអស់ស្របតាមការចាំបាច់នៃគម្រោងនីមួយៗ។

## ៥- យន្តការតាមដាន និងត្រួតពិនិត្យ

**(៨៦)**. **ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃបាន** យើងត្រូវរៀបចំ**យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**ដែលមានសារៈសំខាន់ដល់ការធានាប្រសិទ្ធភាព គណនេយ្យភាព និងសក្តិសិទ្ធភាពនៃការអនុវត្តគម្រោងកម្មវិធីនីមួយៗ ឱ្យស្របតាមកាលកំណត់នីមួយៗ។ ការអនុវត្តផែនទីចង្អុលផ្លូវនេះ ត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃដោយ**គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍**។

## សេចក្តីសន្និដ្ឋាន

**(៨៧)**. ឥទ្ធិពលឬផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ នេះ គឺពិតជាពិបាកក្នុងការធ្វើការវាយតម្លៃ ឱ្យប្រាកដប្រជាណាស់។ កម្ពុជាក៏ដូចជាបណ្តាប្រទេសដទៃទៀតលើសកលលោក បានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺកូវីដ-១៩ នេះចាប់តាំងពីដើមឆ្នាំ២០២០ មកម្ល៉េះ ក្នុងនោះ**វិស័យទេសចរណ៍បានទទួលរងផលប៉ះពាល់ជាអវិជ្ជមានយ៉ាងដំណំពីវិបត្តិនេះ** ដែលត្រូវបានសន្និដ្ឋានថា ឆ្នាំ២០២០ ពិតជានាំមកនូវបញ្ហាប្រឈមយ៉ាងខ្លាំង ដល់វិស័យទេសចរណ៍កម្ពុជាមិនធ្លាប់មានក្នុងរយៈពេល ៣០ឆ្នាំចុងក្រោយនេះ។ ប៉ុន្តែចំណុចនេះក៏បានឆ្លុះបញ្ចាំងឱ្យឃើញអំពីតួនាទីដ៏មានសារៈសំខាន់របស់វិស័យទេសចរណ៍ក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គម ក៏ដូចជាឥទ្ធិពលដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាជាអន្តរវិស័យ ជាមួយបណ្តាវិស័យសេដ្ឋកិច្ចសង្គមសំខាន់ៗដទៃទៀតរបស់ជាតិ។

**(៨៨)**. ដូច្នេះ ការរៀបចំផែនទីចង្អុលផ្លូវ ស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ គឺជាត្រីវិស័យមួយដ៏មានសារៈសំខាន់ និងជាយុទ្ធសាស្ត្រកៀរគរឱ្យគ្រប់ភាគីពាក់ព័ន្ធស្របតាមពាក្យស្លោក “**ទាំងអស់គ្នា រួមគ្នា យើងនឹងឆ្លងផុតគ្រាលំបាកនេះជាមួយគ្នា**” ដើម្បីចូលរួមក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាឡើងវិញ និងជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ឆ្ពោះទៅរកអនាគតថ្មី “**ទម្លាប់ថ្មីនៃទេសចរណ៍**”។

**(៨៩)**. ផែនទីចង្អុលផ្លូវនេះនឹងបន្តជំរុញការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍទេសចរណ៍ឱ្យមានគុណភាព សុវត្ថិភាព និងនិរន្តរភាព និងប្រែក្លាយការគំរាមកំហែងពីជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់ការកែទម្រង់រចនាសម្ព័ន្ធ ក្នុងឧស្សាហកម្មទេសចរណ៍ ឆ្ពោះទៅយន្តការស្ថាប័នរឹងមាំ ឆ្លាតវៃ និងកាន់តែមានប្រសិទ្ធភាពជាងមុន អមជាមួយការដាក់ចេញនូវកម្មវិធីនយោបាយដ៏មុតស្រួចក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា។ ដើម្បីចាប់យកឱកាសនៃវិបត្តិនេះ រាជរដ្ឋាភិបាលកម្ពុជានឹងយកឆ្នាំ២០២១ ជាឆ្នាំគោលក្នុងការកែប្រែកម្ពុជាឱ្យក្លាយទៅជាគោលដៅទេសចរណ៍ដែលមានគុណភាព ស្អាត បៃតង សុវត្ថិភាព និងនិរន្តរភាពដែលជាបច្ច័យគាំទ្រដល់ការលើកកម្ពស់ភាពប្រកួតប្រជែងនៃវិស័យទេសចរណ៍កម្ពុជាក្នុងបរិបទថ្មីព្រមទាំងលើកស្ទួយកិត្យានុភាព“**កម្ពុជា: ព្រះរាជាណាចក្រអច្ឆរិយៈ**” លើឆាកអន្តរជាតិ។

# ឧបសម្ព័ន្ធ

## ១- តារាងគម្រោងកម្មវិធីអាទិភាពសម្រាប់ស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា (២០២០-២០២៥)

## ១.១- គាំពារ និងលើកកម្ពស់សេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍កម្ពុជា

**គម្រោងទី១: គម្រោង “ទេសចរណ៍ប្រភេទ ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព - Travel Bubble និង One way/Two way Closed-loop Chartered Plane”**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: គាំពារ និងលើកកម្ពស់សេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍កម្ពុជា**

<table>
<tr><th>ល.រ.</th><th colspan="2">ចំណងជើងគម្រោង</th><th>ភាគីពាក់ព័ន្ធ</th><th>ប្រភពថវិកា</th><th>អាទិភាពនៃពេលវេលា</th></tr>
<tr><td>គ.១</td><td colspan="2">“ទេសចរណ៍ប្រភេទ ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព - Travel Bubble និង One way/Two way Closed-loop Chartered Plane”</td><td>ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ សេវាកម្មទេសចរណ៍</td><td>រដ្ឋ និងឯកជន</td><td>អាទិភាព១</td></tr>
<tr><th colspan="2">ទីតាំងគម្រោង</th><th>ភ្នាក់ងារអនុវត្តគម្រោង</th><td colspan="3" rowspan="2">វិធីសាស្ត្រនៃការអនុវត្ត÷<br>១- រៀបចំកិច្ចព្រមព្រៀងរវាងកម្ពុជា និងប្រទេសគោលដៅទេសចរណ៍សំខាន់ៗ ដូចជាចិន ជប៉ុន កូរ៉េ ថៃ វៀតណាម និងឡាវ<br>២- ការរៀបចំ Fast Tracking Entry តាមព្រលានយន្តហោះ<br>៣- ការជ្រើសរើសការីទេសចរណ៍ក្នុងស្រុកជាដៃគូជាមួយការីទេសចរណ៍ទីផ្សារគោលដៅ។ល។</td></tr>
<tr><td colspan="2">រាជធានីភ្នំពេញ ខេត្តសៀមរាប តារាសាគរ និងខេត្តព្រះសីហនុ</td><td>• ក្រសួងទេសចរណ៍<br>• ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>• ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>• វិស័យឯកជន</td></tr>
<tr><td colspan="3">សារវិតារ÷<br>គម្រោង “ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព - Travel Bubble និង One way/Two way Closed-loop Chartered Plane”<br>គឺជាទម្រង់នៃការធ្វើដំណើរដែលក្រុមទេសចរមកពីប្រទេសណាមួយដែលអាចគ្រប់គ្រងស្ថានភាពវិបត្តិជំងឺកូវីដ-១៩ បាន។</td><td colspan="3">សមាសភាពអនុវត្តគម្រោង÷<br>១- រៀបចំគោលការណ៍ប្រតិបត្តិស្តង់ដា នៃប្រភេទកញ្ចប់ទេសចរណ៍មកតាម Travel Bubble និង One Way/Two Way Closed-loop Chartered Plane និងបង្កើតតំបន់ទេសចរណ៍សុវត្ថិភាព<br>២- ការអនុវត្តវិធានសុវត្ថិភាពសុខាភិបាល និងសុវត្ថិភាពទេសចរណ៍<br>៣- ការរៀបចំឱ្យមានភាពជឿទុកចិត្ត និងភាពជឿជាក់ ពីដើមខ្សែ រហូតដល់ចុងខ្សែ ពិសេសមានដូចជាកម្មវិធីទូរសព្ទ និងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងភ្ញៀវទេសចរ (Tracking System)។</td></tr>
</table>

<table>
<tr><td>គោលបំណង÷<br>ការបង្កើត គម្រោង “ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព” មានគោលបំណងទាក់ទាញភ្ញៀវទេសចរដោយផ្ទាល់ពីបណ្តាប្រទេសគោលដៅសុវត្ថិភាព ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍ដោយឈរលើគោលការណ៍ កិច្ចព្រមព្រៀងទ្វេភាគី ឬ ត្រីភាគី។</td><td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង÷<br>១- ចូលរួមស្តារវិស័យទេសចរណ៍ និងសេដ្ឋកិច្ចក្នុង និងក្រោយកូវីដ-១៩<br>២- រក្សាការងារ និងប្រាក់ចំណូលរបស់បុគ្គលិកក្នុងវិស័យទេសចរណ៍នៅតំបន់គោលដៅទេសចរណ៍។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និង បរិស្ថាន ប្រសិនបើអនុវត្តបានដោយខ្ជាប់ខ្ជួនតាម (គោលការណ៍ប្រតិបត្តិស្តង់ដា) នៃកញ្ចប់ទស្សនៈកិច្ចមកតាម Travel Bubble។</td><td>រយៈពេល÷<br>គម្រោងអនុវត្តក្នុងរយៈពេលខ្លី (២០២១-២០២២) ដោយក្រសួងទេសចរណ៍សហការជាមួយក្រុមហ៊ុនអាកាសចរណ៍ ប្រតិបត្តិករទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ។</td><td>ថវិកានៃគម្រោង÷<br>គម្រោងនេះប្រើប្រាស់ថវិកាសរុបប្រមាណ ២០ម៉ឺនដុល្លារអាម៉េរិក។</td></tr>
</table>

**គម្រោងទី២: គម្រោងអនុវត្តយុទ្ធនាការ "វិធានសុវត្ថិភាពទេសចរណ៍" សម្រាប់ឆ្នាំ (២០២០-២០២៣)**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: គាំពារ និងលើកកម្ពស់សេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍កម្ពុជា**

<table>
<tr><th>ល.រ</th><th colspan="2">ចំណងជើងគម្រោង</th><th>ភាគីពាក់ព័ន្ធ</th><th>ប្រភពថវិកា</th><th>អាទិភាពនៃពេលវេលា</th></tr>
<tr><td>គ.២</td><td colspan="2">គម្រោងកម្មវិធីអនុវត្តយុទ្ធនាការ "វិធានសុវត្ថិភាពទេសចរណ៍" សម្រាប់ឆ្នាំ (២០២០-២០២៣)</td><td>វិស័យឯកជនក្នុងវិស័យទេសចរណ៍ សហគ្រាសធុនតូច និងមធ្យម សហគមន៍ទេសចរណ៍ ក្រសួងទេសចរណ៍ និងប្រជាពលរដ្ឋមូលដ្ឋាន</td><td>រដ្ឋ និងដៃគូអភិវឌ្ឍ</td><td>អាទិភាព១ និង ២</td></tr>
<tr><td colspan="2">ទីតាំងគម្រោង</td><td>ភ្នាក់ងារអនុវត្តគម្រោង</td><td colspan="3" rowspan="3">វិធីសាស្ត្រនៃការអនុវត្ត÷<br>ឯកសារទ្រទ្រង់ដល់ការអនុវត្ត រួមមាន÷<br>១- ច្បាប់ស្តីពីទេសចរណ៍<br>២- សារាចរណែនាំលេខ ០០៤ សរណន. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ក្នុងដំណាក់កាលទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩<br>៣- សារាចរណែនាំលេខ ០១៣ សរណន. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩<br>៤- ប្រកាសលេខ ០៨១ ប្រក.ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍<br>៥- ប្រកាសលេខ ០៨២ ប្រក.ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក<br>៦- ប្រកាសលេខ ០៨៣ ប្រក.ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក<br>៧- ប្រកាសលេខ ០៨៤ ប្រក.ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មរមណីយដ្ឋានទេសចរណ៍<br>៨- ប្រកាសលេខ ០៨៥ ប្រក.ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍។</td></tr>
<tr><td colspan="2">រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ</td><td>ក្រសួងទេសចរណ៍</td></tr>
<tr><td colspan="3">សាវតារ÷<br>ក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ជនគ្រប់រូបត្រូវបានណែនាំឱ្យអនុវត្តខ្ជាប់ខ្ជួននូវវិធានសុវត្ថិភាពចាំបាច់មួយចំនួន ទាំងនៅក្នុងជីវភាពប្រចាំថ្ងៃ និងសកម្មភាពសេដ្ឋកិច្ច-សង្គម ដូចជាការរក្សាអនាម័យ និងភាពស្អាត រក្សាសុវត្ថិភាពម្ហូបអាហារ និងការរក្សាគម្លាតសុវត្ថិភាព។<br><br>ក្រសួងទេសចរណ៍បានរៀបចំ "គោលការណ៍ណែនាំថ្មី - New Norms/Protocols" មានឈ្មោះថា "វិធានសុវត្ថិភាពទេសចរណ៍" ទាំងសម្រាប់មូលដ្ឋានអាជីវកម្ម ដែលកំពុងដំណើរការ និងមូលដ្ឋានអាជីវកម្មដែលបានផ្អាក ឬបិទទ្វារ នៅពេលមានការអនុញ្ញាតឱ្យបើកដំណើរការឡើងវិញ ទោះបីជាអាចប្រឈមនឹងកត្តាមិនអំណោយផលមួយចំនួន ដូចជា លទ្ធភាពទទួលភ្ញៀវបានចំនួនតិចជាងមុន និងចំណាយប្រតិបត្តិការខ្ពស់ជាងមុនក៏ដោយ ក៏នៅតែត្រូវអនុវត្ត ដើម្បីធានាបាននូវសុវត្ថិភាពសម្រាប់គ្រប់ភាគីពាក់ព័ន្ធ ទាំងភ្ញៀវ និងបុគ្គលិក។</td></tr>
</table>

| | |
|---|---|
| | ៩- ប្រកាសលេខ ០៩៥ ប្រក.ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មការីទេសចរណ៍ក្នុងស្រុក (Domestic Tour Operator)<br>១០- ប្រកាសលេខ ១២៨ ប្រក.ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត |
| **គោលបំណង÷**<br>គម្រោងនេះ មានគោលបំណង ០២ រួមមាន÷<br>**១-** ចូលរួមទប់ស្កាត់ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ លើវិស័យទេសចរណ៍<br>**២-** ចូលរួមបង្កើនចលនាសេដ្ឋកិច្ច តាមរយៈការរក្សាឱ្យអាជីវកម្មទេសចរណ៍នៅតែអាចដំណើរការបានផង និងក៏ដូចជាការបន្តចូលរួមទប់ស្កាត់ និងកាត់បន្ថយហានិភ័យនៃការចម្លងក្នុងមូលដ្ឋានអាជីវកម្មទេសចរណ៍ផង។ | **សមាសភាពអនុវត្តគម្រោង÷**<br>**សមាសភាគទី១: បទដ្ឋានគតិយុត្តគាំទ្រការអនុវត្ត**<br>**១-** ការរៀបចំបង្កើតវិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មនីមួយៗ<br>**២-** ការរៀបចំកែសម្រួលប្រកាស ស្តីពី ការគ្រប់គ្រង និងផ្តល់អាជ្ញាបណ្ណទេសចរណ៍សម្រាប់សេវាកម្មនីមួយៗដោយមានគិតបញ្ចូលនូវអត្ថប្រយោជន៍បន្ថែមសម្រាប់អាជីវកម្មទេសចរណ៍ជាប្រភេទសហគ្រាសធុនតូច និងមធ្យម<br>**៣-** ការរៀបចំបង្កើតនីតិវិធីអនុវត្ត ការពិនិត្យ និងផ្តល់ឡាបិលបញ្ជាក់ការអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍<br>**៤-** ការរៀបចំក្រុមការងារត្រួតពិនិត្យ និងផ្តល់ឡាបិល បញ្ជាក់ថ្នាក់រាជធានី-ខេត្ត<br>**៥-** ការអនុវត្តត្រូវពិនិត្យ តាមដាន និងវាយតម្លៃលទ្ធផលសម្រេចបានជារៀងរាល់ខែ។<br>**សមាសភាគទី២: ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈ**<br>**៦-** ការកសាងសមត្ថភាពសម្រាប់មន្ត្រីបច្ចេកទេស សម្រាប់ការអនុវត្តជាក់ស្តែងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>**៧-** ការផ្សព្វផ្សាយអំពី "**វិធានសុវត្ថិភាពទេសចរណ៍**" ក្នុងទម្រង់ជាវីដេអូខ្លី (១៤ វីដេអូឃ្លីប) អត្ថបទផ្សព្វផ្សាយ ឬកិច្ចសម្ភាសខ្លីៗ តាមទូរទស្សន៍ និងបណ្តាញសង្គម បទយកការណ៍ ដែលឆ្លុះបញ្ចាំងនូវឧទាហរណ៍អំពីការអនុវត្តជាក់ស្តែង បណ្ណផ្សព្វផ្សាយ និងផលិត Spot អប់រំនានា<br>**សមាសភាគទី៣: ការពិនិត្យ និងផ្តល់ឡាបិលបញ្ជាក់**<br>**៨.** ការត្រួតពិនិត្យអាជីវកម្មទេសចរណ៍ទាំងអស់នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ<br>**សមាសភាគទី៤: ការគាំទ្រដោយបច្ចេកវិទ្យា**<br>**៩.** ការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យភ្ញៀវតាមប្រព័ន្ធអនឡាញសម្រាប់សេវាកម្មស្នាក់នៅទេសចរណ៍ www.accommodationregistrat.net<br>**១០.** ការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យភ្ញៀវតាមប្រព័ន្ធ Telegram BOT នៅតាមអាជីវកម្មទេសចរណ៍។ |
| **ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷**<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ដល់សង្គម និងបរិស្ថាន។ | **លទ្ធផលរំពឹងទុកនៃគម្រោង÷**<br>គម្រោងនេះនឹងជំរុញឱ្យគ្រប់មូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់អនុវត្តវិធានសុវត្ថិភាពទេសចរណ៍។ |

| | | |
|---|---|---|
| | **រយៈពេល៖**<br>អនុវត្តគម្រោង**រយៈពេលខ្លី និងមធ្យម (២០២០-២០២៣)** ដោយអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។ | **ថវិកានៃគម្រោង៖**<br>គម្រោងនេះប្រើប្រាស់ថវិកាសរុបប្រមាណ **៤០ម៉ឺនដុល្លារអាមេរិក**។ |

**គម្រោងទី៣: គម្រោង "យុទ្ធនាការអក្ខរកម្មឌីជីថល និងជំនាញឌីជីថលក្នុងវិស័យទេសចរណ៍ (២០២១-២០២៥)"**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: គាំពារ និងលើកកម្ពស់សេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍កម្ពុជា**

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពនៃពេលវេលា |
|---|---|---|---|---|
| គ.៣ | យុទ្ធនាការអក្ខរកម្មឌីជីថល និងជំនាញឌីជីថលក្នុងវិស័យទេសចរណ៍ (២០២១-២០២៥) | ប្រជាពលរដ្ឋ មន្ត្រីរាជការ បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ យុវជន សិស្ស-និស្សិត សាស្ត្រាចារ្យ អ្នកជំនាញ និងសហគមន៍ទេសចរណ៍ | រដ្ឋ និងឯកជន | អាទិភាព១ ២ និង ៣ |

| ទីតាំងគម្រោង | ភ្នាក់ងារអនុវត្តគម្រោង |
|---|---|
| រាជធានី-ខេត្ត | • ក្រសួងទេសចរណ៍<br>• ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>• ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>• មជ្ឈមណ្ឌលម្ពុជា ៤.០<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• វិស័យឯកជន<br>• សហភាពសហព័ន្ធយុវជនកម្ពុជា |

**វិធីសាស្ត្រនៃការអនុវត្ត÷**

ធ្វើយុទ្ធនាការអក្ខរកម្មឌីជីថល និងជំនាញឌីជីថលក្នុងវិស័យទេសចរណ៍ រួមមាន÷

១- កម្មវិធីបណ្តុះបណ្តាល មានដូចជាការបណ្តុះបណ្តាលអចល័ត បណ្តុះបណ្តាលចល័ត បណ្តុះបណ្តាលក្នុងក្រុមហ៊ុន បណ្តុះ-បណ្តាលនៅកន្លែងធ្វើការ អមជាមួយនឹងកម្មវិធីទស្សនកិច្ចសិក្សា និងកម្មសិក្សាតាមក្រុមហ៊ុន

២- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសេវាទូរគមនាគមន៍ និងសេវាអ៊ីនធឺណិតឱ្យមាននៅទីតាំងសាធារណៈ ទីប្រជុំជន ទីតាំងបណ្តុះ-បណ្តាល និងនៅតាមប៉ូលទេសចរណ៍

៣- ពង្រីកការផ្តល់សេវាកម្មអ៊ីនធឺណិតល្បឿនលឿន (Broadband) នៅតាមគោលដៅទេសចរណ៍អាទិភាព

៤- បង្កើតកម្មវិធីបណ្តុះបណ្តាល E-Learning តាមគេហទំព័រ និងកម្មវិធីទូរសព្ទ។ល។

៥- សហការជាមួយស្ថាប័នបណ្តុះបណ្តាលជំនាញឌីជីថល និងដៃគូពាក់ព័ន្ធផ្សេងទៀត។

**សាវតា÷**

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរដ្ឋសភាអណត្តិទី៦ នេះ ក្នុងការត្រៀមលក្ខណៈសម្បត្តិសម្របខ្លួននឹងបដិវត្តន៍ឧស្សាហកម្មទី៤ ខណៈដែលបដិវត្តន៍ឧស្សាហកម្មទី៤ កំពុងបង្ហាញពីការរីកចម្រើននៃបច្ចេកវិទ្យានៅក្នុងពិភពលោក ដែលជះឥទ្ធិពលយ៉ាងខ្លាំងលើការកំណត់ឡើងវិញនូវកត្តាផលិតកម្ម ឥរិយាបថការប្រើប្រាស់ និងរចនាសម្ព័ន្ធសេដ្ឋកិច្ច ដូចជាការប្រើប្រាស់បច្ចេកវិទ្យា បញ្ញា-សិប្បនិមិត្ត (AI) ប្រើប្រាស់មនុស្សយន្ត (Robot) ការបោះពុម្ព 3D។ល។ ដែលបច្ចេកវិទ្យា

**សមាសភាពអនុវត្តគម្រោង÷**

១- បណ្តុះបណ្តាលគ្រូបង្គោល និងជនបង្គោលលើកម្មវិធី និងជំនាញឌីជីថល

២- តម្រូវការរថយន្តសម្រាប់អនុវត្តការបណ្តុះបណ្តាលចល័តតាមរាជធានី-ខេត្តគោលដៅ

៣- ការបណ្តុះបណ្តាលអាចធ្វើឡើងទៅតាមប្រភេទ ឬក្រុមអ្នកសិក្សា ដូចជាកម្មវិធីអក្ខរកម្មឌីជីថលសម្រាប់ប្រជាពលរដ្ឋ មន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុន និងអង្គការ អាជីវករ និស្សិត សិស្ស និងពង្រឹងជំនាញឌីជីថលសម្រាប់អ្នកជំនាញ បច្ចេកវិទ្យា សាស្ត្រាចារ្យ គ្រូបង្រៀន និងអ្នកស្រាវជ្រាវ។ល។

<table>
<tr>
<td>ទាំងនេះ បានធ្វើឱ្យមានការផ្លាស់ប្ដូរយ៉ាងលឿនក្នុងល្បឿនមួយ ដែលមិនធ្លាប់មានពីមុនមកក្នុងវិស័យទេសចរណ៍។<br><br>ដោយឡែក នៅក្នុងវិស័យទេសចរណ៍យើងត្រូវគិតគូរអំពីគំរូអាជីវកម្មប្រភេទថ្មី ដើម្បីសម្របទៅតាមស្ថានភាពសេដ្ឋកិច្ច-សង្គម ជាក់ស្ដែង ដោយក្នុងនោះ ទី១)-អាជីវកម្មអាចអនុវត្តដំណោះស្រាយឌីជីថល តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ និង ទី២)-ត្រូវពង្រឹងសមត្ថភាព និងគុណភាព ពិសេសការបង្កើនផលិតភាព ដើម្បីត្រៀមខ្លួនរួចជាស្រេចសម្រាប់ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ ទីផ្សារកាន់តែរួមចង្អៀត ហើយខ្សែចង្វាក់ផ្គត់ផ្គង់កាន់តែបង្រួមខ្លី។<br><br>ដើម្បីជំរុញ និងលើកស្ទួយវិស័យទេសចរណ៍ក្នុងការស្តារឡើងវិញ និងការរៀបចំឆ្ពោះទៅអនាគតថ្មី ក្រសួងទេសចរណ៍នឹងដាក់ចេញនូវយុទ្ធនាការអក្ខរកម្មឌីជីថល និងយុទ្ធនាការជំនាញឌីជីថល (២០២១-២០២៥)។</td>
<td colspan="2">៤- សិក្ខាសាលា វេទិកា ឬ កម្មវិធីប្រឹក្សាយោបល់ពាក់ព័ន្ធបច្ចេកវិទ្យាឌីជីថល ក៏នឹងត្រូវរៀបចំឡើង ដើម្បីជំរុញការចែករំលែកចំណេះដឹង បទពិសោធន៍ពាក់ព័ន្ធនឹងការប្រើប្រាស់កម្មវិធីឌីជីថល និងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល<br>៥- កម្មវិធីបញ្ជ្រាបការយល់ដឹង និងផ្សព្វផ្សាយអំពីបច្ចេកវិទ្យាឌីជីថលផ្សេងៗតាមគ្រប់មធ្យោបាយ ដូចជា Facebook, Twitter, Youtube ឬ ការបង្ហាញក្នុងពិពណ៌អប់រំ តាមទូរទស្សន៍ ឬបណ្ដាញឌីជីថលផ្សេងៗ<br>៦- រៀបចំកម្មវិធីប្រកួតប្រជែងធុរកិច្ចថ្មីៗ (Startups) ក្នុងវិស័យទេសចរណ៍ និងការផ្តល់មូលនិធិក្នុងការចាប់ផ្តើមអាជីវកម្មថ្មី<br>៧- រៀបចំប្រព័ន្ធសិក្សា និងស្វ័យសិក្សាអក្ខរកម្មឌីជីថល និងជំនាញឌីជីថលអនឡាញ និងប្រព័ន្ធគ្រប់គ្រងការបណ្ដុះបណ្ដាលអក្ខរកម្មឌីជីថល<br>៨- ដាក់ចេញយុទ្ធនាការអក្ខរកម្មឌីជីថល និងជំនាញឌីជីថលក្នុងវិស័យទេសចរណ៍។</td>
</tr>
<tr>
<td>គោលបំណង÷<br>• លើកកម្ពស់សមត្ថភាពឌីជីថលរបស់ប្រជាពលរដ្ឋ បុគ្គលិក មន្ត្រី សហគ្រិន អាជីវករ កម្មករ សិស្ស-និស្សិត និងយុវជនកម្ពុជា ចូលរួមអភិវឌ្ឍន៍កម្ពុជាឆ្ពោះទៅសេដ្ឋកិច្ចឌីជីថល និងគាំទ្រការអនុវត្តរបៀបវារៈនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរដ្ឋសភា<br>• បង្កើនសមត្ថភាព និងផលិតភាពសម្រាប់អាជីវកម្មទេសចរណ៍ ដើម្បីប្រកួតប្រជែងក្នុងបរិបទថ្មី (ក្រោយកូវីដ-១៩)។</td>
<td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង÷<br>១- បង្កើនភាពប្រកួតប្រជែងក្នុងវិស័យទេសចរណ៍<br>២- សមាហរណកម្មវិស័យទេសចរណ៍ក្នុងបរិបទនៃឧស្សាហកម្ម ៤.០<br>៣- បង្កើនសមត្ថភាពឌីជីថលរបស់ប្រជាពលរដ្ឋ មន្ត្រីរាជការ បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ យុវជន-សិស្សនិស្សិត សាស្ត្រាចារ្យ អ្នកជំនាញ និងសហគមន៍ទេសចរណ៍<br>៤- "ឆ្ពោះទៅឆ្នាំ ២០២៥: បុគ្គលិកក្នុងឧស្សាហកម្មទេសចរណ៍ចំនួនប្រមាណ ៤០ម៉ឺននាក់ (៥០% នៃកម្លាំងពលកម្មក្នុងឧស្សាហកម្មទេសចរណ៍) និងទទួលបានការបណ្ដុះបណ្ដាល ជំនាញឌីជីថលយ៉ាងហោចណាស់កម្រិតមូលដ្ឋាន" ក្នុងនោះ÷<br>• ២ម៉ឺននាក់ ឆ្នាំ២០២១<br>• ៨ម៉ឺននាក់ ឆ្នាំ២០២២<br>• ១០ម៉ឺននាក់ ឆ្នាំ២០២៣<br>• ១០ម៉ឺននាក់ ឆ្នាំ២០២៤<br>• ១០ម៉ឺននាក់ ឆ្នាំ២០២៥។</td>
</tr>
<tr>
<td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷<br>គម្រោងនេះជួយកាត់បន្ថយផលប៉ះពាល់វិជ្ជមានដល់ផ្នែកបរិស្ថាន និងសង្គមតាម</td>
<td>រយៈពេល÷</td>
<td>ថវិកានៃគម្រោង÷<br>គម្រោងនេះប្រើប្រាស់ថវិកាប្រមាណ ÷</td>
</tr>
</table>

| | | |
|---|---|---|
| រយៈបង្កើនការយល់ដឹងពីបរិស្ថានដោយប្រើប្រាស់ប្រព័ន្ធឌីជីថល។ | អនុវត្តរយៈពេលខ្លី មធ្យម និងវែង (២០២១-២០២៥) ដោយក្រសួងទេសចរណ៍ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋបាលរាជធានី-ខេត្ត មជ្ឈមណ្ឌលកម្ពុជា ៤.០ សហភាពសហព័ន្ធយុវជនកម្ពុជា និងផ្នែកឯកជន។ | • **៣០ម៉ឺនដុល្លារអាមេរិកនៅឆ្នាំ២០២១**<br>• **១លានដុល្លារអាមេរិកនៅឆ្នាំ២០២២**<br>• **១,៥លានដុល្លារអាមេរិកនៅឆ្នាំ២០២៣**<br>• **១,៥លានដុល្លារអាមេរិកនៅឆ្នាំ២០២៤**<br>• **១,៥លានដុល្លារអាមេរិកនៅឆ្នាំ២០២៥**<br>(បណ្តុះបណ្តាលបុគ្គលិកមួយនាក់ចំណាយ ១៥ដុល្លារ) |

**គម្រោងទី៤: “គម្រោងកាត់បន្ថយភាពខ្លះខ្លាយសេដ្ឋកិច្ចពីវិស័យទេសចរណ៍”**

## តារាងសង្ខេបនៃគម្រោង

## ផ្នែក: គាំពារ និងលើកកម្ពស់សេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍កម្ពុជា

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពនៃពេលវេលា |
|---|---|---|---|---|
| គ.៤ | គម្រោងកាត់បន្ថយភាពខ្លះខ្លាយសេដ្ឋកិច្ចពីវិស័យទេសចរណ៍ | ប្រតិបត្តិករទេសចរណ៍ និងប្រជាពលរដ្ឋមូលដ្ឋាន | រដ្ឋ និងដៃគូអភិវឌ្ឍ | អាទិភាព១ ,២ និង ៣ |

| ទីតាំងគម្រោង | ភ្នាក់ងារអនុវត្តគម្រោង | វិធីសាស្ត្រនៃការអនុវត្ត÷ |
|---|---|---|
| រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ | • ក្រសួងទេសចរណ៍,<br>• ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,<br>• ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍,<br>• ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>• រដ្ឋបាលរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ<br>• សិប្បករ និងកសិករ,<br>• ដៃគូអភិវឌ្ឍ,<br>• ប្រតិបត្តិករទេសចរណ៍ (សណ្ឋាគារ ភោជនីយដ្ឋាន មគ្គុទ្ទេសក៍ទេសចរណ៍ ... ) | ១- បង្កើតអន្តរការីសម្របសម្រួល និងផ្គូរផ្គងរវាងប្រតិបត្តិករទេសចរណ៍ និងអ្នកផលិតក្នុងស្រុក<br>២- បង្កើតបណ្តាញសិប្បករ និងកសិករដែលមានស្នាដៃផ្តើមទទួលបានស្លាកសញ្ញាទេសចរណ៍បៃតង និងច្នៃប្រឌិត<br>៣- បង្កើតឡាបិលប្រើប្រាស់ផលិតផលក្នុងស្រុក (កើ្ត)<br>៤- កំណត់អត្តសញ្ញាណដៃគូសក្តានុពលដែលជាតួអង្គសំខាន់ៗក្នុងគម្រោងនេះ (សហគមន៍ជនបទ អង្គការក្រៅរដ្ឋាភិបាល។ល។)<br>៥- ពង្រីកគម្រោងខ្សែក្រវាត់បៃតង ក្នុងបណ្តាស្រុកផ្សេងៗទៀត<br>៦- បង្កើតថ្នាលឌីជីថលដើម្បីតភ្ជាប់រវាងតម្រូវការ និងការផ្គត់ផ្គង់ផលិតផលក្នុងស្រុក<br>៧- ពិនិត្យតាមដានទីផ្សារតាមរយៈថ្នាលឌីជីថល<br>៨- ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ម៉ាកផលិតផល តាមរយៈការបណ្តុះបណ្តាល ការផ្ទេរបច្ចេកវិទ្យា ការផ្តល់យោបល់ការគាំទ្រកសិករ និងសិប្បករក្នុងសកម្មភាពរបស់ពួកគេ ធានានូវគុណភាពនៃផលិតផល និងសកម្មភាពជួយក្នុងការជំរុញ និងលើកកម្ពស់ម៉ាកផលិតផលក្នុងស្រុក។ល។<br>៩- សកម្មភាពទំនាក់ទំនងនៅថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីអភិវឌ្ឍន៍ម៉ាកផលិតផល ក្នុងនោះត្រូវជំរុញចលនាប្រឡងប្រណាំងរង្វាន់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ដែលមានស្តង់ដាផ្តើមប្រើប្រាស់ផលិតផលក្នុងស្រុក។ |

<table>
<tr>
<td>សាវតារ÷<br>ផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ វិស័យទេសចរណ៍កម្ពុជាត្រូវបានចាត់ទុកថាបានកំពុងដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ការទាញយកផលប្រយោជន៍សេដ្ឋកិច្ច-សង្គមពីវិស័យទេសចរណ៍ នៅមានកម្រិតនៅឡើយ ក្នុងនោះភាពផ្ទុះធ្លាយសេដ្ឋកិច្ចមានក្នុងរង្វង់ប្រមាណ (៣០%-៣៥%) នៅឡើយ។ ផ្ទុយទៅវិញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញមានសក្តានុពលជាច្រើន ដែលអាចរៀបចំ ឬ អភិវឌ្ឍន៍ឡើង ដើម្បីទាញយកផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមពីវិស័យទេសចរណ៍ តាមរយៈការបង្កើតអន្តរសកម្មរវាងវិស័យទេសចរណ៍ កសិកម្ម សិប្បកម្ម និងវត្ថុអនុស្សាវរីយ៍ និងឧស្សាហកម្មច្នៃប្រឌិត។</td>
<td colspan="2">សមាសភាពអនុវត្តគម្រោង÷<br>១- ជំរុញការប្រើប្រាស់ផលិតផលកសិកម្មក្នុងស្រុកបម្រើឱ្យឧស្សាហកម្មទេសចរណ៍កម្ពុជា តាមរយៈការធានាឱ្យមានការផ្គត់ផ្គង់ក្នុងស្រុក ប្រកបដោយគុណភាព ជឿជាក់ និងចីរភាព<br>២- លើកកម្ពស់សិប្បកម្មកែច្នៃ និងឧស្សាហកម្មច្នៃប្រឌិត បម្រើឱ្យវិស័យទេសចរណ៍ (ពិសេសវត្ថុអនុស្សាវរីយ)<br>៣- លើកកម្ពស់វិស័យឧស្សាហកម្មម្ហូបអាហាររបស់ប្រជាពលរដ្ឋមូលដ្ឋានបម្រើឱ្យភ្ញៀវទេសចរ<br>៤- លើកកម្ពស់ការផ្តល់ការស្នាក់នៅតាមផ្ទះប្រជាពលរដ្ឋ និងផ្ទះសហគមន៍<br>៥- បង្កើតឡាបិលគុណភាពសម្រាប់ផលិតផលក្នុងស្រុក (កើរ្តិ៍)<br>៦- ជំរុញចលនាប្រឡងប្រណាំងរង្វាន់ សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ដែលមានស្នាដៃឆ្នើមក្នុងការជំរុញផលិតផលក្នុងស្រុក។</td>
</tr>
<tr>
<td>គោលបំណង÷<br>គម្រោងនេះនឹងបង្កើនអត្ថប្រយោជន៍សេដ្ឋកិច្ច-សង្គមពីវិស័យទេសចរណ៍ឱ្យបានជាអតិបរមា÷<br>• ការបង្កើតខ្សែក្រវាត់បៃតង<br>• ការផ្តល់ផលប្រយោជន៍ដល់ប្រជាជននៅតំបន់ជនបទតាមរយៈឥទ្ធិពលសេដ្ឋកិច្ចពីវិស័យទេសចរណ៍<br>• បង្កើតអន្តរសកម្មរវាងវិស័យទេសចរណ៍ កសិកម្ម សិប្បកម្ម និងវត្ថុអនុស្សាវរីយ៍ និងឧស្សាហកម្មច្នៃប្រឌិត។</td>
<td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង÷<br>១- បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈការប្រកបរបរបម្រើឱ្យភ្ញៀវទេសចរ<br>២- បង្កើនការពេញចិត្តរបស់ភ្ញៀវទេសចរបន្ថែមទៀត តាមរយៈការប្រើប្រាស់ផលិតផលក្នុងស្រុក<br>៣- លើកកម្ពស់ភាពច្នៃប្រឌិត នវានុវត្តន៍ និងឧស្សាហកម្មច្នៃប្រឌិត<br>៤- អភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន ដែលចូលរួមបង្កើនចំណែកនៃឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាប ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។</td>
</tr>
<tr>
<td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td>
<td rowspan="2">រយៈពេល÷<br>អនុវត្តរយៈពេលខ្លី មធ្យម និងវែង (២០២១-២០២៥) ដោយសហការជាមួយប្រតិបត្តិករទេសចរណ៍ សហគមន៍ជនបទ និងដៃគូអភិវឌ្ឍ។</td>
<td rowspan="2">ថវិកានៃគម្រោង÷<br>គម្រោងនេះប្រើប្រាស់ថវិកាសរុបប្រមាណ ១,៥ លានដុល្លារអាម៉េរិក។</td>
</tr>
<tr>
<td>គម្រោងពាក់ព័ន្ធផ្សេងទៀត÷<br>១- ចលនាប្រឡងប្រណាំងរង្វាន់ សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ដែលមានស្នាដៃឆ្នើម ក្នុងការប្រើប្រាស់ផលិតផលក្នុងស្រុក<br>២- គម្រោងខ្សែក្រវាត់បៃតងក្នុងស្រុកបន្ទាយស្រី តំបន់អង្គរ GIZ។ល។</td>
</tr>
</table>

**គម្រោងទី៥: “គម្រោងបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍ (ខេត្តសៀមរាប និងខេត្តមណ្ឌលគិរី)”**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: គាំពារ និងលើកកម្ពស់សេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍កម្ពុជា**

<table>
<tr><th>ល.រ.</th><th colspan="2">ចំណងជើងគម្រោង</th><th>ភាគីពាក់ព័ន្ធ</th><th>ប្រភពថវិកា</th><th>អាទិភាពនៃពេលវេលា</th></tr>
<tr><td>គ.៥</td><td colspan="2">គម្រោងបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍ (ខេត្តសៀមរាប និងខេត្តមណ្ឌលគិរី)</td><td>ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និង ប្រតិបត្តិករទេសចរណ៍</td><td>រដ្ឋ</td><td>អាទិភាព២ និង៣</td></tr>
<tr><th colspan="2">ទីតាំងគម្រោង</th><th>ភ្នាក់ងារអនុវត្តគម្រោង</th><td colspan="3" rowspan="2">វិធីសាស្ត្រនៃការអនុវត្ត៖<br>១- បង្កើតសាលាជាតិបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពខ្ពស់នៅខេត្តសៀមរាប និងមណ្ឌលគិរី<br>២- កំណត់អត្តសញ្ញាណតួអង្គដៃគូសក្តានុពលសម្រាប់ដំណើរការសាលាជាតិវិជ្ជាជីវៈទេសចរណ៍<br>៣- ប៉ាន់ប្រមាណតម្លៃ និងលទ្ធភាពប្រតិបត្តិការរបស់សាលាជាតិវិជ្ជាជីវៈទេសចរណ៍<br>៤- ស្វែងរកដៃគូសហការលើដំណើរការសាលាជាតិវិជ្ជាជីវៈទេសចរណ៍ (ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ)។</td></tr>
<tr><td colspan="2">តំបន់បុរីទេសចរណ៍វប្បធម៌ (ទីក្រុងសៀមរាប) និងខេត្តមណ្ឌលគិរី</td><td>• ក្រសួងទេសចរណ៍<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• សាលាជាតិវិជ្ជាជីវៈទេសចរណ៍</td></tr>
<tr><td colspan="3">សាវតារ៖<br>បច្ចុប្បន្នមានសាលាវិជ្ជាជីវៈទេសចរណ៍ពាក់ព័ន្ធ ដូចជា៖<br>• អង្គការបណ្តុះបណ្តាលបដិសណ្ឋារកិច្ច និងទេសចរណ៍ អេកបក់ (EGBOK)<br>• វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប<br>• សកលវិទ្យាល័យ Southeast Asia ខេត្តសៀមរាប<br>• សាលាសណ្ឋាគារ សាលាបាយ<br>• សាលាសណ្ឋាគារ និងទេសចរណ៍ ប៉ូល ឌុយ ប្រ៊ូល<br>• មជ្ឈមណ្ឌលបណ្តុះបណ្តាល ឡើម<br>• អង្គការដើម្បីភាពញញឹមនៃកុមារ (PSE)<br>ប៉ុន្តែការផ្តល់ការបណ្តុះបណ្តាលដោយមជ្ឈមណ្ឌល/សាលាបណ្តុះបណ្តាលខាងលើមិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាបនៅឡើយ និងពិសេសនៅខេត្តមណ្ឌលគិរីគឺនៅខ្វះខាតសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៅឡើយ។</td><td colspan="3">សមាសភាពអនុវត្តគម្រោង៖<br>អនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ ១៤៨ អនក្រ បក.ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាជាតិវិជ្ជាជីវៈទេសចរណ៍៖<br>១- រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ លើការរៀបចំសាលាជាតិវិជ្ជាជីវៈទេសចរណ៍៖<br>• រៀបចំកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ និងអាស៊ានដែលឆ្លើយតបទៅនឹងតម្រូវការ<br>• កំណត់គំរូសេដ្ឋកិច្ចរបស់សាលា (ថ្លៃសាលាតាមកម្រិត ថវិកាសាធារណៈ សកម្មភាពបង្កើតចំណូល រំហូរប្រចាំឆ្នាំនៃនិស្សិត ចំនួនគ្រូបណ្តុះបណ្តាលដែលត្រូវជ្រើសរើស។ល។) និងកំណត់តម្រូវការថវិកាបន្តបន្ទាប់<br>• រៀបចំអភិបាលកិច្ចរបស់សាលា<br>• ការរៀបចំរចនាអគារ និងបញ្ជីឧបករណ៍ដើម្បីឆ្លើយតបនឹងតម្រូវការបណ្តុះបណ្តាល<br>២- រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង (សាងសង់សាលា) ដោយត្រូវការអនុលោមតាមប្លង់ស្ថាបត្យកម្ម។</td></tr>
</table>

<table>
<tr>
<td>គោលបំណង÷<br>ការបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍មានគោលបំណង÷<br>– សាលាជាតិវិជ្ជាជីវៈទេសចរណ៍ ដើរតួនាទីសំខាន់សម្រាប់ឆ្លើយតបទៅនឹងកំណើនតម្រូវការធនធានមនុស្សនៅក្នុងវិស័យទេសចរណ៍ ជាពិសេសបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពយុវជនកម្ពុជា និងផ្តល់ឱកាសដល់យុវជនកម្ពុជា (ពិសេសយុវជនក្រីក្រ) សម្រាប់កសាងអនាគតរបស់ខ្លួន តាមរយៈការចាប់យកអាជីពជាអ្នកជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងក្នុងប្រទេស និងការបម្លាស់ទីនៅក្នុងតំបន់អាស៊ាន ដែលជាកត្តាមួយចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ<br>– សាលាជាតិវិជ្ជាជីវៈទេសចរណ៍ត្រូវផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាព ស្របតាមស្តង់ដាកម្មវិធីសិក្សា និងក្របខ័ណ្ឌគុណវុឌ្ឍិថ្នាក់ជាតិ និងអាស៊ាន<br>– ផ្តល់ឱកាសឱ្យមានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលមានតម្លៃសមរម្យដល់យុវជន សិស្សនិស្សិតក្រីក្រទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈស្របតាមទស្សនៈ "ការអប់រំសម្រាប់ទាំងអស់គ្នា"<br>– ពង្រឹងការផ្គត់ផ្គង់នូវការបណ្តុះបណ្តាលបច្ចុប្បន្នទាក់ទងនឹងសមត្ថភាព<br>– បង្កើតវគ្គបណ្តុះបណ្តាលថ្មីៗស្របតាមវិជ្ជាជីវៈទេសចរណ៍ក្នុងបរិបទថ្មី<br>– អភិវឌ្ឍន៍ជំនាញក្នុងវិស័យទេសចរណ៍<br>– ពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្នុងគោលបំណងកែលម្អការពេញចិត្តរបស់ភ្ញៀវទេសចរ។</td>
<td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង÷<br>១- ផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាពស្របតាមស្តង់ដាកម្មវិធីសិក្សា និងក្របខ័ណ្ឌគុណវុឌ្ឍិថ្នាក់ជាតិ និងអាស៊ាន និងបង្កើតឱ្យបានធនធានប្រកបដោយសមត្ថភាពជំនាញវិជ្ជាជីវៈទេសចរណ៍ឆ្លើយតបនឹងតម្រូវការភ្ញៀវទេសចរនៅឆ្នាំ ២០៣៥ (ទេសចរណ៍គុណភាព)<br>២- អាចផ្តល់ឱកាសឱ្យយុវជន សិស្ស និស្សិត គ្រប់ស្រទាប់ (រួមទាំងយុវជនក្រីក្រអាចទទួលបានការបណ្តុះបណ្តាលក្នុងតម្លៃសមរម្យ)។</td>
</tr>
<tr>
<td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td>
<td rowspan="2">រយៈពេល÷<br>អនុវត្តរយៈពេលមធ្យម និងវែង (២០២៣-២០២៥) ដោយក្រសួងទេសចរណ៍ និងសាលាជាតិវិជ្ជាជីវៈទេសចរណ៍។</td>
<td rowspan="2">ថវិកានៃគម្រោង÷<br>គម្រោងនេះប្រើប្រាស់ថវិកាសរុបប្រមាណ ១២លានដុល្លារអាម៉េរិក។</td>
</tr>
<tr>
<td>ហេតុផល÷<br>តម្រូវការបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅខេត្តសៀមរាប និងខេត្តមណ្ឌលគីរីនេះ គឺអនុលោមតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២១-២០៣៥) និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគីរី (២០២១-២០៣៥)។</td>
</tr>
</table>

**គម្រោងទី៦: "គម្រោងរៀបចំបង្កើតគណនីទេសចរណ៍រណប (TSA)"**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: គាំពារ និងលើកកម្ពស់សេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍កម្ពុជា**

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពនៃពេលវេលា |
|---|---|---|---|---|
| គ.៦ | **គម្រោងរៀបចំបង្កើតគណនីទេសចរណ៍រណប (TSA)** | ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ សេវាកម្មទេសចរណ៍ ក្រសួងទេសចរណ៍ រដ្ឋបាលរាជធានី-ខេត្ត និងអង្គការដៃគូ | រដ្ឋ | អាទិភាព១ ២ និង ៣ |

| ទីតាំងគម្រោង | ភ្នាក់ងារអនុវត្តគម្រោង | វិធីសាស្ត្រនៃការអនុវត្ត÷ |
|---|---|---|
| រាជធានី-ខេត្ត | • ក្រសួងទេសចរណ៍<br>• សមាគមទេសចរណ៍<br>• ប្រតិបត្តិករទេសចរណ៍<br>• ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១- ក្រសួងទេសចរណ៍ទទួលខុសត្រូវក្នុងការអនុវត្តគម្រោងដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ<br>២- បង្កើតរចនាសម្ព័ន្ធគ្រប់គ្រងគណនីទេសចរណ៍រណប<br>៣- រៀបចំវិធីសាស្ត្រ និងនិតិវិធីអនុវត្តគណនីទេសចរណ៍រណប<br>៤- ដាក់ឱ្យអនុវត្តសកម្មភាពនានានៃគណនីទេសចរណ៍រណប<br>៥- រៀបចំយន្តការគាំទ្រ និងតាមដាន ត្រួតពិនិត្យ។ |

| សាវតារ÷ | សមាសភាពអនុវត្តគម្រោង÷ |
|---|---|
| បច្ចុប្បន្នមានការប្រមូលទិន្នន័យ ស្ថិតិទេសចរណ៍អន្តរជាតិ តាមច្រកទ្វារអន្តរជាតិ អនុវត្តដោយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ប៉ុន្តែសម្រាប់ទេសចរណ៍ក្នុងស្រុក និងទេសចរណ៍ផ្ទៃក្នុង មិនទាន់មានការប្រមូលច្បាស់លាស់នៅឡើយ។ ការប្រមូលទិន្នន័យធ្វើឡើងម្តងម្កាលពេលបុណ្យទានម្តងៗ ដោយមន្ទីរទេសចរណ៍រាជធានី-ខេត្ត ដូចនេះដើម្បីប្រមូលទិន្នន័យច្បាស់លាស់ ត្រូវរៀបចំឱ្យមានការគ្រប់គ្រង និងប្រមូលទិន្នន័យ ដោយមានរចនាសម្ព័ន្ធច្បាស់លាស់ ឱ្យបានទៀងទាត់និងត្រឹមត្រូវ អំពីនិន្នាការទេសចរណ៍ ទិន្នន័យទេសចរណ៍ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍ក្នុងវិស័យទេសចរណ៍។ | ១- ផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសក្នុងការបង្កើត និងអនុវត្តការងាររបស់គណនីទេសចរណ៍រណប<br>២- ធ្វើការពិគ្រោះយោបល់លម្អិតជាមួយអ្នកជំនាញការ និងស្ថាប័នពាក់ព័ន្ធដោយផ្ទាល់ដើម្បីពិនិត្យឡើងវិញនូវស្ថានភាពទេសចរណ៍ និងទិន្នន័យទាក់ទងនឹងទេសចរណ៍នាពេលបច្ចុប្បន្នដែលអាចរកបានសម្រាប់ការចងក្រងប្រព័ន្ធ<br>៣- ផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសក្នុងការបង្កើត និងអនុវត្តការស្ទង់មតិផ្សេងៗ ដែលចាំបាច់ត្រូវធ្វើ ដើម្បីទទួលបានទិន្នន័យបឋមដែលឆ្លើយតបនឹងចន្លោះប្រហោងទិន្នន័យដែលបានកំណត់<br>៤- ផ្តល់ការបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់ដល់អ្នកពាក់ព័ន្ធ និងមន្ត្រី ក្នុងការចងក្រងប្រព័ន្ធទិន្នន័យ ទាំងនេះអាចរួមបញ្ចូលសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការរៀបចំប្រព័ន្ធគណនីទេសចរណ៍រណប<br>៥- រៀបចំវិធីសាស្ត្រផ្សព្វផ្សាយទិន្នន័យស្ថិតិតាមរយៈ ព្រឹត្តិបត្រព័ត៌មានប្រចាំខែ របាយការណ៍ស្ថិតិ ក្រាហ្វិក និង ព័ត៌មានតាមអ៊ីនធឺណិតដើម្បីជួយទាំងវិស័យសាធារណៈ និងឯកជនឱ្យយល់អំពីស្ថានភាពនៃវិស័យទេសចរណ៍។ |

| | | |
|---|---|---|
| | ទស្សនៈនេះបង្ហាញថា ការយល់ដឹងពីទេសចរណ៍ និងសកម្មភាពទេសចរណ៍កាន់តែច្រើន ការគាំទ្រដែលអាចទទួលបានពីរដ្ឋាភិបាលនិងវិស័យឯកជននឹងកើនឡើងដើម្បីផ្តល់មូលនិធិសម្រាប់គោលបំណងស្ថិតិទេសចរណ៍។ | |
| **គោលបំណង÷**<br>ការរៀបបង្កើតគណនីទេសចរណ៍រណប មានគោលបំណង ផ្តល់ព័ត៌មានទេសចរណ៍សំខាន់ៗ និងចាំបាច់ពីភ្ញៀវទេសចរ ផលិតផលទេសចរណ៍ សេវាកម្មទេសចរណ៍ បទពិសោធន៍ និងពិសេសការវិភាគទិន្នន័យទេសចរណ៍ ដើម្បីបង្កើតយុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ និងក៏ដូចជាការផ្តល់ជាមូលដ្ឋានដល់ការសម្រេចចិត្តជម្រើសជាយុទ្ធសាស្ត្រគ្រប់គ្រងវិស័យទេសចរណ៍កម្ពុជាឱ្យមានប្រសិទ្ធភាព។ | **លទ្ធផលរំពឹងទុកនៃគម្រោង÷**<br>**១-** សមត្ថភាពរបស់មន្ត្រី និងបុគ្គលិករបស់គណនីទេសចរណ៍រណប និងអ្នកបច្ចេកទេសពីស្ថាប័នផ្សេងៗសម្រាប់ទទួលខុសត្រូវក្នុងការប្រមូល វិភាគ និងចងក្រងទិន្នន័យបឋមទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ក្នុងវិស័យទេសចរណ៍ដើម្បីកែលម្អ និងពង្រឹងប្រព័ន្ធស្ថិតិទេសចរណ៍ជាតិ<br>**២-** ទទួលបានទិន្នន័យស្ថិតិទេសចរណ៍តាមគោលដៅទេសចរណ៍ជាប្រព័ន្ធ និងជាប្រចាំ សម្រាប់តាមដានការវិវត្តនៃវិស័យទេសចរណ៍គោលដៅ<br>**៣-** ចូលរួមដល់ការសម្រេចចិត្តដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍កម្រិតថ្នាក់ជាតិក្នុងវិស័យទេសចរណ៍។ | |
| **ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷**<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។ | **រយៈពេល÷**<br>អនុវត្ត**រយៈពេលខ្លី មធ្យម និងវែង (២០២១-២០២៤)** ដោយក្រសួងទេសចរណ៍សហការជាមួយស្ថាប័ន-ក្រសួងពាក់ព័ន្ធ។ | **ថវិកានៃគម្រោង÷**<br>គម្រោងនេះប្រើប្រាស់ថវិកាសរុបប្រមាណ **១លានដុល្លារអាម៉េរិក**។ |

## ១.២- លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា

**គម្រោងទី៧: “សិក្សាលទ្ធភាពរៀបចំតំបន់បេតិកភណ្ឌអង្គរ: គោលដៅទេសចរណ៍បែបឆ្លាតវៃ-Smart Destination”**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា**

<table>
<tr><th>ល.រ.</th><th colspan="2">ចំណងជើងគម្រោង</th><th>ភាគីពាក់ព័ន្ធ</th><th>ប្រភពថវិកា</th><th>អាទិភាពនៃពេលវេលា</th></tr>
<tr><td>គ.៧</td><td colspan="2">សិក្សាលទ្ធភាពរៀបចំតំបន់បេតិកភណ្ឌអង្គរ : គោលដៅទេសចរណ៍បែបឆ្លាតវៃ-Smart Destination</td><td>ភ្ញៀវទេសចរ បុគ្គលិកគ្រប់គ្រងនៅតំបន់អង្គរ</td><td>រដ្ឋ</td><td>អាទិភាព១ និង ២</td></tr>
<tr><th>ទីតាំងគម្រោង</th><th>ភ្នាក់ងារអនុវត្តគម្រោង</th><td colspan="4" rowspan="2">វិធីសាស្ត្រនៃការអនុវត្ត÷<br>១- សិក្សារៀបចំសម្បទាទ្រទ្រង់បណ្ដាញ និងប្រព័ន្ធទូរគមនាគមន៍នៅតំបន់អង្គរវត្ត<br>២- ជ្រើសរើសអ្នកផ្គត់ផ្គង់សេវាកម្មបច្ចេកវិទ្យាទំនើបនេះ<br>៣- ដាក់ឱ្យដំណើរការគម្រោងបច្ចេកវិទ្យាផ្សេងៗ និងជំរុញការគ្រប់គ្រង និងផ្ដល់សេវាដល់ភ្ញៀវទេសចរជាក់ស្ដែង ដូចជាការប្រើប្រាស់បច្ចេកវិទ្យាដើម្បីសម្រួលវិហូរភ្ញៀវ និងគ្រប់គ្រងសមត្ថភាពផ្ទុកភ្ញៀវទេសចរមកកាន់ប្រាសាទនីមួយៗ ដែលមានសកម្មភាពអនុវត្តរួមមាន÷<br>• ទិញ ឬជួលគ្រឿងបរិក្ខារ (E-Gate) សម្រាប់គ្រប់គ្រងវិហូរភ្ញៀវនៅតាមប្រាសាទនីមួយៗ<br>• ការបំពាក់មគ្គុទ្ទេសក៍សំឡេងតាមទូរសព្ទដៃឆ្លាត ឬ TABLET ជាភាសាខ្មែរ និងភាសាបរទេសនៅតាមប្រាសាទមួយចំនួន (ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល AR/VR;...)</td></tr>
<tr><td>តំបន់អង្គរ (ខេត្តសៀមរាប)</td><td>• អាជ្ញាធរជាតិអប្សរា<br>• គ្រឹះស្ថានអង្គរ<br>• ក្រសួងទេសចរណ៍<br>• ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍</td></tr>
<tr><td colspan="3">សារៈតារ÷<br>ដើម្បីឱ្យតំបន់អង្គរក្លាយជាគោលដៅទេសចរណ៍បែបឆ្លាតវៃគឺត្រូវចេះកែច្នៃផលិតផលទេសចរណ៍តាមរយៈបច្ចេកវិទ្យា និងដើម្បីទាក់ទាញទេសចរណ៍ថ្មីៗ ជាពិសេសទាក់ទាញទេសចរណ៍ដែលមានស្រាប់ ឱ្យត្រឡប់មកជាលើកទី២ និងបន្តបន្ទាប់ទៀតគឺជាការសំខាន់។ ជាមួយការវិវត្តយ៉ាងលឿនផ្នែកបច្ចេកវិទ្យា បានផ្ដល់ឱកាសដល់ភ្ញៀវទេសចរ ដែលជាអ្នកប្រើប្រាស់សេវាកម្មទេសចរណ៍អាចផ្ដល់នូវការពេញចិត្តភ្លាមៗ និងស្របទៅតាមបុគ្គលិកលក្ខណៈពិសេសរៀងៗខ្លួន ដើម្បីបម្រើសេវាឱ្យទាន់សភាពការណ៍ ព្រោះថាការរីកលូតលាស់</td><td colspan="3">សមាសភាពអនុវត្តគម្រោង÷<br>១- ការរៀបចំដាក់ផ្ទាំងបង្ហាញចំនួនភ្ញៀវទេសចរ (Outdoor Eco-meter LED Display) នៅបរិវេណមុខប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងប្រាសាទតាព្រហ្ម និងកម្មវិធីទូរសព្ទ សម្រាប់ភ្ញៀវទេសចរ<br>២- ការរៀបចំសម្បទាបច្ចេកវិទ្យា ដូចជាការរៀបចំមណ្ឌលព័ត៌មានទេសចរណ៍ (Parvis) សម្រាប់គោលដៅទេសចរណ៍វប្បធម៌ ពិសេសប្រាសាទអង្គរវត្ត និងការស្ថាបនាសារមន្ទីរទំនើបមាន (Virtual Reality Theatre) នៅមណ្ឌលព័ត៌មានទេសចរណ៍ ឬទីតាំងមុនចូលទស្សនាប្រាសាទ</td></tr>
</table>

<table>
<tr><td>នៃបច្ចេកវិទ្យាបានជំរុញឱ្យមានការប្រែប្រួលនៅក្នុងគំរូពាណិជ្ជកម្មក្នុងវិស័យទេសចរណ៍ និងការប្រែប្រួលតម្រូវការរបស់ភ្ញៀវទេសចរ។</td><td colspan="2">៣- ត្រូវបំពាក់ឱ្យមាន (Free Wi-Fi) នៅទីតាំងសាធារណៈមួយចំនួនក្នុងក្រុងសៀមរាប និងតំបន់ទេសចរណ៍បេតិកភណ្ឌអង្គរ និងតាមរមណីយដ្ឋានទេសចរណ៍សំខាន់ៗក្នុងខេត្តសៀមរាប (ក្នុងរយៈពេលខ្លី)<br>៤- ផ្តល់មធ្យោបាយអេឡិចត្រូនិចតាមតម្រូវការចាំបាច់។</td></tr>
<tr><td>គោលបំណង៖<br>• ធ្វើពិពិធកម្ម ផលិតផល និងសេវាកម្មនៅខេត្តសៀមរាប តាមរយៈបច្ចេកវិទ្យាទំនើបៗ<br>• ផ្តល់បទពិសោធន៍ពិសេសប្លែកៗ និងថ្មីៗដល់ភ្ញៀវទេសចរតាមរយៈការពង្រឹងបច្ចេក-វិទ្យា។</td><td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង<br>១- បង្កើនភាពប្រកួតប្រជែងទេសចរណ៍ខេត្តសៀមរាប<br>២- សមាហរណកម្មទេសចរណ៍ខេត្តសៀមរាបក្នុងបរិបទនៃឧស្សាហកម្ម ៤.០ ក្នុងតំបន់អង្គរ<br>៣- បង្កើនសមត្ថភាពនៃការផ្សព្វផ្សាយទេសចរណ៍បែបឌីជីថល។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម៖<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ដល់សង្គម និងបរិស្ថាន។</td><td rowspan="2">រយៈពេល៖<br>អនុវត្តរយៈពេលខ្លី និងមធ្យម(២០២១-២០២៣) ដោយអាជ្ញាធរអប្សរា គ្រឹះស្ថានអង្គរ ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងផ្នែកឯកជន។</td><td rowspan="2">ថវិកានៃគម្រោង៖<br>ថវិកានៃគម្រោងនេះនឹងកំណត់នាពេលក្រោយ។</td></tr>
<tr><td>ផ្សេងៗ៖<br>អាជ្ញាធរអប្សរាកំពុងរៀបចំឱ្យមានអង់តែនទូរសព្ទនៅក្នុងតំបន់ទេសចរណ៍បេតិកភណ្ឌសៀមរាប-អង្គរ។</td></tr>
</table>

**គម្រោងទី៨: "គម្រោងកែលម្អកំពង់ផែទេសចរណ៍ចុងឃ្នាស"**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា**

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពនៃពេលវេលា |
|---|---|---|---|---|
| គ.៨ | គម្រោងកែលម្អកំពង់ផែទេសចរណ៍ចុងឃ្នាស | សហគមន៍ទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរ | រដ្ឋ និងឯកជន | អាទិភាព១ និង ២ |

| ទីតាំងគម្រោង | ភ្នាក់ងារអនុវត្តគម្រោង | វិធីសាស្ត្រនៃការអនុវត្ត÷ |
|---|---|---|
| តំបន់បឹងទន្លេសាប (ខេត្តសៀមរាប) | – គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍<br>– រដ្ឋបាលខេត្តសៀមរាប<br>– ក្រសួងទេសចរណ៍ | ១- រៀបចំកំពង់ផែទេសចរណ៍ចុងឃ្នាសឱ្យស្របតាមស្តង់ដាកំពង់ផែទេសចរណ៍ (ការអភិវឌ្ឍកំពង់ផែទេសចរណ៍នេះត្រូវមានប្លង់មេអភិវឌ្ឍអមជាមួយប្លង់ស្ថាបត្យកម្មលម្អិត)<br>២- បំពាក់ឱ្យមានសម្ភារទេសចរណ៍គាំទ្រដល់កំពង់ផែទេសចរណ៍នេះ ពិសេសរៀបចំឱ្យមានការសម្រាកលំហែភ្ញៀវ និងហូបចុក។ល។<br>៣- បន្ថែមនូវសេវាកម្មទេសចរណ៍ ត្រូវមានផលិតផលទេសចរណ៍ថ្មីៗ (ក្នុងនោះត្រូវការបង្កើតឱ្យមានសារមន្ទីរបឹងទន្លេសាប) |

| សារវតារ÷ | សមាសភាពអនុវត្តគម្រោង÷ |
|---|---|
| បឹងទន្លេសាប ជាបឹងមួយក្នុងចំណោមបឹងទឹកសាបដ៏ធំបំផុតនៅលើពិភពលោក ដែលចំណាយពេលធ្វើដំណើរប្រមាណ ២៥នាទី **(ចម្ងាយ ១៥គ.ម.) ទៅភាគខាងត្បូងនៃខេត្តសៀមរាប។** នៅបឹងទន្លេសាប មានសេវាទូកដឹកភ្ញៀវទេសចរខ្នាតតូច ដែលធ្វើសកម្មភាពដោយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ និងទស្សនាភូមិនេសាទបណ្តែតទឹក។ តំបន់បឹងទន្លេសាបនេះមានសក្តានុពលអេកូទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍កម្រិតខ្ពស់។ បើគិតតាមទស្សនៈ **"អេកូទេសចរណ៍"** តំបន់នេះអាចមានមូលដ្ឋានអភិវឌ្ឍន៍ **"ភូមិទេសចរណ៍ធម្មជាតិ"**។ ចំណុចដ៏ល្អមួយសម្រាប់ការទស្សនាទេសភាពបឹងទន្លេសាប និងតំបន់ជុំវិញ គឺចំណុចកំពូលនៃភ្នំក្រោម។ លើសពីនេះទៅទៀត លើកំពូលភ្នំក្រោម មានប្រាសាទបុរាណដ៏ទាក់ទាញមួយ គឺជាតំបន់ដែលមានប្រវត្តិនៃការសាងសង់ទីតាំង និងរចនាបទល្អឯក ដើម្បីលើកកម្ពស់សោភណភាព និងបង្កើនភាពទាក់ទាញបន្ថែម។ | ១- កែលម្អផែទូកទេសចរណ៍ឱ្យមានភាពងាយស្រួលសម្រាប់ភ្ញៀវទេសចរ និងរៀបចំសណ្តាប់ធ្នាប់នៃទូកស្របតាមស្តង់ដា<br>២- បង្កើតសួនច្បារ (តំបន់បៃតង) នៅកំពង់ផែចុងឃ្នាស<br>៣- រៀបចំអគាររដ្ឋបាលសម្រាប់ធ្វើការងារ និងគ្រប់គ្រងតំបន់ផែទេសចរណ៍<br>៤- បង្កើតភោជនីយដ្ឋានបម្រើឱ្យភ្ញៀវទេសចរ (កម្រិតខ្ពស់ប្រណិត)<br>៥- បង្កើតផ្ទះលំហែកម្រិតខ្ពស់<br>៦- បង្កើតផ្សារសហគមន៍ (ដើម្បីលក់ផលិតផលក្នុងស្រុក និងផ្សាររាត្រី)<br>៧- បង្កើតស្ថានីយប្រេងឥន្ធនៈ<br>៨- បង្កើតសារមន្ទីរទន្លេសាបប្រើប្រាស់បច្ចេកវិទ្យាទំនើបឌីជីថលដែលបញ្ចូលនូវខ្លឹមសារសារមន្ទីរនេសាទ : ដោយការនេសាទ គឺជាសកម្មភាពប្រពៃណីរបស់ប្រជាជនខ្មែរតាំងពីសម័យយូរលង់ណាស់មកហើយ ពោលគឺមានន័យថាត្រីជា |

<table>
<tr>
<td colspan="1"></td>
<td colspan="2">ប្រភពអាហារចម្បង។ ក្នុងន័យនេះ ការបង្ហាញអំពីបច្ចេកទេសនេសាទផ្សេងៗ គ្នា អាចផ្តល់បទពិសោធន៍ថ្មីៗសម្រាប់ភ្ញៀវទេសចរអន្តរជាតិ។ល។<br>៩- បង្កើតមណ្ឌលព័ត៌មានទេសចរណ៍<br>១០- បង្កើតហាងកាហ្វេ<br>១១- បង្កើតចំណតរ៉ឺម៉កកង់បី ម៉ូតូ កង់ ចំណតរថយន្តលក្ខណៈគ្រួសារ និងចំណតរថយន្តក្រុង។<br>១២- ពង្រឹងសេវាកម្មទូកទេសចរណ៍ឱ្យស្របតាមស្តង់ដាទូកទេសចរណ៍។ល។</td>
</tr>
<tr>
<td>គោលបំណង÷<br>ការកែលម្អកំពង់ផែទេសចរណ៍ភ្នំក្រោម (ចុងឃ្នាស) មានគោលបំណង÷<br>– ធ្វើពិពិធកម្មផលិតផលទេសចរណ៍ដើម្បីបង្កើនរយៈពេលស្នាក់នៅយូរជាងមុន (យ៉ាងហោចបន្ថែមឱ្យបាន ១ ថ្ងៃ ធៀបក្នុងពេលបច្ចុប្បន្ន)<br>– លើកកម្ពស់ទន្លេសាបជាតំបន់ទេសចរណ៍ធម្មជាតិដ៏ទាក់ទាញ<br>– គ្រប់គ្រងវិហ្វូរទេសចរណ៍ក្នុងតំបន់ទន្លេសាបដោយប្រែក្លាយជាមេដែក ទាញទៅកាន់គោលដៅទេសចរណ៍/ សហគមន៍ទេសចរណ៍ផ្សេងៗទៀតនៅក្នុងតំបន់បឹងទន្លេសាប<br>– អភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ។</td>
<td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង÷<br>១- អាចពន្យារការស្នាក់នៅរបស់ភ្ញៀវទេសចរ តាមរយៈការបង្កើតខ្សែទស្សនាចរផ្លូវទឹក ដោយប្រើប្រាស់បឹងទន្លេសាប (កំពង់ផែទេសចរណ៍ចុងឃ្នាស) ជាខ្សែតភ្ជាប់តំបន់ទេសចរណ៍ក្នុងតំបន់ទន្លេសាប<br>២- បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈការប្រកបមុខរបរបម្រើឱ្យភ្ញៀវទេសចរ<br>៣- តាមរយៈពិពិធកម្មទេសចរណ៍ថ្មីៗទាំងនេះនឹងអាចទាក់ទាញភ្ញៀវទេសចរមកកម្សាន្តកាន់តែច្រើន<br>៤- ប្រែក្លាយតំបន់នេះជាតំបន់ទេសចរណ៍ប្រកបដោយនិរន្តរភាព<br>៥- ចូលរួមចំណែកក្នុងការអភិរក្សជីវៈចម្រុះប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប<br>៦- ធានាបាននូវភាពស្អាត អនាម័យ កាត់បន្ថយការបំពុលទឹក<br>៧- ទទួលបានការរៀបចំផែទេសចរណ៍ដែលមានរចនាបទ និងភាពគង់វង្សយូរអង្វែង<br>៨- ភាពចម្រុះនៃសកម្មភាពទេសចរណ៍។</td>
</tr>
<tr>
<td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷<br>គម្រោងនេះ មិនមានផលប៉ះពាល់ដល់ផ្នែកបរិស្ថាន និងសង្គម</td>
<td rowspan="3">រយៈពេល÷<br>អនុវត្តរយៈពេលខ្លី និងមធ្យម (២០២១-២០២៣) ដោយគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និងរដ្ឋបាលខេត្តសៀមរាប និងវិនិយោគិនឯកជន។</td>
<td rowspan="3">ថវិកានៃគម្រោង÷<br>ថវិកានៃគម្រោងនេះនឹងកំណត់នាពេលក្រោយ។</td>
</tr>
<tr>
<td>ហេតុផល÷<br>ខេត្តសៀមរាបមានចំណុចពិសេសចាំបាច់ត្រូវធ្វើការអភិវឌ្ឍទេសចរណ៍ថ្មីប្រកប ដោយគុណភាព ដើម្បីបំពេញសេចក្តីត្រូវការរបស់ភ្ញៀវទេសចរទៅថ្ងៃអនាគត។<br>តំបន់ភ្នំក្រោម (ចុងឃ្នាស) ជាចំណុចគន្លឹះ (ច្រកចូល) ក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពនៅក្នុងតំបន់ទន្លេសាប។</td>
</tr>
<tr>
<td>គម្រោងពាក់ព័ន្ធផ្សេងទៀត÷<br>បច្ចុប្បន្នក្រុមហ៊ុន ស៊ូ ជីង បានទទួលសិទ្ធិវិនិយោគតំបន់ចុងឃ្នាស។</td>
</tr>
</table>

**គម្រោងទី៩: "គម្រោងរៀបចំតំបន់ថ្មើរជើងនៅខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ"**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា**

<table>
<tr><th>ល.រ.</th><th colspan="2">ចំណងជើងគម្រោង</th><th>ភាគីពាក់ព័ន្ធ</th><th>ប្រភពថវិកា</th><th>អាទិភាពនៃពេលវេលា</th></tr>
<tr><td>គ.៩</td><td colspan="2">គម្រោងរៀបចំតំបន់ថ្មើរជើងនៅខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ</td><td>ភ្ញៀវទេសចរ វិស័យឯកជន ប្រជាជនមូលដ្ឋាន</td><td>រដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍ</td><td>អាទិភាព១ និង ២</td></tr>
<tr><th colspan="2">ទីតាំងគម្រោង</th><th>ភ្នាក់ងារអនុវត្តគម្រោង</th><td colspan="3" rowspan="2">វិធីសាស្ត្រនៃការអនុវត្ត÷<br>កំណត់ប្រភេទទីតាំងផ្លូវអាទិភាព និងធ្វើការសិក្សាកែលម្អ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងអនុវត្តដាក់/ឱ្យដំណើរការដោយគិតគូរដល់ការបង្កើតឱ្យមានសម្បទាទេសចរណ៍ទ្រទ្រង់ដល់ការបង្កើតតំបន់ថ្មើរជើង។</td></tr>
<tr><td colspan="2">ខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ</td><td>• រដ្ឋបាលរាជធានី-ខេត្ត<br>• ក្រសួងទេសចរណ៍</td></tr>
<tr><td colspan="3">សាវតារ÷<br>ការរៀបចំតំបន់ទេសចរណ៍ថ្មើរជើង ដែលបច្ចុប្បន្ន សកម្មភាពទេសចរណ៍ថ្មើរជើងទីក្រុងមានភាពទាក់ទាញខ្លាំង សម្រាប់ភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិ តែអ្វីដែលជាបញ្ហា ចំពោះ ការរៀបចំតំបន់ទេសចរណ៍ថ្មើរជើងនេះគឺនៅខ្វះខាតនៅឡើយ ដែលរួមមាន ទំហំផ្លូវតូច ការរំលោភដីចំណីផ្លូវពីប្រជាពលរដ្ឋមូលដ្ឋាន ម្ចាស់អាជីវកម្ម និងការរៀបចំសំណង់អគារចាស់ៗ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការរៀបចំទិសដៅចរាចរណ៍ត្រូវកែលម្អនិងរៀបចំជាថ្មី។ល។ អ្វីដែលកាន់តែពិសេស សម្រាប់ធ្វើឱ្យទីក្រុងកាន់តែមានភាពទាក់ទាញ និងផ្តល់នូវភាពកក់ក្តៅ ពេញចិត្តពីសំណាក់ភ្ញៀវទេសចរគឺ ម្ហូបអាហារ ការស្នាក់នៅ ព្រឹត្តិការណ៍កម្សាន្ត សិល្បៈ និងការទិញទំនិញ ...ត្រូវបានប្រមូលផ្តុំក្នុងតំបន់មួយ។</td><td colspan="3">សមាសភាពអនុវត្តគម្រោង÷<br>បង្កើតតំបន់ថ្មើរជើងទេសចរណ៍មួយនៅរាជធានីភ្នំពេញ មួយនៅខេត្តព្រះសីហនុ និងមួយនៅខេត្តសៀមរាប។<br>ដើម្បីឱ្យមានតំបន់ថ្មើរជើងត្រូវគិតគូរ÷<br>• កែលម្អសោភណភាពតាមដងផ្លូវ<br>• បង្កើតសម្បទាទេសចរណ៍តាមដងផ្លូវ<br>• សម្រួលការធ្វើដំណើររបស់ភ្ញៀវទេសចរថ្មើរជើង<br>• បង្កើតសកម្មភាពទេសចរណ៍ និងពាណិជ្ជកម្មនៅតាមដងផ្លូវគោលដៅ<br>• រៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវទេសចរណ៍<br>• ធានារក្សាសុវត្ថិភាពចរាចរណ៍សម្រាប់ទេសចរណ៍ទីក្រុង<br>• ផ្តល់នូវបទពិសោធន៍សម្រាប់ទេសចរថ្មើរជើង<br>• មានឱកាសក្នុងការផ្សព្វផ្សាយពីទេសចរណ៍វប្បធម៌របស់កម្ពុជា<br>• បង្កើតជាតំបន់ទេសចរណ៍ថ្មើរជើងគំរូនៅកម្ពុជា<br>• ជួយសម្រួលដល់ការលក់ដូរអាជីវកម្មរបស់ប្រជាពលរដ្ឋនៅគ្រប់ច្រកល្ហកនៃផ្លូវក្នុងតំបន់នេះ<br>• បង្កើតបានតំបន់ទេសចរណ៍ដែលមាននិមិត្តសញ្ញាច្បាស់លាស់។</td></tr>
</table>

<table>
<tr>
<td>គោលបំណង÷<br>បង្កើតផលិតផលទេសចរណ៍ទីក្រុង ដ៏ទាក់ទាញសម្រាប់រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ។</td>
<td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង÷<br>១- អាចពន្យារការស្នាក់នៅរបស់ភ្ញៀវទេសចរ<br>២- បង្កើនភាពទាក់ទាញបន្ថែមទៀតសម្រាប់ទេសចរណ៍ទីក្រុង ពិសេសនៅពេលរាត្រី<br>៣- ប្រែក្លាយតំបន់នេះជាតំបន់ទេសចរណ៍ប្រកបដោយនិរន្តរភាព<br>៤- ទទួលបានការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងកាន់តែមានរបៀបរាបរយមានសោភណភាពល្អក្នុងតំបន់ទីក្រុង<br>៥- ជាតំបន់ដែលមានអត្តសញ្ញាណទេសចរណ៍បែបទីក្រុងច្បាស់លាស់។</td>
</tr>
<tr>
<td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷<br>គម្រោងនេះនឹងផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានតិចតួចបំផុតដល់សង្គម និងបរិស្ថាន។</td>
<td>រយៈពេល÷<br>អនុវត្តរយៈពេលខ្លី និងមធ្យម(២០២១-២០២៣) ដោយគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ក្រសួងទេសចរណ៍ រដ្ឋបាលរាជធានី-ខេត្ត និងវិនិយោគិនឯកជន។</td>
<td>ថវិកានៃគម្រោង÷<br>គម្រោងនៃការបង្កើតតំបន់ថ្មើរជើងក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុនេះនឹងកំណត់នាពេលក្រោយ។</td>
</tr>
</table>

**គម្រោងទី១០: "គម្រោងបង្កើតបណ្ណទេសចរណ៍កម្ពុជា** (Cambodia Pass)"

## តារាងសង្ខេបនៃគម្រោង

## ផ្នែក: លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពនៃពេលវេលា |
|---|---|---|---|---|
| គ.១០ | គម្រោងបង្កើតបណ្ណទេសចរណ៍កម្ពុជា (Cambodia Pass) | ភ្ញៀវទេសចរ វិស័យឯកជន សិស្សនិស្សិត សាស្ត្រាចារ្យ និងមន្ត្រីរាជការ | រដ្ឋ និងឯកជន | អាទិភាព១ |

| ទីតាំងគម្រោង | ភ្នាក់ងារអនុវត្តគម្រោង | វិធីសាស្ត្រនៃការអនុវត្ត÷ |
|---|---|---|
| រាជធានី-ខេត្ត | • ក្រសួងទេសចរណ៍<br>• គ្រឹះស្ថានអង្គរ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• វិស័យឯកជន | ១- បង្កើតភាពជាដៃគូសម្រាប់តួអង្គសំខាន់ៗក្នុងការដាក់ឱ្យដំណើរការគម្រោងបណ្ណទេសចរណ៍កម្ពុជានេះ។<br>២- ដំណើរការ និងបង្កើតប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រង និងផ្គត់ផ្គង់បណ្ណទេសចរណ៍កម្ពុជា និងការប្រើប្រាស់ QR-Code<br>៣- ការទទួលបានបណ្ណ<br>• ទិញនៅតាមក្រុមហ៊ុនទេសចរណ៍ ឬទីភ្នាក់ងារទេសចរណ៍<br>• នៅអាកាសយានដ្ឋាន<br>• បញ្ជរព័ត៌មានទេសចរណ៍<br>• នៅតាមសណ្ឋាគារជាដៃគូ និងតាមរយៈអនឡាញ<br>៤- ដំណើរការបណ្ណ<br>• បង្ហាញបណ្ណនៅមធ្យោបាយដឹកជញ្ជូនជាដៃគូ នៅតាមរមណីយដ្ឋាន ឬគោលដៅទេសចរណ៍ដែលអ្នកបានទៅដល់។ |

| សាវតារ÷ | សមាសភាពអនុវត្តគម្រោង÷ |
|---|---|
| បណ្ណទេសចរណ៍កម្ពុជា ជាបណ្ណឌីជីថលប្រមូលផ្តុំគោលដៅទេសចរណ៍ និងសម្បទាទេសចរណ៍ដែលផ្តល់ជាមធ្យោបាយ មួយដ៏ល្អប្រសើរមានភាពងាយស្រួល និងទាក់ទាញទេសចរណ៍ដើរកម្សាន្ត។ បណ្ណនេះ នឹងជួយដល់ការគ្រប់គ្រងចលនាវិហូររបស់ភ្ញៀវទេសចរផងដែរ។ ដើម្បីទាក់ទាញភ្ញៀវទេសចរឱ្យប្រើប្រាស់បណ្ណនេះ គឺត្រូវមានការបញ្ចុះតម្លៃសម្រួលការទិញសំបុត្រ ចូលទស្សនាតាមរមណីយដ្ឋានផ្សេងៗ បញ្ចូលសំបុត្រធ្វើដំណើរនិងការបញ្ចុះតម្លៃលើសេវាទេសចរណ៍ផ្សេងៗ។ **បណ្ណ** | រចនាសម្ព័ន្ធបណ្ណទេសចរណ៍កម្ពុជា÷<br>• ក្រសួងទេសចរណ៍<br>• រមណីយដ្ឋាន<br>• កន្លែងកម្សាន្ត<br>• ក្រុមហ៊ុនដឹកជញ្ជូន<br>• សេវាទេសចរណ៍/ សម្បទាទេសចរណ៍ |

<table>
<tr>
<td>ទេសចរណ៍កម្ពុជា ជាបណ្ណកញ្ចប់ទស្សនៈកិច្ចក្នុងទីក្រុង តាមរមណីយដ្ឋាន និងកន្លែងកម្សាន្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលផ្តល់ឱ្យភ្ញៀវទេសចរអន្តរជាតិ ពិសេសទេសចរមកលក្ខណៈជាបុគ្គល នូវកម្មវិធីទស្សនៈកិច្ចគ្រប់ជ្រុងជ្រោយ ដែលជួយសន្សំសំចៃពេលវេលា ថវិកា និងភាពតានតឹង ឆ្លើយតបទៅនឹងតម្រូវការដើរកម្សាន្តប្រកបដោយបទពិសោធន៍។</td>
<td colspan="2">• ភ្ញៀវទេសចរ<br>• គ្រប់គ្រង និងរៀបចំជាដំណើរកម្សាន្តថ្មីៗមួយចំនួនតាមរយៈដៃគូសហការជាមួយវិស័យឯកជន។<br>• ប្រើបច្ចេកទេសឌីជីថលក្នុងការរៀបចំកញ្ចប់ទស្សនៈកិច្ចប្រកបដោយនវានុវត្តន៍ដែលផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរដោយមិនចាំបាច់ចំណាយពេលឈររង់ចាំទិញសំបុត្រ ឬធ្វើដំណើរទៅកាន់គោលដៅទេសចរណ៍ផ្ទាល់</td>
</tr>
<tr>
<td>គោលបំណង៖<br>• ជំរុញចលនាទេសចរណ៍ផ្ទៃក្នុងទៅតាមគោលដៅនានាក្នុងព្រះរាជាណាចក្រកម្ពុជា<br>• ផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរមកលក្ខណៈជាបុគ្គលអាចជ្រើសរើសដំណើរកម្សាន្តបាន<br>• បង្កើនការផ្សព្វផ្សាយផលិតផលទេសចរណ៍កម្ពុជា។</td>
<td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង៖<br>បណ្ណទេសចរណ៍កម្ពុជានេះនឹងផ្តល់ផលវិជ្ជមាននាពេលអនាគត រួមមាន៖<br>១- ជួយដល់ការគ្រប់គ្រង និងវិហ្វូររបស់ភ្ញៀវទេសចរនៅទូទាំងប្រទេសកម្ពុជា (ពោលគឺជំរុញចលនាទេសចរណ៍ផ្ទៃក្នុង)<br>២- ជួយរមណីយដ្ឋាន កន្លែងកម្សាន្ត ក្រុមហ៊ុនដឹកជញ្ជូន ឬអ្នកផ្តល់សេវាកម្មដទៃទៀតដែលនៅកម្ពុជាឱ្យទទួលបានអត្ថប្រយោជន៍ពីចលនាទេសចរណ៍ផ្ទៃក្នុងនេះ<br>៣- បង្កើនចំណូលទេសចរណ៍ ជាពិសេសសម្រាប់ប្រតិបត្តិករក្នុងស្រុកដែលជាដៃគូក្នុងបណ្ណទេសចរណ៍កម្ពុជា<br>៤- គ្រប់គ្រងឱ្យកាន់តែប្រសើរឡើងនូវវិហ្វូរភ្ញៀវទេសចរដែលមាន ដោយការចែករំលែកភ្ញៀវទេសចរអន្តរជាតិទៅកាន់ទីតាំងទេសចរណ៍នានានៅទូទាំងប្រទេស។</td>
</tr>
<tr>
<td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម៖<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។<br><br>ហេតុផល៖<br>ដើម្បីរិះរកវិធីជួយសម្រួលដល់ការធ្វើដំណើរកម្សាន្តរបស់ភ្ញៀវទេសចរអន្តរជាតិនៅខេត្តសៀមរាប ភ្នំពេញ ខេត្តព្រះសីហនុ និងតំបន់ផ្សេងៗទៀតនៃប្រទេសកម្ពុជា និងការអនុវត្តតាមផែនការសកម្មភាពជំរុញវិស័យទេសចរណ៍ដើម្បីទាក់ទាញ ភ្ញៀវទេសចរ ពិសេសជំរុញចលនាទេសចរណ៍ផ្ទៃក្នុងនិង ក៏ដូចជាទាក់ទាញភ្ញៀវទេសចរអន្តរជាតិលក្ខណៈជាបុគ្គល។</td>
<td>រយៈពេល៖<br>អនុវត្តក្នុងរយៈពេលខ្លី (២០២១-២០២២) ដោយក្រសួងទេសចរណ៍ និងវិស័យឯកជន។</td>
<td>ថវិកានៃគម្រោង៖<br>គម្រោងនេះប្រើប្រាស់ថវិកាសរុបប្រមាណ ៣០ម៉ឺនដុល្លារអាម៉េរិក។</td>
</tr>
</table>

**គម្រោងទី១១: “ពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្លូវជាអាទិភាព) និងបញ្ចូលទឹក ភ្លើង លូ និងការគ្រប់គ្រងបរិស្ថាន (ជាពិសេសសំរាម) ដើម្បីជំរុញដល់ចលនាទេសចរណ៍ក្នុងស្រុកទៅកាន់រមណីយដ្ឋានទេសចរណ៍សំខាន់ៗ”**

តារាងសង្ខេបនៃគម្រោង

ផ្នែក÷លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា

<table>
<tr><th>ល.រ.</th><th colspan="2">ចំណងជើងគម្រោង</th><th>ភាគីពាក់ព័ន្ធ</th><th>ប្រភពថវិកា</th><th>អាទិភាពនៃពេលវេលា</th></tr>
<tr><td>គ.១១</td><td colspan="2">ពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្លូវជាអាទិភាព) និងបញ្ចូលទឹក ភ្លើង លូ និងការគ្រប់គ្រងបរិស្ថាន (ជាពិសេសសំរាម) ដើម្បីជំរុញដល់ចលនាទេសចរណ៍ក្នុងស្រុកទៅកាន់រមណីយដ្ឋានទេសចរណ៍សំខាន់</td><td>ប្រជាជន ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ វិស័យរដ្ឋ និងវិស័យឯកជន</td><td>រដ្ឋ និងដៃគូអភិវឌ្ឍ</td><td>អាទិភាព ១ ២ និង ៣</td></tr>
<tr><th colspan="2">ទីតាំងគម្រោង</th><th>ភ្នាក់ងារអនុវត្តគម្រោង</th><td colspan="3" rowspan="2">វិធីសាស្ត្រនៃការអនុវត្ត÷<br>១- កំណត់ប្រភេទ ទីតាំងផ្លូវ អាទិភាព និងធ្វើការសិក្សាកែលម្អ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងអនុវត្តដាក់/ ឱ្យដំណើរការដោយគិតគូរដល់ផ្លូវទេសចរណ៍ថ្មើរជើង ផ្លូវសម្រាប់ការបែងចែកការធ្វើដំណើរ របស់រថយន្ត ផ្លូវសម្រាប់ម៉ូតូ ផ្លូវសម្រាប់ជិះកង់ ផ្លូវសម្រាប់ជនពិការ សួនទេសចរណ៍ ការបំពាក់សម្បទាទេសចរណ៍ និងសម្បទាមួយចំនួនដែលបម្រើឱ្យវិស័យទេសចរណ៍។ ដោយបំពេញបន្ថែម និងបន្សីជាមួយផែនការ និងប្លង់បច្ចេកទេសរបស់អាជ្ញាធរខេត្ត ក្រសួងដែនដីនគរូបនីយកម្មនិងសំណង់ និងស្ថាប័នពាក់ព័ន្ធ។<br>២- កែលម្អស្ថានភាពផ្លូវជាតិក្នុងក្រុងសៀមរាប ព្រះសីហនុ និងភ្នំពេញ<br>៣- ធ្វើការសិក្សាពីផលប៉ះពាល់និងសក្តានុពលនៃហេដ្ឋារចនាសម្ព័ន្ធនីមួយៗ ដើម្បីងាយស្រួលក្នុងការវាយតម្លៃ និងដាក់ចេញនូវស្តង់ដាបច្ចេកទេសសមាមាត្រនឹងការប្រើប្រាស់។<br>៤- កំណត់ទំហំការងារនិងការប្រើប្រាស់ថវិកា</td></tr>
<tr><td colspan="2">រាជធានី-ខេត្ត</td><td>• រដ្ឋបាលរាជធានី-ខេត្ត<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន<br>• ក្រសួងទេសចរណ៍<br>• ក្រសួងអភិវឌ្ឍន៍ជនបទ<br>• ក្រសួងបរិស្ថាន<br>• ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>• ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ</td></tr>
<tr><td colspan="3">សារៈតារ÷<br>ហេដ្ឋារចនាសម្ពន្ធ័ទៅកាន់រមណីយដ្ឋានទេសចរណ៍ត្រូវបានលើកឡើងជាញឹកញាប់ដោយប្រជាជន ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ និងភាគីពាក់ព័ន្ធ ពីបញ្ហាផ្លូវពិសេសផ្លូវជនបទតភ្ជាប់ទៅកាន់រមណីយដ្ឋានទេសចរណ៍សំខាន់ៗ (តំបន់អេកូទេសចរណ៍)។</td><td colspan="3">សមាសភាពអនុវត្តគម្រោង÷<br>១- កែលម្អ និងរៀបចំផ្លូវតភ្ជាប់ទៅកាន់តំបន់ទេសចរណ៍សំខាន់ៗ (ពិសេសរមណីយដ្ឋានអេកូទេសចរណ៍)។<br>២- កែលម្អស្ថានភាពហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុងទេសចរណ៍ពិសេសនៅក្នុងទីក្រុងសៀមរាប ព្រះសីហនុ និងខេត្តដែលជាគោលដៅទេសចរណ៍ទីក្រុងទីពីរ (Secondary city) ជាអាទិ៍ បាត់ដំបង ក្រចេះ កំពត កែប។ល។</td></tr>
</table>

<table>
<tr>
<td>គោលបំណង៖<br>• បង្កើនភាពទាក់ទាញទេសចរណ៍ទៅកាន់រមណីយដ្ឋានទេសចរណ៍ដែលមានសក្តានុពល<br>• បង្កើនភាពទាក់ទាញទេសចរណ៍ទីក្រុង។</td>
<td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង៖<br>១- បង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរចូលទៅកាន់រមណីយដ្ឋានទេសចរណ៍<br>២- មានហេដ្ឋារចនាសម្ព័ន្ធផ្លូវស្អាត និងទាក់ទាញក្នុងក្រុងជាគោលដៅទេសចរណ៍អាទិភាព</td>
</tr>
<tr>
<td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម៖<br>គម្រោងនេះ មានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមតិចតួចបំផុត ហើយគម្រោងនេះនឹងផ្តល់ផលចំណេញដល់បរិស្ថាន សង្គម និងសេដ្ឋកិច្ចក្រោយបញ្ចប់គម្រោង។</td>
<td rowspan="2">រយៈពេល៖<br>អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង(២០២១-២០២៥) ដោយក្រសួងអភិវឌ្ឍន៍ជនបទ គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ រដ្ឋបាលរាជធានី-ខេត្ត និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។</td>
<td rowspan="2">ថវិកានៃគម្រោង៖<br>ថវិកានៃគម្រោងនេះនឹងកំណត់នាពេលក្រោយ</td>
</tr>
<tr>
<td>ហេតុផល៖<br>ការកែលម្អហេដ្ឋារចនាសម្ព័ន្ធក្រុងសៀមរាប ព្រះសីហនុ និងភ្នំពេញ គឺជាកត្តាសំខាន់មួយដើម្បីកសាងនូវកេរ្តិ៍ឈ្មោះបន្ថែម និងធ្វើពិពិធកម្មផលិតផលទេសចរណ៍ (ទេសចរណ៍ទីក្រុង) សម្រាប់ផ្សព្វផ្សាយលើទីផ្សារជាតិ អន្តរជាតិ និងស្របជាមួយពាក្យស្លោក និងយុទ្ធនាការនានាៗដែលក្រសួងទេសចរណ៍បាននឹងកំពុងដាក់ចេញ និងដើម្បីដោះស្រាយបញ្ហាប្រឈមដែលលើកឡើងដោយប្រជាពលរដ្ឋ ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ និងភាគីពាក់ព័ន្ធ។</td>
</tr>
</table>

**គម្រោងទី១២: "គម្រោងការអភិវឌ្ឍទេសចរណ៍ដែលធ្វើដំណើរដោយខ្លួនឯង (Self-driving Tourism) "**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា**

<table>
<tr><th>ល.រ.</th><th colspan="2">ចំណងជើងគម្រោង</th><th>ភាគីពាក់ព័ន្ធ</th><th>ប្រភពថវិកា</th><th>អាទិភាពនៃពេលវេលា</th></tr>
<tr><td>គ.១២</td><td colspan="2">គម្រោងការអភិវឌ្ឍទេសចរណ៍ដែលធ្វើដំណើរដោយខ្លួនឯង<br>(Self-Driving Tourism)</td><td>ប្រតិបត្តិករទេសចរណ៍</td><td>រដ្ឋ និងឯកជន</td><td>អាទិភាព ១ និង ២</td></tr>
<tr><th colspan="2">ទីតាំងគម្រោង</th><th>ភ្នាក់ងារអនុវត្តគម្រោង</th><td colspan="3" rowspan="2">វិធីសាស្ត្រនៃការអនុវត្ត៖<br>១- បង្កើតមជ្ឈមណ្ឌលជំនួយទេសចរណ៍ នៅច្រកទ្វារអន្តរជាតិផ្លូវគោក (ពិសេសនៅច្រកទ្វារអន្តរជាតិជាមួយប្រទេសថៃ វៀតណាម និងឡាវ)។<br>២- សម្រួលការធ្វើដំណើររថយន្តទេសចរណ៍ឆ្លងព្រំដែននៅច្រកទ្វាអន្តរជាតិមកកាន់ព្រះរាជាណាចក្រកម្ពុជា<br>៣- បង្កើតកម្មវិធីទូរសព្ទ បង្ហាញព័ត៌មាននៃការធ្វើដំណើរសម្រាប់ភ្ញៀវទេសចរអន្តរជាតិមកកាន់ព្រះរាជាណាចក្រកម្ពុជាភ្ជាប់ទៅនឹងគោលដៅទេសចរណ៍សំខាន់ៗផ្សេងទៀតក្នុងប្រទេសផ្សារភ្ជាប់នឹងប្រព័ន្ធ (GPS) ឬ (Google Map)<br>៤- បំពាក់ស្លាកសញ្ញាបង្ហាញផ្លូវ សម្រាប់ភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិ<br>៥- កែលម្អផ្លូវតភ្ជាប់ទៅកាន់គោលដៅទេសចរណ៍នានា<br>៦- ផ្សព្វផ្សាយ និងធ្វើទីផ្សារទេសចរណ៍ធ្វើដំណើរដោយខ្លួនឯង សម្រាប់ទាំងភ្ញៀវទេសចរក្នុងស្រុក និងភ្ញៀវទេសចរអន្តរជាតិមកពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន។</td></tr>
<tr><td colspan="2">រាជធានី-ខេត្ត</td><td>• ក្រសួងទេសចរណ៍<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន<br>• ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អគ្គនាយកដ្ឋានអន្តោប្រវេសន៍</td></tr>
<tr><td colspan="3">សាវតារ៖<br>បច្ចុប្បន្ន ភ្ញៀវទេសចរនិយមការធ្វើដំណើរតាមដងផ្លូវផ្សារភ្ជាប់ជាមួយនឹងការកម្សាន្តទេសចរណ៍នៅតាមដងផ្លូវ ដោយភ្ញៀវទេសចរអាចថតរូបលេងកម្សាន្ត និងអាចឈានចូលលេងតំបន់រមណីយដ្ឋាននៅតាមតំបន់គោលដៅបានយ៉ាងសប្បាយរីករាយ ដូចនេះផែនទីចង្អុលផ្លូវស្នើឱ្យជំរុញការសម្រួលឱ្យមានការធ្វើដំណើរសម្រាប់ភ្ញៀវទេសចរមកពីប្រទេសជិតខាងពិសេសតាមផ្លូវគោគដល់ភ្ញៀវទេសចរមកពីប្រទេសអាស៊ានដោយសម្រួលឱ្យប្រើប្រាស់រថយន្ត ចេញ-ចូល ព្រះរាជាណាចក្រកម្ពុជាឱ្យបានកាន់តែ</td><td colspan="3">សមាសភាពអនុវត្តគម្រោង៖<br>១- បញ្ចូលការផ្សព្វផ្សាយពីផលិតផលទេសចរណ៍ និងគោលដៅទេសចរណ៍នៅតាមបណ្តោយផ្លូវទេសចរណ៍ដល់ភ្ញៀវទេសចរ<br>២- ត្រូវរៀចំឱ្យមានស្ថានីយ៍ចំណត តាមបណ្តោយផ្លូវទេសចរណ៍ និងផ្លូវជាច្រើនទៀត ពិសេសការភ្ជាប់ពី (ភ្នំពេញ-សៀមរាប) និង/ឬ (ភ្នំពេញ-ព្រះសីហនុ) និង/ឬ (សៀមរាប-បាត់ដំបង) ឬ (សៀមរាប-ប៉ោយប៉ែត) និង/ឬ (សៀមរាប-ព្រះវិហារ-ស្ទឹងត្រែង) ។ល។<br>៣- បន្តពង្រឹងសុវត្ថិភាពចរាចរណ៍ តាមរយៈការត្រួតពិនិត្យបច្ចេកទេស គោរពតាមស្តង់ដាដឹកជញ្ជូន និងផ្លូវថ្នល់មានស្តង់ដាសុវត្ថិភាព<br>៤- ផ្តល់ការសម្រួលដល់ការធ្វើដំណើរទេសចរណ៍: ផ្លូវតភ្ជាប់គោលដៅទេសចរណ៍ទាំងអស់ត្រូវមានផ្លាកសញ្ញា និងសញ្ញាប្រាប់ទិស<br>៥- ពង្រឹងផែនការគ្រប់គ្រងចរាចរណ៍នៅតាមគោលដៅទេសចរណ៍ដោយត្រូវ៖</td></tr>
</table>

<table>
<tr>
<td>ងាយស្រួលអមជាមួយការសម្រួលដល់ទិដ្ឋាការនៃការធ្វើដំណើរដោយអាចប្រើប្រាស់បណ្ណឆ្លងកាត់ព្រំដែន និងអាចបើកបររថយន្តដោយខ្លួនឯងបាន។</td>
<td colspan="2">• ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ឱ្យបានត្រឹមត្រូវ និងត្រូវមានការផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងខ្លឹមសារនៃការអនុវត្តច្បាប់ចរាចរណ៍ដល់ភ្ញៀវទេសចរ។<br>• ពង្រឹងកែលម្អចំណតរថយន្តតាមបណ្ដារាជធានី-ខេត្ត<br>៦- សម្រួលនីតិវិធីក្នុងការចេញ-ចូលរថយន្តទេសចរណ៍មកកាន់ខេត្តសៀមរាបឱ្យកាន់តែងាយស្រួល<br>៧- គួរសម្រួលឱ្យមាន (បណ្ណចេញ-ចូល) ដើម្បីសម្រួលការធ្វើដំណើរដល់ភ្ញៀវទេសចរអន្តរជាតិ។</td>
</tr>
<tr>
<td>គោលបំណង÷<br>• ដើម្បីបង្កើនភាពទាក់ទាញនូវផ្លូវទេសចរណ៍ខាងលើនេះ ឱ្យមានភាព-ទាក់ទាញ និងក៏ដូចជាដើម្បីទាក់ទាញប្រភេទភ្ញៀវទេសចរដែលបើកបររថយន្តដោយខ្លួនឯងដែលជាផ្នែកមួយនៃយុទ្ធនាការ “ASEAN for ASEAN” ចាំបាច់ត្រូវតែបង្កលក្ខណៈងាយស្រួល និងបង្កើនភាពទាក់ទាញផ្នែកទេសចរណ៍<br>• ជំរុញចលនាទេសចរណ៍ផ្ទៃក្នុងតំបន់។</td>
<td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង÷<br>១- ការតភ្ជាប់បណ្ដាញផ្លូវថ្នល់នេះនឹងបម្រើឱ្យយុទ្ធសាស្ត្រគាំទ្រភ្ញៀវទេសចរ ដែលបើកបររថយន្តដោយខ្លួនឯង ពីបណ្ដាប្រទេសក្នុងតំបន់អាស៊ាន ដែលមានបំណងធ្វើដំណើរកម្សាន្តតាមផ្លូវដែលមានទេសភាពល្អៗ ដើម្បីភាពរីករាយ និងទស្សនាតាមដងផ្លូវ ពិសេសពីភ្ញៀវទេសចរមកពីប្រទេសថៃ វៀតណាម និងឡាវ។<br>២- ការតភ្ជាប់ផ្ទៃក្នុងបានល្អប្រសើរ និងជំរុញចលនាទេសចរណ៍ក្នុងស្រុកឱ្យកាន់តែខ្លាំង និងក៏ដូចជាជំរុញចលនាទេសចរណ៍ផ្ទៃក្នុងឱ្យកាន់តែខ្លាំង ដែលជាការគាំទ្រដល់ចលនាសេដ្ឋកិច្ចផ្ទៃក្នុងកាន់តែខ្លាំងថែមទៀត។</td>
</tr>
<tr>
<td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷<br>គម្រោងនេះ មិនមានផ្ដល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td>
<td rowspan="2">រយៈពេល÷<br>អនុវត្តក្នុងរយៈពេលខ្លី និងមធ្យម (២០២១-២០២៣) ដោយគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ក្រសួងទេសចរណ៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។</td>
<td rowspan="2">ថវិកានៃគម្រោង÷<br>ថវិកានៃគម្រោងនេះ នឹងកំណត់នាពេលក្រោយ។</td>
</tr>
<tr>
<td>ហេតុផល÷<br>បច្ចុប្បន្នកម្ពុជាមានការតភ្ជាប់ផ្លូវថ្នល់នានាទៅកាន់គោលដៅទេសចរណ៍បានល្អរួចហើយ ដែលជាសក្ដានុពលក្នុងការអភិវឌ្ឍទេសចរណ៍ធ្វើដំណើរដោយខ្លួនឯង បានកាន់តែប្រសើរ និងអាចទាក់ទាញភ្ញៀវទេសចរពីប្រទេសជិតខាងក្នុងបណ្ដាប្រទេសដែលជាសមាជិកអាស៊ាន (ពិសេសពីប្រទេសថៃ វៀតណាម និងឡាវ) មកទស្សនារាជធានី-ខេត្តនានាកាន់តែច្រើនថែមទៀត។</td>
</tr>
</table>

**គម្រោងទី១៣: យុទ្ធនាការ "កម្ពុជាស្អាត ឆ្ពោះទៅស្វាគមន៍ព្រឹត្តិការណ៍ SEA Game 2023 "**

## តារាងសង្ខេបនៃគម្រោង

## ផ្នែក: លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពនៃពេលវេលា |
|---|---|---|---|---|
| គ.១៣ | កម្ពុជាស្អាត ឆ្ពោះទៅស្វាគមន៍ព្រឹត្តិការណ៍ SEA Game 2023 | ប្រជាពលរដ្ឋ ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ វិស័យរដ្ឋ និងវិស័យឯកជន | រដ្ឋ-ដៃគូអភិវឌ្ឍ | អាទិភាព ១ និង ២ |

| ទីតាំងគម្រោង | ភ្នាក់ងារអនុវត្តគម្រោង | **វិធីសាស្ត្រនៃការអនុវត្ត÷** |
|---|---|---|
| រាជធានីភ្នំពេញ ខេត្តព្រះសីហនុ (កោះរ៉ុង) ខេត្តសៀមរាប (តំបន់អង្គរ) និងខេត្តគោលដៅនៃការរៀបចំព្រឹត្តិការណ៍ SEA Game 2023) | • ក្រសួងទេសចរណ៍<br>• ក្រសួងបរិស្ថាន<br>• រដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ | ១. បង្កើតយុទ្ធនាការ "**គ្មានថង់ប្លាស្ទិក-Free Plastic Zone**" នៅតំបន់អង្គរ និងកោះរ៉ុង<br>២. បង្កើតយុទ្ធនាការអភិវឌ្ឍន៍ "**កម្ពុជាស្អាត**" នៅតាមរាជធានី-ខេត្តជាគោលដៅទេសចរណ៍អាទិភាព (រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តគោលដៅនៃការរៀបចំព្រឹត្តិការណ៍ SEA Game 2023)<br>៣. បង្កើតឱ្យមានសួនទេសចរណ៍។ |

| **សាវតារ÷** | **សមាសភាពអនុវត្តគម្រោង÷** |
|---|---|
| ការគ្រប់គ្រងសំណល់ គឺជាបញ្ហាស្មុគស្មាញ ដែលពាក់ព័ន្ធនឹងការទុកដាក់ ប្រមូលដឹកជញ្ជូន និងការគ្រប់គ្រងជារួម។ កំណើនប្រជាជននិងការអភិវឌ្ឍវិស័យទេសចរណ៍បណ្តាលឱ្យមានកំណើននៃការប្រើប្រាស់សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋនិងភ្ញៀវទេសចរ តែស្ថានភាពនៃការគ្រប់គ្រងសំណល់មិនទាន់សមស្របជាមួយនឹងការរីកចម្រើនទាំងនោះទេ ដែលអាចបង្កការប៉ះពាល់ដោយសារតែការបញ្ចេញចោលសំណល់មិនបានត្រឹមត្រូវ។ លើសពីនេះ ការប្រមូល ការសម្អាត ការដឹកជញ្ជូន និងទុកដាក់គ្រប់គ្រងសំណល់ គឺមានសភាពទន់ខ្សោយមិនទាន់សមស្របជាមួយខេត្តដែលមានសក្តានុពលទេសចរណ៍នៅឡើយទេ។ កត្តាទាំងនេះធ្វើឱ្យធ្លាក់ចុះនូវស្ថានភាពបរិស្ថាន អនាម័យ សោភណភាព និងទិដ្ឋភាពទេសភាព ដែលជាផ្នែក | ១- យុទ្ធនាការទប់ស្កាត់ការបោះសំណល់ចោលពាសវាលពាសកាល និងការប្រមូលត្រឡប់មកវិញនូវសំណល់ដែលនៅរាយប៉ាយនៅតាមដងផ្លូវសាធារណៈ លូ ស្ទឹង រមណីយដ្ឋានទេសចរណ៍ នៅតាមរាជធានី-ខេត្តគោលដៅទេសចរណ៍អាទិភាព<br>២- រៀបចំយុទ្ធនាការអភិវឌ្ឍន៍ "**កម្ពុជាស្អាត**"<br>៣- រៀបចំយុទ្ធនាការ "**គ្មានថង់ប្លាស្ទិក**" នៅតំបន់អង្គរ និងកោះរ៉ុង<br>៤- បង្កើតឱ្យមាន "**សួនទេសចរណ៍**" នៅតាមរាជធានី-ខេត្តជាគោលដៅទេសចរណ៍អាទិភាព។ |

| | | |
|---|---|---|
| ដ៏សំខាន់សម្រាប់បរិយាកាសទេសចរណ៍។ ដូច្នេះការគិតគូរឱ្យមានភាពស្អាត និងបៃតង ជាគន្លឹះសម្រាប់ភាពទាក់ទាញទេសចរណ៍នាពេលបច្ចុប្បន្ន និងអនាគត។ | | |
| **គោលបំណង÷**<br>ដើម្បីបង្កើនភាពទាក់ទាញទេសចរណ៍កម្ពុជាជាគោលដៅទេសចរណ៍ “**ស្អាត និងបៃតង**” និងជាទម្លាប់ថ្មីក្រោយជំងឺកូវីដ-១៩។ | **លទ្ធផលរំពឹងទុកនៃគម្រោង÷**<br>**១-** តំបន់អង្គរ និងកោះរ៉ុងមានភាពទាក់ទាញភ្ញៀវទេសចរកាន់តែខ្ពស់<br>**២-** ភាពស្អាត និងបៃតង បង្កើតបានជាទម្លាប់ថ្មី សម្រាប់វិស័យទេសចរណ៍កម្ពុជាក្រោយជំងឺកូវីដ-១៩។ | |
| **ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷**<br>គម្រោងនេះ ផ្តល់ផលជាវិជ្ជមានដល់សង្គម និងបរិស្ថាន។ | **រយៈពេល÷**<br>គម្រោងនេះអនុវត្តក្នុង**រយៈពេលខ្លី និងមធ្យម (២០២១-២០២៣)** ដោយក្រសួងទេសចរណ៍ អាជ្ញាធរជាតិអប្សរា ក្រសួងបរិស្ថាន និងដៃគូអភិវឌ្ឍ។ | **ថវិកានៃគម្រោង÷**<br>គម្រោងនេះប្រើប្រាស់ថវិកាសរុបប្រមាណ **១០ម៉ឺនដុល្លារអាម៉េរិក**។ |

**គម្រោងទី១៤: "ពង្រឹងការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ក្នុងស្រុក និងការបង្កើតមណ្ឌលព័ត៌មានទេសចរណ៍នៅតាមរាជធានី-ខេត្ត"**

## តារាងសង្ខេបនៃគម្រោង

## ផ្នែក: លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពនៃពេលវេលា |
|---|---|---|---|---|
| គ.១៤ | ពង្រឹងការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ក្នុងស្រុក និងការបង្កើតមណ្ឌលព័ត៌មានទេសចរណ៍នៅតាមរាជធានី-ខេត្ត | ប្រជាពលរដ្ឋ ប្រតិបត្តិករទេសចរណ៍ ភ្ញៀវទេសចរ វិស័យឯកជន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ | រដ្ឋ និងឯកជន | អាទិភាព ២ |

| ទីតាំងគម្រោង | ភ្នាក់ងារអនុវត្តគម្រោង | វិធីសាស្ត្រនៃការអនុវត្ត÷ |
|---|---|---|
| រាជធានី-ខេត្ត | • ក្រសួងទេសចរណ៍<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• ប្រតិបត្តិករទេសចរណ៍ | ១- បង្កើតមធ្យោបាយផ្សព្វផ្សាយព័ត៌មានទេសចរណ៍តាមគ្រប់មធ្យោបាយ ពិសេសតាមប្រព័ន្ធឌីជីថល<br>២- បង្កើតមណ្ឌលព័ត៌មានទេសចរណ៍ស្របតាមស្តង់ដានៅទូទៅ ២៥ខេត្ត-ក្រុង<br>៣- រៀបចំយន្តការគ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍ឱ្យមាននិរន្តរភាពក្រោមទម្រង់ភាពជាដៃគូ<br>៤- កំណត់អត្តសញ្ញាណតួអង្គដៃគូសក្តានុពល ប្រតិបត្តិករទេសចរណ៍ សម្រាប់ការសហការផ្សព្វផ្សាយព័ត៌មាន។ |

| សាវតារ÷ | សមាសភាពអនុវត្តនៃគម្រោង÷ |
|---|---|
| បច្ចុប្បន្ន ប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរអាចទទួលបានព័ត៌មានទេសចរណ៍មិនទាន់ទូលំទូលាយពីមន្ទីរទេសចរណ៍ និងប្រព័ន្ធផ្សព្វផ្សាយនានានៅឡើយ។ ដូចនេះដើម្បីបង្កើនការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ ផែនទីចង្អុលផ្លូវស្នើឱ្យពង្រឹងការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ក្នុងស្រុក និងការបង្កើតមណ្ឌលព័ត៌មានទេសចរណ៍ឱ្យស្របតាមស្តង់ដានៅតាមរាជធានី-ខេត្ត សំដៅបង្កើនភាពងាយស្រួលដល់ប្រតិបត្តិករទេសចរណ៍ ភ្ញៀវទេសចរជាតិ និងអន្តរជាតិទទួលបានព័ត៌មានទេសចរណ៍កាន់តែងាយស្រួល។ | **១- បង្កើនប្រសិទ្ធភាពផ្សព្វផ្សាយព័ត៌មានតាមគ្រប់មធ្យោបាយ**<br>• បង្កើតប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទេសចរណ៍តាមអនឡាញ<br>• ការរៀបចំឯកសារ វីដេអូផ្សព្វផ្សាយទេសចរណ៍នៅទូទាំងរាជធានី-ខេត្ត<br>**២- ផ្នែកសាងសង់មណ្ឌលព័ត៌មានទេសចរណ៍នៅតាមរាជធានី-ខេត្តឱ្យស្របតាមស្តង់ដា**<br>**៣- រៀបចំប្រព័ន្ធគ្រប់គ្រងមណ្ឌលពិព័រណ៍ទេសចរណ៍ក្នុងស្រុក**<br>**៤- ធ្វើទំនើបកម្មមណ្ឌលព័ត៌មានទេសចរណ៍ក្នុងស្រុកនៅតាមរាជធានី-ខេត្ត**<br>• រៀបចំប្រព័ន្ធផ្តល់ព័ត៌មានទេសចរណ៍<br>• រៀបចំបំពាក់សម្ភារៈបច្ចេកវិទ្យាបម្រើដល់ការផ្សព្វផ្សាយព័ត៌មានទេសចរណ៍។ល។ |

<table>
<tr>
<td>គោលបំណង÷<br>ការពង្រឹងការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ក្នុងស្រុក និងការបង្កើតមណ្ឌលព័ត៌មានទេសចរណ៍តាមរាជធានី-ខេត្ត មានគោលបំណង÷<br>• ជំរុញចលនាទេសចរណ៍ក្នុងស្រុកតាមរយៈការផ្តល់ព័ត៌មានទេសចរណ៍គ្រប់គ្រាន់ និងច្បាស់លាស់<br>• បង្កើនចលនាទេសចរណ៍ផ្ទៃក្នុង</td>
<td colspan="2">លទ្ធផលនៃគម្រោង÷<br>១- ការបង្កើតប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ទៅប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរជាតិ និងអន្តរជាតិ<br>២- ប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរងាយស្រួលក្នុងការស្វែងរកព័ត៌មានទេសចរណ៍<br>៣- មន្ត្រីផ្សព្វផ្សាយព័ត៌មានទេសចរណ៍មានលទ្ធភាព និងបច្ចេកទេសគ្រប់គ្រងក្នុងការផ្សព្វផ្សាយព័ត៌មានទេសចរណ៍<br>៤- ចូលរួមជំរុញ និងទាក់ទាញភ្ញៀវទេសចរមកប្រទេសកម្ពុជា និងដើរកម្សាន្ត។</td>
</tr>
<tr>
<td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td>
<td>រយៈពេល÷<br>អនុវត្តក្នុងរយៈពេលមធ្យម (២០២២-២០២៣) ដោយក្រសួងទេសចរណ៍។</td>
<td>ថវិកានៃគម្រោង÷<br>គម្រោងនេះប្រើប្រាស់ថវិកាសរុបប្រមាណ ៤-៥លានដុល្លារអាម៉េរិក។</td>
</tr>
</table>

**គម្រោងទី១៥: "ឆ្នាំទស្សនាទេសចរណ៍កម្ពុជា Visit Cambodia Years (២០២២-២០២៣) "**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា**

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពនៃពេលវេលា |
|---|---|---|---|---|
| គ.១៥ | ឆ្នាំទស្សនាទេសចរណ៍កម្ពុជា Visit Cambodia Years (២០២២-២០២៣) | ភ្ញៀវទេសចរ វិស័យឯកជន និង រាជរដ្ឋាភិបាល | រដ្ឋ និងឯកជន | អាទិភាព ២ |

| ទីតាំងគម្រោង | ភ្នាក់ងារអនុវត្តគម្រោង | វិធីសាស្ត្រនៃការអនុវត្ត÷ |
|---|---|---|
| ភ្នំពេញ សៀមរាប ព្រះសីហនុ និងខេត្តគោលដៅផ្សេងទៀត | • ក្រសួងទេសចរណ៍,<br>• ក្រសួងព័ត៌មាន<br>• ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ<br>• វិស័យឯកជន<br>• រដ្ឋបាលរាជធានី-ខេត្ត | ១- ស្វែករកដៃគូសហការពីវិស័យឯកជនក្នុងការរៀបចំព្រឹត្តិការណ៍ទេសចរណ៍នានា (វប្បធម៌កីឡា,....)<br>២- បង្កើតក្រុមការងារ (រដ្ឋ-ឯកជន) សម្រាប់យុទ្ធនាការឆ្នាំទស្សនាទេសចរណ៍កម្ពុជា<br>៣- រៀបចំផែនការសកម្មភាពនៃការរៀបចំព្រឹត្តិការណ៍ចងក្រងជាឆ្នាំទស្សនាទេសចរណ៍កម្ពុជា។ល។ |

| សារៈសំខាន់ | សកម្មភាពអនុវត្តគម្រោង |
|---|---|
| **សារៈ÷**<br>ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ វិស័យទេសចរណ៍កម្ពុជាទាមទារឱ្យមាននូវការជំរុញ និងផ្សព្វផ្សាយទេសចរណ៍ក្នុងកម្រិតខ្ពស់ពិសេសដំណាក់កាលក្រោយជំងឺឆ្លងកូវីដ-១៩។ ដូច្នេះ ក្រសួងទេសចរណ៍គួរកំណត់យកឆ្នាំ ២០២២-២០២៣ ជាឆ្នាំទស្សនាទេសចរណ៍កម្ពុជា ពិសេសយកឆ្នាំ២០២៣ ដែលកម្ពុជារៀបចំព្រឹត្តិការណ៍ទេសចរណ៍កីឡាដ៏ធំ (SEA Game 2023)។ | **សកម្មភាពអនុវត្តគម្រោង÷**<br>**១- រៀបចំព្រឹត្តិការណ៍ទេសចរណ៍**<br>- រៀបចំព្រឹត្តិការណ៍នានា ដែលបានគ្រោងទុកក្នុងផែនការកាលពីដើមឆ្នាំ២០២០ ជាអាទិ៍ ព្រឹត្តិការណ៍កីឡាម៉ារ៉ាតុង ព្រឹត្តិការណ៍ Mozart នៅឆ្នាំ២០២១។ល។<br>- ត្រៀមរៀបចំព្រឹត្តិការណ៍ធំៗនៅឆ្នាំ ២០២២ ដូចជា កិច្ចប្រជុំកំពូលអាស៊ាន ការរៀបចំវេទិកាទេសចរណ៍អាស៊ាន (ATF) ការរៀបចំសន្និបាតក្លិបឆ្នេរសមុទ្រដែលស្អាតជាងគេបំផុតលើសកលលោក និងការរៀបចំព្រឹត្តិការណ៍ប្រណាំងកង់តំបន់ឆ្នេរ ព្រឹត្តិការណ៍អង្គរសង្ក្រាន្តនៅខេត្តសៀមរាប ជាដើម។ |

<table>
<tr><td></td><td colspan="2">-នៅឆ្នាំ២០២៣ នឹងមានទូវការរៀបចំព្រឹត្តិការណ៍ដ៏សំខាន់បំផុតមួយសម្រាប់កម្ពុជា គឺការទទួលជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ស៊ីហ្គេមលើកទី៣២ ដែលនឹងអាចទាក់ទាញអ្នកទស្សនាបានច្រើនផងដែរ។<br>-បង្កើតព្រឹត្តិការណ៍ទេសចរណ៍ផ្សេងៗទៀតនៅតាមបណ្ដារាជធានី-ខេត្ត។<br>២- រៀបចំសន្និសីទកិច្ចប្រជុំនានា<br>៣- រៀបចំយុទ្ធនាការស្អាត និងបៃតងផ្សារភ្ជាប់នឹងយុទ្ធនាការឆ្នាំទស្សនាទេសចរណ៍កម្ពុជានេះ<br>៤- តែងតាំងអនុព័ន្ធអមតាមស្ថានតំណាងនៅទីផ្សារទេសចរណ៍អាទិភាព (អាស៊ាន អាស៊ានបូកបី អឺរ៉ុប អាម៉េរិក ។ល។)</td></tr>
<tr><td>គោលបំណង៖<br>គម្រោងឆ្នាំទស្សនាទេសចរណ៍កម្ពុជា (២០២២-២០២៣) មានគោលបំណង៖<br>• ស្ដារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយជំងឺកូវីដ-១៩<br>• ជំរុញចលនាទេសចរណ៍ក្នុងស្រុក និងទេសចរណ៍ផ្ទៃក្នុង។</td><td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង៖<br>១- បង្កើនចលនាទេសចរណ៍ក្នុងស្រុក និងទេសចរណ៍ផ្ទៃក្នុង<br>២- បង្កើនភាពប្រកួតប្រជែងទេសចរណ៍កម្ពុជាក្រោយជំងឺកូវីដ-១៩<br>៣- បង្កើនចំនួនភ្ញៀវទេសចរអន្តរជាតិត្រឡប់មកទស្សនាកម្ពុជា។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម៖<br>គម្រោងនេះ មិនមានផ្ដល់នូវផលប៉ះពាល់ ដល់សង្គម និងបរិស្ថាន។</td><td>រយៈពេល៖<br>អនុវត្តក្នុងរយៈពេលមធ្យម (២០២២-២០២៣) ដោយក្រសួងទេសចរណ៍ រដ្ឋបាលរាជធានី-ខេត្ត និងផ្នែកឯកជន។</td><td>ថវិកានៃគម្រោង៖<br>គម្រោងនេះប្រើប្រាស់ថវិកាសរុបប្រមាណ ៦-៨លានដុល្លារអាម៉េរិក។</td></tr>
</table>

**គម្រោងទី១៦: “គម្រោងទាក់ទាញទេសចរណ៍ម៉ាយ : កម្ពុជាគោលដៅទេសចរណ៍ម៉ាយ”**

**តារាងសង្ខេបនៃគម្រោង**

**ផ្នែក: លើកកម្ពស់ទីផ្សារទេសចរណ៍កម្ពុជា**

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពនៃពេលវេលា |
|---|---|---|---|---|
| គ.១៦ | គម្រោងទាក់ទាញទេសចរណ៍ម៉ាយ : កម្ពុជាគោលដៅទេសចរណ៍ម៉ាយ | រដ្ឋ និងឯកជនក្នុងវិស័យទេសចរណ៍ | រដ្ឋ និងឯកជន | អាទិភាព ១ ២ និង ៣ |

| ទីតាំងគម្រោង | ភ្នាក់ងារអនុវត្តគម្រោង |
|---|---|
| រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ | • ក្រសួងទេសចរណ៍<br>• ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍<br>• ប្រតិបត្តិករទេសចរណ៍<br>• វិស័យឯកជន |

**វិធីសាស្ត្រនៃការអនុវត្ត÷**

១- ជ្រើសរើសក្រុមហ៊ុនរៀបចំកិច្ចប្រជុំ/សន្និសីទអន្តរជាតិ

២- កំណត់អត្តសញ្ញាណដៃគូសក្តានុពលជាមួយប្រតិបត្តិករទេសចរណ៍ និងសណ្ឋាគារនានាសម្រាប់ការរៀបចំព្រឹត្តិការណ៍នានា

៣- កំណត់សម្បទាទ្រទ្រង់ការរៀបចំព្រឹត្តិការណ៍ម៉ាយ

៤- រៀបចំការផ្សព្វផ្សាយទូលំទូលាយអំពីគម្រោង “កម្ពុជាជាគោលដៅទេសចរណ៍ម៉ាយ”

៥- រៀបចំគោលនយោបាយលើកទឹកចិត្តដើម្បីទាក់ទាញក្រុមហ៊ុនសម្រាប់ការរៀបចំកម្មវិធី

៦- ជំរុញការរៀបចំជា “Special Toursit Visa” និងគោលនយោបាយនានា។ល។ សម្រាប់ប្រើប្រាស់ក្នុងដំណាក់កាលកូវីដ-១៩។

**សារតារ÷**

ការទទួលការរៀបចំការប្រជុំ សន្និសីទ និងការតាំងពិព័រណ៍ / ការប្រជុំជាអន្តរជាតិទាក់ទងនឹងឧស្សាហកម្មទេសចរណ៍ មានឥទ្ធិពលសម្រាប់លើកកម្ពស់កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា ជំរុញកំណើនសេដ្ឋកិច្ចនាពេលអនាគត និងនាំមកនូវប្រភេទភ្ញៀវទេសចរធុរកិច្ចជន ដែលតែងតែចំណាយច្រើនជាងភ្ញៀវទេសចរទូទៅ។ រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ មានលទ្ធភាពដ៏ល្អឥតខ្ចោះសម្រាប់ភាពជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍អន្តរជាតិធំៗ ការតាំងពិព័រណ៍ និងកម្មវិធីផ្សេងៗទៀត។ នាពេលខាងមុខកម្ពុជានឹងមានការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ធំៗ ជាអាទិ៍

- ការរៀបចំព្រឹត្តិការណ៍កិច្ចប្រជុំកំពូលអាស៊ាន
- ការរៀបចំសន្និបាតក្លិបឆ្នេរសមុទ្រដែលស្អាតជាងគេបំផុតលើសកលលោក

**គោលបំណង÷**

គម្រោងនេះមានគោលបំណង÷

**សកម្មភាពអនុវត្តគម្រោង÷**

១- រៀបចំកិច្ចប្រជុំ សន្និសីទ និងការតាំងពិព័រណ៍នានាអមជាមួយការលើកទឹកចិត្តដល់ក្រុមហ៊ុនរៀបចំទេសចរណ៍ម៉ាយ (ខ្វះការលើកទឹកចិត្តឱ្យភ្ញៀវទស្សនាតំបន់អង្គរ...)

២- រៀបចំសម្បទាទ្រទ្រង់ (កន្លែងប្រជុំ កន្លែងតាំងពិព័រណ៍.....) ស្របតាមស្តង់ដាបន្ទប់ប្រជុំអាស៊ាន

៣- បង្កើនការផ្សព្វផ្សាយព័ត៌មាន: កម្ពុជាជាគោលដៅទេសចរណ៍ម៉ាយ

៤- រៀបចំឱ្យមានវគ្គបណ្តុះបណ្តាលទ្រទ្រង់ឧស្សាហកម្មម៉ាយ ។

| | | |
|---|---|---|
| • បង្កើតផលិតផលទេសចរណ៍ម៉ាយ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ ក្រោយជំងឺកូវីដ-១៩<br>• ទាក់ទាញភ្ញៀវទេសចរធុរកិច្ច<br>• ទាក់ទាញភ្ញៀវទេសចរមកម្តងហើយម្តងទៀត<br>• ទាក់ទាញភ្ញៀវទេសចរស្នាក់នៅយូរ និងចំណាយខ្ពស់។ | | |
| **ហេតុផល÷**<br>គោលដៅទេសចរណ៍ទាំងបី (រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ) គឺមានសមត្ថភាពគ្រប់គ្រាន់ ដោយមានជាកន្លែងដែលសមនឹងតម្រូវការទេសចរណ៍បែបម៉ាយ និងសណ្ឋាគារខ្នាតអន្តរជាតិ។ | **លទ្ធផលរំពឹងទុកនៃគម្រោង÷**<br>**១-** មានការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ម៉ាយ កម្រិតជាតិ និងអន្តរជាតិនៅកម្ពុជា<br>**២-** មានសម្បទាទ្រទ្រង់ការរៀបចំព្រឹត្តិការណ៍ម៉ាយ ពិសេសកន្លែងរៀបចំព្រឹត្តិការណ៍ម៉ាយ មាននៅរាជធានី-ខេត្តទាំង៣ ស្របតាមស្តង់ដាអាស៊ាន។ | |
| **ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷**<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។ | **រយៈពេល÷**<br>អនុវត្តក្នុង**រយៈពេលខ្លី មធ្យម និងវែង (២០២១-២០២៥)** | **ថវិកានៃគម្រោង÷**<br>ថវិកានៃគម្រោងនេះនឹងកំណត់នាពេលក្រោយ។ |

## ១.៣- លើកកម្ពស់អភិបាលកិច្ចទេសចរណ៍

## គម្រោងទី១៧: “គម្រោងកម្មវិធីពង្រឹងសមត្ថភាពក្នុងវិស័យទេសចរណ៍កម្ពុជា (២០២០-២០២៣)”

### តារាងសង្ខេបនៃគម្រោង

### ផ្នែក: លើកកម្ពស់អភិបាលកិច្ចទេសចរណ៍

| ល.រ. | ចំណងជើងគម្រោង | ភាគីពាក់ព័ន្ធ | ប្រភពថវិកា | អាទិភាពពេលវេលា |
|---|---|---|---|---|
| គ.១៧ | គម្រោងកម្មវិធីពង្រឹងសមត្ថភាពក្នុងវិស័យទេសចរណ៍កម្ពុជា (២០២០-២០២៣) | ក្រសួងទេសចរណ៍ រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន | ទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD) | អាទិភាព ១ និង២ |

<table>
<tr><th>ទីតាំងគម្រោង</th><th>អង្គភាពអនុវត្តគម្រោង</th><td rowspan="3">វិធីសាស្ត្រនៃការអនុវត្ត÷<br>គម្រោងពង្រឹងសមត្ថភាពក្នុងវិស័យទេសចរណ៍កម្ពុជាត្រូវបានគាំទ្រក្រោមគម្រោងហិរញ្ញប្បទាននៃទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD)។</td></tr>
<tr><td>រាជធានី-ខេត្ត</td><td>• ក្រសួងទេសចរណ៍<br>• ទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD)</td></tr>
<tr><td colspan="2">សាវតារ÷<br>កម្មវិធីពង្រឹងសមត្ថភាពក្នុងវិស័យទេសចរណ៍ គឺជាគំនិតផ្តួចផ្តើមមួយរបស់ក្រសួងទេសចរណ៍កម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមជំនួយហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD)។<br><br>កម្មវិធីពង្រឹងសមត្ថភាពក្នុងវិស័យទេសចរណ៍ គឺជាផ្នែកមួយនៃសសរស្តម្ភពីរ ដើម្បីផ្តល់ការគាំទ្រដល់វិស័យទេសចរណ៍នៅកម្ពុជាតាមរយៈការពង្រឹងសមត្ថភាព (រដ្ឋ-ឯកជន) ឱ្យកាន់តែខ្លាំងថែមទៀត ស្របតាមស្មារតីនៃគោលនយោបាយជាតិទេសចរណ៍។</td></tr>
<tr><td colspan="2">គោលបំណង÷<br>គម្រោងនេះ មានគោលបំណង៣ រួមមាន÷<br>១- ការពង្រឹងសមត្ថភាពផ្នែកឯកជនតាមរយៈការគាំទ្រដល់ការពង្រឹងរចនាសម្ព័ន្ធសមាគមវិជ្ជាជីវៈក្នុងវិស័យទេសចរណ៍</td><td>សមាសភាពអនុវត្តគម្រោង÷<br>សមាសភាគទី១: រចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាពវិស័យឯកជន - ក្នុងសមាសភាគទី១ នេះមានបំណងពង្រឹងរចនាសម្ព័ន្ធសមាគមវិជ្ជាជីវៈ កសាងសមត្ថភាពផ្នែកឯកជន បង្កើនវិសាលភាព និងភាពជាតំណាងរបស់សមាគមវិជ្ជាជីវៈ និងពង្រឹងពហុជំនាញ និងសកម្មភាពភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងផ្នែកឯកជន</td></tr>
</table>

<table>
<tr>
<td>២- ការពង្រឹងសមត្ថភាពផ្នែករដ្ឋ ដើម្បីអនុវត្តយុទ្ធសាស្ត្រជាតិរបស់ខ្លួន និង ដើម្បីគាំទ្រដល់កិច្ចសន្ទនារវាងស្ថាប័នរដ្ឋ និងផ្នែកឯកជន<br>៣- ការរៀបចំ និងបង្កើននូវកិច្ចសន្ទនារវាងផ្នែករដ្ឋ និងឯកជន។<br><br>គោលបំណងនេះនឹងចូលរួមដល់ការពង្រឹងយន្តការអភិបាលកិច្ចទេសចរណ៍ឆ្លើយតបនឹងវិធានការក្រោយជំងឺឆ្លងកូវីដ-១៩។</td>
<td colspan="2">សមាសភាគទី២: កសាងសមត្ថភាពវិស័យសាធារណៈ- ក្នុងសមាសភាពទី២ នេះមានបំណងគាំទ្រអនុវត្តយុទ្ធសាស្ត្រថ្នាក់ជាតិ របស់ក្រសួងទេសចរណ៍ និងគាំទ្រកិច្ចសន្ទនារវាងស្ថាប័នរដ្ឋ និងផ្នែកឯកជន<br>សមាសភាគទី៣: មូលនិធិសម្រាប់ការសិក្សា និងគម្រោងសាកល្បង - ក្នុងសមាសភាពទី៣ នេះមានបំណងរកមូលនិធិ សម្រាប់ការសិក្សាស្រាវជ្រាវ និងរៀបចំគម្រោងសាកល្បងទេសចរណ៍នានា។</td>
</tr>
<tr>
<td rowspan="2">ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷<br>គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ដល់សង្គម និងបរិស្ថាន។</td>
<td colspan="2">លទ្ធផលរំពឹងទុកនៃគម្រោង÷<br>១- ពង្រឹងសមត្ថភាពវិស័យឯកជន សមាគមវិជ្ជាជីវៈទេសចរណ៍ និងពង្រឹងយន្តការភាពជាដៃគូរដ្ឋ-ឯកជន<br>២- ពង្រឹងអភិបាលកិច្ចទេសចរណ៍ឆ្លើយតបនឹងវិធានការក្រោយជំងឺកូវីដ-១៩។</td>
</tr>
<tr>
<td>រយៈពេល÷<br>អនុវត្តរយៈពេលខ្លី និងមធ្យម (២០២០-២០២៣) ដោយក្រសួងទេសចរណ៍ និងទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD)។</td>
<td>ថវិកានៃគម្រោង÷<br>គម្រោងនេះមានហិរញ្ញប្បទានក្រោមគម្រោងពង្រឹងសមត្ថភាពក្នុងវិស័យទេសចរណ៍ (TCBP)។</td>
</tr>
</table>

ឧបសម្ព័ន្ធទី២. ស្ថិតិភ្ញៀវទេសចរជាតិ-អន្តរជាតិចាប់ពីថ្ងៃទី១៧-២១ ខែសីហា ឆ្នាំ២០២០ នាឱកាសឈប់សម្រាកសងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ

| ល.រ | គោលដៅ | ជាតិ | អន្តរជាតិ | សរុប |
|---|---|---|---|---|
| 1 | រាជធានីភ្នំពេញ | 43,810 | 3,053 | 46,863 |
| 2 | កំពង់ធំ | 19,409 | 60 | 19,469 |
| 3 | ឧត្តរមានជ័យ | 11,040 | 10 | 11,050 |
| 4 | ព្រះវិហារ | 60,337 | 241 | 60,578 |
| 5 | សៀមរាប | 212,000 | 2,047 | 214,047 |
| 6 | ព្រះសីហនុ | 111,468 | 4,878 | 116,346 |
| 7 | កំពត | 180,075 | 679 | 180,754 |
| 8 | កែប | 145,856 | 527 | 146,383 |
| 9 | កោះកុង | 44,166 | 318 | 44,484 |
| 10 | ក្រចេះ | 16,405 | 296 | 16,701 |
| 11 | មណ្ឌលគិរី | 43,510 | 204 | 43,714 |
| 12 | រតនគិរី | 50,449 | 179 | 50,628 |
| 13 | ស្ទឹងត្រែង | 96,78 | 6 | 9,684 |
| 14 | បន្ទាយមានជ័យ | 28,153 | 0 | 28,153 |
| 15 | បាត់ដំបង | 132,524 | 825 | 133,349 |
| 16 | ប៉ៃលិន | 21,721 | 5 | 21,726 |
| 17 | ពោធិ៍សាត់ | 59,372 | 34 | 59,406 |
| 18 | កំពង់ចាម | 35,290 | 146 | 35,436 |
| 19 | កំពង់ឆ្នាំង | 45,214 | 0 | 45,214 |
| 20 | កំពង់ស្ពឺ | 39,931 | 426 | 40,357 |
| 21 | កណ្តាល | 52,901 | 137 | 53,038 |
| 22 | ព្រៃវែង | 17,540 | 0 | 17,540 |
| 23 | ស្វាយរៀង | 4,028 | 4 | 4,032 |
| 24 | តាកែវ | 40,835 | 61 | 40,896 |
| 25 | ត្បូងឃ្មុំ | 19,526 | 12 | 19,538 |
| **សរុបរួម** | | **1,445,238** | **14,148** | **1,459,386** |

ប្រភព: មន្ទីរទេសចរណ៍រាជធានី-ខេត្ត

## ឧបសម្ព័ន្ធទី៣. របាយការណ៍ស្ថិតិអាជីវកម្មទេសចរណ៍បានបិទ និងព្យួរទូទាំងប្រទេស ឆ្នាំ២០២០

**១. ចំនួនមូលដ្ឋានអាជីវកម្មទេសចរណ៍ដែលបានប៉ះពាល់ (ផ្អាក ឬព្យួរ) ទូទាំងប្រទេស គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២០**

- មូលដ្ឋានអាជីវកម្មទេសចរណ៍សុរបទូទាំងប្រទេសមានចំនួន ១០ ៣៦៣ទីតាំង ដែលមានបុគ្គលិកបំរើការសុរប ចំនួន ១២៣ ៩៤៥នាក់ ។
- មូលដ្ឋានអាជីវកម្មដែលបានផ្អាក ឬព្យួរសុរបទូទាំងប្រទេសចំនួន ៣ ៤២៩ទីតាំង (ស្មើនឹង ៣៣,០៩% នៃអាជីវកម្មទេសចរណ៍សុរប) និងមានបុគ្គលិកដែលបានប៉ះពាល់សុរបចំនួន ៥៤ ២៥៣នាក់ (ស្មើនឹង ៤៣,៧៧% នៃចំនួនបុគ្គលិកសុរប)។

**២. ចំនួនមូលដ្ឋានអាជីវកម្មទេសចរណ៍ដែលបានប៉ះពាល់ (បិទ ឬផ្អាក) រាជធានី-ខេត្ត ក្រុង ចំនួន ០៧គោលដៅ ដែលបានអន្តរាគមន៍ពីរាជរដ្ឋាភិបាល គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០**

- មូលដ្ឋានអាជីវកម្មរាជធានី-ខេត្ត ក្រុង ចំនួន ០៧គោលដៅ មានចំនួន ៦ ៦៩៨ទីតាំង ដែលមានបុគ្គលិកសុរប ចំនួន ៩៧ ៧៣០នាក់។
- មូលដ្ឋានអាជីវកម្មទេសចរណ៍ដែលបានប៉ះពាល់ (ផ្អាក ឬព្យួរ) សុរបចំនួន ២ ៦០៥ទីតាំង ដែលមានបុគ្គលិកប៉ះពាល់ចំនួន ៣៧ ៣៣២នាក់ ដែលទទួលបានការគាំទ្រពិសេសពីរាជរដ្ឋាភិបាល។ ដូចមានបរិយាយខាងក្រោម÷

**ក. រាជធានីភ្នំពេញ**

- អាជីវកម្មផ្អាក ឬព្យួរចំនួន ៩២៩ទីតាំង (ស្មើនឹង ២៥,៨៨%) ធៀបនឹងអាជីវកម្មសុរប ៣ ៥៨៩ ទីតាំង
- បុគ្គលិកប៉ះពាល់ ១៦ ៧១៨នាក់ (ស្មើនឹង ២៨,៨១%) ធៀបនឹងបុគ្គលិកសុរប ៥៨ ០១២ នាក់

**ខ. ខេត្តសៀមរាប**

- អាជីវកម្មផ្អាក ឬព្យួរចំនួន ៨២១ទីតាំង (ស្មើនឹង ៧៣,៨៩%) ធៀបនឹងអាជីវកម្មសុរប ១ ១១១ទីតាំង
- បុគ្គលិកប៉ះពាល់ ១២,៤០៥នាក់ (ស្មើនឹង ៦០.០២%) ធៀបនឹងបុគ្គលិកសុរប ២០,៦៦៧ នាក់

**គ. ខេត្តព្រះសីហនុ**

- អាជីវកម្មផ្អាក ឬព្យួរចំនួន ៥៨១ទីតាំង (ស្មើនឹង ៦៤.១៩%) ធៀបនឹងអាជីវកម្មសុរប ៩០៥ទីតាំង
- បុគ្គលិកប៉ះពាល់ ៤,៧៥០នាក់ (ស្មើនឹង ៤០.២៤%) ធៀបនឹងបុគ្គលិកសុរប ១១,៨០៤ នាក់

**ឃ. ខេត្តកែប**

- អាជីវកម្មផ្អាក ឬព្យួរចំនួន ១៧ទីតាំង (ស្មើនឹង ១៤.២៨%) ធៀបនឹងអាជីវកម្មសុរប ១១៩ទីតាំង
- បុគ្គលិកប៉ះពាល់ ២១១នាក់ (ស្មើនឹង ២១.១៨%) ធៀបនឹងបុគ្គលិកសុរប ៩៩៦ នាក់

**ង. ខេត្តកំពត**

- អាជីវកម្មផ្អាក ឬព្យួរចំនួន ១៣៣ទីតាំង (ស្មើនឹង ២១.២៤%) ធៀបនឹងអាជីវកម្មសុរប ៦២៦ទីតាំង
- បុគ្គលិកប៉ះពាល់ ១,១១៥នាក់ (ស្មើនឹង ៣៣.៦៩%) ធៀបនឹងបុគ្គលិកសុរប ៣,៣០៩នាក់

**ច. ក្រុងបាវិត**

- អាជីវកម្មផ្អាក ឬព្យួរចំនួន ៨៩ទីតាំង (ស្មើនឹង ៥១.៧៤%) ធៀបនឹងអាជីវកម្មសុរប ១៧២ទីតាំង
- បុគ្គលិកប៉ះពាល់ ១,៤៩៣នាក់ (ស្មើនឹង ៧៦.២៩%) ធៀបនឹងបុគ្គលិកសុរប ១,៩៥៧នាក់

**ឆ. ក្រុងប៉ោយប៉ែត**

- អាជីវកម្មបិទ ឬផ្អាកចំនួន ៥៩ទីតាំង (ស្មើនឹង ៣៣.១៤%) ធៀបនឹងអាជីវកម្មសុរប ១៧៨ទីតាំង
- បុគ្គលិកប៉ះពាល់ ៧៣៦នាក់ (ស្មើនឹង ៦៦.៩៩%)ធៀបនឹងបុគ្គលិកសុរប ១,០៩៩នាក់។

*ប្រភព : ក្រសួងទេសចរណ៍*

## សេចក្តីថ្លែងអំណរគុណ

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និង **ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍** ចំពោះការណែនាំដល់ក្រុមការងាររៀបចំផែនទីចង្អុលផ្លូវ (Roadmap) ស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យ។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តម ហ៊ុន ម៉ានី ប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា** ចំពោះការផ្តល់នូវធាតុចូលដ៏មានតម្លៃសម្រាប់ខ្លឹមសារនៃផែនទីចង្អុលផ្លូវ។

សូមគោរពជូនពរ ឯកឧត្តម សូមទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

### ក្រុមការងាររៀបចំផែនទីចង្អុលផ្លូវ

| | | |
|---|---|---|
| ១- | **ឯកឧត្តម ណេប សាមុត** | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាប្រធានលេខាធិការដ្ឋានក្រុមការងារដើម្បីជំរុញ និងលើកស្ទួយវិស័យទេសចរណ៍ក្នុងដំណាក់កាលវិបត្តិ និងក្រោយវិបត្តិកូវីដ-១៩ (COVID-19) |
| ២- | **ឯកឧត្តម ថោង រដ្ឋសក្តិ** | អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ |
| ៣- | **ឯកឧត្តម ឆាយ យុនឡុង** | ទីប្រឹក្សាក្រសួងទេសចរណ៍ និងជាអគ្គនាយករងគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |
| ៤- | **ឯកឧត្តម អាំង សុវណ្ណរ័ត្ន** | អគ្គលេខាធិការរង គ.ជ.វ.ទ និងជាអគ្គនាយករងអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ |
| ៥- | លោក លន់ ប៊ុនធឿន | ប្រធាននាយកដ្ឋានវាយតម្លៃទីក្រុងស្អាត |
| ៦- | លោកស្រី ហេង ស្រស់ | អនុប្រធាននាយកដ្ឋានទីភ្នាក់ងារដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ |
| ៧- | លោក ហ្គាវិន បេល | ប្រធានក្រុមការងារទីប្រឹក្សាបច្ចេកទេស និងជាអ្នកជំនាញការអន្តរជាតិផ្នែកទេសចរណ៍ |
| ៨- | លោក មឿន ពន្លក | អនុប្រធានការិយាល័យនៃនាយកដ្ឋានវាយតម្លៃទីក្រុងស្អាត |
| ៩- | កញ្ញា ចាន់ ផល្លីកា | អនុប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ |
| ១០- | លោក សេង វិរៈយុទ្ធ | មន្ត្រីជំនួយការអគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |
| ១១- | លោក សុន សំណាង | មន្ត្រីជំនួយការអគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |
| ១២- | លោក នៅ បញ្ញា | មន្ត្រីជំនួយការអគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |

### ក្រុមការងារពិគ្រោះយោបល់

| | | |
|---|---|---|
| ១- | **ឯកឧត្តម ទិត ចន្ថា** | រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ |
| ២- | **ឯកឧត្តម ជា ប៉ូវ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ |
| ៣- | **ឯកឧត្តម សុង តុងហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ |
| ៤- | **ឯកឧត្តម ជា កុសល** | អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យក្រសួងទេសចរណ៍ |
| ៥- | **ឯកឧត្តម ជួន ជ័យសត្យា** | អគ្គលេខាធិការរង គ.ជ.វ.ទ និងជាប្រធាននាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ |
| ៦- | **ឯកឧត្តម គឹម សេរីរដ្ឋ** | អគ្គលេខាធិការរង គ.ជ.វ.ទ និងជាប្រធាននាយកដ្ឋានគ្រប់គ្រង សេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ |
| ៧- | លោកស្រី សាយ៉ា ម៉ារតា | អ្នកជំនាញការជាតិផ្នែកទេសចរណ៍ |
| ៨- | លោក គង់ គួគួ | ប្រធានការិយាល័យនៃនាយកដ្ឋានវាយតម្លៃទីក្រុងស្អាត |

# រៀបចំដោយ

MINISTRY OF TOURISM

CAMBODIA
Kingdom of Wonder
feel the warmth

# សូមថ្លែងអំណរគុណ

គណៈកម្មការអប់រំ យុវជន កីឡា
ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

MINISTRY OF ECONOMY AND FINANCE

NATIONAL COMMITTEE FOR CLEAN CITY ASSESSMENT

AFD
AGENCE FRANÇAISE
DE DÉVELOPPEMENT